


Scanned by CamScanner

ហាមថតចម្លង



…១…

ទីក្រុងសេអ៊ូលប្រទេសកូរ៉េខាងត្បូង

អាគារពាណិជ្ជកម្មលេចធ្លោចំកណ្តាលទីក្រុង ដែលទាក់ទាញភ្ញៀវជាច្រើនមកកំសាន្តនិងស្នាក់នៅទីនេះ ដោយសារថ្ងៃនេះមានកម្មវិធីជប់លាងសំរាប់បុគ្គលិកដូច្នេះមានមនុស្សជាច្រើន ដែលមកចូលរួមកម្មវិធីនេះមិនមែនសំរាប់តែបុគ្គលិកក្នុងនេះនោះទេ សូម្បីតែភ្ញៀក៏អាចចូលរួមបានដែរ។

កម្មវិធីជប់លាងជួបជុំបុគ្គលិកតែងធ្វើឡើងជារៀងរាល់ឆ្នាំ ចំណែកភ្ញៀវដែលចូលរួមភាគច្រើនសុទ្ធតែជាដៃគូរជំនួញរបស់ម្ចាស់អគារ និងជាអ្នកមានមុខមានមាត់ក្នុងសង្គម ហើយលើកនេះក៏មានការចូលរួមពីអគ្គនាយកធំផ្ទាល់ផងដែរ រាល់ឆ្នាំគេមិនដែលបានមកចូលរួមនោះទេ តែឆ្នាំនេះដោយមានការរំអុកពីអ្នកម៉ាក់ទើបគេត្រូវមកចូលរួមដោយផ្ទាល់។

អ៊ែលវិន ហេនរីខូ អគ្គនាយកកំលោះរាងខ្ពស់ស្រឡះ កែវភ្នែកមុតច្រមុះស្រួច ដោយសារមានអ្នកម៉ាក់ជាជនជាតិកូរ៉េ ទើបគេធ្វើការវិនិយោគសណ្ឋាគារនៅទីនេះ ជំនួញសណ្ឋាគាររបស់គេ មានសាខាស្ទើរទូទាំងពិភពលោករួមទាំងទីនេះផងដែរ ក្នុងប្រទេសកូរ៉េសាខាសណ្ឋាគាររបស់គេមិនមែនមាននៅតែក្នុងក្រុងសេអ៊ូលប៉ុណ្ណោះទេ មាននៅកោះជេជូ និងតាមបណ្តាលខេត្តមួយចំនួនទៀត។

ក្នុងអគារមានសុទ្ធតែភ្ញៀវនិងបុគ្គលិក តែកំពុងតែមមាញឹកក្នុងការរៀបចំ អ្នកខ្លះកំពុងតែមមាញឹកនឹងការរៀបចំខ្លួនឲ្យមានភាពទាក់ទាញជាពិសេសបុគ្គលិកនារីៗ គ្រាន់តែឮអ្នកគ្រប់គ្រងអគារប្រាប់ថាឆ្នាំនេះអគ្គ



Scanned by CamScanner

នាយកធំមកចូលរួមម្នាក់ៗខំប្រឹងធ្វើខ្លួនដើម្បីទទួលការចាប់អារម្មណ៍។

«ស៊ូហ៊ី មិនទាន់រៀបចំខ្លួនទេអី ពិធីជិតចាប់ផ្ដើមហើយណ៎ា» សំឡេងនារីម្នាក់នៅតុខាងជាប់ប្រាប់ទៅមិត្តម្នាក់ទៀត។

«អត់ទេ ខ្ញុំចង់ទៅផ្ទះ» អ្នកដែលត្រូវសួរឆ្លើយតប។

«នែ! ពីធីនេះមិនងាយធ្វើទេណា មួយឆ្នាំមានម្ដងនោះទេ ហេតុអីមិននៅចូលរួមសប្បាយណាស់ណ៎ា»

«ឯងក៏ដឹងដែរគ្នាមានម៉ាក់ឈឺនៅផ្ទះ តើឲ្យគ្នានៅសប្បាយយ៉ាងម៉េចទៅ?» នាងនិយាយទាំងធ្វើមុខស្ងួត។

មិត្តម្នាក់ទៀតដែលឮដូច្នេះបានតែនឹកអាណិត ហើយក៏មិនហ៊ាននិយាយអ្វីទៀតនោះដែរ នាងដឹងពីស្ថានភាពគ្រួសាររបស់មិត្តម្នាក់នេះច្បាស់ណាស់ព្រោះពួកគេនៅផ្ទះជិតគ្នានិងធ្លាប់រៀនជាមួយគ្នាទៀតផង។

«មិនអីទេ សេមី ឯងនៅសប្បាយចុះណា គ្នាត្រឡប់ទៅមុន» នាងនិយាយរួចក៏រៀបចំកាបូបរបស់ខ្លួន។

ផាក ស៊ូហ៊ី នារីស្លូតបូតតែរឹងមាំ រស់នៅជាមួយម្ដាយមាននិងប្អូនប្រុសម្នាក់ទៀត នាងប្រឹងប្រែងធ្វើការដើម្បីរកលុយផ្គត់ផ្គង់គ្រួសារ រួមទាំងការរៀនសូត្ររបស់ប្អូនប្រុស ដោយសារសមត្ថភាពភាសាអង់គ្លេសនាងខ្លាំងទើបមិត្តភក្តិណែនាំឲ្យដាក់ពាក្យជាអ្នកទទួលភ្ញៀវនៅទីនេះ នាងទើបចូលធ្វើការបានមួយឆ្នាំជាងតែប៉ុណ្ណោះ ធ្វើឲ្យអ្នកគ្រប់គ្រងទីនេះចូលចិត្តនិងសរសើពីសមត្ថភាពរបស់នាង។

ស៊ូហ៊ី រៀបចំកាបូបរួចរាល់ក៏ដើរចេញពីអគារនេះ តែដោយសារនៅខាងមុខមានមនុស្សច្រើនទើបនាងត្រូវចេញតាមទ្វារក្រោយ នាងដើរចេញ



Scanned by CamScanner

មកដោយអារម្មណ៍មិននៅនិងខ្លួន ព្រោះកំពុងតែគិតរឿងរ៉ាវជាច្រើនចេញមកបានបន្តិចក៏ស្រាប់តែមានរថយន្តពណ៌ខ្មៅមួយ បើកយ៉ាងលឿនមកឈប់ជិតធ្វើឲ្យនាងភ្ញាក់ដួលអុកគូថ នាងថ្ងូរយ៉ាងឈឺចាប់សម្លក់ទៅរថយន្តដែលបើកឈ្លើយអំបាញ់មិញដោយកំហឹង ម្ចាស់រាងខ្ពស់សង្ហារចុះពីរថយន្តដោយឫកពារហំហាន សម្លឹងមកនាងចុងភ្នែកបន្តិចរួចក៏ដើរចេញទៅដោយមិនខ្វល់ នាងក្រមុំដែលឃើញឫកពារឆ្មើងឆ្មៃរបស់គេបែបនេះអត់មិនបាននិងនិន្នារ។

«រូបរាងល្អ តែម៉េចក៏អន់ចរិក ហើយគ្មានសិលធម៌បែបនេះ» ប្រឹងក្រោកបណ្ដើររអ៊ូរៗជាភាសាកូរ៉េបណ្ដើរ ព្រោះឃើញមុខគេជាជនបរទេសគិតថាគេស្ដាប់ភាសានាងមិនបាននោះទេ។

អ្នកដែលទើបដើរចេញទៅបានបន្តិចក៏ឈប់ឆ្ងក់ ពេលដែលឮនាងនិយាយបែបនេះ គេជាកូនកាត់កូរ៉េ ដូច្នេះគេរៀនភាសានេះតាំងពីតូច ចេះស្ទាត់ដូចជាកូនកូរ៉េសុទ្ធដែរទោះបីជាមិនសូវបានប្រើញឹកញាប់ក៏ដោយ។

«នាងនិយាយថាម៉េចមិញ?» គេងាកមកសួរជាភាសាកូរ៉េវិញ ធ្វើឲ្យនារីដែលប្រឹងក្រោកនោះបើកភ្នែកធំៗសម្លឹងមើល គេចេះភាសាកូរ៉េដែរមែនទេ? នាងឧទានក្នុងចិត្ត តែក៏មិនបានភិតភ័យពេលគិតថាគេអាចស្ដាប់យល់គ្រប់ពាក្យដែលនាងនិយាយ។

«ត្រចៀកលោកប្រហែលមានបញ្ហាហើយ ទើបស្ដាប់មិនច្បាស់» នាងនិយាយទាំងសម្លឹងគេថ្ងៃរ។

អ្នកកំលោះដែលឮបែបនេះក៏សម្លឹងនាងដោយក្រសែភ្នែកមុត មិនធ្លាប់មានមនុស្សស្រីណាហ៊ានថាឲ្យគេបែបនេះនោះទេ នាងមកពីណា



Scanned by CamScanner

លោកនោះទេ មានអារម្មណ៍ហួសចិត្តពេលឮពាក្យសម្តីរបស់គេទើបងាកមកសម្លក់ម្តងទៀត។

«នែលោក កុំឈ្លក់វង្វេងខ្លួនឯងពេក ទោះបីជាស្រីៗទូទាំងភូមិរត់តាមលោកក៏ប្រហែលជាគ្មានមុខខ្ញុំនោះដែរ!» ស៊ូហ៊ី និយាយរួចក៏ងាកខ្លួនដើរចេញពីគេម្តងទៀត មិនចង់នៅឈ្លោះជាមួយមនុស្សប្រុសអន់ចរិកម្នាក់នេះទៀតនោះទេ កំលោះដែលឃើញនាងដើរចេញពីគេ ដោយមិនខ្វល់បែបនេះ ចាប់ផ្តើមម៉ូម៉ៅ ព្រោះមិនធ្លាប់មានមនុស្សស្រីណាអៀដាក់គេបែបនេះនោះទេ គេមានរូបរាងសង្ហារស្រីទូទាំងពិភពលោក គ្រាន់តែឃើញរត់មកចោមរោម តែស្រីម្នាក់នេះបែរជាមើលមិនឃើញគេក្នុងខ្សែភ្នែកថែមទាំងថាគេជាមនុស្សអន់ចរិកទៀត គំនិតចង់ឈ្នះក៏កើតមានក្នុងចិត្តគិតរួចក៏ស្ទុះទៅចាប់ដៃនាងឲ្យងាកមកនិយាយជាមួយគេ។

«នែនាង ចង់ទៅណាខ្ញុំមិនទាន់ជំរះបញ្ជីជាមួយនាងនោះទេ?» នាងក្រមុំដែលទើបដើរចេញបានបន្តិច ពេលដែលគេទាញឲ្យងាកមកបែបនេះទប់ជំហរមិនទាន់ក៏ទ្រេតរកដួល ទើបគេត្រូវស្រវាំទាញនាងមកឱបក្លិនក្រអូបផ្កាលីលីដែលរសាត់ប៉ះច្រមុះ ធ្វើឲ្យគេនៅទ្រឹងស្រូបក្លិនក្រអូបនោះមិនចង់លែងរហូតអ្នកក្នុងរង្វង់ដៃរើបម្រះហើយរុញគេចេញ។

«មនុស្សឆ្លៀតឱកាស» នាងស្រែកដាក់មុខសម្លក់គេថ្ងៃ រួចក៏ដើរចេញទៅទាំងមុខក្រហមដោយការខ្មាសអៀន។

កំលោះរាងមឹងមាំងពេលដែលនាងស្រែកដាក់ ព្រោះការប៉ះពាល់គ្មានចេតនាមិញនេះគេគ្រវីក្បាលហួសចិត្តតែហើយក៏ញញឹម សម្លឹងមើលរហូតទាល់តែនាងដើរចេញទៅរាងឆ្ងាយទើបដើរចូលទៅក្នុងទាំងអារម្មណ៍



Scanned by CamScanner

ហាមថតចម្លង

ប្លែកៗ។

«ចៅហ្វាយមិនអីទេមែនទេ?» មនុស្សជំនិតសួរពេលដែលឃើញចៅហ្វាយដូចជាអារម្មណ៍ល្អបន្ទាប់ពីឈ្លោះជាមួយស្រីម្នាក់នោះ។

«គ្មានអីទេ ខាងក្នុងរៀបចំរួចរាល់ហើយមែនទេ?» គេសួរពេលដែលដើរចូលមកក្នុង គេមិនសូវចូលចិត្តភាពអ៊ូអរ ហើយធុញនិងបុត្តលិកស្រីៗនៅទីនេះពេលដែលឃើញគេដូចជាឃើញដុំពេជ្យ ដូចច្នេះទើបគេត្រូវចូលតាមទ្វារក្រោយដើម្បីកុំឲ្យមានការភ្ញាក់ផ្អើលដល់ពួកនោះ។

«រួចរាល់ហើយចៅហ្វាយ» មនុស្សជំនិតរាយការណ៍។

«ល្អ ខ្ញុំចង់សំរាកបន្តិចសិន កុំឲ្យអ្នកណាមករំខាន» គេនិយាយរួចក៏ដើរសំដៅជណ្ដើរយន្តសំរាប់អគ្គនាយក។

នាងក្រមុំដែលទើបតែទៅដល់ផ្ទះ ដើរតិចៗចូលទៅក្នុងព្រោះតែឈឺក្រគាកនឹកទៅដល់អ្នកដែលជាដើមហេតុធ្វើឲ្យនាងខឹងឆេវឆាតែក៏មុខក្រហមគិតដល់ពេលដែលដួលលើគេ ក្លិនកាយបុរសក្រអូបនាងមិនធ្លាប់ស្និទ្ធស្នាលនិងបុរសណាម្នាក់នោះទេក្រៅពីប្អូនប្រុសរបស់នាង បែបនេះទើបធ្វើឲ្យនាងមុខក្រហម។

«ស៊ូហ៊ី ត្រឡប់មកវិញហើយមែនទេ?» សំឡេងនារីម្នាក់ទៀតដែលទើបចេញពីក្នុងផ្ទះឃើញមិត្តឈរភ្លឹកទៅខាងមុខទើបហៅ។

«ហ៊ឹម គ្នាមកវិញហើយ» ស៊ូហ៊ី តបរួចក៏ដើរចូលក្នុងមិត្តដែលឃើញដំណើរនាងមិនស្រួលទើបដើរទៅជិត។

«ស៊ូហ៊ី ឯងយ៉ាងម៉េចហ្នឹង?» មិត្តនាងសួររួចក៏ជួយគ្រា។

«គ្នាមិនអីទេ គ្រាន់តែដួលបន្តិចទើបធ្វើឲ្យឈឺក្រគាក ថ្ងៃនេះយ៉ាង



Scanned by CamScanner

ម៉េចដែរ ធ្វើទុក្ខខ្លាំងដែរទេ?» ស៊ូហ៊ី សួរមិត្តដែលមានអការៈក្ងួតចង្អោរ ព្រោះតែចាញ់កូន មិត្តនាងម្នាក់នោះគ្មានអ្នកណាក្រៅពី ហេជីន នោះទេ នាងទើបត្រឡប់មកពីអង់គ្លេស ថែមទាំងមានរឿងរ៉ាវជាច្រើនជាប់ខ្លួនថែមទៀតហើយបានមកជួប ស៊ូហ៊ី ពួកគេជាមិត្តល្អរៀនវិទ្យាល័យជាមួយគ្នា ហេជីន និយាយរឿងខ្លះៗឲ្យនាងស្តាប់ទើបអត់មិនបាននិងអាណិតមិត្ត ហើយដោយសារឃើញនាងត្រូវនៅម្នាក់ឯង ថែមទាំងមានកូនក្នុងពោះបែបនេះផងទើបនាំនាងមកនៅជាមួយបានជាគ្នា ព្រោះផ្ទះនាងធំល្មម អាចនៅគ្នាបួននាក់បាន។

«មិនអីទេថ្ងៃនេះមិនសូវធ្វើទុក្ខនោះទេ តោះនាំគ្នាទៅក្នុងទៅ» នាងនិយាយរួចក៏នាំគ្នាដើរចូលទៅ។

ស៊ូហ៊ី ដើរទៅបើកទ្វារបន្ទប់តូចមួយដែលនៅជិតនោះ ស្ត្រីចំណាស់ម្នាក់អង្គុយខាងក្នុងបន្ទប់ដូចជាកំពុងធ្វើអ្វីមួយ។

«ម៉ាក់ ខ្ញុំត្រឡប់មកវិញហើយ» នាងប្រាប់ទាំងដើរទៅអង្គុយជិត គាត់ដែលកំពុងញាប់ដៃមិនដឹងធ្វើអ្វី ឮសំឡេងដូចជាស៊ាំទម្លាប់គាត់បង្អង់ដៃងាកមកញញឹមតប។

«មកវិញហើយមែនទេចុះ ដូយ៉ុង មិនទាន់មកវិញទេមែនទេ?» ស្ត្រីចំណាស់សួររកកូនប្រុសទីពីររបស់គាត់ ។

«នៅទេម៉ាក់ ប្រហែលតិចទៀតមកហើយ ម៉ាក់កំពុងធ្វើអីហ្នឹង» ស៊ូហ៊ី សួរម្តាយទាំងសម្លឹងរបស់ក្នុងដៃគាត់។

«កន្សែងបង់ក» គាត់ប្រាប់ទាំងស្នាមញញឹមហើយក៏ធ្វើបន្ត។

«ក្រែងម៉ាក់មិនស្រួលខ្លួននោះអី ហេតុអីនៅប្រឹងធ្វើវាទៀតហើយ



Scanned by CamScanner

មិនព្រមសម្រាកទៅ» នាងប្រាប់ទាំងធ្វើមុខជូរ។

«ម៉ាក់មិនអីទេ កុំបារម្ភអី មកពីទំនេរទើបចេះតែធ្វើទៅ» គាត់ប្រាប់ហើយក៏ធ្វើបន្តស្របពេលឮសំឡេងស្រែកនៅខាងក្រៅដឹងថាអ្នកណាទើបនាំគ្នាចេញមក។

«ខ្ញុំត្រឡប់មកវិញហើយ» ជូយ៉ុង ស្រែកប្រាប់សំឡេងស្រស់ស្រាយពីខាងក្រៅធ្វើឲ្យអ្នកខាងក្នុងនាំគ្នាញញឹម។

«ត្រឡប់មកវិញល្អហើយតោះនាំគ្នាញ៉ាំបាយ» ស៊ូហ៊ី និយាយហើយក៏គ្រាម្ដាយនាងដើរទៅអង្គុយតុអាហារ។

«បើខ្ញុំទាយមិនខុសនេះជាស្នាដៃធ្វើម្ហូបរបស់បង ហេជីន មែនដែរទេ?» ជូយ៉ុង និយាយពេលដែលដួសម្ហូបដាក់មាត់ញ៉ាំ។

«ញ៉ាំទៅកុំសួរច្រើនពេក» ស៊ូហ៊ី ថាឲ្យប្អូនព្រោះដឹងពីគោលបំណងរបស់គេដែលសួរបែបនេះ ហេជីន មិនមាត់គ្រាន់តែញញឹម។

«មិនប្រាប់ក៏ដឹង ព្រោះស្នាដៃធ្វើម្ហូបរបស់បង ហេជីន គ្រាន់ជាងបងស្រីខ្ញុំ ហាសហាស» គេនិយាយទាំងសើចងាកមើលមុខបងស្រី។

ស៊ូហ៊ី បានតែសម្លក់ប្អូនព្រោះដោយសារនាងរវល់ទើបមិនសូវមានពេលរៀនធ្វើម្ហូប ពេលធ្វើម្ដងៗប្អូនប្រុសតែងតែរអ៊ូហើយតាំងពី ហេជីន ពីមកនៅនាងជាអ្នកធ្វើម្ហូបរហូត ដូចច្នេះបានដៃប្អូនប្រុសកាន់តែបង្អាប់បន្ថែមនាងមិនប្រកាន់និងប្អូនម្នាក់នេះនោះទេ ព្រោះគេចូលចិត្តលេងបង្អាប់បែបនេះរាល់តែដងវាក្លាយជារឿងធម្មតាទៅហើយ។

អ្នកស្រី ហេវ៉ៃ បានត្រឹមញញឹមពេលឃើញបរិយាកាសរីករាយក្នុងផ្ទះបែបនេះ តែក៏ធ្វើឲ្យគាត់មុខស្រពោនមួយរំពេចន៍ពេលគិតដល់សភាព



Scanned by CamScanner

ជំងឺរបស់ខ្លួន។

ពីមុនគាត់ជាបុគ្គលិកអនាម័យនៅសណ្ឋាគារដែល ស៊ូហ៊ី ធ្វើការ តែមួយរយៈក្រោយមកនេះគាត់ចេះតែឈឺមិនឈប់ ទើបនាងឲ្យគាត់ឈប់ធ្វើការសម្រាកនៅផ្ទះថែមទាំងមាន ហេជីន នៅជាមួយគាត់ផងទើបនាងមិនសូវបារម្ភ។

សភាពជំងឺគាត់ចេះតែធ្វើទុក្ខខ្លាំងឡើង តែគាត់មិនហ៊ានប្រាប់កូននោះទេព្រោះខ្លាចពួកគេបារម្ភ រហូតថ្ងៃមួយគាត់បានលួចទៅពិនិត្យនៅមន្ទីរពេទ្យក្រុមគ្រូពេទ្យប្រាប់ថាគាត់មានជំងឺដុះសាច់ខួក្បាល ត្រូវធ្វើការវះកាត់ជាបន្ទាន់តែវាត្រូវចំណាយប្រាក់អស់ច្រើន ឃើញកូនស្រីដែលលំបាកតាំងពីតូចគាត់មិនចង់ឲ្យនាងលំបាកទៀតនោះទេ ទើបសម្រេចចិត្តលាក់រឿងនេះ។

ព្រឹកថ្ងៃថ្មី ស៊ូហ៊ី ក្រោកមកធ្វើការដូចធម្មតា ពេលមកដល់នាងចូលកាន់តួនាទីរបស់នាងដូចរាល់ដង។

«សួស្តី សេមី យ៉ាងម៉េចដែរពីធីយប់មិញ?» នាងសួរមិត្តដែលនៅផ្នែកជាមួយគ្នា។

«គឺសប្បាយខ្លាំងណាស់ណា ហើយជាពិសេសឯងដឹងទេអគ្គនាយកធំរបស់យើងពិតជាសង្ហារមែនទែន គ្នាចាប់ចិត្តលើគាត់បាត់ទៅហើយ គាត់សង្ហារខ្លាំងណាស់ដូចតារ៉ាបង្ហាញម៉ូតអញ្ចឹង» អ្នកនិយាយធ្វើកាយវិការនឹងគិតស្រមើស្រមៃទៅដល់ណាទេ។

ស៊ូហ៊ី បានតែគ្រវីក្បាលអស់សំណើចនិងឫកពារឈ្លក់វង្វេងមនុស្សប្រុសរបស់មិត្តរួចក៏បន្តការងាររបស់ខ្លួន ហើយក៏នឹកឃើញដល់បុរសម្នាក់



Scanned by CamScanner

ទៀតដែលជួបកាលពីល្ងាចមិញ គេក៏មានរាងខ្ពស់សង្ហារដូចគ្នាដែរតែអន់ចរិកបន្តិច គេប្រហែលជាស្នាក់នៅទីនេះដែរហើយមើលទៅ នាងគិតក្នុងចិត្តរួចក៏គ្រលៀសភ្នែកជុំវិញនោះបន្តិចហើយក៏ដាក់ចុះវិញ។

សំឡេងបុគ្គលិកស្រីៗ នាំគ្នាឈូឆរដូចជាបានឃើញអ្វីប្លែកនៅមាត់ច្រកអគារធ្វើឲ្យអ្នកដែលនៅជុំវិញក្រូវងាកទៅចាប់អារម្មណ៍ដូចគ្នា រូបរាងសង្ហាររបស់បុរស ដែលដើរចូលមកធ្វើឲ្យស្រីៗសម្លឹងមើលដោយការស្រេកឃ្លាន។

«ស៊ូហ៊ីៗ ឯងឃើញទេនោះគឺអគ្គនាយកធំណាស់» សេមី ដែលនៅតុខោនធ័រប្រាប់មិត្តទាំងសម្លឹងទៅមាត់ច្រកដោយភាពរំភើប។

ស៊ូហ៊ី ដែលមិនសូវចាប់អារម្មណ៍រឿងមនុស្សប្រុសប៉ុន្មានក៏មិនសូវខ្វល់ នាងងាកទៅមើលមួយភ្លែត តែព្រោះតែមនុស្សរោមជិតទីនោះ ទើបមិនបានឃើញរាងខ្ពស់សង្ហាដែលមិត្តប្រាប់នោះ រួចក៏ងាកមមកធ្វើការងាររបស់ខ្លួនបន្ត រាងខ្ពស់របស់បុរសដែលដើរកាត់មុខតុខោនធ័រ មានអារម្មណ៍ដូចជាមានមនុស្សដែលគេស្គាល់ទើបងាកទៅមើល។

គេងាកឃើញនារីដែលឈ្លោះជាមួយកាលពីល្ងាចមិញ នៅតុខោនធ័ររួចងាកមកសួរអ្នកគ្រប់គ្រងទីនេះ ។

«ស្រីម្នាក់នោះធ្វើការនៅទីនេះមែនទេ?»

លោក គីម ផុង អ្នកគ្រប់គ្រងទីនេះ គាត់រាងចំណាស់បន្តិចហើយធ្វើភ្នែកលេងឡង់បន្តិចមិនដឹងថាអគ្គនាយកសួរពីម្នាក់ណានោះទេ ព្រោះបុគ្គលិកស្រីៗនៅទីនេះមានមិនតិចនោះទេ។

«អគ្គនាយកចង់សួរពីម្នាក់ណាដែរ?»

«គឺម្នាក់នោះ» គេនិយាយថែមទាំងងៀងភ្នែកទៅ ស៊ូហ៊ី ដែលឈ្ងោកធ្វើការនៅតុខាងនេះ។

«បាទនាងធ្វើការផ្នែកទទួលអតិថិជន» អ្នកគ្រប់គ្រងដែលងាកតាមក៏ឃើញ ស៊ូហ៊ី ដែលអង្គុយម្នាក់ឯងទើបឆ្លើយតប។

«យកប្រវត្តិរូបស្រីម្នាក់នោះមកឲ្យខ្ញុំ » គេនិយាយរួចក៏ដើរចេញទៅដោយមិនភ្លេចងៀងមើលនាងដោយស្នាមញញឹមមានល្បិច។

ក្នុងបន្ទប់ធ្វើការរបស់អគ្គនាយក ដែលគេកំពុងមមាញឹកនិងឯកសាររបស់គេពេញលើតុ ស្របពេលដែលសំឡេងទូរស័ព្ទរោទ៍ គេងាកមកមើលរួចក៏បង្ហាញទឹកមុខធុញទ្រាន់ ទើបហុចឲ្យមនុស្សជំនិតចាត់ការ។

(អាឡូ អ៉ែលវិន គឺអូនណា ពេលនេះបងនៅឯណា អូនទាក់ទងបងមិនបាននោះទេ?) សំឡេងក្នុងទូរស័ព្ទបន្លឺឡើង។

«ចៅហ្វាយកំពុងរវល់បាទ» មនុស្សជំនិតឆ្លើយតប។

(ហើយចុះពេលនេះគេនៅឯណា?) អ្នកនៅក្នុងទូរស័ព្ទសួរបន្តពេលដឹងថាអ្នកដែលទទួលទូរស័ព្ទមិនមែនជាមនុស្សដែលនាងចង់ជួប។

«នៅសណ្ឋាគារ»

(តែខ្ញុំទាក់ទងទៅហើយគេមិននៅទីនោះទេ? តើគេនៅសណ្ឋាគាសាខាណា?) នាងនិយាយបែបនេះព្រោះនាងបានទាក់ទងទៅសណ្ឋាគារសាខានៅអង់គ្លេសរួចហើយ តែគេប្រាប់ថាអគ្គនាយកគេមិននៅនោះទេ ទើបនាងទាក់ទងមកផ្ទាល់បែបនេះ។

«គឺនៅសណ្ឋាគារសាខា ហេនរីខូ»

(នែលោក សាខាសណ្ឋាគា ហេនរីខូ មិនមែនមានតែមួយពីរនោះ

ទេ?) អ្នកនៅក្នុងទូរស័ព្ទចាប់ផ្តើមនិយាយដោយកំហឹង ព្រោះតែនិយាយយូរហើយមិនទាន់បានចម្លើយច្បាស់។

«សូមទោសអ្នកនាង ចៅហ្វាយកំពុងរវល់មិនចង់ជួបអ្នកណានោះទេបាទ!» ជេក និយាយរួចក៏បិទទូរស័ព្ទគ្រវីក្បាល អេឡា នារីបង្ហាញម៉ូតនិងជាគូបណ្តើរចុងក្រោយរបស់ចៅហ្វាយគេ នាងតែងតែទូរស័ព្ទសួរជានិច្ចធ្វើឲ្យចៅហ្វាយគេធុញ ព្រោះគេមិនចូលចិត្តមនុស្សស្រីដែលរញេរញៃច្រើននោះទេ មនុស្សស្រីដែលតាមទាមគេគឺសម្លឹងឃើញលុយតែប៉ុណ្ណោះពេលដែលបានរបស់ដែលត្រូវការហើយ ក៏ចេញទៅហើយមើលទៅម្នាក់នេះប្រហែលមិនយូរនោះទេដែលត្រូវខ្ចាតចេញដូចស្រីមុនៗនោះដែរ។

«ចៅហ្វាយ ឯកសារដែលចៅហ្វាយត្រូវការ» មនុស្សជំនិតម្នាក់ទៀតរបស់គេចូលមកនឹងយកឯកសារដាក់លើតុ។

«អរគុណ» គេនិយាយរួចក៏ទាញឯកសារលើតុយកមកបើកមើលជាប្រវត្តិរូបរបស់ ស៊ូហ៊ី មនុស្សជំនិតទាំងពីរងាកមើលមុខគ្នាមិនយល់ពេលដែលចៅហ្វាយមើលឯកសារហើយក៏ញញឹម មិនដឹងជាចៅហ្វាយគេចង់លេងអីជាមួយនាងតូចម្នាក់នោះពួកគេគិតទាំងរអាចិត្ត។

ស៊ូហ៊ី ដែលកំពុងតែមមាញឹករៀបចំឥវ៉ាន់របស់ខ្លួនព្រោះ ហេជីនខលប្រាប់ថាម៉ាក់នាងមិនស្រួលខ្លាំងណាស់ត្រូវបញ្ជូនទៅមន្ទីរពេទ្យ ទើបនាងសុំចេញមុនម៉ោងដើម្បីទៅមើលគាត់ ដោយសារតែប្រញាប់ពេកទើបពេលដើរមកដល់មាត់ទ្វារបានបុកជាមួយ និងរាងខ្ពស់របស់បុរសម្នាក់យ៉ាងខ្លាំង រៀបនិងដួលតែក៏បានដៃរឹងមាំនោះឱបចង្កេះជាប់។

«ស៊ូហ៊ី មិនអីទេមែនទេ?»



Scanned by CamScanner

អ្នកកំលោះដែលត្រកងនាងសួរ ព្រោះមើលទៅទឹកមុខនាងដូចជាភ័យខ្លាំង។

«មិនអីទេ អរគុណប្រធានផ្នែក» នាងនិយាយទាំងញញឹមតិចៗ និងប្រឹងងាកខ្លួនចេញ ទើបគេរសាយរង្វង់ដៃទាំងសោកស្ដាយ។

«ហេតុអីក៏ប្រញាប់បែបនេះ មានរឿងអីមែនទេ?»

«គឺនៅផ្ទះមានរឿងបន្តិចបន្តួចទើបសុំទៅមុន» នាងនិយាយរួចក៏សុំចេញទៅ រូបរាងបុរសម្នាក់ទៀតដែលឈរនៅជ្រុងម្ខាងនៃអគារ គេឈរមើលឃើញគ្រប់សកម្មភាពទាំងអស់ មិនដឹងមូលហេតុអីពេលដែលឃើញនាងស្និទ្ធជាមួយប្រុសដ៏ទៃ ហេតុអីក៏មានអារម្មណ៍ម៉ូម៉ៅទៅវិញគេរម្ងាប់អារម្មណ៍នោះរួចក៏ដើរចេញទៅ។

ស៊ូហ៊ី មកដល់មន្ទីរពេទ្យទាំងប្រញាប់ប្រញាល់ សួរគិលានុបដ្ឋយិការកបន្ទប់របស់ម្ដាយមុននឹងដើរសំដៅទៅ។

«ម៉ាក់ ម៉ាក់យ៉ាងម៉េចហើយ?» នាងសួរទាំងព្រួយបារម្ភពេលចូលមកដល់ក្នុងដើរសំដៅគ្រែគាត់យ៉ាងលឿនដែលមាន ហេជីន នៅឈរជិតនោះដូចគ្នា។

«ម៉ាក់មិនអីទេ!» គាត់ញញឹមតិចៗតបកូនស្រី។

«ច្បាស់ហើយថាមិនអី ចុះគ្រូពេទ្យថាយ៉ាងម៉េច?» នាងប្រាប់គាត់ហើយក៏ងាកមកសួរ ហេជីន ដែលឈរក្បែរ។

ហេជីន រាងទាក់ទើរសម្លឹងមុខអ្នកស្រី ហេវ៉ន នាងទើបតែដឹងពីសភាពជំងឺគាត់ច្បាស់ពេលនេះទេ តែគាត់សុំឲ្យនាងលាក់រឿងនេះព្រោះគាត់មិនចង់ឲ្យកូនស្រីលំបាកជាងនេះនោះទេ។



Scanned by CamScanner

«គ្រាន់តែជាអាការៈធម្មតារបស់មនុស្សចាស់តែប៉ុណ្ណោះ គ្មានអីទេកូនកុំបារម្ភអី» សំឡេងស្ត្រីចំណាស់បន្លឺឡើងទើបនាងដកភ្នែកពី ហេជីនងាកទៅមើលគាត់។

«មិនអីល្អហើយ ខ្ញុំខំតែបារម្ភ» នាងប្រាប់ទាំងញញឹមតិចៗលើកដៃគាត់មកកាន់ដាក់អឹបថ្នាល់ អ្នកជាម្ដាយបានត្រឹមញញឹមអង្អែលក្បាលកូនស្រីតែឆ្ងៀតលួចសម្លឹងទៅ ហេជីន ដែលមានទឹកមុខស្រពោនគាត់យល់ពីគំនិតនាងទើបញញឹមតិចៗលួងចិត្ត។

អគ្គនាយកធំកំពុងធ្វើការ តែអារម្មណ៍មិនសូវស្ងប់នោះទេ ពេលនឹកឃើញរូបភាព ស៊ូហ៊ី ស្និទ្ធស្នាលជាមួយប្រុសផ្សេងមុននេះ តែក៏ព្យាយាមរលាស់រូបភាពនោះចេញ និងចាត់ការឯកសាររបស់គេបន្ត។



Scanned by CamScanner







...២...

ព្រឹកនេះ ស៊ូហ៊ី មកធ្វើការធម្មតាតែទឹកមុខមិនសូវស្រស់នោះទេ ថែមទាំងពេលដែលឮថាអគ្គនាយកឲ្យទៅជួបនៅបន្ទប់ ក៏ចាប់ផ្ដើមភ័យ ព្រោះនាងមិនធ្លាប់ជួបអគ្គនាយកធំ ហើយមិនដឹងគេចង់ជួបនាងព្រោះអ្វីនោះទេ ហើយនាងក៏មិនបានធ្វើអីខុសនោះដែរ។

«ស៊ូហ៊ី មានរឿងអីមែនទេ ទើបអគ្គនាយកហៅឯងទៅជួប» សេមី មិត្តរបស់នាងសួរពេលឃើញនាងត្រឡប់មកវិញទាំងមុខក្រញូវ។

«គ្មានអីនោះទេ» ស៊ូហ៊ី ឆ្លើយតបមិត្តទាំងមុខក្រហម ព្រោះនឹកដល់រឿងមិញនេះ។

នាងឡើងមកដល់បន្ទប់អគ្គនាយក មនុស្សជំនិតរបស់គេនាំនាងចូលក្នុងរួចគេក៏ចេញមកវិញ ក្នុងបន្ទប់មានតែនាងនិងអគ្គនាយកតែប៉ុណ្ណោះ គេអង្គុយកៅអីស្បែកធំបែរមុខទៅជញ្ជាំងកញ្ចក់ នាងឈរចាំគេឡើងយូរមិនហ៊ាននិយាយអីនោះទេ ចាំរហូតដល់កៅអីអគ្គនាយកបែរត្រឡប់មកវិញ តែកៅអីនោះនៅតែមិនបែរទើបនាងដាច់ចិត្តនិយាយតិចៗ។

«សូមទោសអគ្គនាយកនាងខ្ញុំ ផាក ស៊ូហ៊ី មកដល់ហើយ» នាងនិយាយទាំងញញើតញញើម ព្រោះធ្លាប់ឮបុគ្គលិកនៅទីនេះប្រាប់ថាអគ្គនាយកកាចខ្លាំងណាស់ ហើយថ្ងៃនេះត្រូវជួបគេផ្ទាល់បែបនេះទៀតនាងគិតក្នុងចិត្តទាំងភ័យព្រួយ ស្របពេលកៅអីស្បែករបស់គេបែរមករូបភាពបុរសដែលអង្គុយលើកៅអីនោះធ្វើឲ្យនាងបើកភ្នែកធំៗព្រោះតែភ្ញាក់ផ្អើល។

«លោក...» នាងនិយាយបានត្រឹមហ្នឹងក៏លើកដៃបិទមាត់ គេជាអគ្គនាយកទីនេះមែនទេ ស្លាប់ហើយខ្ញុំគិតធ្វើយ៉ាងម៉េចទៅបើគេដេញ

នាងចេញព្រោះតែរឿងកាលពីល្ងាចនោះគិតយ៉ាងម៉េចទៅ នាងគិតក្នុងចិត្តទាំងខ្វល់ខ្វាយមិនហ៊ានងើបសម្លឹងមុខគេនោះទេ។

«ងើបមុខឡើង» គេប្រាប់សំឡេងរឹងទើបនាងត្រូវធ្វើតាម។

«យ៉ាងម៉េចភ្ញាក់ផ្អើលខ្លាំងណាស់មែនទេ ហេតុអីក៏មិនធ្វើដូចថ្ងៃនោះទៀតក្រែងនាងក្លាហាននោះអី» គេនិយាយទាំងក្រោកដើរមកឈរចំពោះមុខធ្វើឲ្យនាងចាប់ផ្ដើមភ័យមិនហ៊ានមើលមុខគេចំនោះទេ។

«សូមទោស អគ្គនាយក» នាងនិយាយទាំងឱនលំទោន ទើបធ្វើឲ្យក្លិនក្រអូបផ្កាលីលីនោះរសាត់ប៉ះច្រមុះគេម្ដងទៀត គ្រាន់តែបានឈរជិតនាងក៏ធ្វើឲ្យគេមានអារម្មណ៍ចង់តែចាប់ក្រញេចយ៉ាងម៉េចមិនដឹងទេ។

«ត្រចៀកខ្ញុំប្រហែលមានបញ្ហាដូចនាងប្រាប់ហើយ ទើបស្ដាប់មិនសូវច្បាស់បែបនេះ» គេនិយាយទាំងយកដៃកេះត្រចៀក ស៊ូហ៊ី មានអារម្មណ៍ចង់តែដាល់មាត់បុរសម្នាក់នេះខ្លាំងណាស់ តែមិនអាចព្រោះគេជាអគ្គនាយកទីនេះដូច្នេះបានត្រឹមទ្រាំ។

«មិនមែនបែបនោះទេ អគ្គនាយក» នាងនិយាយតិចៗទាំងធ្វើមុខញញឹមៗមើលទៅគេ។

អែលវិន ឈរមើលមុខនាងដែលញញឹមខ្សោះដាក់ គេចង់សើចខ្លាំងណាស់ ពេលឃើញនាងក្លាយជាកូនឆ្មាស្លូតបូតបែបនេះ តែក៏ធ្វើឲ្យគេឈ្លក់វង្វេងលើផ្ទៃមុខនាងដូចគ្នា បបូរមាត់នាងពិតជាទាក់ទាញដល់ហើយចង់តែថើបញក់ញីនោះទេ គិតរួចក៏រលាស់គំនិតនោះចេញវិញ។

«មិនមែនបែបនោះតើបែបណា?» គេបន្តសំនួរធ្វើឲ្យនាងរកពាក្យតបមិនឃើញដូចគ្នា នាងបានសុំទោសគេហើយតើ គេនៅរករឿងនាងធ្វើ





អីទៀត នាងគិតក្នុងចិត្តមុននឹងងើបមុខមកសម្លឹងមុខគេ។

«អគ្គនាយកចង់ឲ្យខ្ញុំធ្វើយ៉ាងម៉េច?» នាងសួរតបសំឡេងស្រាល នាងមិនអាចត្រូវគេដេញចេញពេលនេះនោះទេ ព្រោះពេលនេះម៉ាក់នាងឈឺបើនាងគ្មានការងារធ្វើទៀតនោះតើគ្រួសារនាងគិតយ៉ាងម៉េច នាងគិតក្នុងចិត្តទាំងមុខស្រពោន។

អែលវិន ឃើញនាងធ្វើមុខបែបនេះធ្វើឲ្យគេមានអារម្មណ៍អាណិតតិចដែរតែនឹកឃើញសម្ដីឌឺដងរបស់នាងក៏នឹកចង់លេងសើចបន្ត គេឈរសម្លឹងនាងពីលើដល់ក្រោម ហាក់ចង់មើលឲ្យធ្លុះដល់រាងកាយនាងថែមទៀតរួចមកឈប់ត្រឹមបបូរមាត់ពណ៌ក្រហមនោះ ស៊ូហ៊ី ចាប់ផ្ដើមមានអារម្មណ៍មិនសូវស្រួលពេលឃើញខ្សែភ្នែករបស់គេបែបនេះ អែលវិនសន្សឹមៗដើរមកឈរកៀក ទើបនាងឈានថយក្រោយដោយភាពភិតភ័យព្រោះមិនដឹងគេចង់ធ្វើអីនោះទេ។

«អគ្គនាយក» នាងហៅគេសំឡេងញ័ររួចក៏បែខ្លួនបំរុងនឹងរត់ចេញ តែក៏ត្រូវគេចាប់ក៏ដៃជាប់ទាញមកផ្អឹមដើមទ្រូងរឹងមាំ ថែមទាំងក្រសោបចង្កេះនាងជាប់ទៀត ស៊ូហ៊ី ប្រឹងរើបម្រះតែមិនបានសម្រេច គេយកដៃម្ខាងទៀតចាប់ផ្ទៃមុខនាងជាប់ មុននឹងឱនទៅរកបបូរមាត់ស្ដើងនោះថើបជញ្ជក់គ្រលាស់អណ្ដាតនាងទៅមក ស៊ូហ៊ី ដែលមិនធ្លាប់មានបទពិសោធន៍បានត្រឹមទន់ខ្លួនក្នុងរង្វង់ដៃគេ ការតបស្នងបែបមិនដឹងអីរបស់នាងធ្វើឲ្យគេពេញចិត្ត គេសន្សឹមៗលូកដៃចូលក្នុងអាវសឺមីរបស់នាង បាតដៃក្ដៅប៉ះជាមួយស្បែកខ្នង ទើបធ្វើឲ្យនាងរាងភ្ញាក់ខ្លួនរើបម្រះម្ដងទៀតហើយក៏បានសម្រេច រុញរាងក្រាស់ចេញរួចក៏ថយក្រោយដោយភាពភ័យខ្លាច

អែលវិន ដែលកំពុងជក់ចិត្តនឹងបប្ញូរមាត់ផ្ដែមក្រអូបនោះ បានត្រឹមស្រទាំងកាំងបន្តិចពេលនាងរុញគេចេញ បើមនុស្សស្រីផ្សេងច្បាស់ជាតបស្នងគេដោយក្ដីពេញចិត្ត តែស្រីម្នាក់នេះបែរជាធ្វើបែបនេះធ្វើដូចគេជារបស់ដែលគួរឲ្យខ្ពើមរអើមគិតហើយក៏ចាប់ផ្ដើមម៉ូម៉ៅ គេសម្លឹងទៅនាងដោយក្រសែភ្នែកមុត ស៊ូហ៊ី ដែលមុខក្រហមមិនទាន់បាត់នោះចាប់ផ្ដើមញាប់ញ័រ។

«នាងត្រូវការប្រាក់ប៉ុន្មាន?» អែលវិន សួរសំឡេងរឹងព្រោះគិតថានាងបដិសេធមុននេះប្រហែលមកពីគេមិនទាន់និយាយរឿងនេះជាមួយ។

ស៊ូហ៊ី ងើបមុខមកសម្លឹងគេព្រោះមិនយល់ នាងមិនបាននិយាយអ៊ីទាក់ទងរឿងប្រាក់នោះទេ ហេតុអីសុខៗក៏គេសួររឿងនេះទឹកមុខងឿងឆ្ងល់របស់នាងធ្វើឲ្យគេកាន់តែម៉ូម៉ៅ គេនៅក្ដៅខ្លួនមិនទាន់បាត់នោះទេ ព្រោះតែភ្លើងដែលបង្កើតជាមួយនាងមុននេះ ហើយនាងធ្វើដូចគ្មានអីកើតឡើងទៅកើតគិតរួចក៏ដើរទៅរកនាងម្ដងទៀត នាងក្រមុំបែខ្លួនបំរុងនឹងរត់តែក៏ត្រូវគេក្រសោបជាប់។

«ខ្ញុំសួរនាងថាត្រូវការប៉ុន្មាន ខ្ញុំត្រូវការនាងឥលូវនេះ» សំនួររបស់គេម្ដងនេះធ្វើឲ្យនាងឈប់ឆ្ងល់មិនមែនព្រោះតែសប្បាយចិត្តនោះទេ នាងងាកមកមើលមុខគេ អែលវិន បានត្រឹមញញឹមចុងមាត់មនុស្សស្រីមិនខុសគ្នានោះទេធ្វើឫកធ្វើពារតែឲ្យតែនិយាយរឿងនេះទើបងាយស្រួលបន្តិច។

«ខ្ញុំមិនបានត្រូវការប្រាក់របស់លោកនោះទេ ហើយខ្ញុំក៏មិនមែនស្រីលក់ខ្លួននោះដែរ» នាងនិយាយសំឡេងរឹងបន្ទាប់ពីយល់ន័យរបស់គេ គិតថានាងត្រូវការប្រាក់ដោយការដោះដូរខ្លួនឬយ៉ាងម៉េច មនុស្សគំរក់នាង





គិតក្នុងចិត្តមុននិងប្រឹងរើបម្រះឲ្យរួចផុតពីដៃគេ រួចក៏រត់ចេញទៅយ៉ាងលឿន គេបានត្រឹមឈរម៉ូម៉ៅតែម្នាក់ឯងប្រឹងរម្ងាប់អារម្មណ៍ត្រូវការមុននេះឆ្កួតមែន ហេតុអីក៏ត្រូវការស្រីម្នាក់នេះដល់ថ្នាក់នេះ ឬមកពីគេខានរំសាយអារម្មណ៍យូរ គិតរួចក៏ដើរទៅតុធ្វើការរបស់ខ្លួនទាំងអារម្មណ៍មិនស្ងប់។

ស៊ូហ៊ី ដែលរត់ចេញមកនាងទៅឈររម្ងាប់អារម្មណ៍នៅក្នុងបន្ទប់ទឹក រៀបចំសំលៀកបំពាក់របស់ខ្លួនឲ្យមានរបៀប មុននឹងទៅកន្លែងរបស់ខ្លួន នឹកឃើញរឿងទាំងនេះធ្វើឲ្យមុខនាងក្រហម មិនគួរលង់ខ្លួនឲ្យគេលូកលាន់សោះ គួរឲ្យខ្មាសណាស់បែបនេះមែនទេទើបគេគិតថានាងជាស្រីមុខលុយ ហើុយយ៉ាប់មែននាងរអ៊ូម្នាក់ឯងក្នុងចិត្ត ស្របពេលមាននារីពីរបីនាក់ដើរមកឈប់ខាងមុខតុធ្វើការរបស់នាង សម្លឹងមកដោយក្រសែភ្នែកស្អប់ខ្ពើម ពួកនាងជាបុគ្គលិកផ្នែកផ្សេងដោយសារទើបដឹងថា ស៊ូហ៊ី ត្រូវអគ្គនាយកហៅឲ្យទៅជួបទើបកើតអការៈច្រណែន ព្រោះពួកនាងធ្វើការនៅទីនេះយូរហើយតែអគ្គនាយកមិនដែលហៅទៅជួបនោះទេ។

ស៊ូហ៊ី សម្លឹងមើលពួកនាងដែលឈរចំពោះមុខដោយទឹកមុខស្មើមិនដឹងថាពួកនោះមករករឿងនាងព្រោះអីទៀតហើយទេ ពីមុនក៏ធ្លាប់មករករឿនាងម្ដងមកហើយពេលដែលនាងទើបចូលធ្វើការដំបូង ខ្ជិលគិតហើយក៏ធ្វើការងាររបស់ខ្លួនបន្ត។

«អគ្គនាយកហៅនាងទៅធ្វើអី?» សំឡេងនារីម្នាក់ក្នុងចំណោមប៉ុន្មាននាក់នោះបន្លឺឡើង ស៊ូហ៊ី ចាប់ផ្ដើមយល់ហើយថាព្រោះរឿងអីទើបពួកនាងនាំគ្នាលើកទ័ពមកទីនេះ។

«មិនមែនជារឿងរបស់ពួកនាងនោះទេ?» នាងក្រមុំតបសំឡេងស្មើ

ដើបសម្លឹងមុខពួកនោះបន្តិចមុននឹងទម្លាក់ចុះវិញបែបមិនខ្វល់។

«ឯងនិយាយថាម៉េចមិញ?» សំឡេងនារីម្នាក់ទៀតបន្លឺឡើងទើប នាងបង្អង់ដៃដែលនៅលើបើបតាដើបសម្លឹងអ្នកម្ខាងទៀត បង្ហាញទឹកមុខធុញទ្រាន់ព្រោះមិនចង់មានរឿងជាមួយពួកនេះនោះទេ។

«ក្រចៀកនាងប្រហែលជាមានបញ្ហាហើយ បានជាស្តាប់មិនច្បាស់បែបនេះ» ផាច់...សំឡេងបាតដៃប៉ះ និងសាច់ថ្ពាល់លាន់ឮមិនធូន់ហើយក៏មិនស្រាលដែរអាចធ្វើឲ្យមនុស្សនៅជុំវិញនេះឮនាំគ្នាសម្លឹងមកគ្រប់គ្នា។

«នែ! ហើយពួកនាងធ្វើស្អីហ្នឹង?» សំឡេង សេមី បន្លឺឡើងនាងទើបមកពីបន្ទប់ទឹកស្របពេលមកឃើញពួកនោះទះកំផ្លៀង ស៊ូហ៊ី ល្មមទើបចូលមកមើលយ៉ាងលឿន។

«យ៉ាងម៉េច យើងកំពុងប្រដៅមនុស្សដែលមិនស្គាល់អ្នកណាមុនអ្នកណាក្រោយ» សំឡេងនារីម្នាក់ដែលទះនាងមុននេះបន្លឺឡើងថែមទាំងសម្លឹងមកពួកនាងដោយក្រសែភ្នែកមុត។

«មកមុនមកក្រោយអី?» សេមី និយាយតិចៗងាកមកមើល ស៊ូហ៊ី ក្រោយមកក៏នឹកឃើញរឿងមុននេះទើបងាកទៅមើលពួកគេវិញ ។

«មកមុនយ៉ាងម៉េច មកពីនាងគេមើលមិនចូលភ្នែកទើបនៅដល់ពេលនេះកុំមកបន្ទោសគេ» សេមី ប្រាប់ទៅវិញទាំងញញឹមចំអកធ្វើឲ្យពួកនោះនាំគ្នាក្តាប់ដៃណែនដោយកំហឹង។

«នាង...នាង...»

«មានរឿងអីហ្នឹង?» សំឡេងមានអំណាចរបស់អ្នកណាម្នាក់បន្លឺឡើងនៅខាងក្រោយទើបនាំគ្នាងាកទៅមើល ហើយក៏បើកភ្នែកធំៗ ពេល





ឃើញថាជាអ្នកណា។

អែលវិន ទើបចុះមកដើរមកដល់ខាងមុខស្របពេលក្រឡេកឃើញមនុស្សអ៊ូអរទើបដើរមកមើល គេសម្លឹងមុខ ស៊ូហ៊ី ដែលកំពុងឱនមុខចុះតែក៏អាចមើលស្នាមក្រហមលើថ្ពាល់នាងបានដែរ កំលោះធ្វើមុខស្មើរសម្លឹងទៅនារីពីរបីនាក់ទៀតដោយក្រសែភ្នែកមុតធ្វើឲ្យម្នាក់ៗនាំគ្នាភ័យ។

«គ្មាន... គ្មានអីទេអគ្គនាយក» នារីម្នាក់ក្នុងចំណោមនោះតបទាំងសំឡេងញ័រព្រោះតែភាពភ័យខ្លាច។

«បើគ្មានអីនាំគ្នាទៅធ្វើការទៅ» គេប្រាប់សំឡេងស្មើរហើយក៏ដើរចេញទៅដូចមិនខ្វល់ ទើបពួកនាងប៉ុន្មាននាក់នោះនាំគ្នាងាកមកញញឹមចំអកហើយក៏ដើរចេញទៅ។

«ស៊ូហ៊ី ឯងមិនអីទេមែនទេ?» សេមី សួរទាំងយកដៃទាញមុខមិត្តមកមើលចុះមើលឡើងទាំងបារម្ភ។

«ខ្ញុំមិនអីទេ» នាងតបសំឡេងស្រាលទាំងញញឹមតិចៗ។

«មុខឡើងក្រហមហើយនៅថាមិនអីទៀត ចាំតិចគ្នាទៅយកថ្នាំមកលាបឲ្យណា» សេមី ប្រាប់ទាំងដើរទៅបន្ទប់ពេទ្យដែលនៅក្នុងសណ្ឋាគារ ស៊ូហ៊ី យកដៃអង្អែលថ្ពាល់ដែលក្រហម ព្រោះមិនចង់មានរឿងជាមួយពួកនោះទើបសុខចិត្តនៅស្ងៀម នាងឆ្លៀតសម្លឹងទៅអ្នកដែលទើបដើរចេញទៅមុននេះដោយមិនចាប់អារម្មណ៍ពីនាងអីបន្តិចទាំងទើបតែមានរឿងនៅក្នុងបន្ទប់គេសោះ មនុស្សគ្មានចិត្ត នាងរអ៊ូក្នុងចិត្ត។

អែលវិន ដែលទើបដើរចេញទៅមុននេះគេមិនទាន់ទៅណាឆ្ងាយនោះទេ គេនៅឈរមើលនាងនៅជ្រុងមួយ មិនដឹងដូចគ្នាគ្រាន់តែឃើញ



Scanned by CamScanner

ហេជីន ប្រាប់សំឡេងស្រាលទើបធ្វើឲ្យអ្នកដែលមកមុននេះសំដៅបន្ទប់គាត់សម្រាកយ៉ាងលឿន តែក៏ត្រូវអ្នកម្នាងទៀតកាន់ដៃជាប់។

«មានអីមែនទេ ហេជីន» ស៊ូហ៊ី ងាកមកសួរមិត្តទាំងសម្លឹងមើលដៃរបស់នាងដែលត្រជាក់ ធ្វើឲ្យនាងចាប់ផ្ដើមមានអារម្មណ៍មិនស្រួលពេលឃើញទឹកមុខមិនល្អរបស់មិត្ត ស្របពេលលោកគ្រូពេទ្យម្នាក់ដើរមកទាំងទឹកមុខតានតឹង មុននឹងហៅពួកនាងទៅជួបដើម្បីនិយាយពីអាការៈជំងឺរបស់សអ្នកស្រី ហេវ៉ន។

ស៊ូហ៊ី ឈរមិនចង់នឹងបន្ទាប់ពីឮនាងអង្គុយយំមិនឈប់នៅមុខបន្ទប់អ្នកជំងឺ តូចចិត្តដែលគាត់លាក់បាំងរឿងនេះជាមួយនាងរហូតសភាពកាន់តែធ្ងន់ធ្ងរ គ្រូពេទ្យប្រាប់ថាគួរតែធ្វើការវះកាត់ជាបន្ទាន់មិនអាចពន្យាពេលទៀតបានទេ ចំណែកថ្លៃព្យាបាលនោះ វាច្រើនខ្លាំងណាស់ធ្វើឲ្យនាងចាប់ផ្ដើមខ្វល់ខ្វាយ ព្រោះមិនដឹងត្រូវរកប្រាក់មកពីណានោះទេ ប្រាក់សន្សំនាងក៏មិនគ្រប់ ហេជីន ដែលឃើញមិត្តបែបនេះធ្វើឲ្យនាងចាប់ផ្ដើមអាណិតដូចគ្នា។

«ស៊ូហ៊ី» ហេជីន ហៅអ្នកដែលកំពុងអង្គុយស្មុគស្មាញនៅខាងមុខផ្ទះនាងមិនញ៉ាំបាយទឹកគិតតែពីអង្គុយទ្រឹងទើបដើរមកមើល។

«ឯងដឹងរឿងនេះយូរហើយមែនទេ?» ស៊ូហ៊ី សួរសំឡេងស្រាលសម្លឹងមើលមិត្តដោយខ្សែរភ្នែកសោកសៅ។

«ខ្ញុំទើបតែដឹងពេលនាំគាត់ទៅមន្ទីរពេទ្យលើកមុនទេ គាត់សុំខ្ញុំឲ្យលាក់រឿងនេះព្រោះគាត់មិនចង់ឲ្យឯងលំបាកដោយសារគាត់» ស៊ូហ៊ី កាន់តែយំលើសដើមបន្ទាប់ពីឮទើប ហេជីន ត្រូវទាញនាងមកឱបលួងលោម

ផ្តល់កំលាំងចិត្ត។

«ខ្ញុំមានប្រាក់សន្សំមួយចំនួន ឯងយកទៅចេញថ្លៃព្យាបាលអ៊ំស្រីទៅ» ហោជីន ប្រាប់សំឡេងស្រាលញញឹមចេញតិចៗ។

«កុំអី ខ្ញុំដឹងថាឯងចង់ជួយតែឯងក៏គួរគិតខ្លួនឯងដែរ បើឯងយកលុយនោះមកជួយខ្ញុំចុះកូនឯងគិតយ៉ាងម៉េច?» ស៊ូហ៊ី និយាយទាំងសម្លឹងពោះរាបស្មើរបស់នាង ធ្វើឲ្យនាងសម្លឹងតាមទាំងមុខស្ងួត។

«ខ្ញុំ...» ហោជីន និយាយបានត្រឹមហ្នឹងក៏ត្រូវ ស៊ូហ៊ី និយាយកាត់។

«កុំបារម្ភអី ខ្ញុំអាចដោះស្រាយបាន» ស៊ូហ៊ី និយាយទាំងញញឹមក្រៀមរួចក៏នាំគ្នាចូលក្នុង ហោជីន បានត្រឹមចាប់ដៃផ្តល់កំលាំងចិត្តដល់នាងតែប៉ុណ្ណោះ។

យប់នេះ ស៊ូហ៊ី គេងមិនលក់នោះទេព្រោះបារម្ភរឿងម្តាយរបស់នាង ហើយក៏គិតដល់រឿង ដែលកើតឡើងនៅបន្ទប់អគ្គនាយកកាលពីព្រឹកនោះនឹកដល់ស្នាមថើបរបស់គេ នាងភ្លេចខ្លួនអង្អែលបបូរមាត់រួចក៏មុខក្រហម នេះឯងលង់លើស្នាមថើបរបស់គេមែនទេ ស៊ូហ៊ី នាងសួរខ្លួនឯងទាំងខ្មាសអៀនរួចក៏ទាញភួយគ្របខ្លួនជិត។

ស៊ូហ៊ី មកធ្វើការទាំងមុខស្រពោនធ្វើឲ្យមិត្តរួមការងារងឿងឆ្ងល់យ៉ាងខ្លាំងតែមិនបាច់សួរក៏អាចដឹងបានដែរ។

«ស៊ូហ៊ី មិនស្រួលខ្លួនមែនទេ?» សេមី មិត្តរបស់នាងសួរទើបធ្វើឲ្យអ្នកដែលកំពុងអង្គុយភ្លឹកនោះភ្ញាក់បន្តិច។

«គ្មានអីទេ» នាងតបសំឡេងស្រាលនឹកឃើញអ្វីមួយទើបងាកទៅមើលមិត្តនាងម្តងទៀត។





«សេមី ឯងស្គាល់ការងារក្រៅម៉ោងកន្លែងណារកប្រាក់បានច្រើនដែរទេ?» នាងសួរមិត្តសំឡេងស្រាលធ្វើឲ្យអ្នកម្ខាងទៀតងាកមុខមកមើលរាងភ្ញាក់ផ្អើលបន្តិចបន្ទាប់ពីឮមិត្តសួរបែបនេះ។

«ឯងសួរធ្វើអី?»

«គឺ គ្នាត្រូវការប្រាក់មួយចំនួនទើបចង់ធ្វើការងារក្រៅម៉ោងបន្ថែម» សេមី រិះគិតកន្លែងដែលរកប្រាក់បានច្រើនមានតែនៅក្លឹប តែកន្លែងនោះមិនសមជាមួយមិត្តនាងនោះទេ គិតរួចក៏រលាស់គំនិតនោះចេញ។

«យ៉ាងម៉េចស្គាល់ដែរទេ?» នាងសួរមិត្តបន្ថែមពេលមិនឮតប។

«ឯងត្រូវការប្រាក់ធ្វើអី? ខ្ចីគ្នាសិនក៏បានដែរ» សេមី សួរទាំងសម្លឹងមុខមិត្តចាំស្តាប់ ស៊ូហ៊ី ធ្វើមុខតានតឹងបន្តិចមុននឹងតប។

«កុំអី គ្នារកខ្លួនឯងក៏បានដែរ»

«ហេតុអី ឯងគិតថាខ្ញុំគ្មានលុយឲ្យមែនទេ?» សេមី និយាយបែបតូចចិត្តធ្វើឲ្យនាងធ្វើខ្លួនមិនត្រូវ នាងគ្មានគំនិតបែបនេះនោះទេ គ្រាន់តែមិនចង់ឲ្យមិត្តមកលំបាកជាមួយតែប៉ុណ្ណោះ។

«មិនមែនបែបនោះទេ គ្នាត្រូវការច្រើនបើឯងឲ្យគ្នាចុះខ្លួនឯងគិតយ៉ាងម៉េច?»

«ឯងរកធ្វើអីច្រើនម្លេះ?» សេមី សួរបន្ថែមពេលព្រោះមើលទឹកមុខមិត្តដូចជាខ្វាយខ្វល់ខ្លាំងណាស់។

«ជំងឺម៉ាក់កាន់តែធ្ងន់ខ្ញុំត្រូវរកលុយវះកាត់ឲ្យគាត់» ស៊ូហ៊ី ប្រាប់សំឡេងស្រាលឱនមុខចុះ សេមី នៅស្ងៀមបន្ទាប់ពីឮនាងសម្លឹងមុខមិត្តដោយក្តីអាណិត តែគ្មានលទ្ធភាពអាចជួយបានមានតែលើកទឹកចិត្តនាង



Scanned by CamScanner

តែប៉ុណ្ណោះ។

«គ្នាស្គាល់កន្លែងមួយ តែវាមិនសូវសមសម្រាប់ឯងនោះទេ» សេមី ប្រាប់សំឡេងស្រាលគិតដល់កន្លែងដែលនាងនឹកឃើញមុននេះ។

«កន្លែងណាប្រាប់គ្នាមក» ស៊ូហ៊ី ងើបមុខមកសួរយ៉ាងលឿន មើលទៅនាងដូចជារីករាយបន្តិចបន្ទាប់ពីឮ។

ក្នុងបន្ទប់ធ្វើការរបស់អគ្គនាយក អ៊ែលវិន កំពុងមមាញឹកនឹងការងាររបស់ខ្លួននៅលើតុស្របពេលសំឡេងទូរស័ព្ទរោទ៍ ធ្វើឲ្យគេបញ្ឈប់សកម្មភាពការងារបន្តិច ទឹកមុខបង្ហាញភាពធុញទ្រាន់ងាកទៅមើល ហើយក៏ត្រូវសម្រួលទឹកមុខមកវិញ ពេលឃើញថាជាអ្នកណាខលមកមុននឹងលើកទទួល។

«អាឡូម៉ាក់» គេពាក់ទាក់សំឡេងស្រទន់ដាក់អ្នកដែលខលមក។

(អ៊ែលវិន ពេលនេះកូននៅឯណា?) សំឡេងក្នុងទូរស័ព្ទបន្លឺឡើងធ្វើឲ្យអ្នកម្ខាងទៀតធ្វើភ្នែកក្រឡេកក្រឡាប់បន្តិចមុននឹងតប។

«ខ្ញុំនៅសណ្ឋាគារ ចុះម៉ាក់នៅឯណា?»

(សណ្ឋាគារនៅកូរ៉េមែនទេ ម៉ាក់ក៏នៅកូរ៉េដែរ)

«ម៉ាក់មកដល់ពីអង្កាល ហេតុអីមិនប្រាប់ខ្ញុំផង» គេប្រាប់សំឡេងតូចចិត្តបន្តិចធ្វើឲ្យអ្នកជាម្ដាយញញឹម។

(ម៉ាក់ទើបមកដល់ទេ ព្រោះមិនចង់រំខានហ្នឹងណា កូនធ្វើការបន្តទៀតចុះ ម៉ាក់គ្រាន់តែប្រាប់កូនឲ្យដឹង ហើយមិនបាច់ឲ្យមនុស្សមកតាមការពារម៉ាក់ទេ ម៉ាក់មិនចូលចិត្តអ្នកតាមច្រើនប៉ុណ្ណឹងហើយណា) គាត់ប្រាប់រួចក៏បិទទូរស័ព្ទ ស្នាមញញឹមពេញដោយក្ដីស្រលាញ់បង្ហាញលើមុខ





កំលោះ គេរស់នៅតែពីរនាក់ម៉ាក់គេតាំងពីតូចទោះបីជាគ្មានប៉ាក៏គេទទួលបានក្ដីស្រលាញ់ភាពកក់ក្ដៅដូចអ្នកមានគ្រួសារពេញលេញដូចគ្នា ទោះមកដល់ពេលនេះគេមានអាយុច្រើនហើយក្ដី តែពេលខ្លះគេក៏នៅត្រូវការការលួងលោមពីម៉ាក់គេដូចគ្នា គិតដល់អ្នកម៉ាក់គេក៏ធ្វើឲ្យគេនឹកឃើញដល់រង្វង់មុខនារីម្នាក់ជាពិសេសបបូរមាត់ស៊ីជំពូដ៏ទាក់ទាញរបស់នាង គេខានជួបនាងប៉ុន្មានថ្ងៃហើយ ព្រោះត្រូវទៅមើលការងារនៅសាខាកន្លែងផ្សេងនឹកឃើញដល់ឬកពារដូចជាស្អប់ខ្ពើមរបស់នាង ធ្វើឲ្យគេចាបផ្ដើមម៉ូម៉ៅ ប្រហែលជាត្រូវរកកន្លែងបន្ធូរអារម្មណ៍ម្ដងហើយ ព្រោះមួយរយៈនេះការងារច្រើនពេក។

«ជេក ការងារមានតែប៉ុណ្ណឹងទេមែនទេ» គេសួរមនុស្សជំនិតទាំងភ្នែកនៅតែរវល់ជាមួយឯកសារនៅឡើយ។

«បាទចៅហ្វាយ» មនុស្សជំនិតតបតែកំពុងរិះគិត។

«យប់នេះជួយរកកន្លែងបន្ធូអារម្មណ៍ឲ្យខ្ញុំផង» គេប្រាប់សំឡេងស្មើរធ្វើឲ្យមនុស្សជំនិតទាំងពីរញញឹមចុងមាត់ព្រោះដូចអ្វីដែលគេគិត។

«ញញឹមអី» គេងើបមកសួរបន្ថែមព្រោះមិនឮកូនចៅតប ហើយក៏ឃើញពួកនោះញញឹមបែបចំអកឲ្យទើបធ្វើមុខមាំ។

«គ្មានអីទេចៅហ្វាយ មានកន្លែងមួយធានាថាត្រូវចិត្តតែម្ដង» ជីមមនុស្សជំនិតរបស់គេម្នាក់ទៀតតបបន្ថែម ទាំងញញឹមចុងមាត់មុននឹងនាំគ្នាដើរចេញទៅ។

ស៊ូហ៊ី ចេញពីធ្វើការដើរតាមផ្លូវទាំងអារម្មណ៍មិនជាប់ខ្លួនគិតដល់កន្លែងដែល សេមី ប្រាប់មុននេះជាក្លឹបរាត្រីកន្លែងនោះសម្រាប់តែកំលោះ

អ្នកមានតែប៉ុណ្ណោះដែលមកលេងទីនោះ៖ នាងគិតទាំងខ្វល់ខ្វាយពេល គិតថាខ្លួនឯងត្រូវក្លាយជាបុគ្គលិកព្រោះត្រូវការប្រាក់ តែយ៉ាងណាក៏នាងត្រូវធ្វើបែបនេះដែរព្រោះជាការតម្រូវកិច្ច គិតហើយព្យាយាមពង្រឹងខ្លួនឯងឲ្យមានភាពក្លាហានមុននឹងដើរសំដៅផ្ទះ។

«ស៊ុហ៊ី រៀបចំខ្លួនទៅណាហ្នឹង?» ហេជីន ទើបចេញពីផ្ទះបាយ ឃើញមិត្តស្លៀកពាក់ស្អាតប្លែក ដូចជាចេញទៅក្រៅពេលយប់បែបនេះទៀតអត់មិនបាននឹងសួរ។

«ត៏ មានពិធីជប់លៀងមិត្តភក្តិកន្លែងធ្វើការ» នាងតបមិនពេញសំឡេងមិនហ៊ានសម្លឹងមុខអ្នកម្ខាងទៀតចំនោះទេ។

«ហ៊ឺម! ប្រយ័ត្នប្រយែងផងណា»

«ខ្ញុំដឹងហើយ ផ្ញើរទើលផ្ទះម៉ាក់ផង» នាងប្រាប់ហើយក៏ងាកទៅបន្ទប់ជិតនោះបន្តិចទើបដើរចេញទៅ។







...៣...

ឌីប្លូមុន ជាក្លឹបរាត្រីដែលល្បីមួយក្នុងទីក្រុងសេអ៊ូល ក្លឹបនេះសម្រាប់អ្នកដែលមានមុខមានមាត់ក្នុងសង្គមតែប៉ុណ្ណោះ ជាពិសេសអ្នកធុរៈកិច្ចកំលោះចូលចិត្តមកទីនេះជាងគេ ព្រោះមាននារីស្អាតៗប្រចាំទីនេះ

ស៊ូហ៊ី ជិះតាក់ស៊ីមកឈប់ខាងមុខក្លឹបនាងចុះពីរថយន្តសម្លឹងមើលទៅក្នុងដោយបេះដូងដុកដាក់ មិនគិតថាខ្លួនឯងធ្លាក់ខ្លួនដល់ថ្នាក់នេះនោះទេ នាងធ្លាប់សន្យាចំពោះខ្លួនឯង ថាទោះជាជួបរឿងអ្វីក៏ដោយក៏មិនយកខ្លួនប្តូរជាមួយប្រាក់នោះដែរ តែពេលនេះនាងត្រូវឆ្លងកាត់គំនូសនោះព្រោះតែអ្នកមានគុណ នាងព្យាយាមពង្រឹងភាពក្លាហានដើរចូលទៅក្នុង។

ស៊ូហ៊ី ចូលមកដល់ក្នុងឃើញនារីស៊ិចស៊ីជាច្រើនកំពុងកៀកកើយកំលោះៗនាងលេបទឹកមាត់ទាំងស្អិតករ ព្រោះរូបភាពទាំងនោះគួរឲ្យខ្មាសអៀនខ្លាំងណាស់សម្រាប់នាងដែលមិនធ្លាប់ សម្លឹងមើលខ្លួនឯងបន្តិចថ្ងៃនេះនាងស្លៀកពាក់រ៉ូបខ្លីចោមពងថែមទាំង ម៉េកអាប់ក្រាស់ថែមទៀតព្រោះខ្លាចមានអ្នកស្គាល់ នាងដើរសំដៅតុដែលគ្មានមនុស្សហៅអីញ៉ាំអង្គុយទីនោះមួយសន្ទុះក៏មានបុរសប៉ុន្មាននាក់មកសុំអង្គុយ នាងរាងទាក់ទើរបន្តិចតែពេលគិតពីគោលបំណងរបស់ខ្លួនថាមកទីនេះព្រោះអ្វី ទើបយល់ព្រមស្របពេលក្រឡេកឃើញអ្នកទើបដើរចូលមក ធ្វើឲ្យនាងបើកភ្នែកធំៗសម្លឹងមើលដោយភាពភ្ញាក់ផ្អើល ពេលឃើញថាជាអ្នកណា អែលរិន ដើរចូលមករួមទាំងមនុស្សជំនិតរបស់គេពីរនាក់ទៀត។

ស៊ូហ៊ី ប្រញាប់ចុះដើរទៅបន្ទប់ទឹកយ៉ាងលឿនព្រោះខ្លាចគេមើលនាងស្គាល់ទោះបីជានាងតែងខ្លួនប្លែកក៏ដោយ សំងំក្នុងបន្ទប់ទឹកមួយ





សន្ទុះទើបចេញមកវិញបេះដូងនាងលោតចង់ចេញមកក្រៅទៅហើយ មកដល់ខាងក្រៅក្រឡេករកមើលមិនឃើញគេ ទើបប្រញាប់ដើរចេញទៅវិញយ៉ាងលឿនតែមិនប្រយ័ត្នក៏ដើរប៉ះបុរសម្នាក់យ៉ាងខ្លាំង ធ្វើឲ្យនាងរកកល់ចង់ដួលទើបប្រវ៉ៃប្រវាតោងអ្នកម្ខាងទៀត ស្របពេលគេស្រវ៉ាឱបចង្កេះទាញនាងអឹបដើមទ្រូងគេជាប់ដូចគ្នា។

«អរ អរគុណ» នាងតបអ្នកម្ខាងទៀតរដាក់រដុបថែមទាំងបេះដៃគេចេញតែគេមិនព្រមលែងនោះទេ ទើបត្រូវងើបមុខទៅមើលហើយក៏និយាយលែងចេញពេលឃើញកែវភ្នែករបស់គេ នាងចាប់ផ្តើមដកដង្ហើមញាប់ថែមទាំងព្យាយបេះដៃគេចេញភ័យខ្លាចគិតថាគេមើលនាងស្គាល់។

«សួស្តីខ្ញុំឈ្មោះ អែលរិន» កំលោះណែនាំខ្លួនសំឡេងស្រាលរសាយដៃពីចង្កេះស្តើងទាំងសោកស្តាយ ថែមទាំងសម្លឹងមើលមុខនាងដោយខ្សែភ្នែកដែលធ្វើឲ្យនាងចង់រត់គេចច្រើនជាង គេឱបនាងជាប់មុននេះព្រោះមានអារម្មណ៍ប្រហែលៗក្លិនដែលជាប់លើរាងកាយស្តើងនេះ។

ស៊ូហ៊ី សម្លឹងមើលមុខគេបន្តិច ប្រហែលគេមិនស្គាល់នាងនោះទេ ទើបនិយាយបែបនេះ មែនហើយនាងតែងខ្លួនបែបនេះសូម្បីតែនាងក៏មើលខ្លួនឯងមិនចង់ស្គាល់ផង នាងគិតក្នុងចិត្តទាំងសើចតិចៗ ព្រោះគិតតែខ្លួនឯងហើយក៏ភ័យតែខ្លួនឯង។

«ចាសសួស្តី អរគុណម្តងទៀត» នាងតបគេសំឡេងស្រាលឱន គោរពជាការគួរសម ហើយក៏បែខ្លួនបំរុងដើរចេញតែក៏ត្រូវគេចាប់ដៃជាប់ ទាញនាងមកប្រឈម។

«ចង់ទៅទាំងបែបនេះមែនទេ ពួកយើងមិនទាន់និយាយគ្នានោះ



Scanned by CamScanner

គេប្រាប់សំឡេងស្រទន់ គួរតែស្គាល់គ្នាឲ្យច្រើនជាងនេះបន្តិចល្អទេ» ហើយឆ្លៀតងាកទៅបង្ហាញស្នាមញញឹមស្រស់ ទាក់ទាញមន្តស្នេហ៍ ដែលត្រូវមកជួបមនុស្សរបស់គេ ស៊ូហ៊ី ធ្វើមុខលេបមិនចូលខ្ជាក់មិនចេញ គេនៅកន្លែងបែបនេះ នាងធ្លាប់និយាយថា មិនលក់ខ្លួនព្រោះតែលុយនៅចំពោះមុខគេហើយពេលនេះ...។

អែលវិន សម្លឹងមើលនារីក្បែរខ្លួនគេមានអារម្មណ៍ប្លែកៗ ពេលដែលបានជួបនាង ថែមទាំងក្លិនក្រអូបលើខ្លួននាងថែមទៀត គ្រាន់តែឃើញនាងស្លៀកពាក់ស៊ិចស៊ីបែបនេះ ក៏ធ្វើឲ្យអារម្មណ៍គេពុះកញ្ជ្រោល ទៅហើយ មិនបានទេគេមិនបណ្ដោយឲ្យនាងទៅងាយៗនោះទេ គិតហើយក៏លូកដៃស្រវ៉ាឱបចង្កេះ នាងក្រមុំភ្ញាក់ព្រើតងាកទៅមើលគេហើយក៏លេបទឹកមាត់ទាំងពិបាក ពេលប៉ះក្រសែភ្នែកស្រេកឃ្លានមួយគូរនោះ ថាមកទីនេះដើម្បីអី ពេលនេះគោលមែនហើយឯងភ្លេចហើយមែនទេ បំណងរបស់ឯងជិតបានសម្រេចហើយ ហេតុអីក៏ចង់បោះបង់ទៅវិញនាងប្រាប់ខ្លួនឯងក្នុងចិត្ត បង្រ្ហួមភាពក្លាហានសម្លឹងមើលអ្នកម្ខាងទៀតបបូរមាត់ ស្តើងញោចស្នាមញញឹមលូកដៃទៅឱបតបរាងកាយក្រាស់ អែលវិនញញឹមចុងមាត់បង្ហាញជ័យជំនះ ។ រូបរាងរបស់គេគ្មានស្រីណាដែលហ៊ានបដិសេធនោះទេមានតែពួកនាងនាំគ្នារត់តាមមកចោមរោម ហើយក៏មានតែស្រីម្នាក់តែប៉ុណ្ណោះដែលមើលមិនឃើញគេក្នុងខ្សែភ្នែកនោះ គិតឃើញដល់នាងធ្វើឲ្យគេចាប់ផ្ដើមម៉ួម៉ៅ។

«ទៅខុនដូរបស់ខ្ញុំទៅល្អទេ?» កំលោះប្រាប់ឱនមកខ្សឹបសំឡេងស្រទន់សម្លឹងអ្នកម្ខាងទៀត គ្រាន់តែឮទៅខុនដូរបស់គេធ្វើឲ្យបេះដូងនាងចាប់ផ្ដើមលោតញាប់ទៅហើយតែព្យាយាមសម្រួលអារម្មណ៍។

«ខ្ញុំត្រូវការប្រាក់មួយចំនួន» ស៊ូហ៊ី ឱនទៅខ្សឹមប្រាប់សំឡេងស្រាលសម្លឹងមើលអ្នកម្ខាងទៀត កំលោះញញឹមចុងមាត់មិនបាច់ប្រាប់ក៏គេដឹងដែរមនុស្សស្រីត្រូវការតែរបស់នេះតែប៉ុណ្ណោះ មិនដូច្នេះពួកនាងមិនមកកាន់កន្លែងបែបនេះនោះទេគេចំអកក្នុងចិត្ត។

«កុំបារម្ភរឿងនេះ ខ្ញុំធានាសំខាន់នាងធ្វើឲ្យខ្ញុំពេញចិត្តបានកម្រិតណា» គេប្រាប់សំឡេងស្មើរហើយកៀកចង្កេះនាងដើរចេញទៅ។

រថយន្តទំនើបបានមកឈប់នៅមុខខុនដូទំនើបមួយ នៅចំកណ្ដាលក្រុង នាងក្រមុំចាប់ផ្ដើមភ័យកាន់តែខ្លាំង តែក៏ព្យាយាមសម្រួលអរម្មណ៍តាមដែលអាចធ្វើបាន ដើម្បីអ្នកម្ដាយនាងធ្វើបែបនេះត្រឹមត្រូវហើយនាងប្រាប់ខ្លួនឯងក្នុងចិត្ត ជណ្ដើរយន្តបានមកឈប់នៅជាន់លើបំផុតជាជាន់របស់គេ។

«ត្រូវការងូតទឹកដែរទេ?» កំលោះប្រាប់សំឡេងស្រាលពេលនាំនាងមកដល់បន្ទប់ គេដោះអាវក្រៅរួមទាំងអាវសឺមីបង្ហាញរាងកាយរឹងមាំពេញដោយសាច់ដុំ ធ្វើឲ្យនាងក្រមុំចាប់ផ្ដើមដកដង្ហើមញាប់ងាកមុខចេញទាំងអៀនខ្មាស ព្រោះមិនធ្លាប់ឃើញរាងកាយបុរសណានោះទេ ក្រៅពីប្អូនប្រុសរបស់នាង កំលោះជ្រួញចិញ្ចើមមិនសូវពេញចិត្តពេលឃើញឫកពាររបស់នាង គិតថារូបរាងគេអន់ជាងប្រុសផ្សេង ដែលនាងធ្លាប់ឡើងគ្រែជាមួយឬយ៉ាងម៉េចបានងាកមុខចេញដូចជាស្អប់ខ្ពើម គេគិតទាំងម៉ួម៉ៅតិចៗហើយក៏ដើរទៅបន្ទប់ទឹកជំរះខ្លួន។

ស៊ូហ៊ុ នៅឈរកណ្ដាលសម្លឹងជុំវិញបន្ទប់នាងសម្រេចចិត្តមកដល់ទីនេះហើយ ប្រហែលជាមិនអាចបកក្រោយនោះទេ ប្រហែលនេះជាវាសនារបស់នាង ហើយដែលត្រូវជួបរឿងបែបនេះ កំពុងតែគិតស្លុងអារម្មណ៍ដោយមិនដឹង អ្នកម្ខាងទៀតចេញពីបន្ទប់ទឹកតាំងពីពេលណានោះទេ គេស្លៀកតែកន្សែងពោះគោដើរចេញមកសម្លឹងមកនាងដោយក្រសែភ្នែកស្រេកឃ្លានរួមទាំងងឿងឆ្ងល់។

«ចង់ឈរទីនេះយូរទៀតទេ?» គេសួរសំឡេងស្មើរសន្សឹមៗដើរមកជិតធ្វើឲ្យអ្នកម្ខាងទៀត ធ្វើខ្លួនមិនត្រូវចង់គេចតែមិនដឹងគេចទៅណាមានតែឈរស្ងៀមសម្លឹងមើលមុខគេទាំងបេះដូងដុកដាក់ កំលោះសម្លឹងនារីចំពោះមុខឃើញឫកពាររបស់នាងធ្វើឲ្យគេមានអារម្មណ៍ប្លែក បើគេមិនជួបនាងនៅក្នុងក្លឹបនោះគេអាចគិតថាមិនធ្លាប់មានបទពិសោធន៍ តែនេះវាមិនអាចនោះទេនាងធ្វើបែបនេះក្នុងគោលបំណងអី អំ ឬមួយមកពីគេមិនទាន់និយាយថ្លៃជាមួយនាងពិតជាស្រីមុខលុយមែន គេគិតចំអកក្នុងចិត្តដកភ្នែកពីផ្ទៃមុខស្រស់មកសម្លឹងគល់ទ្រូងសខ្ចីដែលហៀរចេញមក។

«នាងត្រូវការប៉ុន្មាន?» គេសួរសំឡេងស្មើធ្វើឲ្យអ្នកដែលឈរទ្រឹងងើបមុខមកមើលរាងទាក់ទើបន្តិចមុននឹងតប។

«១០លានវ៉ុន» កំលោះញញឹមចុងមាត់ ទារថ្លៃខ្ពស់គ្រាន់បើតែមិនអីទេបើនាងធ្វើឲ្យគេពេញចិត្តគេអាចនឹងឲ្យលើសនេះទៀត។

«អូខេ ខ្ញុំនឹងសសេរសែកឲ្យ បែបនេះគួរតែដលពេលត្រូវបំពេញតួនាទីរបស់នាងហើយ» គេប្រាប់ទាំងញញឹមចុងមាត់ដើរទៅអង្គុយលើគ្រែសម្លឹងមកនាងពីលើដល់ក្រោម ដោយភាពញាប់ញ័រ តែព្យាយាមទប់



អារម្មណ៍របស់ខ្លួន មិនយល់ពេលជួបនាងបែរជាធ្វើឲ្យគេមានអារម្មណ៍ចង់គ្រប់គ្រងនាងកាន់តែខ្លាំងបែនេះទៅវិញ។

«ដោះខោអាវ» គេប្រាប់សំឡេងស្មើរធ្វើឲ្យអ្នកដែលឈរឈ្ងោកងើបមុខមកមើលភ្លឹះៗទឹកមុខមិនអីរបស់នាងធ្វើឲ្យគេចាប់ផ្ដើមធុញទ្រាន់។

«នៅឲ្យខ្ញុំប្រាប់ច្រើនជាងនេះទេ បើបែបនេះនាងត្រឡប់ទៅវិញទៅខ្ញុំអាចហៅអ្នកផ្សេងបាន» គេប្រាប់ទាំងក្រោកពីគ្រែសំដៅទូរស័ព្ទលើតុទើបអ្នកដែលឈរប្រញាប់ដើរទៅចាប់ដៃគេយ៉ាងលឿន។

«ខ្ញុំ ខ្ញុំដឹងហើយ» នាងប្រាប់រដាក់រដុបបិទភ្នែករម្ងាប់អារម្មណ៍ខ្លាចចាត់ការទាញរូតរូបរបស់ខ្លួន ដោយសារវានៅក្រោយទើបពិបាកទាញហើយក៏ងាកមកអ្នកដែលឈរជិតសុំជំនួយ កំលោះធ្វើភ្នែកឡេងឡាមស្រីម្នាក់នេះពិតជាចំមែនគិតហើយក៏លូកដៃទៅជួយទាញ ផែនខ្នងសរលោងចាំងភ្នែកគ្មានស្នាមសូម្បីបន្តិចបង្ហាញហ្នឹងមុខ គេសម្លឹងមើលឡើងភ្លឹកហើយក៏កាន់តែភ្ញាក់ផ្អើលថែមទៀត ។ ពេលរាងកាយគ្មានអ្វីបិទបាំងទាំងមូលបង្ហាញនៅចំពោះមុខ នាងក្រមុំបែរមកតែងាកមុខចេញដោយភាពខ្មាសអៀន ដើមទ្រូងណែនក្បំបង្ហាញនៅហ្នឹងមុខរាងកាយនាងពិតជាស៊ិចស៊ីហើយទាក់ទាញមែន គេលេបទឹកមាត់ទាំងពិបាក គ្រាន់តែឃើញរាងកាយទទេស្អាតរបស់នាង ក៏ធ្វើឲ្យគេអារម្មណ៍ពុះកញ្ជ្រោលបាត់ទៅហើយមិនចាំយូរក៏លើកបីនាងទៅដាក់លើគ្រែ ឱនទៅគ្រប់គ្រងបបូរមាត់ស្ដើងជាប់ថើបដោយភាពស្រេកឃ្លាន ការតបស្នងបែបមិនដឹងអីរបស់នាងធ្វើឲ្យគេពេញចិត្តតែក៏ធ្វើឲ្យគេឆ្ងល់ដូចគ្នា ព្រោះដូចជាមនុស្សដែលមិនធ្លាប់ឆ្លងកាត់រឿងបែបនេះ លាក់ចម្ងល់ទុកក្នុងចិត្តពេលនេះរាង

កាយគេពិតជាកក់ក្ដៅខ្លាំងណាស់ ហើយក៏ត្រូវការនាងខ្លាំងណាស់ដែរ គេអូសបបូរមាត់មកថើបឈ្មុសគល់កសខ្ចី ធ្វើឲ្យនាងថ្ងូរតិចៗដោយភាពស្រៀវស្រើបជាអារម្មណ៍ ដែលមិនធ្លាប់ជួបទាល់តែសោះតែក៏សហការតបស្នងគ្រប់យ៉ាងទើបលើកដៃស្រវ៉ាឱបករគេជាប់។

«រាងកាយនាងក្រអូបខ្លាំងណាស់» គេងើបមុខមកប្រាប់សំឡេងស្អក អ្នកស្ដាប់បានត្រឹមញញឹមទាំងអៀនខ្មាសទាញរាងកាយក្រាស់មកអឹបខ្លួនម្ដងទៀត ធ្វើឲ្យគេញញឹមពេញចិត្ត ទើបឱនទៅរកដើមទ្រូងតឹងណែនច្របាច់ថើបជញ្ជក់ដោយភាពពេញចិត្ត គិតថារាងកាយនាងធ្លាប់ឆ្លងកាត់ប្រុសជាច្រើន ធ្វើឲ្យគេមានអារម្មណ៍អន់ចិត្តសោកស្ដាយ ដែលមិនបានធ្វើជាម្ចាស់រាងកាយនេះដំបូងគេ បបូរមាត់នៅតែថៃថើបលើរាងកាយស្ដើងដេញមកដល់ពោះរាបស្មើ ហើយក៏អូសចុះតែទាបទៅ នាងក្រមុំដែលកំពុងតែស្លុងអារម្មណ៍នឹងភាពស្រៀវស្រើបដែលគេផ្ដល់ឲ្យ ទើបមិនដឹងថាគេចង់ធ្វើអីមកដឹងខ្លួនម្ដងទៀត ពេលគេលើកជើងនាងបញ្ឈរ។

«អ្ហា...» នាងខ្ទាំស្មារគេថ្ងូរដោយភាពស្រើបស្រាល ពេលអណ្ដាតឧនៗលិឍត្រលាស់ចំនុចស្រៀវស្រើបបំផុតរបស់នាង គេចាប់ដៃនាងទាំងពីរដាក់លើពូកបបូរមាត់នៅតែធ្វើតួនាទីលិឍជញ្ជក់គ្មានប្រណី រហូតនាងស្រែករមួលខ្លួនអង្វរក៏គេមិនព្រមឈប់។

«បាន...បានហើយ» នាងប្រាប់សំឡេងញ័ររប្រឹងរំកិលខ្លួនចេញតែក៏ត្រូវគេចាប់ត្រគាកជាប់។

«មិនទាន់បានទេ» គេងើបមកប្រាប់នាងហើយក៏ឱនទៅរកចំនុចនោះម្ដងទៀត ចង់ធ្វើឲ្យនាងស្លាប់ឬយ៉ាងម៉េចហ្នឹងនេះជាអារម្មណ៍អីគ្រាន់





តែប៉ុណ្ណឹងវេទនាស្ទើរដាច់ខ្យល់ទៅហើយ នាងរអ៊ូក្នុងចិត្ត តែមិនអាចបញ្ឈប់គេបានរហូតមានទឹកសើមៗជ្រាបចេញមក គេក្រេបទាល់តែអស់ទើបដកបបូរមាត់ចេញ ងើបមុខមកមើលអ្នកដែលគេងបិទភ្នែក ដោយភាពអស់កំលាំង គេញញឹមចុងមាត់បន្តិច មុននឹងឱនទៅរកបបូរមាត់ស្ដើងម្ដងទៀតនាងក្រមុំបើកភ្នែកដោយភាពខ្សោះល្វើយ តែក៏ថើបតបស្នងធ្វើឲ្យគេពេញចិត្តទើបសន្សឹមៗទាញជើងនាងញែកចេញពីគ្នា ទាញដំបងសាច់តម្រង់មាត់ល្អាងព្រោះគិតថានាងត្រៀមខ្លួនសម្រាប់គេរួចហើយ។

«អ្ហា...ឈឺ...» សំឡេងស្រែកពេញដោយភាពឈឺចាប់ថែមទាំងម្រាមដៃដែលខ្ទាំស្មាគេ រហូតមានឈាមតិចៗ ធ្វើឲ្យកំលោះងើបមុខសម្លឹងទៅក្រោម មានអារម្មណ៍ត្រជាក់ខ្លួនស្រេងពេលឃើញឈាមក្រហមប្រលាក់ដំបងសាច់ដែលទើបស៊កចូលបានបន្តិចនោះ គេនៅស្ងៀមទ្រឹងស្ទើរមិនគួរឲ្យជឿនិងអ្វីដែលកើតឡើងពេលនេះ ឃើញទឹកមុខឈឺចាប់របស់នាង គេគួរតែធ្វើអីម្យ៉ាងហើយគិតរួចក៏ឱនទៅថើបបបូរមាត់ដេញមកដល់ដើមទ្រូងតឹងណែន នាងក្រមុំលើកដៃឱបករគេជាប់ភាពឈឺចាប់ដូចជាហែកសាច់ទាំងដុំមុននេះ ត្រូវជំនួសមកវិញដោយភាពស្រៀវស្រើប ឃើញភាពឈឺចាប់របស់នាងថមថយ ទើបគេចាប់ផ្ដើមធ្វើចលនាត្រគាកមួយៗហើយក៏កាន់តែញាប់ទៅៗ រហូតសំឡេងស្រែកថ្ងូរនៃសេចក្ដីសុខបន្លឺឡើងព្រមគ្នា គេសម្លឹងមើលនារីក្រោមទ្រូងនាងបិទភ្នែកដោយភាពអស់កំលាំង ទើបឱនទៅថើបថ្ងាស់ ដែលជោកដោយញើសនោះថ្នមៗមុននឹងប្រះខ្លួនមកគេងក្បែរទាញនាងមកឱបជាប់។

អេលវិន សម្លឹងមើលនារីដែលគេងក្បែរដោយក្ដីពេញចិត្ត រាងកាយ



Scanned by CamScanner

ទទេស្អាតរបស់នាងពិតជាធ្វើឲ្យគេពុះកញ្ជ្រោលមែន ហើយអ្វីដែលធ្វើឲ្យគេសប្បាយចិត្តថែមទៀតនោះ គឺបានធ្វើជាម្ចាស់រាងកាយនេះដំបូងគេមិនគួរឲ្យជឿទេ មនុស្សស្រីដែលទៅទីនោះដូចជានាងអាចរក្សាភាពបរិសុទ្ធបានចម្លល់ជាច្រើនចាក់ស្រេះ គិតហើយក៏ទាញនាងមកគេកើយទ្រូងក្លិនក្រអូបរបស់នាងធ្វើឲ្យគេចាប់ផ្ដើមឆ្ងល់ម្ដងទៀតហើយ តែក៏ខ្ជិលគិតព្រោះគេមានអារម្មណ៍ថាអស់កំលាំងខ្លាំងណាស់ព្រោះតែនាងហ្នឹងហើយ។

រាងកាយក្រាស់ដែលគេងលើគ្រែបើកភ្នែក ដោយភាពងោកងុយសម្លឹងរកមើលនារីក្បែរខ្លួន តែបែរជាជួបភាពទទេស្អាតទើបក្រោកអង្គុយសម្លឹងជុំវិញគិតថានាងនៅបន្ទប់ទឹកតែគ្មាននោះទេ ធ្វើឲ្យគេចាប់ផ្ដើមម៉ូម៉ៅ ហើយក៏ក្រឡេកឃើញសែកនៅលើតុមួយសន្លឹក កំលោះជ្រួញចិញ្ចើមគេសសេរពីរសន្លឹកទុកឲ្យនាងមួយសន្លឹក ១០លានវ៉ុន តែនាងយកទៅតែមួយសន្លឹកនោះទេ។

«ឲ្យហើយមិនយកទៀត» គេរអ៊ូរទាំហើយក៏ក្រោកទៅបន្ទប់ទឹក។

ស៊ូហ៊ី មកដល់ផ្ទះនាពេលជិតភ្លឺ នាងអង្គុយមុខផ្ទះសម្លឹងមើលក្រដាសសែកទាំងទឹកភ្នែក ពេលនឹកឃើញដល់រឿងកើតឡើងក្នុងបន្ទប់ខុនដូរនោះនាងពិតជាគ្មានកេរ្តិ៍ខ្មាសខ្លាំងណាស់ ដែលត្រូវប្ដូរខ្លួនព្រោះតែក្រដាសមួយសន្លឹកនេះ តែវាជាបំណងនាងមិនមែនបើគ្មានវាចុះម្ដាយនាងគិតយ៉ាងម៉េច មែនហើយដើម្បីគ្រួសារទោះនាងធ្វើអីក៏បានដែរ ព្យាយាមលួងខ្លួនឯងក្នុងចិត្តស្របពេលសម្រឹបជើងអ្នកណាម្នាក់ដើរមក។

«ស៊ូហ៊ី ហេតុអីមកអង្គុយត្រង់នេះ?» សំឡេង ហេជីន បន្លឺឡើងទើបនាងងាកទៅមើលទាំងញញឹមតិចៗ។





«គ្មានអីទេ» នាងតបសំឡេងស្រាលហើយក៏ដើរចូលក្នុង ហេជីន ឃើញឫកពាមិត្តដូចជាប្លែកៗ ថែមទាំងការតុបតែងខ្លួនបែបនេះទៀតធ្វើឲ្យនាងកាន់តែឆ្ងល់លើសដើម។

«មិនស្រួលខ្លួនមែនទេ ហើយយប់មិញគេងនៅឯណា?» សំឡេង ហេជីន នៅតបន្លឺឡើងទើបធ្វើឲ្យអ្នកដែលដើរនោះឈប់ឆ្ងក់។

«គឺគេងផ្ទះមិត្តភ័ក្តិ សូមទោសណាដែលមិនបានប្រាប់ឯង» នាងតបទាំងទាញដៃមិត្តមកកាន់កុំឲ្យអ្នកម្ខាងទៀតសង្ស័យ។

«មិនអីទេ ឆាប់ចូលទៅក្នុងរៀបចំខ្លួនទៅខ្ញុំរៀបចំអាហារពេលព្រឹករួចរាល់ហើយ» ហេជីន ប្រាប់ហើយក៏ដឹកដៃគ្នាចូលក្នុង។

«ពីរថ្ងៃទៀតដល់ថ្ងៃវះកាត់អ៊ុំស្រីហើយ ឯងមាន...» ហេជីន ប្រាប់សំឡេងស្រាល ហើយក៏ចង់សួរពីរឿងប្រាក់សម្រាប់ចេញថ្លៃវះកាត់នោះធ្វើឲ្យ ស៊ូហ៊ី ងើបមុខមកមើល។

«ខ្ញុំដឹងហើយ ឯងកុំបារម្ភអីមើលថែសុខភាពខ្លួនឯងទៅ» ស៊ូហ៊ី ប្រាប់មិត្តទាំងញញឹមតិចៗ។

«ឯងរកប្រាក់បានហើយមែនទេ?» ហេជីន សួរបន្តព្រោះមើលទៅមិត្តនាងដូចជាមិនសូវបារម្ភដូចមុន។

«អ៊ឹម មានហើយ»

«មែនហ៎ ឯងបានមកពីណា?» ហេជីន មិនអស់ចិត្តសួរបន្តធ្វើឲ្យអ្នកម្ខាងទៀតរាងទ្រឹងបន្តិច។

«គឺខ្ចីអ្នកនៅកន្លែងធ្វើការ»

«ហ៊ឹម បែបនេះល្អហើយខ្ញុំកំពុងតែបារម្ភផង»

ហេជីន និយាយហើយក៏ញ៉ាំបន្ត ស៊ូហ៊ី សម្លឹងមើលមិត្តដោយអារម្មណ៍ខុសដែលជ្រើសរើសកុហកមានតែធ្វើបែបនេះសិនហើយ ចាំពេលមានឱកាសចាំនិយាយការពិតនាងគិតក្នុងចិត្តទាំងខ្វល់ខ្វាយ។

អែលវិន មកដល់សណ្ឋាគារទាំងអារម្មណ៍មិនសូវស្រស់ ព្រោះគិតដល់តែនារីកាលពីយប់ គួរឲ្យស្ដាយដែលមិនបានស៊ើបពត៌មានស្រីម្នាក់នោះឲ្យច្បាស់ ហើយពេលចង់រកនាងម្ដងទៀតគេមិនដឹងថាត្រូវធ្វើយ៉ាងម៉េចនោះទេ សូម្បីតែឈ្មោះនាងក៏គេមិនស្គាល់ផង គេគិតទាំងច្របូកច្របល់ស្របពេលសំឡេងគោះទ្វារបន្ទប់បន្លឺឡើង។

«ចៅហ្វាយ ស៊ើបហើយតែគ្មានពត៌មានស្រីម្នាក់នោះទេ» ជេក មនុស្សជំនិតរបស់គេចូលមករាយការបន្ទាប់ពី គេបញ្ជាឲ្យទៅស៊ើបពត៌មាននៅក្លឹប កំលោះធ្វើទឹកមុខគាំងបន្ទាប់ពីឮ។

«ស៊ើបបន្តទៀតរហូតបានដំណឹងពីនាង» គេប្រាប់សំឡេងស្មើរធ្វើឲ្យកូនចៅគេទាំងពីរងាកមើលមុខគ្នា។

«បាទចៅហ្វាយ» ជេក តបទទួលហើយក៏ដើរចេញទៅវិញរួមទាំង ជីម ដៃគូរគេម្នាក់ទៀតផងដែរ។

«ប្រហែលជាជាប់ចិត្តខ្លាំងហើយបានជាតាមរកបែបនេះ» សំឡេង ជេក បន្លឺឡើងទាំងញញឹមមើលដៃគូរបន្ទាប់ពីចេញពីបន្ទប់ចៅហ្វាយគេ។

«ប្រហែលហើយ ហាសហាស» សំឡេង ជីម ម្នាក់ទៀតបន្លឺឡើងហើយក៏សើចមុននឹងនាំគ្នាទៅកាន់កន្លែងការងាររៀងខ្លួន។

ស៊ូហ៊ី ត្រូវមកធ្វើការបន្តទាំងទឹកមុខស្លេកស្លាំង ព្រោះនាងស្ទើរមិន





បានគេងពេញមួយយប់ទៅហើយព្រោះតែទ្រាំទ្រអារម្មណ៍របស់គេ។

«ស៊ូហ៊ី មិនអីទេមែនទេហេតុអីក៏មុខស្លេកស្លាំងម្លេះ?» សំឡេង សេមី មិត្តនៅផ្នែកជាមួយនាងបន្លឺឡើងថែមទាំងយកដៃស្ទាបថ្ងាស់វាស់កំដៅព្រោះគិតថានាងក្ដៅខ្លួន។

«គ្នាមិនអីទេ» នាងតបសំឡេងស្រាលទាញដៃមិត្តចេញពីថ្ងាស់ញញឹមតិចៗហើយក៏ធ្វើការងាររបស់ខ្លួនបន្ត មានអារម្មណ៍ថាមានអ្នកណាម្នាក់កំពុងសម្លឹងមើលមកខ្លួនទើបងាកទៅមើល ហើយក៏ចាប់ផ្ដើមភ័យពេលឃើញអគ្គនាយកសម្លឹងមក ទើបប្រញាប់ទំលាក់មុខចុះយ៉ាងលឿនខ្លាចគេចំណាំនាងបានច្បាស់ជាស៊យធំមិនខាន។

អែលវិន កំពុងតែម៉ូម៉ៅព្រោះតែរកនារីកាលពីយប់នោះមិនឃើញ ទើបដើរចេញមកក្រៅស្របពេលក្រឡេកឃើញ ស៊ូហ៊ី ដែលកំពុងឈរភ្លឹកនោះទើបអត់មិនបាននឹងងាកទៅមើល ព្រោះនារីកាលពីយប់មានចំនុចជាច្រើនដែលដូចនាងតែគេនៅតែបែងចែកមិនដាច់ គិតថាប្រហែលមិនមែនជានាងទៅចុះ សម្លឹងមើលនាងបន្តិចហើយក៏ដើរចេញទៅ។

ថ្ងៃនេះ ស៊ូហ៊ី ដាក់ច្បាប់សម្រាកព្រោះជាថ្ងៃវះកាត់ម្ដាយនាង ពួកនាងអង្គុយមុខបន្ទប់វះកាត់ទាំងភ័យព្រួយ ព្រោះជាច្រើនម៉ោងទៅហើយគ្រូពេទ្យនៅមិនទាន់ចេញមកនោះទេ។

«ស៊ូហ៊ី កុំបារម្ភអីគាត់ច្បាស់ជាអាចឆ្លងផុត» ហេជីន និយាយលើកទឹកចិត្តទាញដៃមិត្តមកកាន់ផ្ដល់កំលាំងចិត្តទើបនាងញញឹមតប។

«បងស្រីម៉ាក់យ៉ាងម៉េចហើយ?» សំឡេង ដូយ៉ុង ប្អូនប្រុសនាងទើបមកដល់សួរទាំងព្រួយបារម្ភ។



Scanned by CamScanner

«គ្រូពេទ្យមិនទាន់ចេញមកនោះទេ» ស៊ូហ៊ី តបប្អូនសំឡេងស្រាល ងាកទៅមើលបន្ទប់នោះម្តងទៀត។

ការវះកាត់របស់អ្នកស្រី ហៃយ៉ុង រួចរាល់តែនៅមានបញ្ហាមួយចំនួនទៀត ស៊ូហ៊ី ដើរចេញពីបន្ទប់ពិគ្រោះរបស់ដុកទ័រទាំងទឹកភ្នែក បន្ទាប់ពីក្រុមគ្រូពេទ្យប្រាប់ថា ទោះបីជាម្តាយនាងវះកាត់បានជោគជ័យតែមេរោគបានរីករាលដាលពេញរាងកាយគាត់ទៅហើយ គាត់អាចនឹងរស់បានត្រឹមមួយរយៈទៀតតែប៉ុណ្ណោះ។

ហេជីន ចេញមកស្រោចផ្កានៅសួនមុខផ្ទះគាប់ជួនក្រឡេកឃើញស្ត្រីចំណាស់ម្នាក់ដែលកំពុងឈរវេរានៅខាងមុខទើបដើរទៅមើល។

«អ៊ំស្រីមករកអ្នកណាដែរ?» នាងសួរសំឡេងស្រាលសម្លឹងមើលស្ត្រីចំណាស់មិនដាក់ភ្នែក ព្រោះមើលតាមការស្លៀកពាក់របស់គាត់មិនមែនជាមនុស្សធម្មតានោះទេ ស្ត្រីចំណាស់ងាកមកមើលអ្នកសួរបែបរិភាគគាត់សម្លឹងមើលនាងពីលើដល់ក្រោមរិះគិតមុននឹងញញឹមតិចៗតប។

«នេះជាផ្ទះរបស់ ហេវ៉ន មែនទេ?» សំឡេងស្ត្រីចំណាស់បន្លឺឡើងគាត់រេភ្នែកទៅមើលក្នុងផ្ទះបន្តិច ទើបងាកមកមើលអ្នកចំពោះមុខវិញ។

«ចាស អ៊ំស្រីមានការអីមែនទេ?»

«ខ្ញុំជាមិត្តចាស់របស់គេ តើគេនៅផ្ទះដែរទេ?» គាត់សួរទាំងសម្លឹងទៅក្នុងផ្ទះម្តងទៀតព្រោះដូចជាស្ទាត់យ៉ាងម៉េចមិនដឹងទេ ហេជីន ធ្វើទឹកមុខខ្វល់ខ្វាយបន្តិចពេលឮអ្នកម្ខាងទៀតសុំជួប។

«ចាសគាត់នៅខាងក្នុង» នាងតបទាំងញញឹមតិចៗមុននឹងបើកទ្វារអញ្ជើញភ្ញៀវចំណាស់ចូលក្នុង។



«នាងជាកូនស្រីគេមែនទេ?» ស្ត្រីចំណាស់សួរ ហេជីន ពេលដែលដើរមកដល់ក្នុងព្រោះឃើញឫកពារនាងគួរឲ្យចូលចិត្ត។

«ចាសមិនមែនទេ ខ្ញុំជាមិត្តភក្តិកូនស្រីគាត់» ហេជីន តបទាំងលើកទឹកដាក់ឲ្យភ្ញៀវគាត់មើលរូបរាងនាងដោយក្តីពេញចិត្តហើយក៏គិតទៅដល់កូនប្រុសកំពូលខិលរបស់គាត់។

«អ្នកផ្ទះនេះទៅណាអស់ហើយ?» គាត់សួរនាងតិចៗលើកទឹកមកញ៉ាំសម្លឹងមើលជុំវិញផ្ទះដោយក្តីអាណិត មិនគិតថាមិត្តជិតដិតជំនាន់រៀនធ្លាក់ខ្លួនដល់ថ្នាក់នេះនោះទេ។

«ពួកគេនាំគ្នាទៅធ្វើការអស់ហើយ» នាងតបទាំងញញឹមក្រៀមធ្វើឲ្យស្ត្រីចំណាស់ហាក់យល់អ្វីមួយ។

«ហេវ៉ន នៅឯណាខ្ញុំអាចជួបនាងបានទេ?» គាត់សួរតិចៗទើបនាងនាំគាត់សំដៅបន្ទប់មួយដែលនៅជិតនោះ។

រូបរាងរបស់ស្ត្រីចំណាស់ម្នាក់ ដែលមានទឹកមុខស្លេកស្លាំងកំពុងសម្រាកក្នុងបន្ទប់ដណ្តប់ភួយនៅសល់តែរង្វង់មុខ ធ្វើឲ្យអ្នកដែលទើបចូលទៅមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។

«ស៊ូហ៊ី មកវិញហើយមែនទេ ហេជីន» សំឡេងស្អកៗបន្លឺឡើងបើកភ្នែកប្រឹមៗសម្លឹងមើលទៅអ្នកដែលទើបចូលមក។

«មិនមែនទេ គឺមានអ៊ំស្រីម្នាក់គាត់ប្រាប់ថាជាមិត្តចាស់ចង់ជួបអ៊ំ» ហេជីន ប្រាប់ទាំងដើរទៅអង្គុយជិតជួយគ្រាគាត់ឡើង។

«មិត្តចាស់ អ្នកណាគេ?» សំឡេងស្អកបន្លឺមកទៀតគាត់សម្លឹងមើលអ្នកដែលអង្គុយខាងមុខទាំងជ្រួញចិញ្ចើម។



Scanned by CamScanner

«ហេវ៉ន គឺខ្ញុំ សុងហ៊ីណា» សំឡេងភ្ញៀវចំណាស់បន្លឺឡើងសម្លឹងមើលអ្នកម្ខាងទៀតដោយក្ដីអាណិត ខានជួបគ្នាតែប៉ុន្មានឆ្នាំសោះមិនគិតថាមិត្តចាស់ទ្រុឌទ្រោមដល់ថ្នាក់នេះនោះទេ។

«សុងហ៊ី...» សំឡេង អ្នកស្រី ហេវ៉ន បន្លឺឡើងបែបរកនឹកគាត់ព្យាយាមសម្លឹងមើលអ្នកម្ខាងទៀតឲ្យច្បាស់ តែសភាពភ្នែករបស់គាត់មិនអាចធ្វើបាននោះទេ។

«ឯងភ្លេចខ្ញុំហើយមែនទេ ពួកយើងធ្លាប់រៀនវិទ្យាល័យជាមួយគ្នាណាឯងតែងតែស្ដីឲ្យខ្ញុំមិនឈប់នោះអី» សំឡេង អ្នកស្រី សុងហ៊ី បន្លឺឡើងទាំងទាញដៃអ្នកម្ខាងទៀតមកកាន់។

«ខ្ញុំនឹកឃើញហើយ» សំឡេងស្អកតបទាំងញញឹមគ្រេកអរលោទៅឱបទើបអ្នកម្ខាងទៀតឱបតប។

«ហេតុអីក៏ឯងធ្លាក់ខ្លួនដល់ថ្នាក់នេះ ហេតុអីមិនទៅពេទ្យ» អ្នកស្រី សុងហ៊ី ប្រាប់ទាំងសម្លឹងមើលសភាពរបស់មិត្តដោយក្ដីសង្វេគ។

«អ៊ំស្រីគាត់មានជំងឺទើបវះកាត់ហើយថ្មីៗទេ» ហេជីន ប្រាប់ទាំងសម្លឹងមើលស្ត្រីចំណាស់ ដែលអង្គុយក្បែរខ្លួនដោយក្ដីអាណិតមានតែនាងតែប៉ុណ្ណោះដែលនៅក្បែរគាត់ជាងគេ អ្នកស្ដាប់បើកភ្នែកធំៗបន្ទាប់ពីឮងាកមកមើលមិត្តចាស់ដោយក្ដីអាណិត ស្របពេលសំឡេងនៅខាងក្រៅបន្លឺឡើងហើយទ្វារក៏របើកដោយនារីម្នាក់ ទើបនាំគ្នាងាកទៅមើលព្រោះគ្មានអ្នកណាក្រៅពី ស៊ូហ៊ី នោះទេ។

«ម៉ាក់ធ្វើទុក្ខទៀតហើយមែនទេ?» ស៊ូហ៊ី ឧទានទាំងព្រួយបារម្ភដើរទៅអង្គុយជិតគាត់ ដោយមិនបានចាប់អារម្មណ៍ភ្ញៀវចំណាស់ម្នាក់ទៀត





ដែលអង្គុយជិតនោះទេ។

«ម៉ាក់មិនអីទេ ឯងកុំបារម្ភអី» សំឡេងស្អកបន្លឺឡើងតបកូនស្រី ហើយក៏ងាកទៅមិត្តចាស់របស់គាត់។

«ម៉ាក់តែងតែបែបនេះ មិនឲ្យខ្ញុំបារម្ភរហូតមានរឿងកាន់តែធំ» នាងប្រាប់សំឡេងតូចចិត្តទឹកភ្នែកក៏ចាប់ផ្ដើមហូរចុះមកតិចៗ។

«ម៉ាក់សូមទោស» គាត់ប្រាប់សំឡេងស្អកលូកទៅចាប់ដៃកូនស្រី អ្នកស្រី សុងហ៊ី សម្លឹងមើលពីរនាក់ម្ដាយកូនដោយក្ដីអាណិត តែក៏ពេញចិត្តរូបរាងក្មេងស្រីម្នាក់នេះដែរ នាងមានមុខមាត់និងឫកពារមិនខុសពីម្ដាយនាងនោះទេ។

«ជាកូនស្រីនាងមែនទេ?» សំឡេងអ្នកស្រី សុងហ៊ី បន្លឺឡើងធ្វើឲ្យអ្នកដែលមិនបានចាប់អារម្មណ៍ងាកមកមើលទាំងងឿងឆ្ងល់។

«នាងជាកូនស្រីបង នៅមានកូនប្រុសខ្ញុំម្នាក់ទៀត»

ស៊ូហ៊ី ដឹងថាអ្នកម្ខាងទៀតជាមិត្តចាស់ម៉ាក់នាងក៏ធ្វើការគោរពគួសមហើយក៏នាំគ្នាចេញមកក្រៅបន្ទាប់ពីគាត់សម្រាក។

«អ៊ំស្រីអញ្ជើញមកលេងទីនេះមែនទេ?» ស៊ូហ៊ី សួរស្ត្រីចំណាស់ពេលដែលនាំគាត់មកដល់ខាងក្រៅ។

«ត្រូវហើយ ខ្ញុំឮ ហេជីន ប្រាប់ថាឯងធ្វើការមែនទេ?»

«ចាស ខ្ញុំជាបុគ្គលិកទទួលភ្ញៀវ» នាងតបទាំងញញឹមតិចៗ

«អ៊ំ កូនប្រុសខ្ញុំក៏មានសណ្ឋាគារនៅទីនេះដែរ» គាត់ប្រាប់ទាំងញញឹមសម្លឹងមើលនាងដោយខ្សែភ្នែកស្រទន់ នារីពីរនាក់នេះហាក់ត្រូវចិត្តគាត់ទាំងពីរតែម្ដង គាត់គិតក្នុងចិត្តទាំងរីករាយ ធ្វើឲ្យពួកនាងធ្វើខ្លួន

មិនត្រូវនោះទេពេលឃើញគាត់សម្លឹងមិនដាក់ភ្នែកបែបនេះ។

«ចុះប្អូនប្រុស គេធ្វើការអីដែរ?»

«គេនៅរៀនមិនទាន់ចប់នោះទេ» ស៊ូហ៊ី តបសំឡេងស្រាលសម្លឹងមើលស្ត្រីចំណាស់ចំពោះមុខបែបរិះគិត មើលគាត់ឃ្លូវៗទៅមានអារម្មណ៍ថាដូចនណាម្នាក់តែនឹកមិនឃើញនោះទេ។





...៤...

ថ្ងៃនេះ ស៊ូហ៊ី មកធ្វើការតែម្នាក់ឯងនោះទេព្រោះ សេមី មិត្តនាងគេដាក់ច្បាស់ហើយថ្ងៃនេះក៏មានភ្ញៀវច្រើនទៀតផង ទើបនាងត្រូវធ្វើការរហូតដល់យប់បន្តិចទើត្រឡប់ទៅផ្ទះ។

នាងរៀបចំអីវ៉ាន់របស់ខ្លួនរួចរាល់ ចេញមកដល់ក្រៅដើម្បីហៅតាក់ស៊ីជិះទៅផ្ទះតែមិនមាននោះទេ រាល់ថ្ងៃនាងចេញពីភ្លឺត្រូវដើរទៅចំណតឡានក្រុងដើម្បីជិះ តែថ្ងៃនេះរាងយប់ទៅហើយទើបមិនហ៊ានដើរ នាងនៅឈរមុខសណ្ឋាគារមួយសន្ទុះនៅតែមិនឃើញមានទើប ដើរលេងសំដៅចំណតឡានក្រុង។

«សួស្តីអូនស្រី ទៅណាឲ្យបងជូនទៅល្អទេ?» សំឡេងអ្នកណាមិនដឹងបន្លឺឡើងធ្វើឲ្យអ្នកដែលកំពុងដើរឈប់ឆ្ងក់ងើបមុខទៅមើល។

«មិន...មិនបាច់ទេ» នាងតបរដាក់រដុបសម្លឹងមើលបុរសខាងមុខដែលមានគ្នាពីរនាក់សម្លឹងមកនាងដោយខ្សែភ្នែកមមិនគួរឲ្យទុកចិត្ត។

«យប់ហើយមិនខ្លាចទេឬ?» សំឡេងបុរសម្នាក់នោះនៅតែបន្លឺមកទៀត ស៊ូហ៊ី ព្យាយាមពង្រឹងអារម្មណ៍ខ្លាច។

«មិនអីទេ អរគុណ» នាងតបហើយក៏បែរខ្លួនបំរុងរត់តែក៏ត្រូវវាស្រវ៉ាចាប់ដៃជាប់។

«លែងយើងទៅ» នាងប្រាប់ទាំងប្រឹងរមួលដៃរបស់ខ្លួនឲ្យផុតពីដៃអ្នកម្ខាងទៀតតែមិនងាយនោះទេ។

«ចង់ទៅណាគិតថារត់រួចមែនទេ?» អាម្នាក់ក្នុងចំណោមនោះនិយាយទាំងសើចងាកញាក់ភ្នែកទៅដៃគូរវាម្នាក់ទៀត។





«វ៉ាយ ឆាប់លែងយើងទៅ ជួយផង អ្នកណាក៏បានដែរ ជួយផង» នាងប្រឹងស្រែកទាំងយកដៃគក់ខ្នងពេលវាលើកនាងលី តែមិនអាចនោះទេនាងចាប់ផ្តើមភ័យកាន់តែខ្លាំង ពេលពួកវានាំគ្នាដើរសំដៅរថយន្តដែលឈប់ចំហៀងផ្លូវ។

«អត់ទេ លែងយើង ជួយផង ជួយ...» នាងប្រឹងស្រែកម្តងទៀតតែក៏ត្រូវអាម្នាក់ទៀតយកកន្សែងមកខ្ទប់មាត់ជាប់ ធ្វើឲ្យនាងចាប់ផ្តើមទន់ដៃទន់ជើងគ្មានកំលាំងតែមិនទាន់សន្លប់នោះទេ សង្ឃឹមមានមនុស្សមកជួយទាន់ពេលនាងមិនចង់ធ្លាក់ក្នុងសភាពដូចយប់នោះទៀតទេ នាងបុណ្យក្នុងចិត្តទាំងទឹកភ្នែកព្រោះគ្មានកំលាំងស្រែកតទៀត។

«ឆាប់លែងនាងភ្លាម» សំឡេងមានអំណាចរបស់អ្នកណាម្នាក់បន្លឺឡើងទើបពួកនោះនាំគ្នាងាកទៅមើល។

«ឯងជាអ្នកណា កុំមកចេះដឹងរឿងអ្នកដទៃ អាបារាំងសេស» បុរសម្នាក់ដែលកំពុងតែលីនាងងាកមកថាឲ្យអ្នកម្ខាងទៀត។

អែលវិន ញញឹមចុងមាត់តែជាស្នាមញញឹមត្រជាក់គួរឲ្យខ្លាចបំផុត គេទើបចេញពីសណ្ឋាគារឃើញនាងទើបចេញមកដូចគ្នា អារម្មណ៍ម្យ៉ាងប្រាប់ឲ្យគេតាមនាងទើបបានមកជួបហេតុការណ៍នេះ។

«និយាយស្រួលមិនចង់ស្តាប់ ចង់លេងធម៌ក្តៅមែនទេ» កំលោះនិយាយសំឡេងស្មើរសម្លឹងមើលពួកនោះដោយក្រសែភ្នែកមុត។

«យើងប្រាប់ហើយថាកុំមកចេះដឹងរឿងអ្នកដទៃ» បុរសម្នាក់នោះតបទាំងដាក់ ស៊ូហ៊ី ចុះឲ្យគ្នាវាម្នាក់ទៀតមើលនាង ហើយដើរសំដៅមកអ្នកម្ខាងទៀតដោយឫកពារខែងរែង។



Scanned by CamScanner

«ថៃដន្យអី យើងជាមនុស្សចង់ដឹងចង់ឮរឿងគេ យ៉ាងម៉េច?» កំលោះប្រាប់ខ្ចីងាកទៅមនុស្សជំនិតរបស់គេទាំងពីរ។

សំឡេងសន្ទនាឮល្ងៀងៗដូចជាប្រហែលៗ ធ្វើឲ្យអ្នកដែលត្រូវថ្នាំទន់ខ្លួននោះប្រឹងបើកភ្នែកសម្លឹងមើលតែមិនច្បាស់នោះទេ តែយ៉ាងណាក៏ត្រេកអរដែលមានមនុស្សមកជួយនាងទាន់ពេល។

ជេក និង ជីម ងាកមកសម្លឹងមុខគ្នាចាប់ផ្ដើមដកកាំភ្លើងខ្លីពីចង្កេះភ្ជង់សំដៅអ្នកម្ខាងទៀត គ្រាន់តែឃើញកាំភ្លើងធ្វើឲ្យបុរសម្នាក់នោះរាងភ័យបន្តិចទើបថយក្រោយយ៉ាងលឿន។

«ល្បងមិនស្រួលទេ គិតយ៉ាងម៉េចទៅ?» សំឡេងគ្នាវាម្នាក់ទៀតខ្សឹបសួរដៃគូរ។

«មានយ៉ាងម៉េចគឺរត់ហ្នឹងណា ឯងចង់ងាប់ឬយ៉ាងម៉េច?» គ្នាវាប្រាប់ហើយក៏នាំគ្នារត់សំដៅឡានដែលឈប់ជិតនោះ ស៊ូហ៊ី ដែលគ្មានកំលាំងឈរពេលត្រូវគេលែងដៃក៏ទ្រេត រកដួលសំណាងមានដៃរឹងមាំដើរមកទប់ឱបទាន់ កំលោះសម្លឹងមើលនារីក្នុងរង្វង់ដៃមុននឹងលើកបីនាងសំដៅរថយន្តរបស់គេ។

ឥទ្ធិពលថ្នាំសណ្ដំធ្វើឲ្យនាងសន្លប់ គេមិនដឹងថានាំនាងទៅណានោះទព្រោះមិនស្គាល់ផ្ទះរបស់នាង បានត្រឹមអង្គុយក្នុងឡានសម្លឹងនាងមិនដាក់ភ្នែក ជាពិសេសក្លិនក្រអូបរបស់នាងធ្វើឲ្យគេគិតដល់នារីកាលពីយប់ក្នុងខុនដូរនោះ ចម្ងល់ជាច្រើនក្នុងខួរក្បាលជានាងដែលធ្លាប់បដិសេធគេថាមិនលក់ខ្លួនព្រោះលុយ តែគេមានអារម្មណ៍ថាជានាងច្បាស់ណាស់ក្នុងយប់នោះគេនឹងស៊ើបរឿងនេះបើវាជាការពិតនោះ គិត





ហើយក៏ងាកទៅមើលនាងម្ដងទៀត តើនាងមានគោលបំណងអីឲ្យប្រាកដដែលសម្ដែងជារឿងបែបនេះ។

«តើទៅណាចៅហ្វាយ?» សំឡេងមនុស្សខាងមុខបន្លឺឡើងទើបគេដកក្រសែភ្នែកពីនារីក្បែរខ្លួនទៅមើល។

«ទៅខុនដូរ» គេប្រាប់ខ្លីៗហើយក៏ងាកមើលអ្នកក្បែរខ្លួនម្ដងទៀតបបូរមាត់នាងធ្វើឲ្យគេមានអារម្មណ៍មិនស្ងប់នោះទេ ទ្រាំមិនបានទើបឱនទៅថើបញក់ញើរហូតអស់ចិត្តទើបដកបបូរមាត់មកវិញ គេញញឹមចុងមាត់ដោយភាពពេញចិត្ត គេប្រហែលឆ្កួតហើយដែលលួចថើបមនុស្សស្រីពេលសន្លប់បែបនេះ រាល់ដងមានតែមនុស្សស្រីតាមគេតែប៉ុណ្ណោះ នាងជាមនុស្សស្រីសំណាងហើយ គេគិតក្នុងចិត្តស្របពេលរថយន្តមកដល់ខុនដូរ ទើបបីនាងសំដៅជណ្ដើរយន្តឡើងទៅជាន់របស់ខ្លួន។

ស៊ូហ៊ី ចាប់ផ្ដើមដឹងខ្លួនពេលជាតិថ្នាំចាប់ផ្ដើមសាបជាបណ្ដើរៗនាងបើកភ្នែកដោយភាពល្ងើយ សម្លឹងមើលជុំវិញបន្ទប់ដោយការរិះគិតមានអារម្មណ៍ដូចជាធ្លាប់ស្គាល់ មកឈប់ត្រឹមអ្នកដែលគេងក្បែរទើបបើកភ្នែកធំៗដោយភាពភ្ញាក់ផ្អើល នេះយើងមកទីនេះបានយ៉ាងម៉េចហ្នឹងស្លាប់ហើយ នាងឧទានក្នុងចិត្តសន្សឹមៗចុះពីគ្រែថ្នមៗខ្លាចធ្វើឲ្យអ្នកម្ខាងទៀតភ្ញាក់។

«ដឹងខ្លួនហើយមែនទេ?» សំឡេងបន្លឺឡើងក្បែរខ្លួនធ្វើឲ្យអ្នកដែលរៀបនឹងចុះពីគ្រែឈប់ឆ្ងក់ នេះគេភ្ញាក់តាំងពីពេលណាហើយគេដឹងអីខ្លះទៅលោកអើយនាងឧទានក្នុងចិត្តទាំងភ័យព្រួយ។

«ហេតុអីក៏ខ្ញុំនៅទីនេះ?»



Scanned by CamScanner

នាងងាកសន្សឹមៗទៅសួរអ្នកកំពុងគេងយកដៃទ្រក្បាល សម្លឹងមកដោយក្រសែភ្នែកធម្មតាតែធ្វើឲ្យនាងចង់រត់ច្រើនជាង។

«មិនចាំរឿងកាលពីយប់មិញទេហ៎» គេតបមកវិញសំឡេងស្ទើរសម្លឹងមុខនាងមិនដាក់ភ្នែកនោះទេ នាងក្រមុំចាប់ផ្ដើមគិតនឹកឃើញរឿងកាលពីយប់ធ្វើឲ្យចាប់ផ្ដើមភ័យតិចៗ ប្រតិកម្មរបស់នាងមិនរួចផុតពីក្រសែភ្នែកអ្នកម្ខាងទៀតនោះទេ។

«អរគុណដែលបានជួយ ខ្ញុំសុំទៅវិញហើយ» នាងប្រាប់ហើយក៏ក្រោកចុះពីគ្រែយ៉ាងលឿន មិនហ៊ាននៅយូរជាងនេះទេ។

«ចាំខ្ញុំឲ្យមនុស្សជូនទៅ» សំឡេងគេបន្លឺឡើងពីក្រោយពេលនាងដើរជិតដល់មាត់ទ្វារទើបងាកមកប្រុងតប តែរាងកាយគេបែរជានៅឈរកៀកនាងទៅហើយទើបត្រូវថយក្រោយដោយស្វ័យប្រវត្តិ។

«មិន មិនអីទេ គ្រាន់តែជួយជូនខ្ញុំទៅចំណតឡានក្រុងបានហើយ» នាងប្រាប់សំឡេងស្រាលទាំងញញើតញើម។

អែលវិន នៅអង្គុយក្នុងឡានសម្លឹងរហូតនាងឡើងឡានក្រុងចេញទៅទើបគេត្រឡប់មកខុនដូរវិញ តាមផ្លូវគេនៅតែគិតពីរង្វង់មុខនិងក្លិនក្រអូបជាប់ខ្លួនរបស់នាងមិនឈប់ គិតយូរទៅធ្វើឲ្យគេចាប់ផ្ដើមច្របូកច្របល់ទើបឈប់គិតតទៅទៀត។

ស៊ូហ៊ី មកធ្វើការជាធម្មតាតែអារម្មណ៍មិននៅនិងខ្លួននោះទេ ព្រោះគិតតែរឿងកាលពីយប់ នៅខ្វល់ខ្វាយខ្លាចគេចំណាំនាងបានសង្ឃឹមថាគេមិនចាំទៅចុះ នាងបួងសួងក្នុងចិត្តទាំងភ័យព្រួយ។

«ស៊ូហ៊ី មែនទេ?» សំឡេងអ្នកណាម្នាក់បន្លឺឡើងទើបនាងងាកទៅ





មើលជាអ្នកស្រី សុងហ៊ី មិត្តចាស់របស់ម៉ាក់នាងរាងភ្ញាក់ផ្អើលបន្តិចពេលដែលឃើញគាត់នៅទីនេះ។

«ចាស អ៊ំស្រីសម្រាកនៅទីនេះមែនទេ?»

«ហ៊ឹម នេះជាសណ្ឋាគារកូនប្រុសខ្ញុំ» គាត់តបទាំងស្នាមញញឹមតែធ្វើឲ្យអ្នកម្ខាងទៀតបើកភ្នែកធំៗដោយភាពភ្ញាក់ផ្អើលបន្ទាប់ពីឮ ម៉េចនឹងអាចទៅរួចទៅ គាត់ជាម្ដាយរបស់អគ្គនាយកមែនទេ នាងសួរខ្លួនឯងក្នុងចិត្ត ស្របពេលសំឡេងស្ត្រីចំណាស់នៅតែបន្លឺមកទៀត។

«ពិតជាចៃដន្យមែន មិនគិតថានាងធ្វើការនៅទីនេះនោះទេ?»

«ចាស» នាងតបសំឡេងស្រាលញញឹមតិចៗ តែក្នុងចិត្តកំពុងតែខ្វល់ខ្វាយហេតុអីក៏មានរឿងចៃដន្យបែបនេះ។

នៅជ្រុងមួយនៃអគារ បុរសម្នាក់កំពុងតែសម្លឹងមកដោយភាពងឿងឆ្ងល់និងរិះគិត អែលវិន ទទួលទូរស័ព្ទពីម៉ាក់គេថាគាត់មកទីនេះទើបគេចុះមកចាំទទួលហើយក៏បានឃើញរូបភាពទាំងនេះ គេចាប់ផ្ដើមយល់ខ្លះៗហើយ កំលោះសម្លឹងមើលនារីដែលកំពុងនិយាយជាមួយម្ដាយគេដោយក្រសែភ្នែកមុតគិតថារឿងនេះគួរតែសួរម្ដាយគេឲ្យដឹងរឿងល្អជាង។

«ម៉ាក់ អញ្ជើញមកដល់យូរហើយមែនទេ?» សំឡេងដែលស៊ាំទំលាប់ហៅទើបធ្វើឲ្យអ្នកជាម្ដាយញញឹមមុននឹងងាកទៅមើល។

«ម៉ាក់ទើបមកដល់ទេ» តបរួចក៏ងាកមកនាងក្រមុំចំពោះមុខធ្វើឲ្យកំលោះសម្លឹងទៅតាមដោយក្រសែភ្នែកមុត ស៊ូហ៊ី មានអារម្មណ៍មិនសូវស្រួលពេលឃើញក្រសែភ្នែករបស់គេដែលសម្លឹងមក មិនដឹងថាគេកំពុងគិតអីលើនាងនោះទេ។

ក្បៀកដៃស្ត្រីចំណាស់ផ្សៀតសម្លឹងនាងក្រមុំចុងភ្នែកបន្តិច។

«អញ្ជើញទៅក្នុងតែម្តងទៅល្អទេម៉ាក់» កំលោះប្រាប់ទាំងដើរទៅ

«ក៏បាន ស៊ូហ៊ី ខ្ញុំទៅសិនហើយណា»

«ចាស អ៊ំស្រី» នាងតបទាំងឱនគោរពមិនហ៊ានសម្លឹងមើលមុខគេនោះទេ រហូតពួកគាត់នាំគ្នាដើរចេញទៅ។

«ហេតុអីក៏ម៉ាក់ស្គាល់នាង?» អ៊ែលវិន សួរម្តាយពេលនាំគាត់មកដល់បន្ទប់ធ្វើការរបស់ខ្លួន។

«នាងជាកូនស្រីមិត្តភក្តិម៉ាក់» អ្នកជាម្តាយតបទាំងញញឹមសម្លឹងមុខកូនប្រុសតែគេកំពុងតែរិះគិតរឿងផ្សេងច្រើនជាង។

«ម៉ាក់មិនដឹងថានាងធ្វើការនៅទីនេះនោះទេ ពិតជាចៃដន្យមែន» សំឡេងស្រីចំណាស់នៅតែបន្លឺ តែក្នុងចិត្តគាត់កំពុងគិតរឿងផ្សេងដែលទាំងញញឹមលាក់គំនួច។

«ម៉ាក់នៅសម្រាកទីនេះយូរទៀតទេ?»

«ម៉ាក់ចង់នៅមួយរយៈទៀត ព្រោះខានមកទីនេះយូរហើយចង់នៅលេងឲ្យបានយូរបន្តិច»

«បាទម៉ាក់» គេតបហើយក៏ធ្វើការងាររបស់ខ្លួនបន្តរហូតដល់រសៀលទើបនាំគាត់ទៅពិសាអាហារល្ងាចនៅសណ្ឋាគារ។

ស៊ូហ៊ី ត្រឡប់មកដល់ផ្ទះទាំងភ័យព្រួយពេលប្អូនប្រុសប្រាប់ថាម៉ាក់នាងធ្វើទុកហើយចង់ជួបនាងយ៉ាងខ្លាំងទើបសុំគេចេញមកមុន។

«ម៉ាក់ ម៉ាក់ខ្ញុំមកដល់ហើយ» នាងប្រាប់ទាំងទឹកភ្នែករត់ទៅអង្គុយជិតគាត់យ៉ាងលឿន ស្ត្រីចំណាស់ប្រឹងបើកភ្នែកបន្ទាប់ពីឮ គាត់សន្សឹមៗ





លើកដៃដែលក្រៀមទៅរកកូនស្រីទើបនាងទាញមកដាក់ជាប់ថ្ពាល់។

«ស៊ូហ៊ី ម៉ាក់សូមទោសណា៎ មកពីម៉ាក់មិនល្អទើបធ្វើឲ្យកូនលំបាក» គាត់និយាយសំឡេងស្អកលាយយំ ទើបធ្វើឲ្យអ្នកជុំវិញនេះយំដូចគ្នាទាំង ដូយ៉ុង និង ហេជីន។

«ម៉ាក់កុំនិយាយបែបនេះអី ខ្ញុំមិនអីទេដើម្បីម៉ាក់ឲ្យខ្ញុំធ្វើអ្វីក៏បាន សុំតែម៉ាក់កុំទៅណាចោលពួកខ្ញុំទៅបានហើយ» នាងតបបណ្តើរយំបណ្តើរ គាត់លើកដៃអង្អែលក្បាលទាញនាងមកឱបជាប់ទ្រូងរួមទាំង ដូយ៉ុង ប្អូនប្រុសនាងដែរ។

«អរគុណ ម៉ាក់អរគុណពួកកូនខ្លាំងណាស់» គាត់ប្រាប់ទាំងអង្អែលក្បាលពួកគេរហូតលែងមានចលនាតទៅទៀត ទើបនាំគ្នាយំឱបគាត់កាន់តែខ្លាំង។

ក្រោយពីពិធីបុណ្យសពចប់សព្វសគ្រប់ ស៊ូហ៊ី អង្គុយស្ងៀមស្ងាត់សម្លឹងមើលជុំវិញផ្ទះមិនឈប់ អ្នកស្រី សុងហ៊ី ក៏ឧស្សាហ៍មកទីនេះដូចគ្នា គាត់សម្លឹងមើលពួកគេដោយក្តីអាណិត តែមិនអាចជួយអ្វីបានគាត់ក៏មានការសោកស្តាយដែរ ដែលទើបតែរកមិត្តឃើញតែក៏ត្រូវបែកគ្នាម្តងទៀតហើយបែកជារៀងរហូតបែបនេះទៀត។

ស៊ូហ៊ី មកធ្វើការទាំងមុខស្រពោន ព្រោះតែនៅពិបាកចិត្តតែប្រឹងញញឹមក្រៀមដាក់ភ្ញៀវ សេមី ឃើញមិត្តក្នុងសភាពបែបនេះក៏នឹកអាណិតដូចគ្នាតែនាងគ្មានលទ្ធភាពជួយបានត្រឹមលួងលោម។

«ស៊ូហ៊ី» សំឡេងហៅដូចជាប្រហែលៗទើបងើបមុខទៅមើល។

«ចាស អ៊ំស្រីមានការអីមែនទេ?» នាងតបសួរទាំងញញឹមក្រៀម

ដាក់អ្នកម្ខាងទៀតពេលឃើញថាជាអ្នកណា។

«ពួកយើងនិយាយគ្នាបន្តិចបានទេ?» គាត់ប្រាប់តិចៗធ្វើឲ្យនាងងឿងឆ្ងល់បន្តិច តែក៏ងក់ក្បាលតបទទួល គាត់នាំនាងទៅអង្គុយនៅតុអាហារជាន់ក្រោមរបស់សណ្ឋាគារ។

«អ៊ំស្រីមានអីមែនទេ?» ស្ត្រីចំណាស់ញញឹមតិចៗទាញដៃនាងមកកាន់ក្នុងន័យលួងលោម មុននឹងដកស្រោមសំបុត្រពណ៌សមួយមកដាក់លើតុរុញវាទៅឲ្យនាង។

«នេះជាអ្វី?» នាងសួរសំឡេងស្រាលសម្លឹងមើលស្រោមសំបុត្រទាំងងឿងឆ្ងល់។

«ជាប្រាក់មួយចំនួន ឯងទុកប្រើការទៅ» គាត់ប្រាប់ទាំងញញឹមតែអ្នកម្ខាងទៀតបែរជាជ្រួញចិញ្ចើមរាងភ្ញាក់ផ្អើល។

«អ៊ំស្រីកុំធ្វើបែបនេះអី ខ្ញុំអាចដោះស្រាយខ្លួនឯងបានហើយ» នាងតបទាំងញញឹមតិចៗរុញសំបុត្រនោះទៅវិញ។

«ទុកទៅ ប្អូនប្រុសឯងរៀនមិនទាន់ចប់មែនទេ ប្រហែលត្រូវការវា ខ្ញុំមិនអាចជួយអ្វីម្ដាយឯងបាន ទើបចង់ជួយសម្រាលពួកឯង» សំឡេងគាត់នៅតែបន្លឺមក ទើបនាងងើបមុខទៅមើលគាត់ នាងដឹងយល់ពីសណ្ដានចិត្តរបស់គាត់តែនាងពិតជាមិនអាចទទួលវាបានមែន នាងធ្លាប់ធ្វើខុសម្ដងហើយហើយក៏មិនចង់ទទួលគុណពីអ្នកណាទៀតដែរ។

«អ៊ំស្រីកុំបារម្ភអី ខ្ញុំអាចដោះស្រាយខ្លួនឯងបានហើយ អរគុណដែលយកចិត្តទុកដាក់និងពួកខ្ញុំ» ស្ត្រីចំណាស់មើលក្មេងស្រីចំពោះមុខពិតជារឹងរូស ហើយក៏រឹងមាំដែរ បើនាងបដិសេធទៅហើយគាត់ក៏មិនហ៊ាន





បង្ខំទៀតដែរ។

រូបភាពរបស់ពួកគាត់ទាំងពីរក៏មិនអាចរួចផុត ពីក្រសែភ្នែកអ្នកនៅទីនេះបានដែរ អែលវិន ត្រូវចុះមកមើលការងារចែដន្យក៏បានឃើញរូបភាពទាំងនេះវាដូចអ្វីដែលគេស្មានមិនខុសនោះទេ។

«មនុស្សស្រីមានល្បិច ផែនការខ្ពស់មែន» កំលោះនិយាយសំឡេងតាមដើងធ្មេញក្ដាប់ដៃណែនដោយកំហឹង សម្លឹងមើលនារីដែលអង្គុយទល់មុខម្ដាយគេដោយក្រសែភ្នែកមុតមុននឹងដើរចេញទៅវិញ។

ស៊ូហ៊ី ត្រូវអគ្គនាយកប្រាប់ឲ្យទៅជួបនៅបន្ទប់ធ្វើការនាងឡើងទៅទាំងភ័យព្រួយមិនដឹងមានរឿងអីទៀតហើយទេ។

«ចៅហ្វាយ អ្នកនាង ស៊ូហ៊ី មកដល់ហើយ» ជេក រាយការណ៍ពេលនាំនាងមកដល់ខាងក្នុង។

«អស់កិច្ចការហើយចេញទៅវិញទៅ» គេងាកមុខពីជញ្ជាំងកញ្ចក់មកប្រាប់កូនចៅសំឡេងស្មើរសម្លឹងមើលនារីចំពោះមុខ ដោយក្រសែភ្នែកមុត ស៊ូហ៊ី លេបទឹកមាត់ទាំងពិបាកពេលឃើញខ្សែភ្នែករបស់គេ មិនដឹងថានាងធ្វើអីខុសនោះទេ។

អែលវិន នៅឈរសម្លឹងនាងដោយក្រសែភ្នែស្អប់ខ្ពើមមុននឹងបោះជំហ៊ានដ៏មានអាចមកឈរចំពោះមុខ។

«នាងត្រូវការអី?» កំលោះសួរសំឡេងស្មើរធ្វើឲ្យក្រមុំងើបមកមើលទាំងងឿងឆ្ងល់មិនដឹងគេចង់មានន័យពីអ្វីនោះទេ។

«អគ្គនាយកចង់មានន័យពីអី ខ្ញុំមិនយល់ទេ»

«ពិតជាពូកែសម្ដែងមែន» កំលោះនិយាយទាំងញញឹមចំអកនឹងភាព



Scanned by CamScanner

មិនដឹងខ្យល់របស់នាង ដៃម្ខាងចាប់កន្ត្រាក់រាងកាយស្ដើងមកអឹបដើមទ្រូងដោយកំហឹង។

«អគ្គនាយក លែងខ្ញុំទៅ» នាងក្រមុំប្រាប់សំឡេងញ័រព្រោះភ័យបុករួមទាំងកំលាំងដៃរបស់គេជងស្មារនាងទាំងសងខាងស្ទើរបាក់ទៅហើយ។

«នាងជាមនុស្សស្រីមានល្បិចខ្លាំងណាស់» គេប្រាប់សំឡេងតាមដើងធ្មេញថែមទាំងរុញនាងចេញទាំងកម្រោល នាងក្រមុំយកដៃក្ដោបស្មាបន្ធូយការឈឺចាប់ ព្យាយាមឃាត់ទឹកភ្នែកកុំឲ្យហូរតែមិនអាចនោះទេ។

«ពិតជាប៉ិនសម្ដែងមែន ដំបូងធ្វើជាសម្ដែងមកប៉ះឡានខ្ញុំក្រោយមកធ្វើជាមិនចាប់អារម្មណ៍រឿងលុយ តែចុងក្រោយក៏ធ្វើដើម្បីលុយ» កំលោះប្រាប់ទាំងដើរមកជិតនាងម្ដងទៀត នាងក្រមុំថយគេចទាំងភ័យខ្លាចតែក៏ត្រូវគេទាញមកឈរចំពោះមុខ។

«លោកប្រហែលយល់ច្រលំរឿងអ្វីមួយហើយ» នាងក្រមុំប្រាប់ទាំងសម្លឹងមុខគេ កំលោះញញឹមបែបចំអក។

«យល់ច្រលំមែនទេ ចុះកាលដែលនាងបង្ហាញខ្លួនដើម្បីទាក់ប្រុសអ្នកមានរកលុយនោះ ជាការយល់ច្រលំដែរមែនទេ?» នាងក្រមុំស្ងាត់ស្ងៀមមិនហ៊ានមាត់ដូចជាមានប្រផ្នូលម្យ៉ាង។

«ប្រហែលត្រូវចំនុចហើយមែនទេ នាងប្រហែលមិនទាន់ភ្លេចយប់នៅខុនដូរទេដឹង» កំលោះនិយាយទាំង ដើរទៅអង្គុយគងទាក់ខ្លាលើសាឡុងសម្លឹងមកបែបចំអក នាងក្រមុំចាប់ផ្ដើមដកដង្ហើមញាប់តាមពិតគេចាំនាងបានពិតមែន ព្រោះតែបែបនេះមែនទេទើបគេហៅនាងមកដើម្បីចំអកពីរឿងនេះ នាងគិតទាំងតូចចិត្ត។





«ព្រោះខ្ញុំត្រូវការប្រាក់បន្ទាន់តែប៉ុណ្ណោះ» នាងប្រាប់សំឡេងស្រាលទាំងទំលាក់ភ្នែកចុះ។

«ប្រាក់ ក្រែងនាងធ្លាប់និយាយមែនទេ ថាមិនយកខ្លួនទៅប្ដូរព្រោះវានោះហេតុអីក៏ឆាប់ភ្លេចយ៉ាងនេះ» គេនៅបង្ហើរសំឡេងចំអកមកទៀត។

«សូមទោស បើលោកហៅខ្ញុំមកព្រោះតែរឿងនេះ ខ្ញុំសូមត្រឡប់ទៅវិញហើយ» នាងក្រមុំប្រាប់ទាំងបែខ្លួនចេញទៅស្របពេលសំឡេងមានអំណាចរបស់គេបន្លឺមកទៀត។

«នាងដឹងថាម៉ាក់ខ្ញុំជាមិត្តចាស់ម៉ាក់នាង ទើបបង្កើតរឿងទាំងនេះឡើងដើម្បីបានមកជិតខ្ញុំមែនទេ» កំលោះសួរសំឡេងតាមដើងធ្មេញសម្លឹងនាងដោយក្រសែភ្នែកមុត អ្នកស្ដាប់បានត្រឹមបើកភ្នែកធំៗព្រោះភ្ញាក់ផ្អើលបន្ទាប់ពីឮ។

«ខ្ញុំគ្មានគំនិតបែបនោះទេហើយខ្ញុំក៏មិនដឹងថាអ្នកស្រី សុងហ៊ី ជាមិត្តម៉ាក់ខ្ញុំនោះដែរ» នាងប្រាប់សំឡេងម៉ឺងម៉ាត់ ព្រោះតែបែបនេះមែនទេទើបគេគិតថានាងជាមនុស្សពុតត្បុត មកពីគ្រួសារនាងក្រហើយបែរជាស្គាល់គ្រួសារគេជាអ្នកមានទើបគេគិតថានាងជាមនុស្សមុខលុយ។

«មិនដឹង គួរឲ្យអស់សំណើចណាស់» កំលោះនៅតែបោះសម្ដីចំអកមើលងាយ នាងក្រមុំមានអារម្មណ៍ខ្លួនឯងតូចទាបខ្លាំងណាស់បើប្រៀបនឹងគេ។

«លោកគិតយ៉ាងម៉េចជារឿងរបស់លោក តែអ្វីទាំងអស់មិនមែនខ្ញុំជាអ្នកបង្កើតឡើងនោះទេ ជឿមិនជឿតាមចិត្ត» នាងក្រមុំប្រាប់សំឡេងម៉ឺងម៉ាត់ហើយក៏ដើរចេញទៅ។



Scanned by CamScanner

«គិតថាខ្ញុំជឿនាងមែនទេ មនុស្សស្រីទាំងអស់សុទ្ធតែដូចគ្នា» គេអុ
ង្គុយម្នាក់ឯងមុននឹងដើរ មកអង្គុយកៅអីស្បែករបស់ខ្លួនស្របពេលមនុស្ស
របស់គេចូលមក។

«តាមដានស្រីម្នាក់នោះរួមទាំងអ្នកផ្ទះនាងផង ថាមានទាក់ទងអីនឹង
ម៉ាក់ខ្ញុំ» គេប្រាប់សំឡេងស្មើធ្វើការងាររបស់ខ្លួនបន្ត ទាំងអារម្មណ៍មិន
ស្ងប់។

ស៊ូហ៊ី មកដល់ក្រោមនាងសំងំយំក្នុងបន្ទប់ទឹកនៅឡើយទេ...

«លោកបំផ្លាញរបស់មានតម្លៃរបស់ខ្ញុំហើយ នៅតិះដៀលខ្ញុំទៀត
មែនទេ ខ្ញុំដឹងថាខ្លួនឯងមិនល្អតែលោកក៏មិនគួរមើលងាយខ្ញុំ ទាំងគ្រួសារ
ខ្ញុំដល់ថ្នាក់នេះដែរ» នាងនិយាយម្នាក់ឯងទាំងទឹកភ្នែក។

ដូយ៉ុង ជានិស្សិតឆ្នាំទី៣ គេធ្វើការបណ្ដើររៀនបណ្ដើរដើម្បីជួយ
សម្រាលបន្ទុកចំណាយរបស់បងស្រី ព្រោះនាងត្រូវចំណាយថ្លៃថ្នាំម្ដាយ
ផងហើយនៅបង់ថ្លៃសាលាឲ្យគេថែមទៀត។

«ឯងគឺដូយ៉ុងមែនទេ?» សំឡេងស្ត្រីចំណាស់ម្នាក់បន្លឺឡើងទើបធ្វើ
ឲ្យអ្នក ដែលទើបចេញពីសាលា ងាកមកមើលព្រោះហៅចំឈ្មោះរបស់
គេ។ ដូយ៉ុង មឹងមាំងបន្តិចក្រោយមកដូចជានឹកឃើញទើបញញឹមតប។

«បាទ អ៊ំស្រីជាមិត្តម៉ាក់ខ្ញុំមែនទេ?» គេសួរតបព្រោះមិនសូវច្បាស់
ស្ត្រីចំណាសញញឹម តិចៗឈានជើងដើរមកជិត។

«ឯងរៀននៅទីនេះមែនទេ?» គាត់សួរទាំងសម្លឹងទៅខាងក្នុងសា
លាដែលគេទើបចេញមកមុននេះ។





«បាទ អ៊ំស្រីមានការអីមែនទេ?» គេសួរទាំងយកដៃអេះក្បាល។

«ពួកយើងនិយាយគ្នាបន្តិចទៅ» គាត់ប្រាប់ទាំងដើរសំដៅរថយន្ត
ដែលឈប់ក្បែរទើបគេត្រូវដើរតាមទាំងងឿងឆ្ងល់ ព្រោះមិនដឹងគាត់ចង់
និយាយអីនោះទេ។

នៅក្នុងហាងកាហ្វេមួយនៅជិតសាលារបស់គេ ស្ត្រីចំណាស់សម្លឹង
មើលគេដោយក្ដីអាណិត គាត់លូកយកស្រោមសំបុត្រពណ៌សមួយមក
ដាក់ខាងមុខគេ។

«ឯងយករបស់នេះទុកប្រើការទៅ ឬក៏ទុកបង់ថ្លៃសាលាក៏បាន» គាត់
ប្រាប់ទាំងរុញសំបុត្រទៅជិតដៃរបស់គេ ដូយ៉ុង មើលទាំងងឿងឆ្ងល់។

«ជាស្អីគេ អ៊ំស្រី» គេសួរទាំងលើកស្រោមសំបុត្រនោះមកមើល
ហើយក៏បើកភ្នែកធំៗ ពេលឃើញក្រដាសសែកមានទឹកលុយយ៉ាងច្រើន
ដំបូងសប្បាយចិត្តតែក្រោយមកក៏មុខស្រពោនទុកវានៅលើតុវិញ។

«ហេតុអីមិនយកទៅ?» សំឡេងស្ត្រីចំណាស់បន្លឺឡើង។

«ហេតុអីក៏អ៊ំស្រីឲ្យមកខ្ញុំ?» គេសួរតបទាំងសម្លឹងមុខស្ត្រីចំណាស់
មិនដាក់ភ្នែកព្រោះទឹកប្រាក់ទាំងនោះច្រើនហេតុអីក៏ឲ្យគេទទេបែបនេះ។

«ខ្ញុំគ្រាន់តែចង់ជួយពួកឯង ពេលដែលម៉ាក់ឯងលែងនៅតែប៉ុណ្ណោះ
ឆាប់យកទុកទៅណា» គាត់ប្រាប់ទាំងញញឹមយកសំបុត្រនោះដាក់លើដៃ
ទើបគេទទួល មានប្រាក់នេះក៏ល្អម្យ៉ាងដែរបងស្រីមិនបាច់លំបាកព្រោះតែ
ជួយបង់ថ្លៃសាលាគេទៀត គេគិតក្នុងចិត្តទាំងរីករាយធ្វើឲ្យស្ត្រីចំណាស់
ញញឹមរីករាយដូចគ្នា។

«ស៊ូហ៊ី ចេញទៅផ្ទះហើយមែនទេ?»

សំឡេងអ្នកណាម្នាក់ហៅ ទើបធ្វើឲ្យអ្នកដែលទើបដើរចេញមកដល់មាត់ទ្វារងាកមកមើល ឃើញថាជាអ្នកណាទើបញញឹមតប។

«ចាស មានអីមែនទេប្រធានផ្នែក?»

«គ្មានអីទេ គ្រាន់តែ...» កំលោះនិយាយបែបអៀន យូជុន ជាប្រធានផ្នែកមួយក្នុងសណ្ឋាគារនេះ គេលួចពេញចិត្តនាងជាយូរមកហើយតាំងពីនាងចាប់ផ្ដើមធ្វើការនៅទីនេះម្លេះ តែនាងមិនដឹងខ្លួននោះទេ។

«មានអីមែនទេ?» ក្រមុំសួរបន្ថែមទាំងងឿងឆ្ងល់ ព្រោះមិនឮអ្នកម្ខាងទៀតតបគិតតែពីនៅស្ងៀម។

«ល្ងាចនេះទំនេរដែរទេ?» គេសួរសំឡេងស្រាលទាំងញញឹមតិចៗ ស៊ូហ៊ី នៅស្ងៀមបន្តិច។

«ចាសទំនេរ មានការអីមែនទេ?»

«គ្រាន់តែចង់ណាត់ញ៉ាំអាហារល្ងាចនេះ តើអាចផ្ដល់ឱកាសឲ្យខ្ញុំបានទេ?» គេប្រាប់ទាំងសម្លឹងមុខនាងដោយខ្សែភ្នែកស្រទន់ក្រមុំ ធ្វើខ្លួនមិនសូវត្រូវព្រោះមិនធ្លាប់មានមនុស្សប្រុសមកសុំនាងបែបនេះនោះទេ។

«ចាសបាន តែប្រធានផ្នែក...»

«កុំហៅខ្ញុំប្រធានផ្នែកអី ហៅឈ្មោះខ្ញុំក៏បានដែរពេលនេះផុតម៉ោងការងារហើយ» គេប្រាប់ទាំងញញឹមទើបនាងញញឹមតបមុននឹងនាំគ្នាដើរចេញទៅ។

រូបភាពពួកគេទាំងពីរ ឈរនិយាយគ្នាសើចសប្បាយមុននេះធ្វើឲ្យអ្នកដែលទើបដើរចេញពីជណ្ដើរយន្តសម្លឹងមកដោយកំហឹង។

អែលវិន ទើបចេញពីជណ្ដើរយន្តកំពុងតែខឹងស្រាប់បន្ទាប់ពីមនុស្ស





របស់គេរាយការណ៍ ពីម៉ាក់គេជួបជាមួយប្អូនប្រុសនាងថែមទាំងឲ្យលុយមួយចំនួនទៀត ហើយពេលចេញមកជួបរូបភាពទាំងនេះទៀតធ្វើឲ្យគេកាន់តែក្ដៅ ហេតុអីក៏គេត្រូវខឹងពេលដែលនាងទៅជាមួយប្រុសផ្សេងទៅវិញ មែនហើយនាងជាស្រីមុខលុយហ៊ានធ្វើអ្វីគ្រប់យ៉ាងដើម្បីវា តែនាងត្រូវដឹងខ្ញុំជាម្ចាស់រាងកាយនាងដំបូងគេ ហើយក៏គ្មានអ្នកណាមានសិទ្ធិបន្តទៀតដែរ។

«តាមមើលថាពួកគេទៅកន្លែងណា» គេប្រាប់មនុស្សជំនិតមុននឹងឈានជើងដើរចេញទៅ ជេក និង ជីម សម្លឹងមុខគ្នាបន្តិចមុននឹងដើរតាមចៅហ្វាយគេទាំងងឿងឆ្ងល់តែក៏ធ្វើតាមបញ្ជា។

យូជុន នាំនាងមកញ៉ាំបាយនៅហាងមួយនៅមិនឆ្ងាយពីផ្ទះនាងប៉ុន្មាននោះទេហើយក៏បើកឡានជូននាងទៅផ្ទះ កម្មភាពរបស់ពួកគេមិនផុតពីក្រសែភ្នែករបស់ អែលវិន នោះទេគេតាមឃ្លាំមើលនាងរហូតហើយក៏កាន់តែបង្កើនកំហឹងលើសដើម។

«អរគុណ សម្រាប់អាហារល្ងាចនេះ» ស៊ូហ៊ី និយាយពេលចេញមកឈរនៅមុខផ្ទះរួមទាំង យូជុន ដូចគ្នា។

«គួរតែខ្ញុំទេជាអ្នកត្រូវអរគុណ» គេតបទាំងញញឹមស្រទន់ ស៊ូហ៊ី ញញឹមតបតិចៗ ទោះដឹងពីគោលបំណងអ្នកម្ខាងទៀតមិនច្បាស់តែមើលទៅគេក៏ជាមនុស្សល្អដែរ នាងគិតក្នុងចិត្ត។

«ឆាប់ចូលក្នុងទៅខ្ញុំត្រឡប់ទៅវិញហើយ»

«ចាស អញ្ជើញធ្វើដំណើរដោយសុវត្ថិភាព» នាងប្រាប់ទាំងឈរមើលគេបើកឡានចេញទៅរាងឆ្ងាយបន្តិច ទើបបែខ្លួនបំរុងចូលក្នុងផ្ទះ



Scanned by CamScanner

ស្របពេលមានរថយន្តមួយគ្រឿងទៀតបើកមកឈប់ជិត ទើបងាកមកមើលហើយក៏ធ្វើឲ្យនាងភ្ញាក់ផ្អើលពេលឃើញអ្នកណាចុះមក។

«ប្រហែលជាសប្បាយខ្លាំងណាស់ហើយ ពេលទាក់បានគោលដៅថ្មី» អែលវិន និយាយសំឡេងស្មើរសម្លឹងមុខនាងមិនដាក់ភ្នែក នាងក្រមុំឈរស្ងៀមជ្រួញចិញ្ចើមសម្លឹងមុខអ្នកម្ខាងទៀត គេនៅតាមមករករឿងស៊ីទៀតហើយ នាងគិតទាំងអោរចិត្ត។

«ប្រហែលមិនទាក់ទងនិងលោកទេ» នាងតបបែបហី តែធ្វើឲ្យអ្នកស្តាប់ក្តៅដេរតែព្យាយាមរម្ងាប់អារម្មណ៍។

«ច្បាស់ហើយថាមិនទាក់ទង?» គេសួរទាំងញញឹមចុងមាត់ឈានជើងដើរមកជិតនាងកាន់តែកៀក នាងក្រមុំថយក្រោយដោយស្វ័យប្រវត្តិព្រោះមិនដឹងគេចង់ធ្វើអី តែក៏ត្រូវដៃរឹងមាំស្រវ៉ាឱបចង្កេះទាញមកអឹបដើមទ្រូងរឹងមាំជាប់។

«នែ! លោកចង់ធ្វើអី ឆាប់លែងទៅ» នាងក្រមុំប្រាប់ទាំងប្រឹងរើបម្រះតែមិនរួចនោះទេព្រោះដៃគេមាំខ្លាំងណាស់។

«និយាយម្តងទៀតទៅថាមិនទាក់ទងនិងខ្ញុំ» គេប្រាប់ទាំងឱនមុខមករកនាងដោយការដាក់សំពាធ។

«ខ្ញុំមិនត្រូវជាអ្វីនិងលោកទេ ហេតុអីក៏ត្រូវទាក់ទងគ្នា» នាងប្រាប់សំឡេងតូចចិត្តទាំងងាកមុខគេចពីផ្ទៃមុខរបស់គេ កំលោះឈប់ទ្រឹងមែនហើយនាងនិងគេមិនត្រូវជាអ្វីនិងគ្នាទេ ដូច្នេះនាងចង់ធ្វើអីជារឿងរបស់នាងកំលោះគិតក្នុងចិត្តតែពេលបានកៀកស្និទ្ធនិងនាងបែបនេះ ក្លិនក្រអូបរបស់នាងធ្វើឲ្យគេនឹកឃើញកាលពីយប់នៅខុនដូរ នាងពិតជាធ្វើឲ្យគេ





មានអារម្មណ៍ពុះកញ្ជ្រោលខ្លាំងណាស់ គិតហើយរាងកាយគេក៏ចាប់ផ្តើមក្តៅទ្រាំលែងបានហើយ គេតបក្នុងចិត្តស្រវ៉ាលើកនាងបីចូលឡានឲ្យមនុស្សរបស់គេបើកសំដៅខុនដូរយ៉ាងលឿន។

«នែ លោកចង់នាំខ្ញុំទៅណា ឆាប់ឈប់ឡានភ្លាមទៅ»

«ទៅរំឭកមេរៀនចាស់ នាងប្រហែលជាភ្លេចហើយ» គេប្រាប់ទាំងសម្លឹងមុខនាងដោយខ្សែរភ្នែកស្រេកឃ្លាន នាងក្រមុំចង់ស្រែកខ្លាំងណាស់ ហើយក៏ចង់រត់ចេញពីឡាននេះដូចគ្នា។

«ឆាប់ដោះលែងខ្ញុំទៅ» នាងអង្វរគេបណ្តើរប្រឹងរើបម្រះបណ្តើរពេលគេអូសនាងចេញពីជណ្តើរយន្តសំដៅបន្ទប់របស់គេ។

«ខ្ញុំនឹងដោះលែងនាងពេលខ្ញុំបានអ្វីដែលត្រូវការរួច» គេប្រាប់សំឡេងស្មើរបស់ត្រូវការមែនទេ? នាងគ្មានអ្វីនោះទេ នាងតបក្នុងចិត្តក្រោយមកក៏ងាកទៅមើលគេម្តងទៀតស្របពេលគេងាកមកដូចគ្នា។

«អត់ទេ ខ្ញុំមិនត្រូវការបែបនេះទេ» នាងប្រាប់ទាំងរើបម្រះម្តងទៀត គេទ្រាំមិនបានទើបលើកនាងលីរហូតដល់បន្ទប់សម្រាក ហើយបោះនាងទៅលើគ្រែ។

«ក្រែងនាងត្រូវការប្រាក់មិនមែន ខ្ញុំនិងឲ្យនាង» គេប្រាប់សំឡេងតាមជើងធ្មេញដៃចាត់ការឡេវអាវបណ្តើរ នាងក្រមុំចាប់ផ្តើមលេបទឹកមាត់ទាំងស្អិតករ។

«ខ្ញុំមិនត្រូវការវាទៀតទេ ខ្ញុំចង់ត្រឡប់ទៅវិញ» នាងស្រែកប្រាប់ទាំងស្រវ៉ាចុះពីគ្រែតែក៏ត្រូវគេតាមក្រសោបមកវិញ សង្កត់នាងលើពូកជាប់ទាំងតាមទៅទ្រោមពីលើ។



Scanned by CamScanner

...ហួសពេលហើយ» កំលោះប្រាប់រួចក៏ឱនទៅបិទបបូរមាត់ស្តើងជាថ្មីយ៉ាងញញួយកតែចិត្តខ្លួនឯង នាងក្រមុំលើកដៃគក់ស្មារឲ្យគេដោះលែងនាងតែប្រហែលមិនអាចនោះទេ។

«សូមអង្គដោះលែងខ្ញុំទៅ» នាងនិយាយសំឡេងស្អកលាយទឹកភ្នែកពេលគេដកបបូរមាត់ចេញ ដៃក៏ប្រឹងរុញរាងក្រាស់តែមិនបានសម្រេចនោះទេ ហើយក៏ត្រូវគេចាប់សង្កត់លើក្បាលជាប់។

បបូរមាត់នៅតែអូសកាត់ស្បែកករសខ្ចីដោយភាពពេញចិត្ត អាវស្តើងត្រូវទាញឲ្យដាច់រហែកគ្មានប្រណី នាងក្រមុំបានត្រឹមគេងបង្ហូរទឹកភ្នែកព្រោះគ្មានកំលាំងរើតទៀត។

«នាងត្រូវការប៉ុន្មានប្រាប់មកខ្ញុំនិងឲ្យ» កំលោះងើបប្រាប់សំឡេងតាមដើងធ្មេញព្រោះមិនដូចអ្វីដែលគេគិត ក្នុងខ្លួនគេកំពុងតែក្តៅតែនាងបែរបដិសេធធ្វើឲ្យគេស្ទើរឆ្កួតទៅហើយ។

«ពីមុនខ្ញុំត្រូវការមែន តែពេលនេះលែងត្រូវការវាទៀតហើយ» នាងប្រាប់ទាំងល្ងើយដាកខ្លួនចេញទាំងមុខក្រហម ព្រោះរាងកាយល្វែងលើគ្មានអ្វីបិទបាំងនោះទេ។

«តែពេលនេះខ្ញុំត្រូវការនាង កុំសង្ឃឹមថាខ្ញុំដោះលែងនាងងាយៗនោះ» គេប្រាប់សំឡេងស្ទើរទាញនាងឲ្យបែរមក មុននឹងឱនទៅបិទបបូរមាត់ស្តើងម្តងទៀត ដៃក៏ចាត់ការច្របាច់ដើមទ្រូងណែនក្បំទាំងគូរមុននឹងឱនបបូរមាត់មករកអណ្តាតដ៏ប៉ិនប្រសព្វ លិឍជញ្ជក់ដោយភាពស្រេកឃ្លាន នាងក្រមុំដែលគ្មានកំលាំងតបត បានត្រឹមលើកដៃឱបកគេជាប់ព្រោះតែអារម្មណ៍ស្រៀវស្រើបនាងព្យាយាមទប់សំឡេងថ្ងូររបស់ខ្លួន មិន





ចង់ឲ្យឮតែក៏ត្រូវស្រែកចេញមកព្រោះតែអណ្តាតរបស់គេ ឃើញនារីក្នុងរង្វង់ដៃទោទន់តាមខ្លួនទើបក្រោកមកចាត់ការខោអាវលើខ្លួនរហូតអស់ រួមទាំងសំពត់ខ្លីនិងខោតូចរបស់នាង កំលោះញញឹមពេញចិត្តពេលនាងស្របតាមមិនជំទាស់ទៀត ទើបឱនទៅរកចុងកំពូលស្រួចម្តងទៀតមុននឹងអូសកាត់ពោះរាបស្មើរមកដល់តំបន់អាថ៌កំបាំងរបស់នាង តែសំរាប់គេរាងកាយនាងគ្មានកន្លែងណាដែលគេមិនធ្លាប់ប៉ះនោះទេ មិនចាំយូរបបូរមាត់ដ៏រស់រវើកក៏ឱនទៅចាត់ការទួលសាច់ដែលជាចំនុចស្រៀវស្រើបបំផុតដោយភាពពេញចិត្ត ជាលើកទីមួយដែលគេធ្វើបែបនេះចំពោះមនុស្សស្រីគេមិនធ្លាប់ធ្វើបែបនេះចំពោះស្រីណានោះទេ តែសំរាប់នាងគេចង់ធ្វើបែបនេះជាអារម្មណ៍ពុះកញ្ជ្រោលដែលមិនធ្លាប់មានពីមុនមក។

«អ្ហា...បានហើយ...អ្ហា...» នាងស្រែករមួលខ្លួនស្ទើរដាច់ខ្យល់ព្រោះអណ្តាតដ៏ជំនាញរបស់គេ ព្យាយាមរើគេចតែក៏ត្រូវគេចាប់ត្រគាកជាប់។

«ឈប់មិនទាន់បានទេ» គេងើបតបតបបែបហើថែមទាំងញញឹចំអកនាងថែមទៀតមុននឹងឱនមុខជាលើកទីពីរ ដៃស្រទបទាំងពីរខ្ទាំពូករំសាយភាពស្រៀវស្រើបព្រោះបបូរមាត់គេ ហើយក៏ព្យាយាមទប់សំឡេងរបស់ខ្លួនមិនឲ្យឮខ្លាំងជាងនេះដែរ កំលោះនៅធ្វើបាបនាងដោយបបូរមាត់រហូតអស់ចិត្តទើបងើបមកឃើញអ្នកម្ខាងទៀតបិទភ្នែក ដោយភាពអស់កំលាំងគេញញឹមចុងមាត់ មុននឹងឱនទៅរកបបូរមាត់ស្តើងបឺតជញ្ជក់ឆ្អែតទើបដកបបូរមាត់ចេញ រាងកាយស្តើងត្រូវទាញក្រឡាស់តែបន្តិចក៏ត្រូវមកនៅពីលើរាងកាយក្រាស់ ធ្វើឲ្យនាងក្រមុំបើកភ្នែកសម្លឹងមុខអ្នកម្ខាងទៀតដោយភាពងឿងឆ្ងល់លាយខ្មាស។

«ដល់វេននាងម្តងហើយ» គេប្រាប់ទាំងញញឹមមានល្បិចធ្វើឲ្យអ្នកម្ខាងទៀតបើកភ្នែកធំៗថែមទាំងគ្រវីក្បាល។

«ខ្ញុំមិនចេះទេ» នាងប្រាប់ទាំងរើចុះពីខ្លួនគេតែក៏ត្រូវទាញមកអង្គុយដូចដើមថែមទាំងទាញនាងមកថើបមាត់ជាប់។

«ចាំខ្ញុំបង្រៀន» គេប្រាប់ពេលដកបបូរមាត់ចេញ ចាប់លើត្រគៀកតូចឡើងហើយក៏ដាក់ចុះវិញ នាងក្រមុំថ្ងូរសំឡេងថ្នមរហូតដំបងសាច់គេលូនចូលកប់ក្នុងល្អាងនាងបាត់ កំលោះញញឹមដោយភាពពេញចិត្តចាប់យោគត្រគៀកតូចទៅមកបង្កើតជាសំឡេងថ្ងូររបស់នាងម្តងទៀត សូម្បីតែគេក៏ថ្ងូរដូចគ្នាព្រោះតែស្រៀវស្រើប នាងក្រមុំដឹងតួនាទីរបស់ខ្លួនដោយមិនចាំបាច់គេបង្រៀនតទៀត។

«អ្ហា ញាប់ជាងហ្នឹងទៀត ស៊ូហ៊ី» កំលោះស្រែកប្រាប់ទាំងសំឡេងស្អក ហើយក៏ជួយយោគខ្លួននាងបន្ថែមទៀត ទើបនាងធ្វើតាមសម្តីគេ សំឡេងដកដង្ហើមដង្ហក់ ស្រមនឹងសំឡេងស្រែកថ្ងូរត្រេដមត្រសងប្រណាំងគ្នា លាន់ឮពេញបន្ទប់រហូតដល់ត្រើយនៃសេចក្តីសុខ។

អែលវិន សម្លឹងនារីទ្រោមលើទ្រូងគេ រាងកាយនាងជោកទៅដោយញើស ព្រោះតែឆ្លងកាត់សង្គ្រាមស្នេហ៍មុននេះ ស្បែកកាយនាងពិតជាក្រអូបទាក់ទាញខ្លាំងណាស់ គិតហើយក៏លើកដៃអង្អែលផែនខ្នងសរលោងនោះស្បែកនាងពិតជារលោងគ្មានត្រើមអីបន្តិច គេអង្អែលទៅមករហូតដល់ត្រគៀកមូលក្លំ គ្រាន់តែប៉ុណ្ណឹងក៏ធ្វើឲ្យគេចាប់ផ្តើមមានអារម្មណ៍ទៀតហើយ ឆ្កួតមែនគេមិនដែលមានអារម្មណ៍ចង់បានមនុស្សស្រីច្រើនដងដូចជានាងនោះទេ ស្រីដែលឡើងគ្រែជាមួយគេតែម្តងគ្រប់គ្រាន់ហើយ





ហើយក៏គ្មានលើកក្រោយទៀតដែរ តែចំពោះនាងបែរជាធ្វើឲ្យគេត្រូវការមិនឈប់បែបនេះ កំលោះសម្លឹងមើលរាងកាយស្តើងម្តងទៀតមុននិងលើកនាងឲ្យគេងរាបលើពូកដោយមានរាងកាយគេតាមទ្រោមពីលើ។

«នាងត្រូវតែទទួលខុសត្រូវ ព្រោះតែនាងទើបខ្ញុំក្លាយជាបែបនេះ» កំលោះប្រាប់អ្នកដែលកំពុងបិទភ្នែកលង់លក់ព្រោះតែអស់កំលាំង សម្លឹងមើលរាងកាយទទេស្អាតរបស់នាងម្តងទៀត មកឈប់ត្រឹមដើមទ្រូងតឹងណែន មុននឹងឱនមុខទៅគ្រប់គ្រងចុងកំពូលស្រួចធ្វើឲ្យអ្នកដែលទើបបិទភ្នែកមុននេះត្រូវបើកមកវិញព្រោះតែមានអារម្មណ៍ស្រៀវ។

«ខ្ញុំគ្មានកំលាំងទេ» ក្រមុំប្រាប់សំឡេងស្រាលលើកដៃដែលគ្មានកំលាំងរុញស្មារគេចេញទាំងល្ហើយ កំលោះមិនខ្វីតបគេចាប់ដៃនាងទាំងពីរសង្កត់លើពូក បបូរមាត់នៅតែថើបជញ្ជាក់មិនឈប់ ធ្វើឲ្យអ្នកម្ខាងទៀតចាប់ផ្តើមស្រែកថ្ងូរតិចៗម្តងទៀត។

«ខ្ញុំមិនខ្វល់ ខ្ញុំនិងគិតលុយថែមពីលើចំនួនដែលយើងគេងជាមួយគ្នា» កំលោះងើបមកប្រាប់សំឡេងស្អកហើយក៏ឱនមុខទៅវិញ ដោយមិនបានចាប់អារម្មណ៍ពីអ្នកម្ខាងទៀត គេងបង្ហូរទឹកភ្នែកនោះទេ បន្ទាប់ពីឮពាក្យសម្តីរបស់គេប្រៀបដូចម្ជុលដ៏មុតស្រួចចាក់ទំលុះបេះដូងនាង ក្នុងភ្នែកគេនាងត្រឹមតែជាមនុស្សស្រី ដែលត្រូវការលុយដោយយកខ្លួនទៅប្តូរតើមែនទេ ជីវិតនាងបោះត្រាស្នាមនេះជាប់រហូតហើយមែនទេ នាងមិនចង់បានបែបនេះទេ នាងគិតទាំងតូចចិត្ត បានត្រឹមគេងបង្ហូរទឹកភ្នែកបណ្តោយទៅតាមអ្វីដែលគេត្រូវការតែប៉ុណ្ណោះ។



Scanned by CamScanner







...៥...

ក្នុងបន្ទប់ដែលមានសភាពងងឹត តែអាចមើលឃើញផ្ទៃទាំងមូលបានបើសម្លឹងឲ្យយូរបន្តិច នាងក្រមុំដែលគេងនៅលើគ្រែចាប់ផ្តើមដឹងខ្លួនបើកភ្នែកដោយភាពខ្សោះល្វើយសម្លឹងជុំវិញបន្ទប់មកឈប់ត្រឹម អ្នកដែលគេងក្បែរមើលមុខគេធ្វើឲ្យទឹកភ្នែកនាងចាប់ផ្តើមហូរមកម្តងទៀត នាងជូតទឹកភ្នែកចេញប្រឹងក្រោកសន្សឹមៗចុះពីគ្រែ ដើម្បីរៀបចំខ្លួនត្រឡប់ទៅវិញ ដើរបានបន្តិចក៏ក្រឡេកប៉ះក្រដាសសែកនៅលើតុ នេះជាលុយថ្លៃខ្លួននាងមែនទេ នាងសួរខ្លួនឯងតិចៗសន្សឹមៗទាញវាមកមើល ចំនួនទឹកលុយច្រើនតែវាមិនអាចធ្វើឲ្យនាងសប្បាយចិត្តនោះទេ ព្រោះវាមិនមែនជាតម្រូវការរបស់នាង នាងក្រមុំដាក់វាទៅលើតុវិញសំដៅបន្ទប់ទឹកចាត់ការធុរៈផ្ទាល់ខ្លួន។

ស៊ូហ៊ី ចុះមកដល់ជាន់ក្រោមទាំងល្វើយពេលនេះជិតភ្លឺទៅហើយ នាងដើរតិចៗសំដៅមុខអគារដើម្បីហៅតាក់ស៊ីជិះ តែគ្មានសូម្បីតែមួយ។

«អ្នកនាងចាំខ្ញុំជូនទៅ» សំឡេងអ្នកណាម្នាក់បន្លឺឡើងធ្វើឲ្យអ្នកដែលកំពុងឈរស្លុងអារម្មណ៍នោះភ្ញាក់ព្រើតងាកមកមើល ហើយក៏ធូរទ្រូងពេលដឹងថាគេជាមនុស្សរបស់ អែលវិន។

«ខ្ញុំអាចជិះតាក់ស៊ីបានហើយ អរគុណ» នាងក្រមុំតបទាំងញញឹមតិចៗហើយក៏ងាកមកផ្លូវម្តងទៀត។

«ចាំខ្ញុំជូនទៅល្អជាងព្រោះខ្លាចមានរឿងដូចលើកមុនទៀត» ជេកប្រាប់ម្តងទៀតធ្វើឲ្យនាងចាប់ផ្តើមរិះគិតហើយក៏ងក់ក្បាលយល់ព្រម គេជូននាងមកដល់ផ្ទះមើលរហូតនាងចូលក្នុងបាត់ទើបត្រឡប់ទៅវិញ។

កំលោះដែលគេងលើគ្រែចាប់ផ្តើមកម្រើកខ្លួន តែមិនទាន់បើកភ្នែក គេវាសដៃគិតថាឱបអ្នកគេងក្បែរ តែបែរជាជួបភាពទទេស្អាត ទើបបើកភ្នែកមកមើលទាំងម៉ូម៉ៅព្រោះនាងតែងតែក្រោកចោលគេរហូត គេលៀសភ្នែកជុំវិញបន្ទប់មិនឃើញដឹងថានាងត្រឡប់ទៅវិញហើយ ទើបក្រោកចុះពីគ្រែហើយក៏ទាក់ភ្នែកនិងសែកនៅលើតុ ដែលគេសសេរទុកឲ្យ។

«ចិត្តខ្លាំងមែន ឲ្យលុយហើយមិនយកចង់បម្រើហ្វ្រីមែនទេ?» គេនិយាយតិចៗហើយក៏សំដៅបន្ទប់ទឹករៀបចំខ្លួន។

ថ្ងៃនេះ ស៊ូហ៊ី ដាក់ច្បាប់មិនបានមកធ្វើការនោះទេ ធ្វើឲ្យអគ្គនាយកមានអារម្មណ៍មិនសូវល្អដែលមិនបានឃើញមុខនាង ទោះបីជាគេងឱបពេញមួយយប់ហើយក៏ដោយ។

ស៊ូហ៊ី កំពុងសម្រាកក្នុងបន្ទប់ព្រោះអស់កំលាំងនាងមិនបានគេងពេញមួយយប់ទៅហើយព្រោះតែបុរសម្នាក់នោះ ហើយមកដល់កាលពីព្រឹកក៏ត្រូវ ហេជីន សួរទើបកុហកថាគេងផ្ទះមិត្តភក្តិព្រោះមិនចង់ឲ្យនាងបារម្ភ ដូចជានឹកឃើញអ្វីមួយទើបក្រោកចេញមកក្រៅ។

«ដូយ៉ុង ឈប់សិន» ឮសំឡេងស្រែកប្រាប់ទើបធ្វើឲ្យអ្នកដែលដើរដល់មាត់ទ្វារងាកមកមើល។

«បងស្រីមិនទៅធ្វើការទេហ៎» ដូយ៉ុង សួរទាំងដើរមកអង្គុយជិត។

«បងមិនសូវស្រួលខ្លួនទេ»

«បើចឹងបងសម្រាកទៅ ខ្ញុំទៅសាលាសិនហើយ» គេប្រាប់ទាំងក្រោកឈរតែក៏ត្រូវនាងឃាត់ឲ្យឈប់។

«នេះជាថ្លៃបង់សាលា»





នាងប្រាប់ទាំងយកស្រោមសំបុត្រមួយចេញមកហុចឲ្យគេ ដូយ៉ុងមើលស្រោមសំបុត្រដែលនៅក្នុងដៃនាង។

«ខ្ញុំមានហើយបងទុកវិញទៅ» គេប្រាប់ទាំងរុញមកវិញធ្វើឲ្យអ្នកស្តាប់ជ្រួញចិញ្ចើមបែបរិះគិត។

«ឯងបានលុយមកពីណា?» នាងសួរសំឡេងរឹងសម្លឹងមុខប្អូនប្រុសមិនដាក់ នាងដឹងថាគេធ្វើការតែប្រាក់ខែក៏នៅមិនគ្រប់អាចបង់ថ្លៃសាលានោះដែរទើបចាប់ផ្តើមសង្ស័យខ្លាចគេទៅធ្វើអីផ្តេសផ្តាស ដូយ៉ុងរាងទាក់ទើរបន្តិច គេហូតស្រោមសំបុត្រមួយពីកាបូបចេញមក។

«អ៊ំស្រីមិត្តចាស់ម៉ាក់គាត់ឲ្យមក»

គេប្រាប់សំឡេងស្រាលឱនមុខចុះ ស៊ូហ៊ី សម្លឹងស្រោមសំបុត្រក្នុងដៃប្អូនប្រុស។

«ហេតុអីក៏ទទួលរបស់នេះ បងធ្លាប់ប្រាប់ហើយមែនទេ?»

«គាត់ថាគ្រាន់តែជួយយើងពេលក្នុងនាមជាមិត្តម៉ាក់តែប៉ុណ្ណោះ»

«បងដឹងថាគាត់ជាមនុស្សល្អ តែបងមិនចង់ឲ្យឯងទទួលរបស់នេះទេ ព្រោះជាញើសឈាមដែលគេរកបានយើងមិនគួរយកមកដោយភាពរីករាយនោះទេ» នាងប្រាប់ទាំងយំតិចៗ។

«ខ្ញុំយល់ហើយ បងស្រីចាំខ្ញុំយក់ទៅឲ្យគាត់វិញ»

«មិនអីទេ ចាំបងយកទៅ ឯងទៅសាលាទៅ»

នាងប្រាប់ហើយក៏ដើរចូលបន្ទប់ សម្លឹងមើលក្រដាសសែកនោះ នាងមិនមែនស្អប់គាត់នោះទេគ្រាន់តែមិនចង់ទទួលជំនួយពីគាត់ មិនចង់ឲ្យកូនប្រុសគាត់មើលងាយគ្រួសារនាងតែប៉ុណ្ណោះ។



Scanned by CamScanner

ក្នុងហាងការហ្វេមួយនៅមិនឆ្ងាយប៉ុន្មានពីផ្ទះនាងនោះទេ ស៊ូហ៊ី បានណាត់ជាមួយអ្នកស្រី សុងហ៊ី ដើម្បីប្រគល់លុយឲ្យគាត់វិញ។

«ស៊ូហ៊ី មានរឿងអីមែនទេ?» សំឡេងស្ត្រីចំណាស់បន្លឺឡើងគ្រាន់តែឮថានាងចង់ជួប គាត់គិតថានាងប្រហែលមានបញ្ហាអីហើយទើបប្រញាប់មកយ៉ាងលឿនបែបនេះ។

«គ្មានអីទេ អ៊ំស្រី ខ្ញុំគ្រាន់តែចង់ប្រគល់របស់នេះជូនអ៊ំវិញតែប៉ុណ្ណោះ» នាងប្រាប់សំឡេងស្រាលយកស្រោមសំបុត្រមួយមកដាក់លើតុ ស្ត្រីចំណាស់សម្លឹងមើលទាំងដកដង្ហើមធំ។

«ហេតុអីមិនទទួលទុកទៅ?» គាត់សួរតិចៗសម្លឹងមុខនាងចាំស្តាប់គាត់នៅតែមិនយល់ហេតុអីនាងមិនព្រមទទួលជំនួយពីគាត់។

«ខ្ញុំអាចដោះស្រាយខ្លួនឯងបានអ៊ំកុំបារម្ភអី» នាងប្រាប់ទាំងញញឹមតិចៗ។

«ខ្ញុំដឹង ខ្ញុំគ្រាន់តែចង់ជួយឯងបន្ថែមទៀតតែប៉ុណ្ណោះ» គាត់ប្រាប់ទាំងសំឡេងខកបំណងធ្វើឲ្យនាងមានអារម្មណ៍អាណិត។

«ខ្ញុំអរគុណចំពោះអ៊ំដែលតែងយកចិត្តទុកដាក់ពួកខ្ញុំ តែយ៉ាងណាខ្ញុំនៅតែមិនហ៊ានទទួលរបស់នេះដែរអ៊ំយកទុកវិញទៅ បើសិនខ្ញុំត្រូវការខ្ញុំនិងសុំជំនួយពីអ៊ំណា» ស៊ូហ៊ី ព្យាយាមនិយាយលួងព្រោះមិនចង់ឲ្យគាត់ពិបាកចិត្តព្រោះតែភាពរឹងរូសរបស់នាង។

«មិនអីទេ បើឯងមានបញ្ហាអីត្រូវប្រាប់ខ្ញុំឮទេ»

«ចាសអ៊ំស្រី» នាងតបទាំងញញឹមពេលឃើញគាត់យល់ពីរឿងនេះ

«ម៉ាក់ហេតុអីក៏មកទីនេះ?»







សំឡេងអ្នកទីបីបន្លឺឡើង ទើបធ្វើឲ្យនារីខុសវ័យទាំងពីរងាកទៅមើល អែលវិន ត្រូវមកជួបភ្ញៀវនៅទីនេះថៃដន្យក៏បានឃើញអ្នកទាំងពីរគេឈរមើលមួយសន្ទុះហើយ ឃើញសកម្មភាពទាំងអស់ដូចគ្នាគេគិតថា ស៊ូហ៊ី មិនយកសែកដែលគេទុកឲ្យ ព្រោះមកជួបម៉ាក់គេក្នុងគោលបំណងផ្សេងបែបនេះ ថែមទាំងឃើញស្រោមសំបុត្រលើតុថែមទៀត មិនបាច់ប្រាប់ក៏ដឹងថាជាអ្វីនោះដែរ ទាំងបងទាំងប្អូនមកតាមទាមម៉ាក់គេបែបនេះមែនទេ គេក្តាប់ដៃណែនដោយកំហឹង ប្រហែលគេគួរតែចាត់ការរឿងនេះឲ្យងាយស្រួលល្អជាង កំលោះគិតក្នុងចិត្តសម្លឹងមុខនាងដោយខ្សែភ្នែកមុត។

«ម៉ាក់មកជួប ស៊ូហ៊ី ចុះកូនមកទីនេះធ្វើអីដែរ?» ស្ត្រីចំណាស់សួរកូនប្រុសទាំងញញឹម ពេលឃើញគេសម្លឹងមើលនារីដែលអង្គុយជាមួយគាត់មិនដាក់ភ្នែក នាងក្រមុំមិនហ៊ានសម្លឹងមើលមុខគេនោះទេទើបឱនមុខចុះរហូត។

«ខ្ញុំមកជួបភ្ញៀវ បើចឹងមិនរំខានម៉ាក់ទេខ្ញុំទៅសិនហើយ» កំលោះងាកមកនិយាយជាមួយម្តាយទាំងញញឹម ហើយក៏ឆ្លៀតងាកទៅមើលអ្នកម្ខាងទៀតមុននឹងដើរចេញទៅ។

«ស៊ូហ៊ី មិនអីទេមែនទេ កូនប្រុសខ្ញុំកាចយកតែចិត្តខ្លួនឯងបន្តិចហើយតែគេក៏ជាមនុស្សល្អដែរ» ស្ត្រីចំណាស់ប្រាប់ទាំងស្នាមញញឹមសម្លឹងមើលនាងមិនដាក់ភ្នែក គេជាមនុស្សកំណាចខ្លាំងណាស់នាងតបក្នុងចិត្តនឹកឃើញរឿងកាលពីយប់ ធ្វើឲ្យនាងមានអារម្មណ៍ឈឺចិត្តមិនទាន់បាត់នោះទេ តែព្យាយាមញញឹមតិចៗដាក់ស្ត្រីចំណាស់។

ស៊ូហ៊ី នៅដើរលេងតាមសួនច្បាររហូតដល់រសៀលទើបត្រឡប់មក

វិញ នាងដើរមកដល់មុខផ្ទះស្របពេលមានរថយន្តពណ៌ខ្មៅមួយគ្រឿងបើកមកឈប់ជិតទើបងាកទៅមើល រូបរាងបុរសម្នាក់ចុះពីរថយន្តនាងសម្លឹងមើលដោយភាពភ័យខ្លាចទើបប្រញាប់ដើរចូលផ្ទះ តែក៏នៅយឺតជាងរាងកាយគេដើរតែមួយជំហ៊ានក៏មកដល់ជិតនាងទៅហើយ ថែមទាំងទាញនាងទៅបុកដើមទ្រូងរបស់គេថែមទៀត។

«លែងខ្ញុំទៅ» ក្រមុំប្រាប់សំឡេងញ័រព្យាយាមបេះដៃដែលឱបចង្កេះជាប់នោះតែមិនរបូតនោះទេព្រោះកំលាំងដៃគេរឹតខ្លាំងណាស់។

«ពួកយើងមានរឿងត្រូវនិយាយគ្នា» អែលវិន ប្រាប់សំឡេងស្មើរសោយដៃពីចង្កេះរុញនាងចូលឡានយ៉ាងលឿន ដោយមានគេចូលតាមក្រោយទើបនាងមិនអាចរើបម្រះបានមានតែស្របតាម។

«លោកចង់នាំខ្ញុំទៅណា?» ស៊ូហ៊ី សួរអ្នកដែលអង្គុយក្បែរគេនៅស្ងៀមងាកមកសម្លឹងមុខនាងដោយទឹកមុខស្មើកែវភ្នែកគេគួរឲ្យខ្លាចខ្លាំងណាស់តាំងពីជួបនៅក្នុងហាងជាមួយម៉ាក់គេតាំងពីព្រឹក នាងមិនដឹងថាគេខឹងនាងរឿងអីនោះទេ ឬជារឿងដែលនាងមិនព្រមយកសែកនៅលើតុដែលគេទុកឲ្យនោះតែមិនគួរនោះទេ នាងគិតក្នុងចិត្តទាំងខ្វល់ខ្វាយស្របពេលរថយន្តរបស់គេមកឈប់ខាងមុខផ្ទះថ្មមួយនៅម្តុំជាយក្រុង នាងក្រមុំចាប់ផ្តើមដកដង្ហើមញាប់ គេគិតចង់ទុកនាងជាស្ត្រីបម្រើរបស់គេដាច់ថ្លៃយ៉ាងម៉េច នាងសួរខ្លួនឯងហើយក៏គ្មានចម្លើយសម្រាប់ខ្លួនឯងដូចគ្នា។

«ចុះទៅ» គេប្រាប់សំឡេងស្មើរចុះទៅមុនទើបនាងចុះតាមក្រោយមិនហ៊ានជំទាស់នោះទេ កំលោះដើរសំដៅខាងក្នុងដោយមិនរង់ចាំ នាងបានត្រឹមឈរសម្លឹងមើលខ្នងគេ មិនយល់ពីទង្វើរបស់គេ រហូតឮសំឡេង





មនុស្សរបស់គេបន្លឺឡើង។

«អ្នកនាងអញ្ជើញ» ជេក ប្រាប់ទាំងលាដៃឲ្យនាងដើរទៅមុខទើបនាងត្រូវដើរតាមទៅតាមទាំងទើសទាល់។

ស៊ូហ៊ី សម្លឹងមើលជុំវិញផ្ទះដែលតុបតែងស្អាតមើលទៅគួរឲ្យចង់រស់នៅប្រហែលជាផ្ទះរបស់គេហើយ គិតហើយក៏ដើរទៅក្នុងបន្តឃើញគេកំពុងអង្គុយលើសាឡុងបន្ទប់ទទួលភ្ញៀវ សម្លឹងមកដោយទឹកមុខស្មានមិនត្រូវទើបដើរទៅអង្គុយសាឡុងទល់មុខ។

«នាងត្រូវការប្រាក់ប៉ុន្មានទើបគ្រប់គ្រាន់?» គេសួរសំឡេងរឹងធ្វើឲ្យអ្នកម្ខាងទៀតងើបមុខមកមើល ទឹកមុខមិនដឹងខ្យល់របស់នាងធ្វើឲ្យគេមានអារម្មណ៍ធុញទ្រាន់ គេគិតថានេះជាការសម្តែងរបស់នាងច្រើនជាងហើយវាក៏កើតឡើងច្រើនដងហើយដែរ។

«ឈប់សម្តែងធ្វើមិនដឹងអីនៅមុខខ្ញុំទៀតទៅ និយាយមកថាត្រូវការប៉ុន្មានទើបគ្រប់គ្រាន់សម្រាប់នាងកុំមកទាក់ទងនិងម៉ាក់ខ្ញុំទៀត» ម្តងនេះគេនិយាយច្បាស់ទើបធ្វើឲ្យអ្នកដែលជ្រួញចិញ្ចើមចាប់ផ្តើមយល់។

«ខ្ញុំធ្លាប់ប្រាប់លោកហើយថាខ្ញុំលែងត្រូវការវាទៀតហើយ» នាងក្រមុំប្រាប់សំឡេងស្មើក្នុងគំនិតគេនាងជាស្រីមុខលុយខ្លាំងណាស់មែនទេហេតុអីក៏ចេះតែសួរនាងពីរឿងនេះ នាងមិនធ្លាប់ចង់បានលុយរបស់គេដោយការដោះដូរអ្វីផ្សេងនោះទេ នាងគិតទាំងតូចចិត្ត កំលោះញញឹមចុងមាត់ជាស្នាមញញឹមគួរឲ្យខ្លាច គេក្តាប់ដៃណែនសម្លឹងនារីចំពោះមុខ។

«នាងពិតជាប៉ិនសម្តែងខ្លាំងណាស់ នៅមុខខ្ញុំប្រាប់ថាមិនត្រូវការលុយតែបែរជានាំគ្នាតាមតោងទាមម៉ាក់របស់ខ្ញុំទៅវិញ»



Scanned by CamScanner

«ខ្ញុំមិនបានគោងទាមគាត់នោះទេ»

«ចុះនាងទៅជួបគាត់ធ្វើអី ទាំងបងទាំងប្អូនសម្តែងឲ្យគាត់អាណិត គោលបំណងគឺចង់បានលុយតែប៉ុណ្ណោះ»

«ខ្ញុំមិនធ្លាប់សម្តែងចង់ឲ្យគាត់អាណិតនោះទេ ហើយក៏មិនធ្លាប់សុំគាត់ឲ្យជួយអ្វីនោះដែរ»

«នាងនៅប្រកែកទៀតមែនទេ ឃើញផ្ទាល់បែបនេះហើយ»

«អ្វីដែលខ្ញុំនិយាយជាការពិតជឿមិនជឿស្រេចតែលោក» នាងនិយាយសំឡេងស្ទើរក្រោកដើរចេញទៅដោយមិនខ្វល់ តែក៏ត្រូវគេក្រោកទៅតាមទាញនាងឲ្យមកប្រឈមនិងគេម្តងទៀត។

«ខ្ញុំសួរនាងថាត្រូវការប៉ុន្មានទើបគ្រប់គ្រាន់?»

«ខ្ញុំប្រាប់ហើយថាខ្ញុំត្រូវការប្រាក់របស់លោកនោះទេ» នាងស្រែកប្រាប់ម្តងទៀតព្រោះទ្រាំមិនបានស្របពេលទឹកភ្នែកហូរមកដូចគ្នា។

«មិនត្រូវការក៏តែខ្ញុំនិងឲ្យនាង ឲ្យថ្លៃដែលនាងកំដរខ្ញុំនោះអី» កំលោះប្រាប់សំឡេងតាមដើងរធ្មេញ កន្ត្រាក់រាងកាយស្តើងមិនអឺបជាប់ខ្លួនមុននឹងខិតទៅបិទបបូរមាត់ស្តើងជាប់ នាងក្រមុំប្រឹងរើបម្រះព្រោះមិនចង់ក្លាយជារបស់ដែលគេយកមកលេងសើចនោះទេ ដៃទាំងពីរប្រឹងគក់ស្មារឲ្យគេដោះលែងតែមិនអាចនោះទេ កំលោះលើកនាងបីសំដៅបន្ទប់គេងយ៉ាងលឿនព្រោះគេគ្មានផ្លូវដោះលែងនាងពេលនេះនោះទេ គេចើបខាំរាងកាយស្តើងដោយការដាក់ទោស ស្បែកដែលសរលោងពេលនេះមានតែស្នាមក្រហមពាសពេញ ព្យាយាមរើបម្រះគេរឹតតែដាក់ទោសនាងខ្លាំងលើសដើមយកតែចិត្តខ្លួនឯង មិនខ្វល់ពីអ្នកម្ខាងទៀតឈឺចាប់យ៉ាងម៉េច





នោះទេ បន្ទាប់ពីដោះលែងអារម្មណ៍ប្រាថ្នា ដែលពុះកញ្ជ្រោលមុនេះ កំលោះក្រោកអង្គុយសម្លឹងអ្នកម្ខាងទៀត ដែលកំពុងគេងបែរខ្នងបង្ហូរទឹកភ្នែក តែគេមិនខ្វល់លូកដៃទៅបើកថតតុជាប់គ្រែ ទាញសៀវភៅសែកចេញមកគេសសេរហើយក៏ហែកវាយកមកដាក់លើតុ។

«នេះជាថ្លៃសម្រាប់យប់នេះ បើត្រូវការបន្ថែមទៀតប្រាប់ខ្ញុំ ហាមទៅរញ៉េរញ៉ៃជាមួយម៉ាក់ខ្ញុំទៀតរួមទាំងប្អូនប្រុសនាងដូចគ្នា បើមិនដូច្នេះទេនាងនិងរស់នៅមិនសុខស្រួលនោះទេ» កំលោះប្រាប់ហើយក៏ក្រោកដើរទៅបន្ទប់ទឹក។

នាងក្រមុំសម្លឹងមើលទ្វារបន្ទប់ទឹកទាំងទឹកភ្នែក មុននឹងក្រោករៀបចំខ្លួនដើម្បីចាកចេញពីទីនេះ នាងសម្លឹងមើលក្រដាសសែកនៅលើតុម្តងទៀតក្នុងចិត្តនាងមិនចង់បានសូម្បីតែបន្តិច តែបើរាងកាយនាងត្រូវគេជាន់ឈ្លីព្រោះតែវាទៅហើយនាងនិងយក។

កំលោះចេញពីបន្ទប់ទឹកមានអារម្មណ៍ស្រស់ស្រាយបន្តិច មុននេះគេពិតជាខឹងខ្លាំងណាស់ តែនឹកឃើញទង្វើរបស់ខ្លួនដែលធ្វើដាក់នាងក៏ធ្វើឲ្យគេមានអារម្មណ៍ខុសតិចតួច គិតថាចេញមកវិញនឹងទន់ភ្លន់ដាក់នាងម្តងទៀតតែបែរជាជួបភាពទទេស្អាត ធ្វើឲ្យគេចាប់ផ្តើមម៉ួម៉ៅ។

ពេលនេះរាងយប់ទៅហើយ ស៊ូហ៊ី ចុះមកដល់ក្រោមមិនឃើញមានមនុស្សជាឱកាសល្អ ទើបសម្រេចចិត្តរត់យ៉ាងលឿនដើម្បីទៅដល់ផ្លូវធំសំណាងពេលនេះនៅមានមនុស្សធ្វើដំណើរនៅឡើយ នាងដើរបណ្តើរងាកមើលក្រោយបណ្តើរខ្លាចគេមកតាម ព្យាយាមហៅតាក់ស៊ីក៏គេមិនឈប់ទើបចេះតែដើរៗ រហូតមានរថយន្តមួយមកឈប់ជិតធ្វើឲ្យនាងចាប់



ផ្អើមភ័យ តែក៏ធូរទ្រូងពេលឃើញថាជាអ្នកណា។

«ស៊ូហ៊ី» យូជុន ចុះពីរថយន្តមកមើលនាងទាំងភ័យព្រួយព្រោះ
នេះស្ងាត់តែបែរជាឃើញនាងដើរតែម្នាក់ឯងទៅវិញ។

«ប្រធានផ្នែក» នាងក្រមុំហៅតិចៗទាំងត្រេកអរ។

«ហេតុអីក៏នៅទីនេះ?» គេសួរទាំងសម្លឹងមើលជុំវិញទាំងឆ្ងល់ ព្រោះមិនដឹងថានាងចេញពីខាងណាមក តែក៏ក្រឡេកឃើញផ្ទះវិឡាមួយនៅជិតនោះធ្វើឲ្យគេចាប់ផ្ដើមរិះគិត មុននឹងងាកមកមើលនាងម្ដងទៀត នាងក្រមុំទាក់ទើរបន្តិចមិនដឹងថាត្រូវប្រាប់យ៉ាងម៉េច។

«ពួកយើងចេញពីទីនេះសិនទៅបានទេ» នាងប្រាប់ទាំងងាកមើលក្រោយដោយភាពភ័យព្រួយ ទើបគេត្រូវធ្វើតាមនាំនាងចូលឡានហើយក៏បើកចេញទៅ។

អែលវិន ឈរសម្លឹងទៅមុខផ្ទះដោយកំហឹង គិតថានាងគ្រាន់តែចុះមកដើរលេងទើបចុះមកតាម តែមនុស្សរបស់គេរាយការណ៍ថានាងចាកចេញទៅជាមួយអ្នកផ្សេងធ្វើឲ្យគេកាន់តែម៉ូម៉ៅ ទើបឡើងទៅលើវិញទាំងអារម្មណ៍មិនស្ងប់។

«ស៊ូហ៊ី មានរឿងអីមែនទេ?» យូជុន សួរពេលដែលបើកឡានចេញមកឆ្ងាយបន្តិច នាងក្រមុំទាក់ទើបន្តិចមុននឹងតប។

«មានមនុស្សនាំខ្ញុំយក ខ្ញុំចង់ទៅវិញគេមិនព្រមទើបលួចរត់ចេញមកបែបនេះ» នាងប្រាប់តិចៗធ្វើឲ្យអ្នកម្ខាងទៀតងាកមកមើលទាំងភ្ញាក់ផ្អើលឈាយឆ្ងល់។





«គេមានធ្វើអីនាងដែរទេ?» គេសួរសំឡេងព្រួយបារម្ភ។

«គ្មាន គ្មានទេលោកកុំបារម្ភអី» ស៊ូហ៊ី ប្រញាប់តបយ៉ាងលឿន ព្រោះខ្លាចគេសង្ស័យថែមទាំងទាញកអាវបិទជិតថែមទៀត។

«មិនអីល្អហើយ ហេតុអីក៏ហ៊ានមកជាមួយគេទីនេះស្ងាត់សឹងអីចុះបើមិនបានជួបខ្ញុំគិតយ៉ាងម៉េច?» គេសួរបែបបន្ទោសលួចមើលមុខនាងម្ដងម្កាលនាងមិនតបគ្រាន់តែញញឹមក្រៀម "បើមិនជួបលោកខ្ញុំប្រហែលជាត្រូវគេចាប់ទៅវិញតែប៉ុណ្ណឹង" នាងតបក្នុងចិត្តទាំងដកដង្ហើមធំផ្អែកខ្លួនដោយភាពអស់កំលាំង យូជុន សម្លឹងមើលនាងដោយខ្សែភ្នែកស្រទន់ហើយក៏ងាកមកមើលផ្លូវវិញ។

ស៊ូហ៊ី ត្រឡប់មកធ្វើការជាធម្មតាទោះបីសុខភាពនាងមិនទាន់ជាស្រួលបួលក៏ដោយ។

«ស៊ូហ៊ី ហេតុអីមិននៅសម្រាកសិនទៅមើលមុខឯងចុះនៅស្លេកស្លាំងនៅឡើយទេ!» សេមី ដែលឃើញទឹកមុខមិត្តដូចជាមនុស្សមិនបានសម្រាកហើយនៅប្រឹងមកធ្វើការទៀតទើបប្រាប់បន្ថែម។

«គ្នាមិនអីទេ កុំបារម្ភអី» នាងតបសំឡេងស្រាលញញឹមតិចៗ ឃើញបែបនេះក៏ខ្ជិលបន្ថែមព្រោះដឹងចរឹកមិត្តនាង ឈឺល្មមៗមិនងាយឈប់នោះទេទាល់តែឈឺធ្ងន់អីថា។

នារីស្រស់ស្អាតស៊ិចស៊ីម្នាក់ ដើរចូលមកដោយឫកពាក្រអឺតក្រទមដើរមកដល់តុខោនផរសម្លឹងមើលពួកនាងចុងភ្នែក។

«ខ្ញុំមកជួបអគ្គនាយកគេនៅជាន់ណាដែរ?» ភ្ញៀវនារីដែលទើបមកដល់សួរសំឡេងស្មើសម្លឹងមើលអ្នកម្ខាងទៀតចុងភ្នែក។



Scanned by CamScanner

«អ្នកនាងមានណាត់ទុកដែរទេ?» ស៊ូហ៊ី សួរទាំងញញឹមតិចៗ ព្រោះគិតថាប្រហែលជាដៃគូជំនួញរបស់គេហើយ តែបែរជាទទួលបាន ខ្សែភ្នែកសម្លក់មកវិញ។

«ខ្ញុំជាអនាគតអ្នកស្រីទីនេះហេតុអីក៏ត្រូវណាត់ជួបមុនដែរ» នាងប្រាប់សំឡេងរឹង ស៊ូហ៊ី ឈរទ្រឹងបន្តិច គ្រាន់តែឮបែបនេះហេតុអីក៏បេះដូងនាងលោតញាប់ទៅកើតនាងគិតក្នុងចិត្ត ស្របពេលសំឡេងអ្នកម្ខាងទៀតបន្លឺឡើងមក។

«នែនាង ឮខ្ញុំសួរដែរទេ បុគ្គលិកទីនេះពិតជាយ៉ាប់មែន ពេលខ្ញុំបានធ្វើជាអ្នកស្រីពេលណានឹងដេញចេញឲ្យអស់» នាងនិយាយទាំងសម្លក់ ស៊ូហ៊ី និង សេមី មិនដាក់ភ្នែកស្របពេលទ្វារកញ្ចក់នៅខាងមុខត្រូវបើកបរាងខ្ពស់របស់អគ្គនាយកដើរចូលមក។

«អែលវីន» សំឡេងនារីម្នាក់ស្រែកហៅទាំងរត់ទៅឱបថើបអ្នកម្ខាងទៀតធ្វើឲ្យបុគ្គលិកនាំគ្នាមើលដោយភាពភ្ញាក់ផ្អើលជាពិសេស ស៊ូហ៊ី បេះដូងនាងដូចជាឈឺផៀបខុសពីធម្មតានាងឈរសម្លឹងពួកគេទ្រឹង។

អែលវីន បង្ហាញទឹកមុខធុញទ្រាន់ពេលដឹងថាជាអ្នកណា អេឡា ជាគូបណ្ដើរចុងក្រោយរបស់គេ នាងតែងតែតាមទាមគេមិនឈប់ទើបតែគេចមកដល់ទីនេះមិនស្មានថានាងនៅតែតាមរកគេឃើញទៀត។

«នាងមកទីនេះធ្វើអី?» គេសួរសំឡេងស្មើរុញអ្នកម្ខាងទៀតចេញ ព្រោះមានអារម្មណ៍ធុលក្លិនទឹកអប់របស់នាង។

«ព្រោះអូននឹកបងទើបមកតាមហ្នឹងណា មិននឹកអូនខ្លះទេហ៎» នាងនិយាយសំឡេងង៉ក់ងរលើកដៃតោងករគេជាប់ ប្រុសកំលោះមាន





អារម្មណ៍ធុញទ្រាន់ស្រីម្នាក់នេះខ្លាំងណាស់ តែពេលក្រឡេកឃើញ ស៊ូហ៊ី កំពុងឈរសម្លឹងមើលពួកគេភ្លឹក ទើបកើតគំនិតចង់បញ្ឈឺនាងម្ដងព្រោះតែរឿងកាលពីយប់។

«បងក៏នឹកអូនដូចគ្នា» គេប្រាប់សំឡេងស្រទន់លូកដៃឱបចង្កេះនាងជាប់បណ្ដើរគ្នាចេញទៅ ថែមទាំងឆ្លៀតងាកមកញញឹមចំអកដាក់អ្នកដែលកំពុងសម្លឹងគេថែមទៀត ស៊ូហ៊ី ប្រញាប់ទម្លាក់ភ្នែកចុះព្រោះមិនចង់ឃើញរូបភាពទាំងនេះ វាធ្វើឲ្យនាងមានអារម្មណ៍ឈឺផៀបក្នុងទ្រូងប្លែក ឃើញអ្នកម្ខាងទៀតដូចជាមិនចាប់អារម្មណ៍ ធ្វើឲ្យអ្នកដែលគិតថាសម្ដែងមុននេះចាប់ផ្ដើមម៉ូម៉ៅ នាងមិនប្រចណ្ឌគេទេឬយ៉ាងម៉េចគេសួរក្នុងចិត្តគ្មានចម្លើយសម្រាប់ខ្លួនឯង ទើបរុញនារីក្បែរខ្លួនចេញដើរសំដៅទៅក្នុងធ្វើព្រងើយ ធ្វើឲ្យនារីបង្ហាញម៉ូតបានត្រឹមមីងមាំងមិនយល់ទង្វើរបស់គេ។

«ស្រីម្នាក់នោះជាអ្នកណា ហេតុអីក៏ស្និទ្ធស្នាលនឹងអគ្គនាយកម្លេះ គួរឲ្យច្រណែននាងដល់ហើយដែលបាននៅកៀកអគ្គនាយកយើង មែនទេស៊ូហ៊ី» សេមី និយាយបណ្ដើរតាមសម្លឹងមើលពួកគេបណ្ដើរហើយក៏ងាកមកសួរអ្នកក្បែរខ្លួន។

«ខ្ញុំមិនដឹងដូចគ្នា» នាងងើបមកតបមិនពេញសំឡេងហើយក៏ឈ្ងោកធ្វើការបន្តដោយមិនចាប់អារម្មណ៍ តែក្នុងចិត្តមានអារម្មណ៍ថាឈឺដើមទ្រូងខាងឆ្វេងខ្លាំងណាស់។

«ស៊ូហ៊ី» សំឡេងហៅដែលរាងសុំទម្លាប់ទោះបងាកទៅញញឹមតបព្រោះដឹងថាជាអ្នកណា។

«ចាស មានអីមែនទេប្រធានផ្នែក»

«គ្មានអីទេ គឺខ្ញុំមានរឿងចង់ពឹងបន្តិចបានទេ» យូជុន និយាយរាងទាក់ទើរបន្តិចសម្លឹងមុខអ្នកម្ខាងទៀតចាំស្តាប់។

«មានអីមែនទេ បើខ្ញុំអាចជួយបានខ្ញុំនិងជួយចាត់ទុកថាជាការសងគុណរឿងកាលពីថ្ងៃមុនក៏បាន» នាងតបតិចៗទាំងញញឹម។

«អរគុណ ពេលចេញពីធ្វើការខ្ញុំនឹងមករកនាងម្តងទៀត» គេប្រាប់រួចក៏ដើរទៅធ្វើឲ្យនារីទាំងពីរមើលមុខគ្នាឡេងឡង់។

«ស៊ូហ៊ី ខ្ញុំថាប្រធានផ្នែកមានចិត្តលើឯងហើយដឹងទេ?» សេម៉ីនិយាយពេលឃើញគេដើរទៅរាងឆ្ងាយទៅហើយ។

«កុំនិយាយផ្តេសផ្តាស មិនអាចនោះទេ» នាងក្រមុំតបទាំងមុខក្រហមនាងក៏ដឹងរឿងនេះដែរតែព្យាយាមធ្វើមិនដឹង ព្រោះនាងទុកគេត្រឹមជាអ្នករួមការងារតែប៉ុណ្ណោះ គ្មានអីលើសពីនេះនោះទេ។

យូជុន សុំពឹងនាងឲ្យជួយបង្រៀនភាសាដល់ប្អូនស្រីគេ នាងក្រមុំរាងទាក់ទើរបន្តិចក្រោយមកក៏យល់ព្រមដូច្នេះពេលចេញពីធ្វើការ គេត្រូវនាំនាងទៅផ្ទះរបស់គេហើយទើបជូននាងត្រឡប់ទៅផ្ទះវិញ។

«ស៊ូហ៊ី អរគុណ» យូជុន និយាយពេលជូននាងមកដល់មុខផ្ទះ។

«មិនអីទេ គ្រាន់ជារឿងតិចតួចប៉ុណ្ណោះ» នាងតបទាំងញញឹមដាក់អ្នកម្ខាងទៀត ដោយមិនដឹងថាស្នាមញញឹមរបស់នាងធ្វើអ្នកណាម្នាក់ទៀតដែលកំពុងសម្លឹងដោយកំហឹងនោះទេ អែលវិន កំពុងអង្គុយក្នុងឡានគេឲ្យមនុស្សតាមដាននាងរហូតដឹងថានាងទៅជាមួយ យូជុន ធ្វើឲ្យគេចាប់ផ្តើមម៉ួម៉ៅលើសដើម ជាពិសេសទៅដល់ផ្ទះរបស់ម្នាក់នោះថែមទៀត គេក៏មិនដឹងដូចគ្នា ពេលឃើញនាងស្និទ្ធស្នាលជាមួយប្រុសផ្សេង





គេបែរជាមានអារម្មណ៍ខឹងម៉ួម៉ៅបែបនេះទៅវិញ គ្មានចម្លើយសម្រាប់ខ្លួនឯងពេលនេះគេគិតថាគួរតែប្រដៅនាងចេញម្តងហើយ។

ស៊ូហ៊ី ឈរសម្លឹងមើលរហូតរថយន្តរបស់ យូជុន ចេញទៅឆ្ងាយទើបបែខ្លួនដើរចូលក្នុង ស្របពេលមានរថយន្តមួយបើកមកឆាបជិត ទើបធ្វើឲ្យនាងដួលព្រោះតែភ្ញាក់ ។

«បើកឡានមិនមើលមនុស្សទេឬយ៉ាងម៉េច គ្មានសិលធម៌មែន» នាងក្រមុំរអ៊ូតិចៗទាំងប្រឹងក្រោក តែមានអារម្មណ៍ដូចជាប្រហែលៗរថយន្តទើបងាកទៅមើលម្តងទៀតហើយក៏បង្ហាញទឹកមុខហាត់នឿយ ពេលដឹងថាជារបស់អ្នកណា មិនដឹងថាគេមករករឿងអីនាងទៀតហើយទេ។

អែលវិន ចុះមកដោយទឹកមុខមាំសម្លឹងមើលនារីចំពោះមុខ តែនាងក្រមុំមិនខ្វល់ព្រោះមិនបានសម្លឹងមុខគេមានអារម្មណ៍ឆ្អែតចិត្ត ហើយក៏មិនចង់ជួបមុខមិនចង់និយាយជាមួយគេដែរ។

«អាម្នាក់នោះជាគោលដៅថ្មីរបស់នាងមែនទេ? ពិតជាមនុស្សស្រីមិនចេះខ្មាសមែន» កំលោះនិយាយទាំងញញឹមចំអក អ្នកស្តាប់ងាកមកសម្លឹងគេថ្ងៃនាងព្យាយាមមិនតប ព្រោះនិយាយទៅក៏គ្មានប្រយោជន៍ដែរ គេមិនធ្លាប់ស្តាប់មិនធ្លាប់ជឿនាងនោះទេ។

«ជារឿងរបស់ខ្ញុំ» នាងប្រាប់សំឡេងរឹងដើរចូលក្នុងដោយមិនខ្វល់ធ្វើឲ្យអ្នកដែលឈរមើលក្តៅឆេវ ដែលនាងហ៊ានព្រងើយកណ្តើយដាក់គេបែបនេះ គិតហើយក៏ស្ទុះទៅស្រវាចាប់ក៏ដៃនាងមកវិញ។

«នាងនិយាយថាម៉េចមិញ?» គេសួរសំឡេងរឹងសម្លឹងនាងដោយក្រសែភ្នែកដាក់ទោស។

«ជារឿងរបស់ខ្ញុំ មិនទាក់ទងនិងលោកនោះទេ ទោះខ្ញុំធ្វើអីទាក់ទងអ្នកណាវាជាសិទ្ធរបស់ខ្ញុំ» នាងប្រាប់ទាំងរលាស់ដៃចេញពីគេ។

«តែនាងជាមនុស្សរបស់ខ្ញុំ» គេស្រែកប្រាប់សំឡេងតាមដើងធ្មេញធ្វើឲ្យនាងក្រមុំញញើមចុងមាត់មុននឹងតប។

«លោកប្រហែលជាច្រលំហើយ ខ្ញុំគឺខ្ញុំមិនមែនជារបស់អ្នកណាម្នាក់នោះទេខ្ញុំធ្វើអីក៏មិនទាក់ទងអ្នកណាដែរ»

«ខ្ញុំប្រហែលត្រូវរំឭកការចងចាំរបស់នាងហើយ ថារាងកាយនាងជារបស់អ្នកណានោះ»

«ខ្ញុំគ្រាន់តែប្រើវា ដើម្បីដោះដូរជាមួយនឹងលុយ ដូច្នេះចង់ប្រើជាមួយអ្នកណាក៏បានដែរ មិនមែនជាកម្មសិទ្ធរបស់អ្នកណាម្នាក់នោះទេ» នាងក្រមុំនិយាយទាំងអួលណែន ជាគេមែនទេដែលលើកដាក់វាមកឲ្យទើបនាងត្រូវទទួលវាដូចពេលនេះឯង។

«នាងសាកនិយាយម្ដងទៀតទៅ?» កំលោះសួរសំឡេងតាមដើងធ្មេញទាញកន្ត្រាក់រាងកាយស្ដើងមកបុកដើមទ្រូងខ្លួន។

«គ្រចៀកលោកប្រហែលមានបញ្ហាមែនហើយ ទើបស្ដាប់មិនច្បាស់បនេះ ឆាប់លែងខ្ញុំទៅ» នាងប្រាប់ទាំងប្រឹងរើបម្រះឲ្យរួចពីដៃគេ តែមានរហំដែលគេព្រមដោះលែងនាងងាយៗនោះ គ្រាន់តែគិតថារាងកាយាងត្រូវប៉ះពាល់ដោយប្រុសផ្សេង ក្នុងចិត្តគេក្ដៅដល់រាប់ម៉ឺនអង្សារទៅហើយ មានតែគេម្នាក់ប៉ុណ្ណោះដែលមានសិទ្ធលើនាង។

«ខ្ញុំមិនដោះលែងនាងនោះទេចាំទុក» គេប្រាប់សំឡេងតាមដើងធ្មេញទាញរាងស្ដើងចូលឡានទាំងក្រដាបក្រដួស ដោយមិនខ្វល់ថាអ្នក





ត្រូវត្រង់ណានោះទេព្រោះគេកំពុងតែខឹងខ្លាំងណាស់។

ស៊ូហ៊ី ត្រូវអូសមកដល់បន្ទប់ខុនដូរដែលជាកន្លែងរបស់គេ កំលោះសម្លឹងមុខនាងដោយក្រសែភ្នែកមុត ដៃក៏ចាត់ការអាវក្រៅរួមទាំងអាវសឺមីរបស់គេបោះទៅលើសាឡុង ហើយដើរទៅរកនាងដោយការដាក់សំពាធ នាងក្រមុំថយគេចដោយភាពភ័យខ្លាចព្រោះតែខ្សែភ្នែករបស់គេ។

«ដោះលែងខ្ញុំទៅ» នាងអង្វរសំឡេងញ័រតែគេមិនខ្វល់នៅតែសំដៅមករករហូតរុញនាងអឹបនឹងជញ្ជាំង។

«គ្មានផ្លូវនោះទេ» គេប្រាប់សំឡេងរឹងកន្ត្រាក់អាវស្ដើងរបស់នាងរហូតដាច់ឡេវអស់ មុននឹងឱនទៅឈ្ងុសគល់ទ្រូងដោយភាពស្រេកឃ្លាន អាវក្នុងក៏ត្រូវគេទាញបណ្ដាច់គ្មានប្រណី ពេលនេះរាងកាយល្វែងលើបង្ហាញនៅចំពោះមុខ កំលោះសម្លឹងមើលដើមទ្រូងណែនក្បំដោយភាពពេញចិត្តមុននឹងឱនទៅរកចុងកំពូលស្រួច គេថើបច្របាច់ពីម្ខាងទៅម្ខាងដោយការដាក់ទោស នាងក្រមុំព្យាយាមទប់សំឡេងថ្ងូររបស់ខ្លួនដៃដែលប្រឹងតប់រុញគេចេញប្ដូរមកលើកតោងករគេជាប់ដើម្បី រម្ងាប់អារម្មណ៍ស្រៀវស្រើប ដឹងថាមិនអាចរើបម្រះឈ្នះនោះទេទើបទ្រាំឲ្យគេញ៉ាំញីតាមចិត្ត ឃើញនាងឈរមិនចង់នឹងទើបលើកទៅដាក់លើគ្រែ ទាំងចាត់ការសំពត់ខ្លីរួមទាំងខោតូច។

«ចាំទុក រាងកាយនាងជាកម្មសិទ្ធខ្ញុំម្នាក់គត់» គេប្រាប់សំឡេងរឹងសម្លឹងរាងកាយស្ដើងទាំងមូលដោយភាពហួងហែង មុននឹងឱនទៅថើបបបូរមាត់ស្ដើងជាប់អូសមកដល់គល់ករសខ្ចី ដេញមកដល់ដើមទ្រូងតឹងណែនថើបខាំញេញញសម្ដែងភាពជាម្ចាស់ ធ្វើឲ្យនាងស្រែកថ្ងូរទាំងឈឺចាប់

លាយស្រៀវស្រើប នាងក្រមុំបានត្រឹមគេងបង្ហូរទឹកភ្នែកតូចចិត្តវាសនារបស់ខ្លួនដែលមកជួបមនុស្សដូចជាគេ កំលោះអូសបបូរមាត់ដ៏ប៉ិនប្រសព្វរសព្វពេញរាងកាយមកឈប់ត្រឹមចំនុចស្រៀវស្រើបបំផុត គេសម្លឹងមើលទួលសាច់ដោយភាពពេញចិត្ត មុននឹងអណ្ដាតឧណ្ហៗចូលលុកលុយតំបន់នោះធ្វើឲ្យនាងចាប់ផ្ដើមរមួលខ្លួនស្រែកថ្ងូរ ដៃម្ខាងលូកចូលសក់ក្បាលគេ ដៃម្ខាងទៀតខ្ទាំស្មារគេរហូតមានឈាមតិចៗ តែគេមិនខ្វល់ឈឺព្រោះកំពុងតែជក់ចិត្ត គេថើបលិឍជញ្ជក់យកតែចិត្តខ្លួនឯងដោយមិនខ្វល់ពីអ្នកម្ខាងទៀតស្ទើរដាច់ខ្យល់ព្រោះតែអណ្ដាតរបស់គេនោះទេ។

«នេះជាការដាក់ទោសដែលនាងហ៊ាននិយាយផ្ដើនជាមួយខ្ញុំ ចាប់ពីពេលនេះទៅនាងជាមនុស្សរបស់ខ្ញុំ ហាមទៅរញ៉េរញ៉ៃជាមួយប្រុសផ្សេងទៀតជាពិសេសសម្ព័ន្ធភាពលើគ្រែ នាងគ្មានសិទ្ធទៅរកអ្នកណាទាំងអស់ក្រៅពីខ្ញុំរឿងលុយមិនបាច់បារម្ភខ្ញុំនឹងផ្ដល់ឲ្យនាងគ្រប់យ៉ាង តួនាទីរបស់នាងគឺកំដរខ្ញុំនៅលើគ្រែ ហើយហាមទាក់ទងទៅម៉ាក់ខ្ញុំដាច់ខាត មិនថាមានរឿងអីនោះទេ មិនអ៊ីចឹងនាងនិងប្អូនប្រុសចាំត្រៀមខ្លួនឲ្យហើយទៅ» កំលោះងើបមកប្រាប់សំឡេងស្ទើរចាត់ការខោរ៉ែងរបស់ខ្លួន រាងកាយបុរសពោរពេញដោយសាច់ដុំកង់ៗបង្ហាញនឹងមុខ ធ្វើឲ្យនាងសម្លឹងមើលទាំងអៀនខ្មាសហើយក៏ងាកមុខចេញ សំងំបង្ហូរទឹកភ្នែកយ៉ាងស្ងៀមស្ងាត់ព្រោះសម្ដីរបស់គេមុននេះ នាងមានតួនាទីត្រឹមស្រីកំដរនៅលើគ្រែតែប៉ុណ្ណោះស្ដាប់បានទេ នាងតឿនប្រាប់ខ្លួនឯងក្នុងចិត្ត ភាពតូចចិត្តត្រូវរលប់បាត់បន្តិចម្ដងៗ ព្រោះអារម្មណ៍ស្រៀវស្រើបចូលមកពេលដែលគេសិកដំបងសាច់ចូលមាត់ល្អាង ព្យាយាមទប់សំឡេងថ្ងូរដៃទាំងសងខាងខ្ទាំពូករំសាយអារម្មណ៍ស្រើបស្រាល។



«អ្ហា...អែល...វិន» នាងស្រែកសំឡេងស្អកពេលគេធ្វើចលនាត្រកៀកខ្លាំងៗទើបត្រូវលើកដៃតោងរាងកាយគេជាប់ ព្រោះយល់លើកនេះគេដូចជាព្រៃផ្សៃជាងលើកមុន។

«យ៉ាង...ម៉េច» គេសួរតបទាំងសំឡេងស្អកដែលត្រគាកនៅតែធ្វើចលនាកាន់តែខ្លាំងហើយខ្លាំងទៀត ព្រោះតែអារម្មណ៍នៅតែខឹងមិនទាន់រលប់បាត់នោះទេ ពេលដែលនាងនិយាយថានិងទៅរកប្រុសផ្សេងនោះទើបគេគិតថាត្រូវតែធ្វើឲ្យនាងរាងចាល ហើយម្យ៉ាងទៀតរាល់ដងនាងតែងតែក្រោកទៅចោលគេជានិច្ច ម្ដងនេះគេនឹងធ្វើឲ្យនាងក្រោកលែងរួចគិតហើយក៏បន្តសាប់បុកកាន់តែខ្លាំងលើសដើម ហើយក៏ក្រឡាសខ្លួននៅពីក្រោមម្ដងនាងក្រមុំដឹងថាគេចង់ធ្វើអីព្រោះធ្លាប់មានបទពិសោធន៍ម្ដងរួចមកហើយ ទើបមិនចាំឲ្យគេប្រាប់ជាលើកទី២ព្រោះកំពុងមានអារម្មណ៍រោលរាលដូចគ្នា នាងយោគត្រកៀកទៅមកដូចជាមនុស្សស្ទាត់ជំនាញធ្វើឲ្យអ្នកនៅខាងក្រោមញញឹមពេញចិត្ត ពេលនាងបង្រៀនឆាប់ចះថែមទាំងសហការគេបានល្អថែមទៀត កំលោះលូកដៃចាប់ត្រកៀកតូចបន្ថែមចលនាយោគទៅមកកាន់តែខ្លាំងឡើង មុននឹងក្រឡាស់រាងស្ដើងមកនៅខាងក្រោមវិញ បន្ថែមចលនាត្រគាករហូតដល់ត្រើយនៃសេចក្ដីសុខទាំងពីនាក់ គេញញឹមមើលនារីក្រោមទ្រូងកំពុងដកដង្ហើមដង្ហក់មិនខុសពីគេមុននឹងទ្រោមពីលើដោយភាពអស់កំលាំង ស្រីម្នាក់នេះពិតជាធ្វើឲ្យគេរោលរាលនិងមានក្ដីសុខគ្រប់ពេល គិតក្នុងចិត្តទាំងទាញនាងមកគេងកើយទ្រូងស្រវាំឱបដោយភាពហួងហែង។







...៦...

ពន្លឺថ្ងៃចាំងចូលតាមបង្អួច ធ្វើឲ្យរាងក្រាស់ដែលគេងលើគ្រែចាប់ផ្ដើមដឹងខ្លួន គេងាកមើលនារីក្បែរខ្លួនឃើញនាងកំពុងគេងបែខ្នងទើបបបូរមាត់ញោចស្នាមញញឹមព្រោះគេភ្ញាក់មុននាង គិតហើយក៏សសៀៗលូកដៃទៅឱប តែបែរជាធ្វើឲ្យគេភ្ញាក់ផ្អើលព្រោះរាងកាយនាងកំពុងតែញាក់ញ័រ ទើបស្ទុះក្រោកមកមើលយ៉ាងលឿនទាញនាងមកប្រឈម ទឹកមុខស្លេកស្លាំងថែមទាំងបែកញើសជោគថ្ងាស់ ធ្វើឲ្យគេកាន់តែភ័យលើសដើមឃើញនាងស្រវាំក្អួយឱបជាប់ទើបទាញចេញព្រោះវាទើស ហើយក៏ធ្វើឲ្យគេសម្លឹងមើលដោយភាពភ្ញាក់ផ្អើល ស្នាមក្រហមជាំពេញរាងកាយស្ដើងធ្វើឲ្យគេនឹកឃើញទង្វើរបស់ខ្លួនកាលពីយប់។

«តើគេធ្វើឆ្កួតស្អីនេះ?» កំលោះរអ៊ូរង៉ូវៗបោចសក់ក្បាលខ្លួនឯងមិនអស់ចិត្តមានអារម្មណ៍ខុស ដែលធ្វើឲ្យរាងកាយសរលោងទៅជាបែបនេះ គិតហើយក៏ស្ទុះក្រោកដើរសំដៅទ្វារយ៉ាងលឿន ព្រោះខ្លួននាងក្ដៅខ្លាំងណាស់គេមិនអាចទុកនាងឲ្យនៅបែបនេះនោះទេ។

«ជេក ឆាប់ទៅតាមពេទ្យមក» គេប្រាប់កូនចៅដែលនៅមុខបន្ទប់។

«បាទ ចៅហ្វាយមិនស្រួលខ្លួនមែនទេ?» កូនចៅសួរតបទាំងព្រួយបារម្ភតែបែរជាទទួលបានខ្សែរភ្នែកមុតត្រឡប់មកវិញ។

«កុំសួរច្រើនពេកប្រាប់ឲ្យតាមឆាប់តាមមក» គេប្រាប់សំឡេងរឹងហើយក៏បែខ្លួនដើរចូលក្នុងវិញ តែដូចជានឹកឃើញអ្វីទើបងាកមកវិញ។

«តាមពេទ្យស្រី ហាមយកពេទ្យប្រុសមក» ប្រាប់ហើយក៏ដើរចូលក្នុងបិទទ្វារគ្រាំង មនុស្សជំនិតទាំងពីរបានត្រឹមនាំគ្នាគ្រវីក្បាលញញឹម។

«ចៅហ្វាយប្រហែលជាលេងជ្រុលហើយ ទើបដល់ថ្នាក់តាមពេទ្យបែបនេះ» ដេក និយាយលាយសើចមុននឹងដើរចេញទៅ។

អែលវិន ត្រឡប់ចូលបន្ទប់វិញសម្លឹងមើលនារីដែលនៅលើគ្រែដោយក្ដីបារម្ភ គេទាញភួយចេញដើម្បីពាក់អាវដំណេកឲ្យនាងមុនគ្រូពេទ្យមកដល់តែនាងឱបវាជាប់ធ្វើឲ្យគេមិនពេញចិត្ត។

«ខ្ញុំរងារ» នាងក្រមុំប្រាប់សំឡេងស្រាលបើកភ្នែកមីមីមើលអ្នកអង្គុយក្បែរថែមទាំងឱបភួយកាន់តែណែន ព្រោះលើខ្លួននាងទទេស្អាតមានតែភួយតែប៉ុណ្ណោះ។

«ខ្ញុំដឹងហើយ ឆាប់ពាក់ខោអាវនេះទៅបន្តិចទៀតគ្រូពេទ្យមកដល់ហើយ» គេប្រាប់តិចៗលួងព្រោះដឹងថានាងមិនស្រួលខ្លួន ហើយក៏ជួយគ្រានាងឲ្យក្រោកអង្គុយដើម្បីងាយស្រួលពាក់។

ស៊ូហ៊ី កំពុងគេងលើគ្រែងាកទៅសម្លក់អ្នកអង្គុយលើសាឡុងមិនដាក់ភ្នែក មុននេះពេលគ្រូពេទ្យពិនិត្យញញឹមចំអកពេលឃើញស្នាមក្រហមពេញខ្លួនរបស់នាង មិនបាច់ប្រាប់ក៏ដឹងថានាងឈឺដោយសារអីទេ តែគេបែរជាដូចមិនមែនជារឿងធំដុំ។

«មនុស្សអាក្រក់» នាងរអ៊ូរទាំរួចហើយក៏បិទភ្នែកគេងយកកំលាំងនឹងបានចេញពីទីនេះ។

អែលវិន កំពុងអង្គុយលើសាឡុងពិនិត្យឯកសារឆ្លៀតងាកមកមើលអ្នកនៅលើគ្រែ ហេតុអីក៏គេត្រូវបារម្ភពីនាងដល់ថ្នាក់ស្ពាយឯកសារមកធ្វើដល់ទីនេះដែរ ពិតជាឆ្កួតមែន គេរអ៊ូក្នុងចិត្តរៀបឯកសារនៅលើតុ មុននឹង





ក្រោកទៅរៀបចំខ្លួនទៅធ្វើការ។

នាងក្រមុំនៅលើគ្រែភ្ញាក់ដឹងខ្លួនជិតថ្ងៃត្រង់ទៅហើយក្រឡេកមើលជុំវិញបន្ទប់មិនឃើញរាងក្រាស់នៅទីនេះនោះទេ ទើបក្រោកទៅរៀបចំខ្លួនត្រឡប់ទៅផ្ទះវិញចុះមកដល់ជាន់ក្រោមចៃដន្យក៏បានជួបអ្នកស្រី សុងហ៊ីដែលរៀបនិងឡើងទៅលើល្ហម។

«ស៊ូហ៊ី មែនទេហេតុអីក៏មកទីនេះ?» ស្ត្រីចំណាស់សួរទាំងងឿងឆ្ងល់ពេលឃើញនាងចេញពីជណ្ដើរយន្តសម្រាប់អ្នកគ្រប់គ្រង។

«ចាសខ្ញុំមកជួបមិត្តភក្តិ ចុះអ៊ំស្រីវិញ» នាងសួរតបសំឡេងស្រាលទាំងញញឹមតិចៗបន្លប់ខ្លាចគាត់សង្ស័យ។

«ទីនេះជាកន្លែងសម្រាករបស់កូនប្រុស ខ្ញុំចង់មកមើលមិនស្មានថាបានជួបនាងនៅទីនេះសោះ» គាត់ប្រាប់ទាំងញញឹមស្រទន់ដើរតិចៗទៅរកនាង ស៊ូហ៊ី ប្រញាប់ទាញក៏អាវបិទទាំងអៀនខ្មាសពេលឃើញគាត់សម្លឹងមិនដាក់ភ្នែក ប្រហែលជាគាត់ឃើញស្នាមក្រហមទាំងនោះហើយនាងធ្វើមុខលេបមិនចូលខ្ជាក់មិនចេញនោះទេ ដែលត្រូវមកជួបគាត់នៅកន្លែងនេះ បើគាត់ដឹងថានាងមានទំនាក់ទំនងនិងកូនប្រុសគាត់នោះតើគិតយ៉ាងម៉េចទៅនាងគិតទាំងខ្វល់ខ្វាយ។

«ពួកយើងទៅរកអីញ៉ាំសិនទៅល្អទេ?» គាត់និយាយតិចៗទាំងទាញដៃនាងមកកាន់ព្រោះមើលទៅនាងដូចជាភ្លឹកៗយ៉ាងម៉េចមិនដឹង។

«ចាសបាន» តបរួចក៏នាំគ្នាដើរចេញទៅ។

ក្នុងបន្ទប់ធ្វើការអគ្គនាយក...



Scanned by CamScanner

-ស៊ុហ៊ី ភ្ញាក់ហើយឬនៅ?- អែលវិន សួរមនុស្សជំនិតដែលទើបដើរចូលមកទាំងមានកាន់ឯកសារមកជាមួយផង តែគេនៅឈរទាក់ទើរមិនទាន់តប ទើបធ្វើឲ្យអ្នកដែលរវល់ជាមួយឯកសារនៅលើតុត្រូវងើបមុខមកមើលទាំងងឿងឆ្ងល់។

-មានរឿងអី?- គេសួរបន្ថែមទាំងសំឡេងរឹង។

-អ្នកនាង ស៊ុហ៊ី នៅជាមួយលោកស្រី- ជេក រាយការណ៍ទាំងញញើតញញើមពេលឃើញទឹកមុខផ្លាស់ប្ដូររបស់ចៅហ្វាយគេ។

-បានហើយនាំគ្នាចេញទៅវិញចុះ- គេប្រាប់សំឡេងស្មើរទាញឯកសារមកមើលបន្ត ធ្វើឲ្យមនុស្សជំនិតទាំងពីរងាកមើលមុខគ្នាទាំងងឿងឆ្ងល់តែមិនហ៊ានសួរក៏នាំគ្នាចេញមកក្រៅ។

-តើចៅហ្វាយកំពុងគិតអីទៅហ្ន៎ មិនយល់ទាល់តែសោះ- ជីម អ៊ុង៉ូវពេលនាំគ្នាមកដល់ខាងក្រៅ។

-យើងក៏មិនដឹងដូចគ្នា- ជេក តបទាំងសំឡេងស្មើរពួកគេនៅជាមួយ អែលវិន យូរមកហើយពេលខ្លះក៏ដឹងចិត្តតែពេលខ្លះទៀតក៏ធ្វើឲ្យពួកគេមិនយល់ដូចគ្នាថាគេកំពុងគិតអី។

អែលវិន អង្គុយក្ដាប់ដៃណែននៅក្នុងបន្ទប់ ស្រីម្នាក់នេះកំពុងលេងល្បិចឲ្យប្រាកដគេបាននិយាយជាមួយនាងច្បាស់លាស់ហើយ ហេតុអីក៏នៅតែតាមទាក់ទងម៉ាក់របស់គេទៀត បើនាងហ៊ាននិយាយរឿងអីនោះច្បាស់ជាត្រូវធ្ងន់មិនខានទេ គេគិតទាំងគំគួន ស្របពេលសំឡេងគោះទ្វារបន្ទប់បន្លឺឡើងនារីស៊ិចស៊ីម្នាក់ដើរចូលមកដោយឫកពាញញឹមញញែម។

-អែលវិន មានរឿងអីមែនទេ ហេតុអីក៏ធ្វើមុខបែបនេះ?-





អេឡា នារីបង្ហាញម៉ូតគួរបណ្ដើរចុងក្រោយរបស់គេ និយាយទាំងដើរមកអង្គុយលើភ្លៅយកចិត្ត ធ្វើឲ្យគេមានអារម្មណ៍ថាធុញទ្រាន់ខ្លាំងណាស់ដែលនាងតាមរញ៉េរញ៉ៃគេមិនឈប់ ថែមទាំងតាមមកដល់ទីនេះថែមទៀត។

-គ្មានអីទេ- គេតបខ្លីទាញនាងចេញពីលើភ្លៅតែនាងមិនព្រមថែមទាំងលើកដៃតោងករគេជាប់ពិតដើមទ្រូងមករកគេថែមទៀត បើពីមុនអាចធ្វើឲ្យគេមានអារម្មណ៍ចំពោះនាងខ្លះ តែតាំងពីមានរាងកាយក្រអូបៗរបស់ ស៊ុហ៊ី មកនៅជិតធ្វើឲ្យគេគ្មានអារម្មណ៍ជាមួយស្រីណានោះទេ។

-ហេតុអីទៅ អែលវិន អូននឹកបងខ្លាំងណាស់ណា ពួកយើងខាននៅជាមួយគ្នាយូរហើយ គួរតែ...- នាងនិយាយម៉ិកម៉ូក់យកចិត្តតែក៏ត្រូវគេនិយាយកាត់ថែមទាំងក្រោកពីកៅអីដោយមិនខ្វល់ថែមទៀត។

-សូមទោសខ្ញុំគ្មានអារម្មណ៍ជាមួយនាងទេ?- គេប្រាប់សំឡេងស្មើរលូកដៃជ្រែងហោប៉ៅធ្វើមិនដឹង។

-គ្មានអារម្មណ៍ជាមួយខ្ញុំ តែមានជាមួយស្រីផ្សេងមែនទេ- នាងនិយាយទាំងសម្លក់សម្លឹងអ្នកម្ខាងទៀត តែគេមិនតបបានត្រឹមឈរស្ងៀមធ្វើឲ្យអ្នកម្ខាងទៀតចាប់ផ្ដើមម៉ូម៉ៅដែល លែងចាប់អារម្មណ៍នាងដូចមុន។

-ខ្ញុំមិនសុខចិត្តទេ ហេតុអីក៏លោកឃើញស្រីផ្សេងល្អជាខ្ញុំនោះ- អេឡា នៅតែនិយាយទាំងតូចចិត្តធ្វើឲ្យគេចាប់ផ្ដើមធុញទ្រាន់កាន់តែខ្លាំង។

-នាងក៏ធ្លាប់ដឹង សម្រាប់ខ្ញុំមនុស្សស្រីគ្រាន់តែសម្រាប់ដោះលែងអារម្មណ៍តែប៉ុណ្ណោះគ្មានអីលើសពីនេះនោះទេ- គេប្រាប់សំឡេងស្មើរសម្លឹងមុខនាងទ្រឹង ធ្វើឲ្យអ្នកម្ខាងទៀតចង់តែស្រែកនោះទេ នាងដឹង

ហើយក៏ដឹងច្បាស់ទៀតផង តែនាងនៅសង្ឃឹមគិតថាគេអាចមើលឃើញនាងក្នុងផ្លូវផ្សេងខ្លះ តែប្រហែលមិនអាចនោះទេ។

-ខ្ញុំយល់ហើយ- នាងតបរួចក៏ដើរចេញទៅវិញធ្វើឲ្យ ដូចជានឹកឃើញអ្វីមួយទើបមើលទៅអ្នកដែលដើរទៅដល់ទ្វារម្តងទៀត។

-ឈប់សិន- សំឡេងរបស់គេធ្វើឲ្យនាងងាកមកយ៉ាងលឿនគិតថាគេអាចផ្លាស់ប្តូរគំនិតក៏ថាបាន។

-នៅមានអីទៀតមែនទេ?- នាងធ្វើជាសួរទាំងមុខស្រពោន។

-ជួយខ្ញុំសម្តែងរឿងមួយ- គេប្រាប់ទាំងញញឹមចុងមាត់ធ្វើឲ្យអ្នកម្ខាងទៀតមានការងឿងឆ្ងល់តែក៏មិនបានសួរនាំអ្វី។

អ្នកស្រី សុងហ៊ី និង ស៊ូហ៊ី ទៅញ៉ាំអាហារក្នុងហាងទំនើបមួយបន្ទាប់ក៏នាំនាងទៅទិញសំលៀកបំពាក់ជាច្រើន។

-អ៊ំស្រីបុំណ្ណឹងបានហើយ- ស៊ូហ៊ី ប្រាប់ស្ត្រីចំណាស់ដែលកំពុងរើសខោអាវមិនឈប់មិនបាច់ប្រាប់ក៏ដឹងថារើសឲ្យអ្នកណានោះដែរ ព្រោះមានតែនាងដែលមកជាមួយគាត់។

-កុំបដិសេធអី ព្រោះឲ្យប្រាក់តែឯងមិនយក ដូច្នេះមានតែទិញវាជាកាដូសម្រាប់ឯង- ស្ត្រីចំណាស់ងាកមកប្រាប់ទាំងស្នាមញញឹមមុននឹងងាកទៅរើសមើលជាបន្ត នាងក្រមុំដកដង្ហើមធំសម្លឹងមើលគាត់ព្រោះតែមិនអាចហាមគាត់បាន ទើបបានត្រឹមឈរមើលព្រោះមើលទៅគាត់ដូចជារីករាយក្នុងការធ្វើទើបមកហ៊ានឃាត់គាត់ទៀត។

-ម៉ាក់កំពុងធ្វើអីហ្នឹង?- សំឡេងដែលស៊ាំទម្លាប់សួរ ធ្វើឲ្យស្ត្រីចំណាស់ងាកទៅមើល គាត់មានទឹកមុខមិនពេញចិត្តពេលឃើញកូនប្រុសកំពុងកៀកស្និទ្ធជាមួយស្រីសក់ទង់ដែងមកពីណាក៏មិនដឹង អែលវិនញញឹមតបទៅម៉ាក់គេបែបហ៊ី ទោះបីជាដឹងថាគាត់មិនចូលចិត្តដែលគេនាំមនុស្សស្រីដើរបង្ហាញគេបែបនេះ គិតហើយក៏ក្រឡេកភ្នែកទៅមើលនារីម្នាក់ទៀតដែលកំពុងតែមើលមកដូចគ្នា ស៊ូហ៊ី មានអារម្មណ៍ឈឺផៀបក្នុងដើមទ្រូងខាងឆ្វេងពេលឃើញគេបណ្តើរស្រីផ្សេង នាងក៏មិនដឹងដូចគ្នាថាមកពីអ្វី ហើយក៏គេចភ្នែកយ៉ាងលឿនពេលគេសម្លឹងមក កំលោះលួចញញឹមចុងមាត់ពេលឃើញខ្សែភ្នែករបស់អ្នកម្ខាងទៀត មិនប្រាប់ក៏អាចដឹងថានាងមានចិត្តលើគេខ្លះៗដែរ។

-ម៉ាក់នាំ ស៊ូហ៊ី មកដើរលេងចុះកូន?- សំឡេងស្ត្រីចំណាស់ធ្វើឲ្យគេដកក្រសែភ្នែកពីនារីចំពោះមុខងាកមកមើលគាត់វិញ។

-ខ្ញុំក៏មកដើរលេងដូចគ្នា បើចឹងមិនរំខានម៉ាក់ទេបន្តទៀតចុះខ្ញុំលាទៅវិញហើយ- គេប្រាប់ទាំងញញឹមតិចៗមុននឹងដើរចេញ។

-មិនណែនាំខ្ញុំឲ្យម៉ាក់លោកស្គាល់ទេហ៎- អេឡា សួរពេលដែលនាំគ្នាដើរចេញមកឆ្ងាយទៅហើយ។

-ខ្ញុំគិតថាមិនចាំបាច់នោះទេ!- គេតបសំឡេងស្មើរធ្វើឲ្យអ្នកម្ខាងទៀតទម្លាក់ទឹកមុខបន្តិចហើយក៏ឆ្លៀតងាកក្រោយមើលម្តងទៀត។

-ចុះស្រីម្នាក់នោះទេជាអ្នកណា ខ្ញុំឃើញនាងសម្លឹងពូកយើងមិនដាក់ភ្នែកនោះទេ- កំលោះញញឹមតិចៗពេលនឹកឃើញដល់ទឹកមុខរបស់ ស៊ូហ៊ី មុននេះ។

-កុំសួរច្រើនពេក នាងមានតួនាទីជាតួសម្តែងជាមួយខ្ញុំប៉ុណ្ណោះ- តបហើយក៏នាំគ្នាដើរសំដៅរថយន្តដែលឈប់ចាំ។

សុហ៊ី តាមសម្លឹងពួកគេរហូតទៅផុតនាងមានអារម្មណ៍ថាឈឺដើមទ្រូងខាងឆ្វេងដោយមិនដឹងមូលហេតុ ឬមកពីឯងមានចិត្តលើគេទៅហើយលួង់មែន ហេតុអីក៏បណ្ដោយឲ្យទៅជាបែបនេះឯងក៏ដឹងថាគេទុកឯងគ្រាន់ជាមនុស្សក់ដរតែប៉ុណ្ណោះ នាងប្រាប់ខ្លួនឯងទាំងតូចចិត្ត។

«ស៊ូហ៊ី យ៉ាងម៉េចហើយ» សំឡេងស្ត្រីចំណាស់បន្លឺឡើងធ្វើឲ្យអ្នកដែលកំពុងស្លុងអារម្មណ៍រាងភ្ញាក់បន្តិចមុននឹងងាកមកតប។

«មិនអីទេអ៊ំស្រី» ចម្លើយរបស់នាងធ្វើឲ្យគាត់ញញឹមចុងមាត់។

«នាងពេញចិត្តកូនប្រុសខ្ញុំមែនទេ?» សំណួររបស់ស្ត្រីចំណាស់ធ្វើឲ្យអ្នកដែលឱនមុខងើបមកមើលយ៉ាងភ្ញាក់ផ្អើល។

«មិន មិនមែនបែបនោះទេអ៊ំស្រី» នាងតបរដាក់រដុបសម្លឹងមើលគាត់បន្តិចហើយក៏ទម្លាក់ភ្នែកចុះយ៉ាងអៀនខ្មាស ស្ត្រីចំណាស់ដកដង្ហើមធំបន្តិចដឹកដៃនាងទៅរកកន្លែងអង្គុយ។

«រូបរាងរបស់គេគ្មានស្រីណាដែលថាមិនចាប់អារម្មណ៍នោះទេ តែសំខាន់គឺខ្ញុំមិនចង់ឲ្យឯងលង់ចិត្តលើគេ ព្រោះកូនម្នាក់នេះមិនធ្លាប់ស្រលាញ់ស្រីណាម្នាក់ច្បាស់នោះទេប្ដូរស្រីដូចខោអាវទៅហើយ ខ្ញុំខ្លាចឯងត្រូវឈឺចាប់ដោយសារគេដឹងទេ?»

«ខ្ញុំយល់ហើយអ៊ំស្រី» នាងតបទាំងញញឹមក្រៀមនាងដឹងច្បាស់ណាស់ពីរឿងនេះ ហើយក៏ព្យាយាមមិនឲ្យលង់ចិត្តទៅលើគេដែរ តែប្រហែលជាហួសពេលហើយមើលទៅ នាងគិតទាំងសោកសៅ។

ស៊ូហ៊ី ត្រឡប់មកដល់ផ្ទះនាពេលល្ងាច ទាំងមានអីវ៉ាន់សំពីងសំពោងធ្វើឲ្យអ្នកនៅខាងក្នុងចេញមកមើលទាំងងឿងឆ្ងល់ បន្ទាប់ពីបាត់





នាងពេញមួយយប់។

«ស៊ូហ៊ី ត្រឡប់មកវិញហើយមែនទេ ដឹងថាខ្ញុំបារម្ភពីឯងប៉ុណ្ណាទេហើយទៅណាក៏មិនខលប្រាប់គ្នាមួយម៉ាត់» ហេជីន ដែលទើបចេញពីក្នុងដើរតិចៗមកថាឲ្យមិត្ត ដោយមិនបានចាប់អារម្មណ៍អ្នកនៅខាងក្រោយនោះទេធ្វើឲ្យ ស៊ូហ៊ី ញាក់មុខមាត់កុំឲ្យនាងរំឭកពីរឿងនេះព្រោះមានអ្នកផ្សេងនៅជិត ហេជីន ទើបក្រឡេកឃើញអ្នកនៅខាងក្រោយទើបស្ងាត់មាត់ងាកទៅអ្នកម្ខាងទៀតដែលកំពុងសម្លឹងមកពួកនាង។

«សួស្ដី អ៊ំស្រី» នាងរាក់ទាក់ទាំងឱនគោរពដៃម្ខាងទប់ពោះដែលរីកធំជាងមុនផងធ្វើឲ្យស្ត្រីចំណាស់ងឿងឆ្ងល់ហើយក៏ងាកមក ស៊ូហ៊ី ដែលធ្វើមុខស្រពោនព្រោះដឹងថាគាត់ចង់សួរពីរឿងអ្វី បន្ទាប់មកក៏រៀបរាប់រឿងរបស់មិត្តប្រាប់គាត់ អ្នកស្រី សុងហ៊ី សម្លឹងមើលពួកនាងដោយក្ដីអាណិតព្រោះគាត់ធ្លាប់ឆ្លងកាត់ជីវិតបែបនេះដូចគ្នាទើបយល់ច្បាស់។

«ខ្ញុំជិតត្រឡប់ទៅអង់គ្លេសវិញហើយ បើមានបញ្ហាអីត្រូវប្រាប់ខ្ញុំឮទេ» សំឡេងស្ត្រីចំណាស់បន្លឺឡើងធ្វើឲ្យនារីទាំងពីរងាកមើលមុខគ្នា។

«ចាសអ៊ំស្រីខ្ញុំដឹងហើយ» ស៊ូហ៊ី តបទាំងញញឹមមានអារម្មណ៍ស្និទ្ធស្នាលកក់ក្ដៅបើសិនគាត់មិនមែនជាម៉ាក់របស់ អែលវិន ជាការល្អខ្លាំងណាស់ នាងគិតក្នុងចិត្ត។

ស៊ូហ៊ី មកធ្វើការជាធម្មតាមកដល់មាត់ច្រកក៏បានជួប អែលវិន គេទើបមកដល់ដូចគ្នា នាងក្រមុំសម្លឹងមើលមុខគេបន្តិចមុននឹងឱនគោរពជាការគួរសម ក្នុងនាមអគ្គនាយកនិងបុគ្គលិកហើយក៏ដើរសំដៅតុធ្វើការរបស់ខ្លួនដោយមិនខ្វល់ ធ្វើឲ្យអ្នកម្ខាងទៀតចាប់ផ្ដើមម៉ូម៉ៅ ដែលនាង

ហ៊ានធ្វើព្រងើយកន្តើយដាក់គេ កំលោះក្ដាប់ដៃរម្ងាប់កំហឹងធ្វើឲ្យកូនចៅទាំងពីរងាកមើលមុខគ្នាទាំងលួចដកដង្ហើមធំ ព្រោះមិនធ្លាប់មានស្រីណាហ៊ានធ្វើបែបនេះដាក់ចៅហ្វាយគេនោះទេ នាងជាមនុស្សស្រីទីមួយហើយគិតហើយក៏ងាកទៅមើល ស៊ូហ៊ី ដែលកំពុងឈ្ងោកធ្វើការមិនខ្វល់ពីអ្នកដែលកំពុងឈរសម្លក់សម្លឹងនាងនោះទេ មិនដឹងថាចៅហ្វាយដាក់ទោសនាងយ៉ាងម៉េចទៀតទេ ពួកគេនាំគ្នាគិតទាំងលួចញញឹមចុងមាត់ ព្រោះដឹងពីវិធីដាក់ទោសនោះច្បាស់ណាស់។

-ហ៊ានព្រងើយដាក់ខ្ញុំផងមែនទេ យប់នេះដឹងគ្នាហើយ- កំលោះអ៊ុង៉ូវហើយក៏ដើរសំដៅជណ្ដើរយន្តធ្វើឲ្យកូនចៅទាំងពីរនាំគ្នាលួចញញឹម។

-ស៊ូហ៊ី ល្ងាចនេះទំនេរដែរទេ?- សំឡេង យូជុន បន្លឺឡើងទើបធ្វើឲ្យអ្នកដែលកំពុងឈ្ងោកងើបមុខមកមើល។

-អឺគឺ...- នាងឆ្លើយរាងទាក់ទើព្រោះមានអារម្មណ៍មិនស្រួលចង់សម្រាកនៅផ្ទះច្រើនជាងតែមិនទាន់តបអ្នកម្ខាងទៀតផង ក៏មានសំឡេងមានអំណាចរបស់អ្នកណាម្នាក់ទៀតបន្លឺឡើង។

-មិនទំនេរទេ ព្រោះខ្ញុំមានការងារថែមម៉ោងឲ្យនាងធ្វើ- អែលវិនប្រាប់សំឡេងស្មើសម្លឹងនាងដោយក្រសែភ្នែកដាក់ទោស មុននឹងងាកមក យូជុន ដែលធ្វើមុខភ្ញាក់ផ្អើលសម្លឹងមកគេ។

-មានការអីមែនទេ?- អែលវិន សួរអ្នកម្ខាងទៀត។

-គ្មានទេអគ្គនាយក- យូជុន តបសំឡេងម៉ឺងម៉ាត់ ឱនគោរពបន្តិចមិនហ៊ានជំទាស់នោះទេ ព្រោះដឹងថាអគ្គនាយកម្នាក់នេះផ្ដាច់ការប៉ុណ្ណា។





-បើគ្មានអីនាំគ្នាធ្វើការទៅ អ្នកនាង ស៊ូហ៊ី បន្តិចទៀតឡើងទៅជួបខ្ញុំនៅបន្ទប់ធ្វើការ- គេប្រាប់សំឡេងស្មើរសម្លឹងនាងបែបចំអកមុននឹងដើរចេញទៅវិញ ទុកឲ្យនាងក្រមុំបានត្រឹមសម្លក់ក្នុងចិត្តចង់តែចាប់ហែកគេជាចំរៀកៗនោះទេ ព្យាយាមរម្ងាប់កំហឹង ក្រឡេកមើលម៉ោងជិតដល់ម៉ោងចេញពីធ្វើការទៅហើយតើឲ្យនាងឡើងទៅធ្វើអី ហ៊ឺយ! មនុស្សអាក្រក់ នាងតបក្នុងចិត្ត ទៅពេលនេះច្បាស់ជា...មិនចង់គិតនោះទេ នាងគិតទាំងគ្រវីក្បាលបណ្ដេញរូបភាពនៅលើគ្រែចេញ។

-ស៊ូហ៊ី មិនអីទេមែនទេ?- សេមី សួរសំឡេងបារម្ភពេលឃើញមិត្តដូចជាអារម្មណ៍មិននឹងយ៉ាងម៉េចមិនដឹង ពេលឮអគ្គនាយកមកប្រាប់ដោយផ្ទាល់បែបនេះ។

-គ្នាមិនអីទេ- នាងតបសំឡេងស្រាល។

-ច្បាស់ហើយថាមិនអី?- សេមី សួរបញ្ជាក់។

-ឯងចង់សួរពីអី?-

-គឺគ្មានអីទេ គ្នាគ្រាន់តែឆ្ងល់ដែលឯងធ្វើការថែមម៉ោងហេតុអីមិនប្រាប់គ្នាផង ថែមទាំងអគ្គនាយកមកដោយផ្ទាល់បែបនេះទៀត- នាងក្រមុំរងាទាក់ទើរបន្តិចមុននឹងតបមិត្ត។

-គឺជាការងារបកប្រែឯកសារ ជាឯកសារសំខាន់ទើបគ្នាមិនបានប្រាប់ឯងហ្នឹងណ៎ា ព្រោះមិនចង់ឲ្យលេចឮ- ស៊ូហ៊ី តបទាំងញញឹមតិចៗដាក់មិត្តបើនាងដឹងវិញនោះច្បាស់ជាមានរឿងអីកើតឡើងនោះទេ។

មែនជាទំនាក់ទំនងធម្មតានោះទេ ក្នុងនាមពួកគេជាមនុស្សប្រុសដូចគ្នា

អាចមើលដឹង គិតហើយក៏សម្លឹងមកនារីក្បែរខ្លួននាងមានអាថ៌កំបាំងអ្វីខ្លះ

ដែលគេមិនដឹង។

-ដូចអ្វីដែលខ្ញុំនិយាយមិនខុសទេ ឃើញទេនាងគ្រាន់តែជា

មនុស្សស្រីរបស់ប្រុសអ្នកមានតែប៉ុណ្ណោះ. យុមី ដែលឃើញបែបនេះទើប

និយាយចំអកបន្ថែមតែក៏មានអារម្មណ៍ច្រណែនអ្នកម្ខាងទៀត ដែលបាន

នៅជិតប្រុសសង្ហាហើយមានលុយបែបនេះ។

-ប្រយ័ត្នសម្ដីរបស់នាងផង. ម៉ៃឈិន ប្រាប់សំឡេងស្ងៀមសម្លឹង

មើលនាងដោយកែវភ្នែកមុតធ្វើឲ្យ យុមី មានអារម្មណ៍ខ្លាចទើបស្ងៀម

កោងដៃរបស់ ដុងហ៊ិន ជាប់។

-ពូកយើងទៅវិញ- អែលវិន ប្រាប់ហើយក៏អូសដៃនាងចេញទៅ ក្រោមក្រសែភ្នែករបស់អ្នកនៅទីនោះជាពិសេស ដុងហ៊ិន គេចង់សួរនាងឲ្យដឹងរឿងខ្លាំងណាស់ តែមើលទៅប្រុសម្នាក់នោះដូចជាមិនធម្មតានោះទេ ទើបបានត្រឹមឈរសម្លឹងមើលពួកគេដើរចេញទៅ។

ស៊ូហ៊ី មានអារម្មណ៍មិនសូវស្រួលពេលឃើញក្រសែភ្នែករបស់គេ ដឹងថាគេកំពុងខឹងតែមិនដឹងថាខឹងរឿងអីនោះទេ នាងគិតទាំងខ្វល់ខ្វាយ តែគេបែរជាអង្គុយស្ងៀមក្នុងឡាន។

-ប្រុសម្នាក់នោះជាអ្នកណា?- អែលវិន សួរសំឡេងស្មើរពេលនាំនាងមកដល់បន្ទប់ ស៊ូហ៊ី រាងមីងម៉ាំងបន្តិចមិនឹងថាគេសួរពីម្នាក់ណាឲ្យប្រាកដព្រោះនាងបាននិយាយជាមួយបុរសពីរនាក់។

-លោកចង់សួរពីអ្នកណា?- នាងសួរតបទាំងញញើតញញើមធ្វើឲ្យគេត្រូវងាកមកមើលនាងដោយក្រសែភ្នែកមុត។

-អ៎! ប្រហែលមានច្រើននាក់មែនទេបានជាមិនចាំ- គេឆ្លៀតចំអកឲ្យនាងបន្ថែមទៀត នាងក្រមុំមានអារម្មណ៍អន់ចិត្តដែលគេនិយាយបែបនេះតែព្យាយាមមិនគិតតបតាមអ្វីដែលជាការពិត។

-មានតែពីរនាក់តែប៉ុណ្ណោះ មានម្នាក់គេប្រាប់ថាជាមិត្តលោក ហើយម្នាក់ទៀតជា...- នាងនិយាយអាក់បន្តិចព្រោះមានអារម្មណ៍អួលណែនក្នុងទ្រូងដែលគេមកកកកាយរឿងផ្ទាល់ខ្លួនរបស់នាង។

-ជាអ្នកណា?- គេស្រែកគំហកពេលមិនឮនាងនិយាយបន្តអាចឲ្យគេស្មានដឹងពីខ្លះៗ។





-ជាអ្នកធ្លាប់ស្គាល់- នាងតបហើយក៏ងាកមុខចេញគេចខ្សែភ្នែករបស់គេតែកាន់តែធ្វើឲ្យកំហឹងគេកើនលើសដើម ទើបស្រវាទាញរាងស្ដើង មកបុកដើមទ្រូងរឹងមាំរបស់ខ្លួន។

-ជាអ្នកធ្លាប់ស្គាល់ ច្បាស់ហើយមែនទេ?- គេសួរសំឡេងតាមដើងធ្មេញស្មារតុចក្រៀវច្រចាច់យ៉ាងខ្លាំង នាងមិនយល់នោះទេហេតុអីក៏ក្លាយទៅជាបែបនេះ។

-ទោះគាត់ជាអ្វី ក៏មិនទាក់ទងនិងលោកដែ-

-មិនទាក់ទងមែនទេ នាងនិយាយម្ដងទៀតទៅ-

-បើលោកនៅតែសួរទៀត ខ្ញុំនិងគិតថាលោកកំពុងតែប្រចណ្ឌខ្ញុំ ហើយនិងគេម្នាក់នោះ- ស៊ូហ៊ី ជ្រើសរើសនិយាយពាក្យនេះព្រោះដឹងថាមិនអាចមានរឿងបែបនេះកើតឡើងនោះទេ។

-ប្រចណ្ឌហ៎ា នាងគួរតែដឹងខ្លួនច្បាស់ថានៅក្នុងឋានៈអី កុំលើកពាក្យនេះមកនិយាយគ្មានថ្ងៃនោះទេ- គេប្រាប់សំឡេងស្មើរុញរាងស្ដើងមួយទំហឹងទៅលើគ្រែ នាងក្រមុំឱបស្មារបន្ថយភាពឈឺចាប់បិទភ្នែកយំយ៉ាងស្ងៀមស្ងាត់។

-ខ្ញុំដឹងតួនាទីខ្លួនឯងច្បាស់ណាស់ថានៅក្នុងឋានៈអី- នាងតបទាំងអណ្ដឺតអណ្ដកហើយក៏ឈឺចាប់កាន់តែខ្លាំងពេលនិយាយពាក្យនេះ។

-បើដឹងល្អហើយ ហើយក៏គួរតែដល់ពេលដែលត្រូវបំពេញតួនាទីរបស់ខ្លួនដែរ- គេប្រាប់សំឡេងរឹងដើរសំដៅគ្រែដោយការដាក់សំពាធ ស៊ូហ៊ី ចង់តែរត់ចេញពីបន្ទប់នេះទៅព្រោះតែឃើញភាពខឹងក្រោធរបស់គេ តែព្រោះជាម្ចាស់មិនមេត្តានាងនោះទេ ទើបទ្រាំបិទភ្នែកទទួលយកជតាកម្ម

របស់ខ្លួន រំលោភត្រូវទាញហែកគ្មានប្រណីបង្ហាញរាងកាយសស្អាតនៅពីមុខ សំឡេងស្រែកថ្ងូរនៃភាពឈឺចាប់បន្លឺឡើង ប្រៀបដូចជាពេលកំពុងនាំក្រចាក់រាងកាយនាងទាំងមូល នាងចង់ឲ្យរឿងទាំងនេះជាការយល់សប្តិតែមិនអាចនោះទេ ពេលនេះនាងស្ទើរតែដាច់ខ្យល់ទៅហើយព្រោះតែភាពព្រៃផ្សៃរបស់គេ។

-សូមអង្វរ ដោះលែងខ្ញុំទៅ អ្ហា...- សំឡេងស្អកស្រែកអង្វរលាយទឹកភ្នែកតែនៅមិនអាចធ្វើឲ្យគេបញ្ឈប់ទង្វើរបស់ខ្លួន អែលវីន កំពុងតែខាំញញូរាងកាយស្តើង ដែលពេលនេះសុទ្ធតែស្នាមក្រហមដោយសាធ្មេញរបស់គេ បែបនេះនៅមិនគ្រប់គ្រាន់នោះទេគេត្រូវតែទុកស្នាមលើរាងកាយនេះបញ្ជាក់កម្មសិទ្ធ។

ស៊ុហ៊ី ភ្ញាក់ដឹងខ្លួននាពេលព្រឹកគិតថាខ្លួនឯងកំពុងតែនៅពិភពផ្សេងមួយទៅហើយ តែមិនមែននោះទេការចងចាំទាំងប៉ុន្មានកាលពីយប់ត្រឡប់មកម្តងទៀត នាងចាប់ផ្តើមកម្រើកខ្លួនតិចៗតែក៏ត្រូវស្រែកថ្ងូរដោយភាពឈឺចាប់ ងាកសម្លឹងមើលក្បែរខ្លួនតែមិនឃើញគេនោះទេ សម្លឹងមើលរាងកាយខ្លួនសុទ្ធស្នាមក្រហមដោយសារធ្មេញ ជាពិសេសដើមទ្រូងទាំងសងខាងមានទាំងស្នាមជាំថែមទៀត។

-មនុស្សអាក្រក់- នាងអ៊ឹម្នាក់ឯងទឹកភ្នែកមុននឹងកម្រើកខ្លួនម្តងទៀតចុះពីគ្រែទាំងគ្រដាបគ្រដូសសំដៅបន្ទប់ទឹក។

ស៊ុហ៊ី រៀបចំខ្លួនរួចរាល់ចុះមកជាន់ក្រោមសម្លឹងមើលបន្ទប់ទទួលភ្ញៀវព្រោះដូចជាឮមាត់មនុស្សនៅទីនោះទើបដើរសំដៅទៅ។

-ខ្ញុំមានផ្ទៃពោះហើយ ជាសាច់ឈាមរបស់លោក-



សំឡេងនារីម្នាក់បន្លឺឡើង ធ្វើឲ្យអ្នកដែលដើរជិតដល់ត្រូវឈប់ឆ្ងក់បន្ទាប់ពីឮ ស៊ុហ៊ី ឈរស្ងៀមទ្រឹងមួយរយៈធ្វើមុននិងឈានជើងតិចៗដើរទៅជិត។

-នាងច្បាស់ហើយមែនទេ ថាជាកូនខ្ញុំ- សំឡេងគ្រលរបន្លឺឡើងដឹងច្បាស់ថាជាអ្នកណា។

-ហេតុអីក៏លោកនិយាយបែបនេះ?-

-នាងធ្វើអីខ្លះគួរតែដឹងខ្លួនឯងហើយ-

-ខ្ញុំច្បាស់ខ្លាំងណាស់- នាងតបសំឡេងស្ទើអែលវីន ញញឹមចំអកចុងមាត់សម្លឹងមើលមនុស្សស្រីដែលអះអាងមានកូនរបស់គេ។

-ខ្ញុំធ្វើអីខ្ញុំដឹងខ្លួនឯងច្បាស់ណាស់ នាងគិតថាខ្ញុំឲ្យមនុស្សស្រីដូចជានាងមកពរពោះកូនរបស់ខ្ញុំមែនទេ នាងប្រហែលជាយល់សប្តិហើយ-

-លោកនិយាយមានន័យថាម៉េច?-

-មិនបាច់ឲ្យខ្ញុំនិយាយច្រើននោះទេ នាងត្រូវការប៉ុន្មានប្រាប់មក-

-ខ្ញុំមិនត្រូវការប្រាក់ ខ្ញុំចង់ឲ្យលោកទទួលខុសត្រូវខ្ញុំនិងកូន-

-នោះមិនមែនជាកូនរបស់ខ្ញុំទេ-

-ហេតុអីក៏លោកជឿជាក់បែបនេះ-

-ខ្ញុំគ្មានថ្ងៃឲ្យកូនរបស់ខ្ញុំ នៅក្នុងពោះមនុស្សស្រីត្រឹមតួនាទីកំដរអារម្មណ៍នោះទេ ទោះបីជាការពិតក៏ខ្ញុំមិនទុកនៅក្នុងពោះនាងដូចគ្នា បែបនេះប្រហែលជាច្បាស់ហើយមែន-

ដេណា នារីបង្ហាញមុំតធ្លាប់ជាដៃគូរបស់គេ មានទឹកមុខអស់សង្ឃឹមមួយរំពេចន៍បន្ទាប់ពីឮ មិនគិតថាគេមានការជឿជាក់ខ្ពស់បែបនេះ

នោះទេសូម្បីតែនាងក៏ដឹងច្បាស់ពីរឿងនេះដូចគ្នា តែនាងពិតជាគ្មានអ្នក
ណាទៀតទេទើបមករកគេគិតថាគេនិងទទួលខុសត្រូវចំពោះរឿងនេះតែគេ
ជាមនុស្សឃោរឃៅគ្មានធម៌មេត្តាទាល់តែសោះ។

-ជេក នាំស្រីម្នាក់នេះចេញពីទីនេះ ខ្ញុំមិនចង់ឃើញមុខនាងទៀត
ទេ- អែលវីន ប្រាប់កូនចៅសំឡេងស្មើរមុននឹងដើរចេញទៅ។

-បាទចៅហ្វាយ- ជេក តបទទួលហើយក៏នាំនាងចេញទៅតែអ្នក
ម្ខាងទៀតបានត្រឹមអស់សង្ឃឹម។

ស៊ូហ៊ី បានត្រឹមឈរមើលទាំងទឹកភ្នែកមានអារម្មណ៍អាណិតស្រី
ម្នាក់នោះមិនគិតថាគេជាមនុស្សប្រុសឃោរឃៅមគ្រជាក់បែបនេះទេ បើជានាង
វិញប្រហែលជាមិនខុសពីស្រីម្នាក់នោះទេ គិតត្រឹមនេះក៏ធ្វើឲ្យនាងបារម្ភ
មួយរំពេចន៍ ព្រោះមួយរយៈក្រោយនេះគេមិនធ្លាប់ការពារជាមួយនាងនោះ
ទេបើនាងមានកូនមែនតើគេអាចនិង...។

-អ្នកនាងហេតុអីក៏នៅទីនេះ?- សំឡេងមេផ្ទះចំណាស់បន្លឺឡើងធ្វើ
ឲ្យនាងភ្ញាក់ព្រើតងាកទៅមើល។

-តឺ គ្មានអីទេ- នាងតបរដាក់រដុបងាកទៅមើលអ្នកនៅបន្ទប់ទទួល
ភ្ញៀវខ្លាចគេដឹងថានាងកំពុងលួចស្តាប់ តែមិនឃើញអ្នកណាម្នាក់នោះទេ
រាងធូរទ្រូងទើបងាកមកញញឹមដាក់ស្ត្រីចំណាស់វិញ។

-អ៊ំមានការអីមែនទេ?-

-តឺខ្ញុំរៀបចំអាហារសម្រាប់អ្នកនាងរួចរាល់ហើយ-

-ខ្ញុំដឹងហើយ អរគុណ- តបហើយក៏នាំគ្នាដើរទៅបន្ទប់អាហារ។

ស៊ូហ៊ី អង្គុយក្រោយភូមិគ្រឹះគិតពីរឿងរ៉ាវដែលកើតឡើងកន្លងមក



កំពុងតែគិតស្លុងអារម្មណ៍ ស្រាប់តែពេលឮសម្រឹបជើងអ្នកណាម្នាក់ដើរមក
ទើបងាកទៅមើល។

ជេក ដើរចូលមករាងទាក់ទើរថែមទាំងមានកាន់ឯកសារមួយនៅ
ក្នុងដៃធ្វើឲ្យនាងចាប់ផ្តើមងឿងឆ្ងល់។

-លោក ជេក មានការអីមែនទេ?-

-តឺចៅហ្វាយ ឲ្យយករបស់នេះប្រគល់ឲ្យអ្នកនាងរួមទាំង...- គេ
និយាយត្រឹមហ្នឹង ក៏ហុចសឺមីនោះទៅឲ្យនាងរួមទាំងសំបុត្រយន្តហោះ
ស៊ូហ៊ី ទទួលមកមើលចញ្ចើមចងចូលគ្នាងើបសម្លឹងអ្នកម្ខាងទៀតក្នុងន័យ
សួរ ជេក រាងញ៉េមញ៉ុមបន្តិចមុននឹងតប។

-ចៅហ្វាយត្រឡប់ទៅអង់គ្លេសហើយ នេះជាសំបុត្រយន្តហោះទៅ
កូរ៉េសម្រាប់អ្នកនាង- ស៊ូហ៊ី ឈរទ្រឹងមួយដង្ហើមបន្ទាប់ពីឮ ទីបំផុតថ្ងៃនេះ
ក៏មកដល់នាងតបក្នុងចិត្តមុននឹងងាកទៅមើលអ្នកម្ខាងទៀត។

-ខ្ញុំទៅរៀបចំសិន- នាងតបទាំងញញឹមក្រៀមហើយក៏ដើរទៅក្នុង
ជេក តាមសម្លឹងមើលនាងដោយក្តីអាណិត គេមិនយល់ចៅហ្វាយគេដូច
គ្នាដែលធ្វើបែបនេះ។

ស៊ូហ៊ី ឡើងមកដល់បន្ទប់លាឯកសារនោះមកមើល ជាក្រដាស
សែកជាច្រើនសន្លឹករួមទាំងកាតក្រេឌីត នេះប្រហែលជាថ្លៃខ្លួនរបស់នាង
ហើយ នាងគិតក្នុងទឹកភ្នែកហូរមកដូចបាក់ទំនប់លើកដៃស្ទាបទ្រូងខាង
ឆ្វេងមានអារម្មណ៍ឈឺខ្លាំងណាស់ នាងអស់តម្លៃសម្រាប់គេទៀតហើយ
ដល់ពេលដែលគេត្រូវកំចាត់នាងចេញពីជីវិតគេដែរ។

-អ្នកនាង- សំឡេងមេផ្ទះហៅទើបធ្វើឲ្យអ្នកដែលទើបចុះមកងាក

ទៅមើល គាត់មានទឹកមុខសោកសៅសម្លឹងមកនាង។

-ខ្ញុំត្រូវត្រឡប់ទៅវិញហើយ អរគុណអ៊ំ- នាងតបទាំងញញឹម ព្រៀមដើរទៅឱបគាត់បន្តិចមុននឹងដើរចេញទៅ។

-ចុះអីវ៉ាន់របស់អ្នកនាង?- ដេក សួរពេលឃើញនាងដើរមកដល់ រថយន្តមានតែកាបូបតូចមិនឃើញវ៉ាលី។

-ពេលខ្ញុំមកមានតែប៉ុណ្ណឹងទៅវិញក៏ដូចគ្នា- នាងតបហើយក៏ដើរ ចូលឡាន ក្នុងបន្ទប់មានសុទ្ធតែខោអាវមនុស្សស្រីទើបនាងគិតថារបស់ ទាំងនោះគេទិញសម្រាប់មនុស្សស្រីគ្រប់គ្នាដែលគេនាំមកទីនេះហើយ វា មិនមែនជារបស់នាងនោះទេហេតុអីក៏ត្រូវយកទៅនោះ។

ស៊ុហ៊ុ អង្គុយចាំងខាងក្រោយនាងចង់ដឹងពីរឿងកាលពីព្រឹកតែភាង ទាក់ទើបន្តិចមិនដឹងថាគួរសួរឬអត់នោះទេ។

-អ្នកនាងមានអីចង់សួរមែនទេ?- សំឡេង ដេក នៅចាំងខាងមុខ បន្លឺឡើងទើបធ្វើឲ្យនាងងើបមុខទៅមើល។

-គឺខ្ញុំចង់ដឹងស្រីម្នាក់កាលពីព្រឹកជា...-

-អ្នកនាងស្ដាប់ឮមែនទេ?- ដេក សួររាងភ្ញាក់ផ្អើលបន្តិច។

-ស្ដាប់ឮដោយចៃដន្យទេ- នាងតបតិចៗទាំងញញឹមខ្មាស។

-ស្រីម្នាក់នោះធ្លាប់ជាគូដណ្ដឹងចាស់របស់ចៅហ្វាយ-

-ចុះកូន កូនក្នុងផ្ទៃនោះ...-

នោះមិនមែនកូនរបស់ចៅហ្វាយទេ-

...កអីក៏លោកដឹង ខ្ញុំចង់សួរថាហេតុអីក៏ច្បាស់ម្ល៉េះ នាងអាច...-

...ហ្វាយមិនចូលចិត្តក្មេង ដូច្នេះគ្មានថ្ងៃដែលគាត់បណ្ដោយឲ្យ





មានរឿងបែបនេះកើតឡើងនោះទេ-

-គេមិនចូលចិត្តក្មេងហ៎- នាងរអ៊ូតិចៗហើយក៏ស្ងាត់ស្ងៀមទៅ បើនាងមានកូនគេ និងឲ្យនាងយកចេញដែរមែនទេ នាងគិតទាំង ខ្លាយស្របពេលរថយន្តមកដល់ព្រលានយន្តហោះ។





...១០...

ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ

ស៊ុហ៊ី ត្រឡប់មកដល់ផ្ទះទាំងអីវ៉ាន់ពេញដៃព្យាយាមបំភ្លេចរឿងទាំងនោះព្រោះកុំឲ្យអ្នកផ្ទះបារម្ភជាពិសេស ហេជីន។

-ស៊ុហ៊ី ត្រឡប់មកវិញហើយមែនទេ?- សំឡេង ហេជីន បន្លឺឡើងទាំងដើរទប់ពោះដែលរាងចាស់ខែសំដៅមក។

-ហ៊ឹម! ឯងយ៉ាងម៉េចហើយ?- ស៊ុហ៊ី សួរតបទាំងដើរទៅជួយត្រានាងដើរទៅក្នុងវិញ។

-គ្នាមិនអីទេ បានដើរលេងសប្បាយដែរទេ?-

-សប្បាយខ្លាំងណាស់-

-ហេតុអីក៏ទិញរបស់ច្រើនយ៉ាងនេះឯងមានលុយមកពីណា?-

-កុំគិតអី គ្នាចង់ទិញឲ្យអ្នកផ្ទះព្រោះមិនដែលបានទិញអីឲ្យឯងនិងជុយ៉ុង នោះទេចាត់ទុកថានេះជាកាដូទៅល្អទេ- នាងតបទាំងញញឹមតែក្នុងចិត្តពិតជាមានអារម្មណ៍ឈឺខ្លាំងណាស់។

ស៊ុហ៊ី ត្រឡប់មកធ្វើការទាំងអារម្មណ៍សោកសៅតែនៅប្រឹងញញឹមរាក់ទាក់ភ្ញៀវនាងខានមកធ្វើការមួយសប្ដាហ៍ ប្រហែលអ្នកនៅទីនេះឆ្ងល់ខ្លាំងហើយគិតហើយក៏រកនឹកហេតុផលពន្យល់ប្រាប់ពួកគេ។

-ស៊ុហ៊ី ត្រឡប់មកវិញហើយហ៎ា នៅទីនោះសប្បាយដែរទេ?- សេសួរសំឡេងរីករាយ ធ្វើឲ្យនាងចាប់ផ្ដើមងឿងឆ្ងល់និងសម្ដីរបស់មិត្តដឹងនាងទៅណាដែរមែនទេ។

-គឺ...-

-ហេតុអីក៏ស្ងាត់ទៅវិញ នៅអែស្សាញមិនសប្បាយទេហ៎- សេមី សួរបន្ថែមធ្វើឲ្យនាងបើកភ្នែកធំៗដោយភាពភ្ញាក់ផ្អើល។

-ហេតុអីក៏ ក៏ឯងដឹងរឿងនេះ-

-អ្នកគ្រប់គ្រងប្រាប់ថាឯងទៅទស្សនៈកិច្ចការងារនៅទីនោះ ហេតុអីក៏ធ្វើឫកពារភ្ញាក់ផ្អើលបែបនេះ- សេមី និយាយបន្ថែមទើបធ្វើឲ្យនាងរាងធូរទ្រូងបន្តិចស្មានថាពួកគេដឹងថានាងទៅធ្វើអីទៅហើយ។

-គ្នាទៅប្រញាប់ប្រញាល់ពេក គិតថាប្រហែលគ្មានអ្នកណាដឹងទេ-

-គេដឹងគ្រប់តែគ្នាហ្នឹង ម្នាក់ៗច្រណែនឯងខ្លាំងណាស់ ដែលបានទៅបារាំងទៀត ទៅអីមិនជាប់ទោស- នាងមិនតបគ្រាន់តែញញឹមតិចៗ។

ពីរខែកន្លងទៅហើយមិនឃើញ អែលវិន មកទីនេះនោះទេ ស៊ូហ៊ុ ស៊ើចចំអកខ្លួនឯងហេតុអីក៏នៅតែគិតពីគេមិនឈប់បែបនេះ ទំនាក់ទំនងពួកនាងចប់ហើយឈប់ចាំគេទៀតទៅនាងប្រាប់ខ្លួនឯងក្នុងចិត្ត ហើយក៏ដើរទៅបន្ទប់ទឹកដើរបានបន្តិចមានអារម្មណ៍វិលមុខរកដួល សំណាងមានដៃអ្នកណាម្នាក់មកជួយទប់ទាន់ទើបងាកទៅមើល។

-ស៊ូហ៊ុ យ៉ាងម៉េចហើយ?- សំឡេង យូជុន បន្លឺឡើងសម្លឹងមើលនាងដោយក្តីបារម្ភ។

-ខ្ញុំមិនអីទេ អរគុណ- នាងតបទាំងញញឹមហើយក៏រើខ្លួនតិចៗទើបគេសោយស្រង់ដៃតែក្នុងចិត្តនៅតែបារម្ភ។

ស៊ូហ៊ុ សង្ស័យក្លួចង្ហោរក្នុងបន្ទប់ទឹកមានអការៈបែបនេះប៉ុន្មានថ្ងៃទៅហើយមានអារម្មណ៍មិនស្វាស្រួល ទើបទៅទិញឧបករណ៍ពិនិត្យទឹកនោមមកមើលហើយក៏បុណ្យក្នុងចិត្តកុំឲ្យដូចអ្វីដែលនាងគិតឲ្យសោះ តែវាផ្ទុយស្រលះលទ្ធផលចេញមកបញ្ជាក់ថានាងមានផ្ទៃពោះ មិនអស់ចិត្តទើបទៅពិនិត្យនៅមន្ទីរពេទ្យម្តងទៀត លទ្ធផលនៅតែដដែលនាងមានផ្ទៃពោះពីរខែហើយ បន្ទាប់ពីដឹងធ្វើឲ្យនាងចាប់ផ្តើមខ្វល់ខ្វាយបើ អែលវិន ដឹងរឿងនេះគេច្បាស់ឲ្យនាងយកកូនចេញមិនខានទេ មិនបានតេជាសាច់ឈាមរបស់នាង នាងនិងមើលថែគេឲ្យបានល្អបំផុតទោះបីជាគេមិនខ្វល់ក៏ដោយនាងគិតហើយក៏យកដៃស្ទាបពោះ មានអារម្មណ៍សប្បាយចិត្តពេលដឹងថាមានជីវិតតូចៗនៅក្នុងនេះ។





ហេជីន ដើរចេញមកក្រៅផ្ទះព្រោះឮសំឡេងក្អួតរបស់មិត្តទើបចេញមកមើលនាងដើរតិចៗទប់ពោះរបស់ខ្លួនដែលចាស់ខែណាស់ទៅហើយ។

-ស៊ូហ៊ុ យ៉ាងម៉េចហើយ?- នាងសួរបណ្តើរអង្អែលខ្នងបណ្តើរដោយក្តីបារម្ភព្រោះឃើញអការៈបែបនេះច្រើនថ្ងៃហើយ។

-ខ្ញុំមិនអីទេ- ស៊ូហ៊ុ ងាកមកតបសំឡេងស្រាលដាក់បង្គុយលើបង់ផិតនោះរួមទាំងគ្រា ហេជីន មកអង្គុយដូចគ្នា។

-ឯងមិនស្រួលខ្លួនហេតុអីមិនទៅពេទ្យ-

-គ្នាមិនអីទេ កុំបារម្ភអី- ស៊ូហ៊ុ ងាកមកតបមិត្តទាំងល្ងើយ ហេជីន មើលមិត្តទាំងបារម្ភ មានអារម្មណ៍ថាប៉ុន្មានថ្ងៃមកនេះមិត្តនាងមានអាការៈប្លែកៗវិលមុខក្អួតចង្អោរដូចអាការៈចាញ់កូនរបស់នាង កាលពីមុនបេះដាក់ទើបចាប់ផ្តើមសង្ស័យពេលគិតដល់ពេលវេះកាត់របស់អ្នកស្រី ហៅនែពេលនោះនាងប្រាប់ថាខ្ចីលុយពីអ្នកធ្វើការ មិនអស់ចិត្តតែក៏មិនបានសួរហេតុមកឃើញអាការៈរបស់នាងបែបនេះទៀត សូមកុំឲ្យដូចអ្វីដែលនាងគិតទៅចុះ ហេជីន គិតទាំងខ្វល់ខ្វាយ។

-មានអីមែនទេ ហេតុអីក៏សម្លឹងមុខខ្ញុំបែបនេះ.- ស៊ុហ៊ី ងាកទៅសួរ ពេលឃើញមិត្តស្ងាត់ស្ងៀមហើយសម្លឹងមុខនាងមិនព្រិច។

-ស៊ុហ៊ី ថ្លៃៈកាត់អំស្រីឯងបានប្រាក់មកពីណា ប្រាប់ខ្ញុំតាមត្រង់មក.- ហេជីន សួរសំឡេងស្រាលធ្វើឲ្យ ស៊ុហ៊ី រាងភ្ញាក់ផ្អើលបន្តិច។

-ហេតុអីក៏ឯងសួរពីរឿងនេះ?- ស៊ុហ៊ី សួរតបនឹងគេចភ្នែកពេលឃើញ ហេជីន សម្លឹងមុខនាងចាំស្ដាប់។

-ឯងមិនទុកខ្ញុំជាមិត្តមែនទេ ទើបមិនចង់ប្រាប់រឿងនេះ.- ហេជីន តបទាំងមុខស្រពោនបែបអន់ចិត្ត។

-មិនមែនបែបនោះទេ ខ្ញុំ...- តើឲ្យប្រាប់យ៉ាងម៉េចទៅថានាងត្រូវលះបង់ខ្លួនដើម្បីបានប្រាក់នោះមកបើ ហេជីន ដឹងនឹងស្ដីបន្ទោសនាងជាមិនខានតែនាងពិតជាគ្មានជំរើសមែនគិតរួចក៏ងើបសម្លឹងមុខនាង។

-ខ្ញុំទៅធ្វើការនៅក្លឹប.- ហេជីន បើកភ្នែកធំៗបន្ទាប់ពីឮ ត្បិតនាងមិនធ្លាប់ទៅកន្លែងបែបនោះ តែនាងក៏ធ្លាប់ដឹងខ្លះៗមកដែរថាកន្លែងបែបនោះទៅវាជាកន្លែងយ៉ាងម៉េច។

-ស៊ុហ៊ី នេះឯង...-

-សុំទោស ហេជីន.- នាងប្រាប់តិចៗទាំងឱបមិត្តយំធ្វើឲ្យអ្នកម្ខាងទៀតឱបតបយំដូចគ្នា ហេតុអីក៏ពួកនាងមានវាសនាដូចគ្នាបែបនេះ។

-ឯងមិនបាច់សុំទោសទេ ខ្ញុំដឹងថាឯងធ្វើព្រោះភាពកត្តញ្ញូ.- នាងនិយាយតិចៗទាំងឱបលួងលោមអ្នកម្ខាងទៀត។

-ពួកយើងចាកចេញពីទីនេះទៅបានទេ?- ស៊ុហ៊ី ងាកខ្លួនចេញតិចៗជូតទឹកភ្នែកមុននឹងនិយាយធ្វើឲ្យអ្នកម្ខាងទៀតរិះគិត មែនហើយ





ចាកចេញពីទីនេះក៏ល្អដូចគ្នាទៅរស់នៅកន្លែងថ្មីចាប់ផ្ដើមជីវិតថ្មី គិតហើយក៏ងក់ក្បាលញញឹមតប ដោយមិនដឹងថាមានមនុស្សម្នាក់ទៀតកំពុងឈរស្ដាប់ពួកនាងនោះទេ។

ដូយ៉ុង ត្រឡប់មកដល់ផ្ទះមិនឃើញពួកនាងទើបដើររកមកមើលហើយក៏បានមកស្ដាប់ឮរឿងទាំងអស់ ដែលគេមិនធ្លាប់ដឹងទាល់តែសោះគេដឹងតែពីរៀន ហើយឆ្លៀតធ្វើការក្រៅម៉ោង មិនធ្លាប់ដឹងពីទុក្ខលំបាករបស់បងស្រីគេនោះទេដែលទ្រាំធ្វើគ្រប់យ៉ាងព្រោះតែអ្នកផ្ទះ។

-បងស្រី.- គេហៅសំឡេងស្រាលធ្វើឲ្យអ្នកដែលយំឱបគ្នាត្រូវងាកមកមើលដោយភាពភ្ញាក់ផ្អើល។

-ដូយ៉ុង មកដល់យូរហើយមែនទេ?- ស៊ុហ៊ី ងាកខ្លួនចេញសួរប្អូនតិចៗទាំងព្យាយាមជូតទឹកភ្នែកចេញពីថ្ពាល់។

-ខ្ញុំមកដល់យូរហើយ បងនាំគ្នាធ្វើអីនៅទីនេះ ឆាប់ចូលក្នុងទៅ.- គេប្រាប់ហើយក៏ដើរចូលក្នុងមុន ព្រោះបើនៅឈរតិចទៀតគេនឹងយំដែរមិនខានទេ នាងក្រមុំទាំងពីរងាកមើលមុខគ្នាទាំងខ្វល់ខ្វាយ មុននឹងនាំគ្នាដើរចូលក្នុងតាមក្រោយ។

-ដូយ៉ុង ឯងឮអស់ហើយមែនទេ?- ស៊ុហ៊ី សួរសំឡេងស្រាលពេលចូលមកដល់ក្នុងឃើញគេអង្គុយយ៉ាងស្ងៀមស្ងាត់នៅតុបាយ។

-នាំគ្នាញ៉ាំបាយទៅខ្ញុំឃ្លានហើយ.- គេប្រឹងនិយាយបន្លប់ហើយដូសបាយដាក់ចានមិនហ៊ានសម្លឹងមុខនាងនោះទេ។

-បងសុំទោស.- នាងនិយាយតិចៗទាំងដើរមកអង្គុយទល់មុខប្រទាំង ហេជីន ដូចគ្នា។

-បងមិនបាច់សុំទោសខ្ញុំនោះទេ ខ្ញុំយល់ហើយកុំបារម្ភអី- គេប្រាប់ តិចៗទាំងញញឹមញៀមមុននឹងចាប់ផ្ដើមញ៉ាំ។

-បងចង់ធ្វើអ្វី:- នាងប្រាប់សំឡេងស្រាលធ្វើឲ្យអ្នកម្ខាងទៀតងាក ទ្រីងបន្តិចងើបមុខមកមើល។

-តាមចិត្តបង ខ្ញុំមិនអីទេទៅនៅកន្លែងណាក៏បានដែរព្រោះគាត់ជួយខ្ញុំ ផ្សងចប់ហើយ- ឮចម្លើយរបស់គេទើបនាងញញឹមតបមុននឹងនាំគ្នាញ៉ាំ បន្តហើយក៏ធុចិត្តដែលប្អូនប្រុសមិនស្អប់ខ្ពើមដែលនាងក្លាយជាបែបនេះ។

ស៊ូហ៊ី សំងំក្នុងបន្ទប់សម្លឹងមើលក្រដាសសែកដែល អែលវិនឲ្យមកទាំងទឹកភ្នែក នាងមាននឹយត្រឹមលុយទាំងនេះតែប៉ុណ្ណោះ គិត ហើយក៏ប្រមូលដាក់ចូលស្រោមសំបុត្រវិញ។

ស៊ូហ៊ី ដាក់លិខិតលាឈប់ស្ងាត់ៗព្រោះមិនចង់ឲ្យអ្នកណាដឹងរឿង នេះទេសូម្បីតែ សេមី នាងឈរសម្លឹងមុខអគារខ្ពស់ទាំងសោកសៅបន្តិច មុននឹងដើរចេញទៅលែងងាកក្រោយ។

ប៉ុសាន...

នាងក្រមុំពីរនាក់ កំពុងតែឈរស្រូបខ្យល់អាកាសមាត់សមុទ្យមើល ទៅពួកនាងដូចជាស្រស់ស្រាយខ្លាំងណាស់ ស្របពេលឮសំឡេងស្រែក ហៅទើបនាំគ្នាងាកទៅមើល។

-បងស្រី!!- ជុយ៉ុង ស្រែកហៅទាំងរត់សំដៅមកស្ដាប់សំឡេងគេ ដូចជារីករាយហ្នឹងអ្វីមួយ។

-មានអីមែនទេ ជុយ៉ុង ហេតុអីក៏សប្បាយចិត្តយ៉ាងនេះ-

-ខ្ញុំឃើញហាងកាហ្វេជិតនេះគេដាក់ផ្លាកលក់ ទើបមានគំនិតចង់





បើកហាងកាហ្វេ- គេប្រាប់សំឡេងដង្ហក់។

-ហាងកាហ្វេ?- ស៊ូហ៊ី ឧទានទាំងងាកទៅសម្លឹងមើល ហេជីន។

-ជាគំនិតល្អបងគាំទ្រ- ហេជីន តបទាំងញញឹម។

-ឯងក៏មានគំនិតបែបនេះដែរមែនទេ?- ស៊ូហ៊ី ងាកមកសួរមិត្ត ដែលនៅជិត។

-ខ្ញុំក៏ចង់បើកហាងដូចគ្នាតែមិនដឹងថាបើកអីឮ ជុយ៉ុង និយាយ រឿងនេះទើបខ្ញុំនឹកឃើញដូចគ្នាដែរ-

-ពិតមែនហ៎បង ចុះបងស្រីគិតយ៉ាងម៉េច?- ជុយ៉ុង ឧទានទាំង សប្បាយចិត្តងាកទៅសួរ ស៊ូហ៊ី បន្ថែម។

-តាមចិត្តឯង បងគ្មានយោបល់ទេ-

-បើចឹងសម្រេចថាបងយល់ស្របហើយណា តែ...- គេនិយាយ ទាំងមុខស្រពោនព្រោះពេលនឹកឃើញថាគេគ្មានលុយគ្រប់គ្រាន់។

-កុំបារម្ភរឿងលុយអី បងមានប្រាក់សន្សំមួយចំនួនឯងយកទៅធ្វើ ដើមទុនទៅ- ស៊ូហ៊ី ប្រាប់ប្អូនប្រុសទាំងញញឹមផ្ដល់កំលាំងចិត្ត។

-បងមានលុយពិតមែនទេកុំកុហកខ្ញុំណា កុំដោយសារខ្ញុំធ្វើឲ្យបង លំបាកទៀតអី- គេប្រាប់ទាំងមុខស្រពោន។

-ឯងកុំគិតច្រើនអីយកប្រាក់នោះទៅ បើមិនចង់ឲ្យបងលំបាកប្រឹង ប្រែងធ្វើវាឲ្យជោគជ័យទៅ- នាងប្រាប់ទាំងដើរទៅជិតប្អូនប្រុសទើបគេញ ញឹមតបស្រាំឱបនាងជាប់។

ហាងកាហ្វេតូចមួយ ជាប់មាត់ឆ្នេរដែលមានអគារខ្ពស់ៗនៅស ខាងតែភ្ញៀវភាគច្រើនចូលចិត្តមកហាងនេះព្រោះតែមាន ម្ចាស់ហាងស្អា

ប្រមទាំងបុគ្គលិកស្រីស្អាតៗថែមទៀត។

«បងស្រីឆាប់ទៅសម្រាកទៅ ទុកខ្ញុំនៅមើលបានហើយ» ម៉ុយឹង ប្រាប់បងស្រីដែលកំពុងវិលៗរកក្តូតព្រោះអាការៈចាញ់កូន គេទើបតែដឹងពីរឿងនេះនោះទេពេលឃើញអាការៈចាញ់របស់នាង គេមិនបានខឹងមានតែបារម្ភអាណិតកាន់តែខ្លាំង ព្រោះដឹងថានាងធ្វើព្រោះតែការៈកាត់របស់ម៉ាក់គេ តែក៏ធ្វើឲ្យគេសប្បាយចិត្តដូចគ្នា ព្រោះគេជិតបានធ្វើជាពូគេទៀតហើយព្រោះ ហេជីន សម្រាលបានកូនស្រីហើយបងស្រីគេក៏មានទម្ងន់ថែមទៀតគេកំពុងតែចូលចិត្តក្មេងស្រាប់ផង។

«បងមិនអីទេ កុំបារម្ភអី» អ្នកដែលកំពុងតែឱនងើបៗនោះងាកមកតបទាំងល្ងើយ។

«បែបនេះហើយនៅថាមិនអីទៀតមែនទេ បងដូចជាម៉ាក់អ៊ុចឹងទោះជាឈឺក៏ប្រាប់ថាមិនអីដែរ» គេរអ៊ូរៗជួយគ្រានាងមករកកន្លែងអង្គុយ ស៊ូហ៊ី ឆ្លៀតសម្លក់ប្អូនប្រុសដែលប្រៀបធៀបនាងបែបនេះ តែគេរាយក៏ត្រូវដូចគ្នា។

«បងដឹងហើយ បងទៅសម្រាកក៏បានដែរ» នាងប្រាប់តិចៗទាំងធ្វើមុខដាក់ប្អូនប្រុសហើយក៏ដើរតិចៗទៅផ្ទះតូចមាត់ឆ្នេររបស់នាង ដែលនៅមិនឆ្ងាយពីហាងប៉ុន្មាននោះទេ។

ស៊ូហ៊ី មិនទាន់ទៅផ្ទះនោះទេនាងដើរលំហែតាមមាត់ឆ្នេរបណ្តើរយកដៃអង្អែលពោះរាបស្មើរដោយភាពរីករាយ ព្រោះមានជីវិតតូចមួយនៅក្នុងនោះនាងក្លាយជាម៉ាក់គេហើយ គិតត្រឹមនេះក៏ធ្វើឲ្យនាងសប្បាយចិត្តតែភាពរីករាយក៏ត្រូវរលប់បាត់ទៅវិញពេលគិតដល់គេ បុរសដែលធ្វើឲ្យ





ជីវិតនាងក្លាយជាបែបនេះ ពេលនេះគេប្រហែលជាសប្បាយចិត្តហើយដែលគ្មាននាងនៅក្បែរចាំតាមជញ្ជក់ឈាមគេតទៀតនោះ ទឹកភ្នែកនៃភាពឈឺចាប់និងតូចចិត្តចាប់ផ្តើមស្រក់ចុះ នាងព្យាយាមជូតចេញញញឹមផ្តល់កំលាំចិត្តខ្លួនឯងមុននឹងដើរត្រឡប់ទៅផ្ទះ។

«មានបានដំណឹងអីដែរទេ?» សំឡេងមានអំណាចបន្លឺឡើងសួរមនុស្សជំនិតដែលទើបដើរចូលមកដោយអន្ទះសារ។

«នៅទេចៅហ្វាយ» ជេក រាយការណ៍ទាំងឱនគោរព។

«គ្មានបានការណ៍មែន គ្រាន់តែមនុស្សស្រីម្នាក់ក៏រកមិនឃើញដែរ» អែលវិន រអ៊ូទាំងម៉ូម៉ៅ គេសំងំធ្វើការនៅអង់គ្លេសដើម្បីកុំឲ្យមានពេលគិតដល់នាងតែបានត្រឹមមួយរយៈប៉ុណ្ណោះ ព្រោះមិនអាចហាមអារម្មណ៍នឹកទើបធ្វើដំណើរទៅកូរ៉េ តែមនុស្សរបស់គេរាយការណ៍ថានាងដាក់ពាក្យលាឈប់ថែមទាំងលក់ផ្ទះថែមទៀតធ្វើឲ្យគេចាប់ផ្តើមម៉ូម៉ៅក្តៅក្រហាយ នៅរឿងមួយទៀតនោះគឺ នាងផ្ញើរបស់ម្យ៉ាងឲ្យគេថែមទៀតវាជាសែកប្រាក់និងកាតក្រេឌីត ដែលគេធ្លាប់ផ្ញើឲ្យនាងកាលនៅអេស្បាញនោះហើយ គេមិនយល់ហេតុអីក៏នាងផ្ញើរបស់នេះឲ្យគេវិញនោះទេព្យាយាមគិតយ៉ាងណាក៏មិនយល់ គេឲ្យមនុស្សតាមស៊ើបជានិច្ចនេះច្រើនខែហើយ នៅតែគ្មានបានដំណឹងអីបន្តិចសោះធ្វើឲ្យគេកាន់តែនៅមិនសុខ។

«ពេលនេះម៉ាក់ខ្ញុំនៅឯណា?»

«លោកស្រីនៅញូយ៉ក»

«តាមដានគាត់ ក្រែងស្រីម្នាក់នោះទាក់ទងទៅឮទេ?» គេប្រាប់មនុស្សជំនិតសំឡេងរឹង។

-បាទចៅហ្វាយ- ជេក តបទទួលហើយក៏ដើរចេញមកវិញ មាន អ្នកដែលខាងក្នុងកំពុងក្ដាប់ដៃណែនដោយកំហឹង។

-ពិតជាខ្លាំងមែន ហ៊ានចាកចេញពីខ្ញុំ បើរកឃើញពេលណា ដឹងគ្នាមិនខានទេ- គេនិយាយសំឡេងតាមដើងធ្មេញចាក់ការកៅ របស់ខ្លួនបន្តែអារម្មណ៍នៅមិនស្ងប់នោះទេ ស្របពេលសំឡេងគោះទ្វារ បន្ទប់បន្លឺឡើងទើងាកទៅមើលទាំងមុខក្រញ៉ូវ។

-ហេតុអីក៏ធ្វើមុខដូចធុញទ្រាន់ពិភពលោកបែបនេះ មានរឿងអី មែនទេ?- សំឡេង ចាស៊ីន ទើបដើរចូលមកបន្លឺឡើង។

-គ្មានស្អីទេ ហើយឯងមកមានការអី?-

-បើគ្មានការមកមិនបានឬយ៉ាងម៉េច?- ចាស៊ីន សួរទាំងធ្វើមុខខឹ ដាក់តែអ្នកម្ខាងទៀតដូចជាគ្មានអារម្មណ៍ចង់និយាយប៉ុន្មានទេ។

-យើងគ្មានអារម្មណ៍ចង់និយាយជាមួយឯងទេ ឆាប់ទៅវិញទៅ- អែលវិន និយាយសំឡេងធុញទ្រាន់ធ្វើឲ្យមិត្តគេចាប់ផ្ដើមងឿងឆ្ងល់។

-នេះមិនសមជាឯងទេ មកដេញយើងគ្មានសុជីវធម៌បែបនេះ-

-យើងប្រាប់ហើយថាកំពុងតែអារម្មណ៍មិនល្អ-

-ការងារច្រើនឬយ៉ាងម៉េច ឬក៏...-

-គ្មានស្អីទេ-

-បើចឹងទៅរកកន្លែងបន្ធូរអារម្មណ៍តើល្អទេ យើងទើបស្គាល់កន្លែង ថ្មីតើចង់ទៅដែរទេ?-

-មិនទៅយើងចង់សម្រាក-

-អេ! ហេតុអីក៏បដិសេធលឿនយ៉ាងនេះ ឯងមិនមែនបែបនេះទេ





កាលពីមុន មានអ្នកណាធ្វើឲ្យឯងក្លាយជាបែបនេះមែនទេ? ឬក៏ស្រីម្នាក់ នោះ?- អែលវិន មិនមាត់បានត្រឹមអង្គុយស្ងៀមធ្វើឲ្យ ចាស៊ីន ចាប់ផ្ដើម សង្ស័យអាការៈរបស់គេ។

-ចុះនាងទៅណាហើយ កុំប្រាប់ថាឯងបោះបង់នាងហើយ ហេតុអី មិនប្រាប់យើង-

-យើងមិនបានបោះបង់នាងនោះទេ តែនាងរត់ចេញពីយើង- ចាស៊ីន បើកភ្នែកធំៗព្រោះតែភ្ញាក់ផ្អើលហើយក៏អស់សំណើចព្រោះអាចស្មាន ដឹងថាមិត្តគេម៉ូម៉ៅដោយសារអី។

-កុំប្រាប់ណាថាឯងម៉ូម៉ៅព្រោះតែរកនាងមិនឃើញ- ចាស៊ីន និយាយបណ្ដើរសើចបណ្ដើរធ្វើឲ្យ អែលវិន ចាប់ផ្ដើមមានអារម្មណ៍មិនសូវ ល្អព្រោះមិត្តគេស្មានដឹងរឿងនេះ។

-ឯងល្មមឈប់សើចបានហើយនៅ ឬក៏ចង់ត្រូវកណ្ដាប់ដៃរបស់ យើងទើបឈប់- អែលវិន និយាយសំឡេងរឹងទើប ចាស៊ីន ត្រូវឈប់សើច តែនៅស្នាមញញឹមលើផ្ទៃមុខនៅឡើយ។

-ហើយឯងធ្វើស្អីខ្លះបាននាងរត់ចេញទៅបែបនេះ-

-គ្មានធ្វើស្អីទេ គ្រាន់តែឲ្យលុយនាងមួយចំនួន ហើយបញ្ជូននាង ទៅភូមិវិញតែប៉ុណ្ណឹង- អែលវិន ប្រាប់សំឡេងស្រាល ចាស៊ីន គ្រាន់តែងក់ ក្បាលទទួលដឹង។

-ហើយចុះពេលនេះមិនទាន់បានដំណឹងពីនាងទៅមែនទេ?-

-នៅទេ កំពុងស៊ើប-

-ហេតុអីក៏នៅតាមរកនាង បើឯងគង់តែបោះបង់នាងដដែល មិន

ឲ្យនាងទៅតាមផ្លូវរបស់ខ្លួនទៅ» អែលវិន នៅស្ងៀមគេក៏មិនដឹងដូចគ្នាហេតុអីក៏ត្រូវតាមរកនាង តែពេលដែលគ្មាននាងនៅក្បែរធ្វើឲ្យគេមានអារម្មណ៍ថានឹកចង់ឃើញមុខនាងខ្លាំងណាស់។

«ឯងប្រហែលកំពុងលង់ស្រលាញ់នាងហើយ មិនដឹងខ្លួនឬយ៉ាងម៉េច» ឃើញមិត្តនៅស្ងៀមទើបនិយាយបន្ថែម។

«បិទមាត់របស់ឯងទៅ គ្មានថ្ងៃទៅជាបែបនោះទេ» អែលវិន តបសំឡេងរឹង ចាស៊ីន បានត្រឹមគ្រវីក្បាលនឹងឫកពាររបស់មិត្តបែបនេះហើយនីមិនដងខ្លួនទៀត។

«យើងគិតថាឯងក៏មិនខុសពីអារម្មៀរ វីឆាត ដែរមិនស្រលាញ់វាតែចុងក្រោយក៏ងប់ស្រលាញ់ងើបមុខមិនរួច» ចាស៊ីន និយាយទាំងឆ្លៀតដៀងភ្នែកមើលមិត្តដែលកំពុងសម្លក់មក។

«កុំយកយើងទៅប្រៀបធៀបជាមួយអារម្មៀនោះ យើងគ្មានថ្ងៃដូចគេទេ ឯងក៏ដឹងមនុស្សស្រីសម្រាប់យើងយ៉ាងម៉េច!»

«អូខេ យើងឈប់និយាយហើយ តែថាបើយើងរកឃើញនាងយើងសុំហើយណា ហាមឯងមករញ៉េរញ៉ៃជាមួយនាងទៀត» ចាស៊ីន និយាយបញ្ជាក់មុននឹងដើរចេញទៅធ្វើឲ្យ អែលវិន ចាប់ផ្តើមម៉ូម៉ៅចង់តែស្ទុះទៅដាល់មាត់នោះទេ។

«យើងស្រលាញ់នាងមែនទេ មិនអាចទេគ្មានផ្លូវនោះទេ» គេរអ៊ូរងុំរវម្នាក់ឯងហើយក៏ធ្វើការបន្តទាំងម៉ូហ្មង។

..................

«ស៊ូហ៊ី ឆាប់ទៅសម្រាកទៅមកធ្វើអីទីនេះ?» ហេជីន និយាយថា



ឲ្យអ្នកដែលមានពោះជិតគ្រប់ខែទៅហើយ តែនៅដើរទៅដើរមកតិបតុបៗក្នុងហាងនៅឡើយ។

«គ្នាអផ្សុកណាស់ ឲ្យគ្នាជួយផងបានទេ?»

«មិនបានទេ ចុះបើមានរឿងអីកើតឡើងនោះគិតយ៉ាងម៉េច ឆាប់ទៅបន្ទប់សម្រាកវិញទៅ» ហេជីន ប្រាប់សំឡេងរឹងទាំងលួចញញឹមចំអកនាងដឹងថាមិត្តអផ្សុកចង់ជួយ តែខ្លាចប៉ះពាល់ដល់កូនក្នុងផ្ទៃទើបចង់ឲ្យសម្រាកច្រើនជាង ហើយម្យ៉ាងទៀតកាលនាងទម្ងន់ជិតគ្រប់ខែក៏ត្រូវគេស្តីឲ្យបែបនេះដូចគ្នាទើបចង់ថាសងសឹកម្តង។

«ឯងស្តីឲ្យព្រោះចង់សងសឹកខ្ញុំមែនទេ ហេជីន» ស៊ូហ៊ី សួរទាំងមុខជូរពេលនឹកឃើញដល់ពេលនាងធ្លាប់ស្តីឲ្យមិត្តម្តងដែរ។

«បើដឹងល្អហើយឆាប់ទៅបន្ទប់វិញទៅ» ហេជីន តបទាំងញញឹមតិចៗជួយគ្រាមិត្តដើរទៅបន្ទប់សម្រាកខាងក្រោយហាង។

ស៊ូហ៊ី សម្រាលបានកូនភ្លោះប្រុសស្រីពីរនាក់នាងសម្លឹងមើលកូនតូចទាំងពីរទាំងទឹកភ្នែក ហេជីន ឃើញបែបនេះទើបដើរទៅជិតលួងលោម ព្រោះដឹងថានាងកំពុងគិតអី ព្រោះស្ថានភាពពួកនាងក៏មិនខុសគ្នានោះទេ នាងដឹងរឿងរបស់ ស៊ូហ៊ី ខ្លះៗតែប៉ុណ្ណោះដឹងថាមិត្តមិនចង់និយាយទើបមិនហ៊ានសួរដេញដោលបន្តទៀត។

ច្រើនឆ្នាំកន្លងទៅ...

ព្រឹកថ្ងៃថ្មីមកដល់ ទេសភាពមាត់ឆ្នេរដ៏ស្រស់ស្អាតកំពុងទាក់ទាញអ្នកទស្សនាយ៉ាងច្រើនកុះករ សំឡេងក្មេងប្រុសស្រីពីរនាក់កំពុងស្រែកប្រទ្បេងគ្នាលេងយ៉ាងសប្បាយរីករាយ ធ្វើឲ្យអ្នកជាម្តាយឈរមើល

ទឹកមុខពោរពេញដោយស្នាមញញឹម ហើយក៏នឹកទៅដល់ [illegible] ពេលនេះប្រហែលជាកំពុងមាន សុភមង្គលជាមួយគ្រួសាររបស់ [illegible] គ្នាបន្ទាប់ពីត្រូវឆ្លងកាត់ព្យុះភ្លៀងរឿងរ៉ាវជាច្រើនកន្លងមក [illegible] រកបានសុភមង្គលពេញលេញ នៅសល់តែនាងនោះទេគិតដល់ត្រឹមនេះ ធ្វើឲ្យមុខនាងចាប់ផ្ដើមស្រពោនពេលនឹកដល់គេម្នាក់នោះ នាងមិនធ្លាប់ភ្លេចគេនោះទេ កាន់តែឃើញមុខកូនធ្វើឲ្យនាងកាន់តែនឹកគេលើសដើម គិតហើយក៏រលាស់គំនិតទាំងនោះចេញងាកទៅមើលក្មេងៗ។

-បានហើយក្មេងៗឆាប់ចូលផ្ទះមក- សំឡេងស្រែកប្រាប់ដែលស៊ាំទម្លាប់ទើបធ្វើឲ្យពួកគេរត់មកយ៉ាងលឿន។

-ម៉ាក់ហ្អាស កូនឃ្លានហើយ-

-កូនក៏ឃ្លានដែរ- សំឡេងក្មេងៗទាំងពីរនិយាយបន្តបណ្ដាក់គ្នាធ្វើឲ្យអ្នកជាម្ដាយញញឹមនឹងភាពគួរឲ្យស្រលាញ់របស់ពួកគេ។

-តោះនាំគ្នាងូតទឹកសិនទើបអាចញ៉ាំបាយបាន ឮទេ- នាងប្រាប់ហើយក៏ដឹកដៃគ្នាចូលទៅក្នុង។

ស៊ូហ៊ី រៀបចំរួចរាល់ទើបជូនកូនទៅសាលាមុននឹងទៅហាង ហាងការហ្វេរបស់នាងកាន់តែល្បី ពីមួយថ្ងៃទៅមួយថ្ងៃមានភ្ញៀវកាន់តែច្រើនភាពច្រើនជាបុគ្គលិកសណ្ឋាគារនៅជិតនេះឯង។

ក្នុងបន្ទប់ធ្វើការរបស់ធំទូលាយ ជាន់លើបំផុតរបស់សណ្ឋាគារ បុរសម្នាក់កំពុងមមាញឹកពិនិត្យឯកសារនៅលើតុយ៉ាងស្ងៀមស្ងាត់ តែដៃរហ័សភ្លែករវៃពិនិត្យហើយស៊ីញ៉េ ស្របពេលសំឡេងគោះទ្វារបន្ទប់បន្លឺឡើង មនុស្សរបស់គេដើរចូលមកទាំងមាកាន់ឯកសារមកជាមួយ។





-ការងារទីនេះយ៉ាងម៉េចហើយ?- គេសួរកូនចៅដែលទើបចូលមកទាំងភ្នែកនៅរវល់ជាមួយឯកសារនៅឡើយ។

-រៀបរយទេចៅហ្វាយ-

-ចុះការងារសាងសង់ មានបញ្ហាអីដែរទេ?-

-គ្មានទេ រៀបរយដូចគ្នា-

-ហ៊ឹម! បើគ្មានអីទេចេញទៅវិញចុះ- គេប្រាប់ទាំងហុចឯងសារដែលឆែករួចត្រឡប់ទៅវិញ។

-គួរឲ្យអាណិតចៅហ្វាយដល់ហើយ- ដេក និយាយទាំងមុខស្រពោនប្រាប់ដៃគូរបស់គេ ជីម ដែលនៅមុខបន្ទប់។

-មានរឿងអី?-

-ឯងក៏ដឹងតាំងពី អ្នកនាង ស៊ូហ៊ី ចាកចេញទៅគាត់ដូចជាស្ងាត់ស្ងៀមយ៉ាងម៉េចមិនដឹងទេ?-

-ឯងគិតថាចៅហ្វាយស្រលាញ់នាងតើមែនទេ?-

-មិនដឹងទេ តែគាត់មិនធ្លាប់បែបនេះចំពោះស្រីណានោះទេ-

-យើងមិនដឹងដូចគ្នា ចាំតែមើលទៅ- គេនិយាយរួចក៏នាំគ្នាទៅធ្វើការរៀងខ្លួន។

អៃលវិន ឈរក្នុងបន្ទប់ធ្វើការបែមុខទៅជញ្ជាំងកញ្ចក់សម្លឹងមើលផ្ទៃសមុទ្រធំធេង គេខានមកកូរ៉េប៉ុន្មានឆ្នាំហើយបន្ទាប់ពីមានរឿងនោះមក មកលើកនេះព្រោះយល់ថាសេអ៊ូលគួរឲ្យធុញ ទើបមកប៊ូសានព្រោះគេមានគំរោងសង់សណ្ឋាគារបន្ថែមផង កំលោះឈរមួយសន្ទុះនឹកឃើញចង់ដើរលំហែរមាត់ឆ្នេរទើបចុះទៅ មកដល់ឆ្នាក់ក្រឡេកឃើញក្មេងប្រុសស្រី

ពីរនាក់កំពុងពួនភ្នំខ្សាច់លេង គេឈរមើលមួយសន្ទុះមុននឹងឈោងជើងដើរតិចៗទៅ -មើលទៅដូចជាកូនកាត់ទៀត- គេគិតក្នុងចិត្តទាំងញញឹមមានអារម្មណ៍ថាពួកគេគួរឲ្យស្រលាញ់។

-សួស្តី កំពុងធ្វើអីហ្នឹង- គេសួរតិចៗទាំងដើរទៅអង្គុយជិតធ្វើឲ្យពួកគេទាំងពីរនាំគ្នាងាកមកមើលទាំងងឿងឆ្ងល់។

-កំពុងលេងភ្នំខ្សាច់- ក្មេងប្រុសងាកមកតបទាំងញញឹមហើយក៏ងាកទៅវិញ។

-ពូចង់លេងដែរទេ?- ក្មេងស្រីងាកមកសួរទាំងញញឹមធ្វើឲ្យគេសម្លឹងមើលនាងរាងភ្លឹកបន្តិចព្រោះមានអារម្មណ៍ថាដូចនណាម្នាក់។

-ពួកយើងដូរលេងអីផ្សេងល្អទេ?- គេសួរតិចៗបង្កប់ស្នាមញញឹមធ្វើឲ្យមនុស្សជំនិតទាំងពីរមើលមុខគ្នាឡេងឡង់ ព្រោះខានឃើញចៅហ្វាយគេញញឹមបែបនេះយូរមកហើយ ហើយគាត់ក៏មិនសូវចូលចិត្តក្មេងដែរតែបែរជាមកអង្គុយនិយាយជាមួយក្មេងតូចទាំងពីរនេះទៅវិញ។

-លេងអីទៅ?- ក្មេងប្រុសសួរតបទាំងងឿងឆ្ងល់សម្លឹងអ្នកម្ខាងទៀតភ្លឹះៗចាំស្តាប់។

-ពួកយើងទៅដើរលេងទិញរបស់អីផ្សេងល្អទេ?- ក្មេងទាំងពីរងាកមើលមុខគ្នាបើកភ្នែកធំៗដោយភាពភ្ញាក់ផ្អើល។

-តែគ្មានលុយទេ- ក្មេងប្រុសតបសំឡេងស្រាលធ្វើមុខស្រពោន។

-ពូទិញឲ្យល្អទេ?- គេស្នើបន្ថែម ធ្វើឲ្យពួកគេទាំងពីរមើលមុខគ្នាញញឹមសប្បាយចិត្ត តែក្រោយមកក៏មុខស្រពោន។

-ម៉ាក់ប្រាប់ថាមិនត្រូវទទួលរបស់ពីមនុស្សមិនស្គាល់នោះទេ- គេ



ផ្អែញចិញ្ចើមញញឹមពិតជាឆ្លាតមែន។

-បើចឹងពួកយើងធ្វើការស្គាល់គ្នាទៅល្អទេ ពូឈ្មោះ អែលវិន- គេប្រាប់ទាំងលូកដៃទៅជាការគួរសម។

-ខ្ញុំឈ្មោះ អេរិច-

-ខ្ញុំឈ្មោះ អាយរីន- ក្មេងទាំងពីរក្រោកឈរនិយាយទាំងញញឹម អែលវិន សម្លឹងមើលមុខពួកគេទាំងពីរកាន់តែធ្វើឲ្យគេមានអារម្មណ៍ស្និទ្ធស្នាលមិនធ្លាប់មាន។

-អូខេ ពេលនេះពួកយើងស្គាល់គ្នាហើយអាចទៅបានហើយនៅ?-

-បាទ/ចាសបាន- ពួកគេឆ្លើយតបព្រមគ្នាទាំងក្រោកឈរបោសខោអាវដោយភាពរីករាយគ្រាន់តែឮថាទៅទិញរបស់លេង។

-នាំគ្នាទៅធ្វើអីធ្វើទៅ- គេងាកមកប្រាប់មនុស្សជំនិតទាំងពីរដែលកំពុងឈរមើលមុននឹងដឹកដៃក្មេងទាំងពីរដើរទៅ ធ្វើឲ្យពួកគេកាន់តែងឿងឆ្ងល់លើសដើមពីឫកពាចៅហ្វាយគេតែបានត្រឹមឈរមើល។

-សូមស្វាគមន៍ ត្រូវការអ្វីដែរ- ស៊ូហ៊ី រាក់ទាក់ភ្ញៀវតែពេលដែលទើបមើលក៏ត្រូវឈប់ឆ្ងក់បន្តិចពេលឃើញថាជាអ្នកណា។

-ស៊ូហ៊ី ហេតុអីក៏នៅទីនេះ?- យូជុន សួរទាំងភ្ញាក់ផ្អើលលាយគ្រេកអរ គេទើបផ្លាស់មកសាខាសណ្ឋាគារនៅប៊ូសាននេះ តាំងពីនាងឈប់ធ្វើការគេព្យាយាមទាក់ទងនាងរហូត តែមិនបានដំណឹងអីនោះទេ ហើយបែរជាមកជួបនាងនៅទីនេះទៅវិញធ្វើឲ្យគេរីករាយខ្លាំងណាស់ នាងក្រមុំញញឹមតិចៗមិនគិតថាបានជួបគេនៅទីនេះនោះទេ។

-ខ្ញុំធ្វើការនៅទីនេះ ចុះលោក?-

-ខ្ញុំប្ដូរមកធ្វើសាខានៅទីនេះដូចគ្នា ពិតជាចៃដន្យមែនដែលបានជួបនាងនៅទីនេះ- គេប្រាប់ទាំងញញឹមតែអ្នកម្ខាងទៀតធ្វើមុខលេបមិនចូលខ្ទាក់មិនចេញនោះទេ ព្រោះនាងព្យាយាមគេចពីមនុស្សគេចពីបញ្ហាទាំងអស់តែនៅតែមិនអាចរួចផុតទៀត។

-ចាស លោកត្រូវការអីដែរ?- នាងសួរតិចៗទាំងលោដៃទៅរកកៅអីដែលនៅជិតនោះ។

-សុំកាហ្វេ-

-ចាស ចាំបន្តិច- នាងប្រាប់ហើយក៏ដើរទៅក្នុង ដោយមិនដឹងថាមានខ្សែភ្នែកពីរគូរកំពុងតែសម្លឹងមើលនាងនោះទេ ជេក និង ជីម បន្ទាប់ពីចៅហ្វាយគេដេញទើបគេត្រូវរកកន្លែងលំហែបន្តិចដែរ តែពេលមកដល់មុននេះបុគ្គលិកស្រីផ្សេងជាអ្នកទទួលទើបមិនឃើញ ស៊ុហ៊ី។

-គួរតែប្រាប់ចៅហ្វាយដែរទេ?- ជីម ខ្សឹបសួរដៃគូទាំងដែលភ្នែកនៅតែសម្លឹងទៅនារីនៅតុខានជ័រមិនឈប់។

-កុំអីល្អជាង-

-ហេតុអី?-

-ព្រោះខ្ញុំអាណិតនាង- ជេក ប្រាប់សំឡេងស្ទើរគេដឹងថាចៅហ្វាយគេមិនធ្លាប់ស្រលាញ់មនុស្សស្រីណាម្នាក់នោះទេ កាន់តែឃើញនាងខុសពីមនុស្សស្រីដទៃទៀតកាន់តែអាណិត។

អែលវិន នាំក្មេងៗមកសណ្ឋាគាររបស់គេមកជាន់ដែលលក់សំភារៈក្មេងមើលទៅពួកគេដូចជាសប្បាយចិត្តខ្លាំងណាស់ ឃើញបែបនេះក៏ធ្វើឲ្យគេមានសេចក្ដីសុខដោយមិនដឹងមូលហេតុទាំងដែលគ្មានជាប់ទាក់ទង



គ្នាអីបន្តិចសោះ។

-រើសឆ្អែតហើយនៅ ហ៊ឹម- គេសួរក្មេងទាំងពីរដែលដើរមើលរបស់របរជាច្រើនតែមិនឃើញរើសអ្វីមួយសោះ។

-អាចទិញបានមែនទេ?- អេរិច សួរសម្លឹងមើលគេភ្លឹះៗ។

-ច្បាស់ជាបាន- គេតបទាំងញញឹមងាកមើលនាងតូចដែលមិនទាន់បានរើសអ្វីមួយនិងគេ។

-អាយរីន ហេតុអីមិនរើសទៅ?- គេសួរតិចៗទាំងលើកនាងមកពរនាងតូចសម្លឹងមើលគេភ្លឹះៗ។

-ម៉ាក់ៗប្រាប់ថាមិនត្រូវទិញរបស់លេងផ្ដេសផ្ដាសទេ- នាងតូចនិយាយតិចៗមើលរបស់នៅនិងមុខទាំងសោកស្ដាយ អែលវិន ជ្រួញចិញ្ចើម "ជាម្ដាយយ៉ាងម៉េចគ្រាន់តែទិញរបស់ឲ្យកូនលេងក៏មិនបានដែរ" គេរអ៊ូរទាំម្នាក់ឯង។

-មិនអីទេ ចាំពូប្រាប់ម៉ាក់ក្មួយថាពូទិញឲ្យល្អទេ- គេប្រាប់ទាំងនាំនាងដើរសំដៅរបស់ដែលនាងចូលចិត្ត។

-ពិតមែនហ៎- នាងតូចសួរបញ្ជាក់ទាំងសម្លឹងមើលមុខគេភ្លឹះៗ។

-បាទពិតហើយ- គេតបទទួលទាំងញញឹមធ្វើឲ្យនាងស្ទុះចុះទៅរើសរបស់ដែលខ្លួនចូលចិត្តជាច្រើន បើគេមានកូនប៉ុននេះមិនដឹងជាល្អយ៉ាងណានោះទេ គេគិតក្នុងចិត្តហើយក៏រលាស់គំនិតទាំងនោះចេញវិញ។

-បង ស៊ុហ៊ី- សំឡេងស្រែកហៅនៅខាងក្រោយដែលស៊ាំទម្លាប់ស្ដាប់ទៅដូចជាមានរឿងអីមិនល្អទើបងាកទៅមើល។

-មានអីមែនទេ អ៊ុនប៊ី- នាងសួរតបទាំងងឿងឆ្ងល់ពេលឃើញអ្ន

ម្នាក់ទៀត អ៊ីនប៊ី ជាក្មេងស្រីកំព្រាដែលនាងទើបជួប [illegible] រាណិតទើបនាំមកនៅជាមួយគ្រាន់ជួយមើលក្មេង [illegible]។

-បងស្រីខ្ញុំរក មេរីត និង រ៉ាយវីន មិនឃើញទេ- [illegible]ប្រាប់ទាំងយំលាយភ័យធ្វើឲ្យអ្នកម្នាក់ទៀតចាប់ផ្ដើមភ័យដូចគ្នា។

-ពួកគេដើរលេងជិតៗនោះទេដឹង ឯងបានរកសព្វហើយនៅ- ស៊ូហ៊ី ព្យាយាមសួរយ៉ាងចិត្តត្រជាក់ នាងមិនបានគិតថាបាត់ពួកគេទាំងពីរនោះទេ បើមែននោះនាងច្បាស់ជាឆ្កួតមិនខានទេ។

-ខ្ញុំរកអស់ហើយតែមិនឃើញនោះទេ គិតយ៉ាងម៉េចទៅបង-

-មិនអីទេ កុំបារម្ភអីពួកយើងទៅរកម្ដងទៀតទៅ- ស៊ូហ៊ី ប្រាប់យ៉ាងចិត្តត្រជាក់ដោះអាវការពារប្រលាក់ចេញនាំគ្នាចេញពីហាង ពាក្យសន្ទនារបស់ពួកនាងធ្វើឲ្យ ជេក និង ជីម មើលមុខគ្នាទាំងងឿងឆ្ងល់មិនគិតថាពួកគេស្ដាប់ច្រលំនោះទេ ពួកគេគិតថានាងប្រហែលរៀបការហើយទើបមានកូនបែបនេះ គិតហើយក៏នាំគ្នាដើរចេញពីហាង។







...១១...

ស៊ូហ៊ី ដើរតាមមាត់ឆ្នេរយ៉ាងយូរនៅតែមិនឃើញ តែទោះបីដើររកមើលតាមហាងនានានៅទីនោះដែរក៏មិនឃើញដូចគ្នា ទើបត្រឡប់មកផ្ទះវិញ ព្រោះគិតថាពួកគេអាចនិងមកផ្ទះមុនតែគ្មាននោះទេ ទើបអង្គុយយំនៅមុខផ្ទះនាងមិនអស់ចិត្តព្រោះពួកគេមិនធ្លាប់ដើរទៅណាឆ្ងាយនោះទេ។

-បងស្រីសូមទោស មកពីខ្ញុំទើបមានរឿងបែបនេះ- អ៊ីនប៊ី និយាយទាំងទឹកភ្នែក មានអារម្មណ៍ខុសព្រោះតែនាងមើលពួកគេមិនបានល្អទើបមានរឿងបែបនេះ។

-កុំបន្ទោសខ្លួនឯងអី បងដឹងថាឯងក៏មិនចង់ឲ្យមានរឿងបែបនេះកើតឡើងដូចគ្នា-

-បងស្រីពួកយើងប្ដឹងប៉ូលីសទៅល្អទេ?-

-ពួកយើងដើររកបន្តទៀតទៅ បងគិតថាពួកគេដើរលេងម្ដុំនេះទេ- នាងនិយាយហើយក៏ក្រោកដើរទៅមាត់ឆ្នេរម្ដងទៀត នាងក៏បារម្ភពីកូនដូចគ្នា តែអារម្មណ៍មួយប្រាប់ថាពួកគេមានសុវត្ថិភាព។

អែលវិន នាំក្មេងៗមកវិញទាំងមានយួរបស់ពេញដៃមកដល់កន្លែងដែលជួបពួកគេកាលពីសៀល។

-ផ្ទះក្មួយនៅឯណា?- គេសួរនាងតូចដែលកំពុងពារនិងដៃម្ខាងទៀតដឹកដៃរបស់ អេរិច។

-នៅទីនោះ- នាងតូចប្រាប់ទាំងចង្អុលទៅផ្ទះឈើតូចមួយជាប់មាត់ឆ្នេរធ្វើឲ្យគេសម្លឹងទៅតាម -ផ្ទះតូចបែបនេះនៅយ៉ាងម៉េចទៅ?- គេរអ៊ូរទាំម្នាក់ឯងមុននឹងងាកមកនាងវិញ។





-ចុះប៉ាក់ទៅណា?- គេសួរបន្តទាំងដើរតិចសំដៅផ្ទះនោះ។

-ប៉ាក់ធ្វើការនៅទីនោះ- នាងប្រាប់ទាំងចង្អុលទៅហាងកាហ្វេនៅជ្រុងម្ខាងទៀតមើលទៅនៅជិតសណ្ឋាគារគេនោះហើយ គេក្រឡេកមើលបន្តិចដូចមិនសូវចាប់អារម្មណ៍ ហើយក៏ងាកមកវិញស្របពេលមកដល់មុខផ្ទះល្មមទើបដាក់នាងចុះ។

-មកដល់ហើយពូទៅវិញហើយណា-

-បាទ/ចាស- ពួកគេតបទទួលហើយក៏នាំគ្នាត់ចូលក្នុង គេសម្លឹងមើលហាក់មិនចង់បែកពីពួកគេយ៉ាងម៉េចមិនដឹងទេ គិតហើយក៏គ្រវីក្បាលអស់សំណើចខ្លួនឯងថ្ងៃនេះគេធ្វើស្អីខ្លះមិនដឹង គិតហើយក៏ដើរត្រឡប់ទៅសណ្ឋាគាររបស់ខ្លួនវិញ។

-អេរិច អាយរីន ទើបមកពីណា?- អ៊ីនប៊ី នៅចាំផ្ទះក្រឡេកឃើញពួកគេមកវិញទើបសួរទាំងក្រេកអរ។

-មកពីដើរលេង- ក្មេងប្រុសប្រាប់ទាំងញញឹមលើករបស់របរជាច្រើនឲ្យនាងមើល។

-អេរិច អាយរីន- ស៊ូហ៊ី ស្រែកហៅទាំងរត់មករកកូនទាំងពីរដោយភាពត្រេកអរបន្ទាប់ពីដើររកទាំងគ្មានកំលាំង។

-ម៉ាក់ៗយំមែនទេ?- នាងតូចសួរម្ដាយពេលរាងកាយញ័រថែមទាំងឱបពួកនាងជាប់បែបនេះទៀត ស៊ូហ៊ី រុញកូនចេញតិចៗដើម្បីបានមើលឲ្យសព្វថាពួកគេមានអីកើតឡើងឬអត់តែគ្មាននោះទេ ហើយក៏ចាប់ផ្ដើមងឿងឆ្ងល់ពេលឃើញរបស់លេងជាច្រើននៅជុំវិញពួកគេ ធ្វើឲ្យនាងចាប់ផ្ដើមខ្វល់ខ្វាយគិតថាពួកគេអាចទៅធ្វើអីផ្ដេសផ្ដាស។

-កូនទើបមកពីណាដឹងថាម៉ាក់បារម្ភដែរទេ ហើយរបស់អស់នេះ កូនបានមកពីណាប្រាប់ម៉ាក់មក- នាងប្រាប់កូនសំឡេងរឹងធ្វើឲ្យពួកគេទាំងពីរងើបមកមើលមុខនាងភ្លឹះៗ។

-ពូស្កាតទិញឲ្យកូន- អេរិច និយាយតិចៗប្រាប់ម្ដាយធ្វើឲ្យនាងចាប់ផ្ដើមជ្រួញចិញ្ចើម។

-អ្នកណាគេ ម៉ាក់ធ្លាប់ប្រាប់ហើយមែនទេថាមិនត្រូវទទួលរបស់ពីមនុស្សមិនធ្លាប់ស្គាល់-

-តែកូនស្គាល់គ្នាជាមួយពូស្កាតនោះហើយ ពូស្កាតប្រាប់ថាគាត់និងប្រាប់ម៉ាក់ថាគាត់ទិញឲ្យ មិនមែនកូនចង់ទិញនោះទេ- នាងតូចនិយាយព្រេតៗប្រាប់ម្ដាយ ធ្វើឲ្យនាងយកដៃស្ទាបទ្រូងហួសចិត្ត នេះកូននាងយករឿងដែលនាងប្រាប់ទៅប្រាប់គេចឹងមែនទេ នាងគិតទាំងដកដង្ហើមធំងាកសម្លឹងមើលទៅ អ៊ីនប៊ី ដែលកំពុងអស់សំណើចដូចគ្នា។

-មិនជាអ្នកណានោះទេ ម៉ាក់ហាមទៅជាមួយគេទៀតឮទេ- នាងប្រាប់កូនសំឡេងរឹងទើបពួកគេនៅស្ងៀមធ្វើមុខជូរ។

អែលីន មកដល់សណ្ឋាគារស្របពេលមនុស្សជំនិតរបស់គេទាំងពីរមកដល់ដូចគ្នា ពួកគេនាំគ្នាមើលមុខចៅហ្វាយដែលខានរីករាយបែបនេះមួយរយៈមកហើយ។

-នាំគ្នាញញឹមស៊ី- គេសួរសំឡេងរឹងធ្វើឲ្យពួកគេត្រូវលប់ស្នាមញញឹមរហ័សប្ដូរមកឈរក្រង់ខ្លួន។

-គ្មានទេចៅហ្វាយ- ជីម តបសំឡេងម៉ឹងម៉ាត់ទើបគេលែងមាត់ហើយក៏ដើរចេញទៅនឹកឃើញអ្វីមួយទើបងាកមកវិញ។





-ម្ចាស់ហាងកាហ្វេជិតនោះជាអ្នកណា ស៊ើបប្រវត្តិមកឲ្យខ្ញុំអោយទាំងបុគ្គលិកគេផងដែរ- គេប្រាប់សំឡេងម៉ឹងម៉ាត់សម្លឹងទៅហាងកាហ្វេដែលនៅជិតមិនដាក់ភ្នែក ធ្វើឲ្យកូនចៅទាំងពីរនាំគ្នាធ្វើមុខមិនសូវស្រួលប៉ុន្មាននោះទេ ពួកគេទើបស៊ើបដឹងនោះទេថាម្ចាស់ហាងនោះគឺ ស៊ូហ៊ី ជាអ្នកគ្រប់គ្រងចុះបើចៅហ្វាយគេដឹងតើគាត់គិតធ្វើយ៉ាងម៉េចទៅ?។

-ចៅហ្វាយចង់ដឹងរឿងអីមែនទេ?- សំណួររបស់ ជីម ធ្វើឲ្យអ្នកដែលបែខ្លួនបម្រុងដើរទៅងាកមកមើលដោយក្រសែភ្នែកមុត។

-មិនបាច់សួរច្រើនទេ គ្រាន់តែធ្វើតាមអ្វីដែលខ្ញុំប្រាប់ទៅ- គេប្រាប់ហើយក៏ដើរចេញទៅទុកឲ្យកូនចៅទាំងពីរនៅសម្លឹងមុខគ្នារិះគិត។

-តើគួរប្រាប់ចៅហ្វាយដែរទេ?- ជីម សួរជេគួរ។

-ដល់ដំណាក់កាលនេះហើយលាក់ម៉េចជិតទៅ- ជេក និយាយហើយក៏ដើរចេញទៅទើប ជីម ដើរទៅតាមក្រោយ។

ក្នុងបន្ទប់ធ្វើការធំទូលាយ អែលីន អង្គុយធ្វើការទាំងអារម្មណ៍ធុញថប់ព្រោះការងារច្រើន ថែមទាំងធ្វើតែម្នាក់ឯងមនុស្សជំនិតទាំងពីរក៏នាំគ្នាបាត់ស្រមោលឈឹងថែមទៀត កំពុងតែគិតម៉ូម៉ៅស្របពេលសំឡេងគោះទ្វារបន្ទប់បន្លឺឡើង កូនចៅទាំងពីរដើរចូលមក។

-ទើបនាំគ្នាមកពីណា?- គេសួរសំឡេងរឹងថែមទាំងធ្វើមុខមាំ។

-មកពីញ៉ាំកាហ្វេចៅហ្វាយ- ជេក តបទាំងលើកកាហ្វេបង្ហាញទើបគេស្ងាត់ស្ងៀមឈ្ងោកធ្វើការបន្ត ជីម ស៊ីញ៉ូភ្នែកដាក់ដៃគួរពីរឿងដែលពួកគេពិភាក្សាមុននេះ។

-មានរឿងអីមែនទេ?- អែលីន ងើបមកសួរបន្តពេលឃើញពួកគេ



Scanned by CamScanner

ទាំងពីរញាក់មុខញាក់មាត់ដាក់គ្នាដូចជាមានរឿងអ្វី។

-ពិត ចៅហ្វាយចង់ញ៉ាំកាហ្វេដែរទេ?- ជេក សួរទាំងញញើត ញញើមព្រោះដឹងថាចៅហ្វាយគេមិនធ្លាប់ផឹកកាហ្វេខាងក្រៅនោះទេ។

-ឯងឃើញខ្ញុំធ្លាប់ផឹកកាហ្វេអស់នោះទេ?- អែលវិន សួរតប សំឡេងស្ទើរធ្វើឲ្យកូនចៅទាំងពីរធ្វើមុខជូរ។

-តែកាហ្វេនៅហាងនោះពិតជាឆ្ងាញ់មែនចៅហ្វាយ ទោះបីជាហាងតូចក៏ដោយ ឆ្ងាញ់ជាងហាងក្នុងសណ្ឋាគាររបស់យើងទៀត បុគ្គលិកភាគច្រើននាំគ្នាទៅតែទីនោះទេ- ជេក រ៉ាយរ៉ាប់បន្ថែមធ្វើឲ្យ អែលវិន ឈប់ឆ្ងល់ដូចកំពុងតែរិះគិត ក្មេងពីរនាក់ដែលជួបកាលពីរសៀលប្រាប់ថាម៉ាក់គេធ្វើការនៅហាងកាហ្វេចាហាងដែលកូនចៅគេនិយាយនោះហើយ។

-ក៏បានជួយហៅឲ្យខ្ញុំមួយកែវមក- គេងើបមកប្រាប់ហើយក៏ធ្វើការងារបន្តកូនចៅទាំងពីនាំញញឹមបន្តិចមុននឹងដើរចេញទៅវិញ កុម្ម៉ង់កាហ្វេ១០កែវទើបគេយកមកឲ្យដល់កន្លែង នេះជារឿងងាយស្រួលសម្រាប់ពួកគេនោះទេគិតហើយក៏នាំគ្នាញញឹមចុងមាត់។

-បងស្រី ខាងសណ្ឋាគារត្រូវការកាហ្វេ១០កែវបងជួយយកទៅបន្តិចបានទេព្រោះខ្ញុំជាប់រវល់ឆុងបន្ថែមហើយ- ជូយ៉ុង ស្រែកប្រាប់ ស៊ូហ៊ី ដែលទើបមកពីក្រៅថែមទាំងរៀបរួចជាស្រេចនាងឃើញបុគ្គលិកក្នុងហាងសុទ្ធតែរវល់ទើបនាងត្រូវជួយតាមប្អូនប្រុសប្រាប់។

ស៊ូហ៊ី យួរកាហ្វេមកដល់សណ្ឋាគារចែកបុគ្គលិកគ្រប់គ្នានៅសល់មួយកែវបុគ្គលិកម្នាក់ប្រាប់ថារបស់អគ្គនាយក ឲ្យនាងជួយយកឡើងទៅឲ្យ នាងភ្ញាក់ផ្អើលបន្តិចពេលឮថាអគ្គនាយកសណ្ឋាគារទាំងមូលកុម្ម៉ង់





កាហ្វេរបស់ហាងនាង តែនេះក៏ជាកិត្តិយសមួយដែរ ទើបយកទៅជូនដោយផ្ទាល់គិតថាបានមានឱកាសបានជួបអគ្គនាយកធំក៏ជាសំណាងរបស់នាងដូចគ្នា គិតហើយក៏សំដៅជណ្ដើរយន្ត ដោយមិនដឹងថាមានអ្នកកំពុងតែតាមសម្លឹងមើលនោះទេ។

ស៊ូហ៊ី ឡើងមកដល់ជាន់លើដែលជាជាន់សម្រាប់អគ្គនាយកនាងមានអារម្មណ៍ប្លែកៗ មានអារម្មណ៍ថាការតុបតែងមួយចំនួនដូចជាសណ្ឋាគារដែលនាងធ្លាប់ធ្វើ តែក៏រលាស់គំនិតទាំងនោះចេញមុននឹងដើរសំដៅបន្ទប់អគ្គនាយក។

-អ្នកនាងមករកអ្នកណាដែរ- សំឡេងលេខាមុខបន្ទប់បន្លឺឡើង។

-គឺខ្ញុំជាអ្នកយកកាហ្វេមកគេប្រាប់ថាជារបស់អគ្គនាយកកុម្ម៉ង់-

-ចាសអញ្ជើញ- លេខាប្រាប់ទាំងចង្អុលទៅបន្ទប់អគ្គនាយកឲ្យនាងចូលទៅ ស៊ូហ៊ី មានអារម្មណ៍ភ័យដុកដាក់ប្លែកនាងឈរមុខបន្ទប់ដកដង្ហើមស្រួលបន្តិចមុននឹងគោះទ្វារចូលទៅ។

អែលវិន កំពុងជាប់រវល់ពិនិត្យឯកសារនៅលើតុទើបមិនបានងើបមកមើលអ្នកដែលដើរចូលមកនោះទេ

-នាងខ្ញុំយកកាហ្វេមក- ស៊ូហ៊ី និយាយសំឡេងស្រាលមិនហ៊ានងើបមើលមុខអ្នកម្ខាងទៀតនោះទេ ដាក់កាហ្វេលើតុហើយក៏បែខ្លួនប៉ុង ដើរចេញទៅវិញស្របពេលឮសំឡេងមានអំណាចបន្លឺឡើង។

-ឈប់សិន- អែលវិន សម្លឹងនារីចំពោះមុខដែលកំពុងឈរបែខ្ន គេមានអារម្មណ៍សំឡេងដូចជាប្រហែលៗ ទើបងើបសម្លឹងមើលមុខ នាងដើរទៅជិតដល់ទ្វារទៅហើយទើបហៅ។



Scanned by CamScanner

ស៊ូហ៊ី ឈប់ឆ្លក់បន្ទាប់ពីឮអ្នកម្ខាងទៀតបោះតែ... ទៅវិញនោះទេ ព្រោះនាងរកអារម្មណ៍ស្គាល់សំឡេងនេះរហូតនាងអារម្មណ៍ជាអ្នកម្ខាងទៀតកំពុងតែដើរសំដៅមករកនាង។

-បែមុខមកនេះ- គេប្រាប់សំឡេងស្មើតែធ្វើឲ្យអ្នកម្ខាងទៀតមានអារម្មណ៍ភ័យកាន់តែខ្លាំងព្រោះតែសំឡេងមានអំណាចមួយនេះ នាងបានឮយូរណាស់មកហើយ ស៊ូហ៊ី ឈរព្រឹងពេលនេះនាងចង់រត់ចេញពីទីនេះខ្លាំងណាស់ គិតហើយក៏ដើរសំដៅទ្វារយ៉ាងលឿន។

-ខ្ញុំប្រាប់ឲ្យឈប់ឮដែរទេ- អែលវិន ស្រែកប្រាប់ម្តងទៀតតែអ្នកម្ខាងទៀតមិនខ្វល់ទាញទ្វារប្រុងនឹងបើក តែក៏ត្រូវរាងក្រាស់ទៅប្រញាប់បិទទៅវិញ ទាញរាងស្តើងមកប្រឈមចំពោះមុខហើយក៏ បើកភ្នែកធំៗដោយភាពភ្ញាក់ផ្អើលលាយអរពេលឃើញថាជាអ្នកណា។

-សូមទោសខ្ញុំត្រូវត្រឡប់ទៅវិញហើយ- ស៊ូហ៊ី ប្រាប់សំឡេងញ័រព្រោះភ័យរើខ្លួនចេញពីរង្វង់ដៃគេ តែមានដែរមែនទេដែលគេព្រមឲ្យនាងទៅតាមសម្រួលនោះ។

-មិនឲ្យទៅ- អែលវិន ប្រាប់សំឡេងស្មើរសម្លឹងមើលនាងមិនព្រិចគេពិតជាត្រេកអរ ដែលបានជួបនាង តែព្យាយាមធ្វើមុខម៉ាំលាក់បាំងអារម្មណ៍ទាំងនេះ នាងពិតជាផ្លាស់ប្តូរខ្លាំងណាស់គេមើលសឹងតែមិនស្គាល់ទៅហើយមើលទៅដូចជាមានសាច់ស្អាតជាងមុនថែមទៀត។

ស៊ូហ៊ី មិនហ៊ានមើលមុខគេចំនោះទេទោះបីជានឹកគេខ្លាំងយ៉ាងណាតែក៏នៅឈឺចិត្តដូចគ្នាពេលនឹកឃើញទង្វើកាលពីមុនរបស់គេ។

-មេត្តាលែងខ្ញុំទៅ-





នាងប្រាប់ទាំងប្រឹងរើម្តងទៅនៅតែមិនបានសម្រេចទើបងើបសម្លឹងមុខគេដែលកំពុងសម្លឹងនាងដូចគ្នា គេសម្លឹងមើលនាងសឹងឆ្លុះពីម្ខាងទៅម្ខាងទៅហើយ ហើយក៏ធ្វើឲ្យនាងកាន់តែចង់ចេញពីទីនេះកាន់តែលឿនមុននឹងមានរឿងអីកើតឡើង។

-សូមអង្វរដោះលែងខ្ញុំទៅ- ម្តងនេះនាងនិយាយទាំងទឹកភ្នែកគិ ជាគេអាចនឹងអាណិត តែគេមិនកម្រើកនៅតែសម្លឹងនាងមិនឈប់ ទើ នាងត្រូវប្រើកំលាំងដ៏ស្តួចស្តើងរបស់ខ្លួនរើបម្រះឲ្យផុតពីក្រញ៉ាំរបស់គេ ក៏ត្រូវគេលើកបីធ្វើឲ្យនាងកាន់តែភ័យលើសដើម។

-ដាក់ខ្ញុំចុះទៅ លោកចង់នាំខ្ញុំទៅណា?-

-ទៅបន្ទប់របស់ខ្ញុំ- គេប្រាប់ហើយក៏ដើរសំដៅទ្វារមួយទៀត ចំហៀងតុធ្វើការ ជាបន្ទប់សម្រាករបស់គេនោះហើយ។

-អត់ទេ លែងខ្ញុំទៅ-

-គង់តែលែងទេ តែចាំ...- គេប្រាប់ទាំងញញឹមលាក់គំនួច ចាប់ផ្តើមលេបទឹកមាត់ទាំងពិបាកព្រោះដឹងថាគេចង់ធ្វើអី មិនទាន់ រើបម្រះក៏ត្រូវគេបោះទៅលើគ្រែថែមទាំងតាមទៅសង្រ្គប់ពីលើ។

-លែងខ្ញុ...- ពាក្យសម្តីរបស់នាងត្រូវទើត្រឹមបំពង់ករព្រោះ មាត់របស់គេ ស៊ូហ៊ី ព្យាយាមគក់ស្មារុញទ្រូងរាងក្រាស់ចេញតែ ខ្វល់ចាប់ដៃទាំងពីររបស់នាងសង្កត់លើពូកជាប់ បបូរមាត់នៅប ជញ្ជក់បបូរមាត់ស្តើង រហូតអ្នកម្ខាងទៀតចាប់ផ្តើមទោទន់ទើប នាងឲ្យមានសេរីភាព ស៊ូហ៊ី លើកដៃខ្ទប់ករគេជាប់តែទាំងទឹកភ្នែ ហូរនាងចង់រើចេញពីក្រញ៉ាំដៃរបស់គេណាស់ តែរាងកាយនាងមិ

បញ្ហាទាល់តែសោះ អារម្មណ៍ត្រូវការផ្ទៃករាងកាយបុរុសមទាំងការដឹកញុក ធ្វើឲ្យនាងមិនអាចប្រឆាំងបានទើបយល់ស្របតាមគេ។

អែលវិន ញញឹមចុងមាត់ពេលឃើញនាងស្របតាម គេរុសបបូរមាត់មកដល់គល់ករសខ្ចីដោយភាពឈ្លក់វង្វេង រាងកាយនាងនៅតែក្រអូបសម្រាប់គេ ម្រៀមដៃក្រាស់ចាត់ការលេវអាវម្ដងមួយៗរហូតអស់ បង្ហាញដើមទ្រូងទ្រលុកទ្រលន់នៅពីក្រោមអាវក្នុងមួយជាន់ទៀត ស៊ូហ៊ី កំពុងលង់អារម្មណ៍ស្រើបស្រាល ទើបមិនដឹងថាខោអាវនាងត្រូវដោះចេញតាំងពីពេលណានោះទេ មកដឹងម្ដងទៀតពេលរាងកាយរបស់ខ្លួនប៉ះនឹងភាពត្រជាក់។

«អែលវិន...» នាងហៅសំឡេងស្អកធ្វើឲ្យអ្នកដែលកំពុងតែឈ្ងុសដើមទ្រូងរបស់នាងត្រូវងើបមុខមកមើល មិនទាន់បានបនិយាយក៏ត្រូវគេឱនមកបិទមាត់ជាប់ទើបលើកដៃតោងស្មារគេ អែលវិន ដកបបូរមាត់ចេញមកដល់ស្មា ហើយក៏ត្រូវឈប់ឆ្ងក់ ពេលប៉ះស្នាមនៅត្រង់ស្មាគត្រើម ធ្វើឲ្យគេឆាប់ផ្ដើមប្ដូរទឹកមុខហើយសម្លឹងមើលមិនដាក់ភ្នែក។

«នេះជាស្នាមអី?» គេសួរសំឡេងរឹងធ្វើឲ្យទឹកភ្នែកនៃតូចចិត្តចាប់ផ្ដើមស្រក់ចុះនេះជាស្នាមដែលគេបន្សល់ទុកឲ្យនាងនៅមកសួរទៀត។

«លោកចាំមិនបានមែនឬ?» ស៊ូហ៊ី សួរទាំងអណ្ដើតអណ្ដកពីខ្លួន ងាកចេញតែក៏ត្រូវគេទាញមកវិញ នេះជាស្នាមធ្មេញរបស់គេមែនទេ អែលវិន សួរខ្លួនឯងក្នុងចិត្តហើយក៏នឹកឃើញទង្វើរបស់ខ្លួនកាលពីមុន គេធ្វើស្អីហេតុអីក៏ធ្វើឲ្យស្បែកសរលោងក្លាយជាបែបនេះ ថែមទាំងឃើញទឹកភ្នែករបស់នាងធ្វើឲ្យគេកាន់តែមានអារម្មណ៍ខុស។





«សូមទោស» គេតបហើយក៏ឱនទៅថើបស្នាមនោះថ្នមៗដេញមកដល់ដើមទ្រូងតឹងណែនរហូតមកដល់ពោះរាបស្មើ ហើយក៏ចេះតែទាបទៅ ស៊ូហ៊ី អឹបជើងជាប់គ្រវីក្បាលប្រាប់ព្រោះដឹងថាគេចង់ធ្វើអី តែមានដែរមែនទេដែលគេយល់ព្រម អែលវិន ញញឹមបន្តិច មុននឹងចាប់ញែកជើងនាងចេញពីគ្នាឱនទៅរកទុលសាច់ នាងក្រមុំលើកដៃទប់សំឡេងថ្ងូររបស់ខ្លួន តែក៏ត្រូវស្រែកចេញមកយ៉ាងខ្លាំងព្រោះតែបបូរមាត់របស់គេ។

«បាន...បានហើយ» នាងប្រាប់សំឡេងស្អករុញស្មារគេចេញតិចៗ ទើបគេដកបបូរមាត់ចេញ ចាត់ការខោអាវលើខ្លួនមុននឹងជ្រែកកាយចូលទៅ អែលវិន ទាញរាងស្ដើងក្រោកអង្គុយយោកត្រគាកតូចទៅមកធ្វើឲ្យនាងស្រែកថ្ងូរមិនដាច់ទាញមុខគេមកផ្រប់ដើមទ្រូងខ្លួនឱបរាងក្រាសជាប់ ទាំងត្រគាកនៅតែធ្វើចលនាពីយឺតមកលឿនមិនឈប់ មុននឹងរុញរាងស្ដើងឲ្យគេងរាប បន្ថែមចង្វាក់កាន់តែញាប់ហើយក៏ញាប់រហូតសង្គ្រាមស្នេហ៍បានបញ្ចប់នៅសល់តែសំឡេងដង្ហើមដង្ហក់ប្រណាំងគ្នា។

ពីរម៉ោងក្រោយមក...

«បងស្រីទើបមកពីណា ហេតុអីក៏ទៅយូរយ៉ាងនេះ?» ជុយ៉ុង សួរអ្នកដែលទើបដើរមក ស៊ូហ៊ី រាងភ្ញាក់បន្តិចពេលឮប្អូនប្រុសសួរ។

«គឺបងជួបជាមួយអ្នកស្គាល់ ទើបជាប់មាត់ជជែកជាមួយគេយូរបន្តិច សូមទោសណ៎ា» នាងប្រាប់ហើយក៏ដើរសំដៅតុខោនដ័រកាន់តួនាទីរបស់ខ្លួន នឹកឃើញរឿងមុននេះធ្វើឲ្យមុខនាងក្រហមមិនទាន់បាត់នោះទេ ដោយសារគេតេងលក់ទើបនាងប្រញាប់រៀបចំខ្លួនចុះមកយ៉ាងលឿន ពិតជាគួរឲ្យខ្មាសខ្លាំងណាស់ដែលនាងស្របតាមគេគ្រប់ទង្វើ ទោះបីជាព្យា

យោមប្រាប់ខ្លួនឯងយ៉ាងណាក៏ដោយ។

បបូរមាត់ក្រាស់ញោចស្នាមញញឹមទាំងភ្នែកមិនទាន់បើក ព្រោះដឹងច្បាស់ថា គេមិនបានយល់សព្វចំពោះរឿងដែលកើតឡើងមុននេះទើបបោះដៃរាវរកភាស្លើងក្បែរខ្លួនតែបែរជាជួបភាពទទេស្អាត ទើបក្រោកអង្គុយឆ្ងក់ដឹងថានាងក្រោកទៅចោលគេបាត់ហើយទើបចាប់ផ្ដើមម៉ូម៉ៅ ហើយក៏ក្រោកទៅរៀបចំខ្លួន។

-នែ! ឯងគិតថាមានអីកើតឡើងមុននេះក្នុងបន្ទប់ចៅហ្វាយ- ជេក សួរដៃគូរដែលឈរក្បែរដឹងថា ស៊ូហ៊ី ចូលទៅជាងមួយម៉ោងទើបតែចេញទៅមុននេះនោះទេទើបពួកគេនាំគ្នាមកឈរមុខបន្ទប់ចាំមើល។

-ចង់ដឹងទៅសួរចៅហ្វាយទៅ- ជីម និយាយលាយសើច។

-ឯងចង់ឲ្យយើងត្រូវដេញចេញពីការងារឬយ៉ាងម៉េច?-

-អឺ បើមិនចង់នៅឲ្យស្ងៀមចាំតែមើលទៅ- ជីម និយាយផុតស្រប ពេលទ្វារបន្ទប់ត្រូវបើកដោយរាងក្រាស់ទើបពួកគេនាំគ្នាដើរសំដៅទៅយ៉ាងលឿនព្រោះមើលទៅទឹកមុខចៅហ្វាយគេដូចមិនសូវស្រួលនោះទេ។

-ចៅហ្វាយមានអីមែនទេ?- ជេក សួរទាំងញញើតញញើម អែលវិន សម្លឹងកូនចៅទាំងពីរដោយក្រសែភ្នែកមុត។

-ពួកឯងដឹងរឿងនេះយូរហើយមែនទេ?- អែលវិន សួរសំឡេងស្មើរ

-ទើបតែដឹងពេលទៅទិញកាហ្វេទេចៅហ្វាយ- ជីម និយាយទាំងញញឹមខ្មោះធ្វើឲ្យគេរាងរសាយទឹកមុខបន្តិច ព្រោះដឹងថាកូនចៅពួកគេរៀបចំឲ្យនាងឡើងមកជួបទាំងនាងមិនដឹងខ្លួន។

-ចុះរឿងឲ្យទៅស៊ើបយ៉ាងម៉េចហើយ- ពួកគេក្រឡេកមើលមុខគ្នា





-ម្ចាស់ហាងនោះគឺអ្នកនាង ស៊ូហ៊ី រួមទាំងប្អូនប្រុសម្នាក់ទៀត-

-ខ្ញុំដឹងហើយនាំគ្នាទៅធ្វើការទៅ- គេប្រាប់ហើយក៏ដើរចេញទៅ។

-ចៅហ្វាយចង់ទៅណាមែនទេ?- ជេក សួរបន្ថែមធ្វើឲ្យគេងាកមកទាំងធ្វើមុខមាំដាក់ ទើបពួកគេនាំគ្នាញញឹមបន្តិចមុននឹងឱនគោរហើយនាំគ្នាដើរចេញទៅ។

អែលវិន ចុះមកដល់ហាងកាហ្វេដែលនៅជិតសណ្ឋាគាររបស់គេមានមនុស្សច្រើនគួរសម គេដើរចូលទៅមានបុគ្គលិកនារីម្នាក់មករាក់ទាក់ហើយក៏ដើរទៅរកកន្លែងអង្គុយ សម្លឹងរកមើលអ្នកដែលចង់រកតែមិនឃើញនាងនោះទេ។

ស៊ូហ៊ី ទៅទទួលកូនព្រោះដល់ម៉ោងដែលពួកគេចេញហើយទើបទុកការងារហាងឲ្យបុគ្គលិកមើលការខុសត្រូវសិន នាងឈប់ឡាននៅអែបផ្លូវហើយដើរចុះទៅព្រោះខ្លាចកូនមិនឃើញ។

-ម៉ាក់ៗ- សំឡេងស្រែកហៅដែលស៊ាំទម្លាប់ធ្វើឲ្យអ្នកជាម្ដាយក្រឡេកទៅទាំងស្នាមញញឹមមុននឹងដើរទៅទទួលពួកគេ។

-ម៉ាក់កូនឃ្លានហើយ- សំឡេងក្មេងស្រីបន្លឺឡើងធ្វើឲ្យអ្នកជាម្ដាយញញឹម។

-ចាសម៉ាក់ដឹងហើយ តោះពួកយើងទៅផ្ទះម៉ាក់មានរបស់ទុកឲ្យ-

-ពិតមែនហ៎- ក្មេងស្រីឧទានទាំងសប្បាយចិត្ត។

-ចុះរបស់កូនហ៎- សំឡេងក្មេងប្រុសសួរ។

-មានដូចគ្នា តោះពួកយើងឆាប់ទៅទៅ- ស៊ូហ៊ី និយាយហើយក៏ដឹកដៃកូនដើរសំដៅឡានជិតដល់ទៅហើយ ក៏មានឡានមួយទៀតបើក

មកយ៉ាងលឿនឆាបពួកនាងសំណាងដែលគ្មានអ្នកណាត្រូវរបួស។

-បើកឡានគ្មានសុជីវធម៌មែន- នាងរអ៊ូរទាំហើយក៏ទាញក្មួយមកឱបព្រោះគិតថាពួកគេប្រហែលជាភ័យហើយ។

ម្ចាស់រថយន្តចុះមកសម្លឹងមើលពួកគេទាំងបី មុននេះដោយសារគេជាប់និយាយទូរស័ព្ទទើបមិនប្រយ័ត្ន គ្មានចេតនានោះទេទើបគិតថាចុះមកសុំទោស គិតហើយក៏ដើរសំដៅពួកនាង។

-សុំទោសតើមានត្រូវត្រង់ណាដែរទេ?- សំឡេងសួរជាភាសាបរទេសបន្លឺឡើងទើប ស៊ូហ៊ី ងាកទៅមើលហើយក៏ត្រូវភ្ញាក់ផ្អើលពេលឃើញថាជាអ្នកណាអ្នកម្ខាងទៀតក៏ដូចគ្នា។

-លោកគឺ ចាស៊ីន មែនទេ?- នាងសួរតបជាភាសាបរទេសទាំងមិនសូវជឿជាក់គិតថាខ្លួនឯងអាចមើលច្រលំ។

-អ្នកនាងគឺ ស៊ូហ៊ី មែនទេ?-

-ចាសគឺខ្ញុំ- នាងតបទាំងញញឹម ធ្វើឲ្យអ្នកម្ខាងទៀតញញឹមមកដូចគ្នា។

-ពិតជាសំណាងមែន ដែលបានជួបនាងនៅទីនេះ- ចាស៊ីន និយាយទាំងរីករាយមើលទៅគេដូចសប្បាយចិត្តប្លែក។

-ចាសរីករាយដូចគ្នា លោកមកធ្វើអីទីនេះមែនទេ?-

-ខ្ញុំមកមើលគំរោងសាងសង់សណ្ឋាគារ ចុះនាង- គេសួរហើយក៏ចាប់ក្លឹកក្មេងពីនាក់កំពុងតែសម្លឹងមុខគេភ្លឹះៗ ធ្វើឲ្យគេងឿងឆ្ងល់បន្តិចទើបងាកមកមើលមុខនាងម្តងទៀត។

-ខ្ញុំមករស់នៅទីនេះ-





-ចុះក្មេងពីនាក់នេះ- ចាស៊ីន សួរទាំងសម្លឹងមើលពួកគេមានអារម្មណ៍ថាដូចនណាម្នាក់ពេលសម្លឹងកាន់តែយូរ។

-ជាកូនខ្ញុំ- ស៊ូហ៊ី តបតិចៗតែធ្វើឲ្យគេភ្ញាក់ផ្អើលយ៉ាងខ្លាំងបន្ទាប់ពីគេគិតថាបើតាមរកនាងឃើញ គេនឹងមើលថែតែប្រហែលជាខកបំណងហើយព្រោះនាងប្រហែលរៀបការហើយ ទើបមានកូនធំប៉ុណ្ណឹងទៅហើយគេគិតទាំងសោកស្តាយ។

-ម៉ាក់កូនឃ្លាន- សំឡេងក្មេងប្រុសបន្លឺឡើងទាំងយកដៃស្ទាបពោះទើបនាងត្រូវប្រញាប់លាអ្នកម្ខាងទៀតទៅមុន។

ចាស៊ីន តាមសម្លឹងមើលរហូតឡានរបស់ពួកនាងទៅផុតគេញញឹមចុងមាត់មុននឹងដើរសំដៅរថយន្តរបស់ខ្លួនវិញ។

ស៊ូហ៊ី អង្គុយយោលទោងខាងមុខផ្ទះគិតរឿងដែលកើតឡើងកាលពីរសៀល នាងមិនគួរបណ្តោយខ្លួនទៅគេទាល់តែសោះនឹកឃើញពេលនោះពិតជាខ្មាសខ្លាំងណាស់ មិនធ្លាប់គិតថាបានជួបគេម្តងទៀតនោះទេតែពេលនេះពិតជាបានជួបមែន តែប្រហែលគ្មានអ្វីផ្លាស់ប្តូរនោះទេសម្រាប់គេនាងគ្រាន់តែជាមនុស្សស្រីដែលត្រូវការលុយតែប៉ុណ្ណោះ។

ក្នុងបន្ទប់ធ្វើការធំទូលាយរបស់អគ្គនាយក អែលវិន កំពុងពិនិត្យឯកសារតែអារម្មណ៍មិននៅនឹងខ្លួននោះទេ កាលពីម្សិលគេខំទៅអង្គុយក្នុងហាងកាហ្វេគិតថាបានជួបនាង តែបែរជាមិនឃើញដឹងថានាងព្យាយាមគេចមុខពីគេទើបត្រឡប់មកវិញសិន ព្រោះដឹងថានាងនៅទីនោះទៅហើយចាំទៅរកពេលក្រោយទៀតក៏បាន កំពុងតែគិតស្ពុងអារម្មណ៍ស្រាប់ពេលសំឡេងគោះទ្វារបន្ទប់បន្លឺឡើង រាងខ្ពស់សង្ហារបស់បុរសម្នាក់ដើរ

ចូលមក។

-សួស្តី លោកអគ្គនាយក តើសុខសប្បាយដែរទេ?» ចាស៊ីន សួរទាំងស្នាមញញឹមចំអកដើរមកអង្គុយសាឡុងខាងមុខតុធ្វើការរបស់គេ។

«ឯងមកធ្វើអីដល់ក្រុមនេះ?»

«ហើយទីនេះមកបានតែឯងឬយ៉ាងម៉េច?» ចាស៊ីន សួរបែបរំខានខ្លួនទាំងធ្វើមុខឌឺដាក់អ្នកម្ខាងទៀត។

«និយាយសាច់ការរបស់ឯងមក កុំឲ្យយើងខាតពេលយូរ» អែលវិន ប្រាប់សំឡេងស្មើរពិនិត្យមើលការងាររបស់គេបន្ត។

«យើងគ្រាន់តែមកលេងចង់ដឹងសុខទុករបស់មិត្តភក្តិផងមិនបានឬយ៉ាងម៉េច?» ចាស៊ីន និយាយសំឡេងបង្អូសទាំងដើរមកឈរពីមុខតុធ្វើការរបស់អ្នកម្ខាងទៀត។

«យើងសុខសប្បាយធម្មតា គ្មានប្រវត្តិធ្លាប់ចូលពេទ្យទេច្រើនឆ្នាំមកនេះ ប៉ុណ្ណឹងច្បាស់ហើយឬនៅ?» ចាស៊ីន ញាក់ស្មារបែបហឹបន្ទាប់ពីឮហើយក៏ដើរសំដៅសាឡុង នឹកឃើញអ្វីមួយទើបញញឹមចុងមាត់។

-ម្សិលមិញយើងបានជួបមនុស្សម្នាក់» ចាស៊ីន និយាយសំឡេងស្មើរសម្លឹងមើលមិត្តតែគេដូចមិនសូវចាប់អារម្មណ៍ទើបនិយាយបន្ត។

-ឯងមិនចង់ដឹងទេថាជាអ្នកណា?»

-ជាអាតីតស្រីរបស់ឯងមែនទេ?» អែលវិន តបទាំងភ្នែកនៅវល់ជាមួយឯកសាររបស់គេ។

-មិនមែនជារបស់យើង ជារបស់ឯងហ្នឹងហើយ» ចាស៊ីន តបធ្វើឲ្យអ្នកម្ខាងទៀតជ្រួញចិញ្ចើមរិះគិតពីសម្តីរបស់មិត្ត។





-ហើយយ៉ាងម៉េច?»

-គ្មានយ៉ាងម៉េចទេ ក្រែងពីមុនឯងតាមរកនាងមិនមែនពេលនេះលែងរកហើយមែនទេ?» អែលវិន ងើបមុខមកមើលមិត្តដែលកំពុងសម្លឹងមកបែបចំអកព្រោះអាចធ្វើគេទុកការងារចោល មកចាប់អារម្មណ៍សម្តីរបស់គេ ក្រោយមកក៏ញញឹមចុងមាត់ពេលស្មានដឹងថាជាអ្នកណា។

«ជារឿងរបស់យើងឯងមិនចាំបាច់ខ្វល់នោះទេ» អែលវិន តបបែបហឹហើយធ្វើការងារបន្ត។

«យើងគិតថាបើរកនាងឃើញមុនឯង និងយកនាងមកទុកក្បែរខ្លួនមើលថែនាងឲ្យបានល្អ តែប្រហែលជាខកបំណងហើយ» ចាស៊ីន និយាយសំឡេងអស់សង្ឃឹម ធ្វើឲ្យអ្នកម្ខាងទៀតលួចញញឹមព្រោះគេបានជួបនាងមុនថែមទាំងបាន... គិតដល់ត្រឹមហ្នឹងធ្វើឲ្យបបូរមាត់ញោចស្នាមញញឹមមុននឹងឮសំឡេងអ្នកម្ខាងទៀតបន្ថែមទៀត។

«នាងប្រហែលជារៀបការហើយ ព្រោះគ្នាឃើញនាងទៅទទួលកូនពីរនាក់ថែមទៀត» ស្នាមញញឹមរបស់ អែលវិន ត្រូវរលប់បាត់បន្ទាប់ពីឮគេស្តាប់ច្រលំឬយ៉ាងម៉េចនាងមានកូនមែនទេ? សំណួរជាច្រើនចាក់ស្រេះក្នុងខួរក្បាលមុនងើបសម្លឹងមើលអ្នកដោយទឹកមុខមាំ។

«ឯងនិយាយស្តីមុននេះ?» អែលវិន សួរមិត្តសំឡេងស្មើ។

«គឺនាងមានកូនពីរហើយ មានន័យថានាងរៀបការហើយ យ៉ាងម៉េចកុំប្រាប់ណាថា...»

«ឈប់និយាយទៅយើងទើបតែជួបនាងពីម្សិលដូចគ្នា» អែលវិន តបសំឡេងម៉ឺងម៉ាត់តែខួក្បាលកំពុងតែរិះគិត នាងមានកូនអ៊ីចឹងឬមិនគួរ

ឲ្យជឿនោះទេ នាងពិតជារៀបការមែនទេ? គេសួរខ្លួនឯងហើយក៏ត្រូវ ចម្លើយសម្រាប់ខ្លួនឯងដូចគ្នា។

អែលវិន អង្គុយក្នុងបន្ទប់ធ្វើការអារម្មណ៍មិនស្ងប់នោះទេ គិតពី សម្តីរបស់ ចាស៊ីន មុននេះចម្ងល់ជាច្រើនក្នុងខួរក្បាលចង់ផ្ទុះទៅហើយ។

-ចៅហ្វាយមានការអីមែនទេ?- ជេក ទើបដើរចូលមកសួរទាំងខ្លះ គោរពបន្ទាប់ពីទទួលទូរស័ព្ទរបស់គេ។

-ឯងស៊ើបដឹងស្អីខ្លះពីស្រីម្នាក់នោះ?- ជេក រាងមិនមាំងបន្តិច ក្រោយមកក៏យល់ចៅហ្វាយគេចង់សួរពីអ្នកណា។

-នាងរស់នៅជាមួយប្អូនប្រុស ក្មេងស្រីម្នាក់ទៀតរួមទាំង.... ជេក និយាយទាំងញញើតញញើមពេលឃើញទឹកមុខផ្លាស់ប្តូររបស់គេ។

-អ្នកណាទៀតឆាប់និយាយមក- គេនិយាយសំឡេងរឹងក្តាប់ដៃ ណែនដោយកំហឹងពេលគិតថាជាមនុស្សប្រុសផ្សេង។

-មានក្មេងប្រុសក្មេងស្រីពីរនាក់ទៀតជាកូនរបស់នាង- ជេក រាយ ការណ៍ហើយក៏ឱនមុខចុះ គេទើបតែដឹងរឿងនេះកាលពីព្រឹកនោះទេ។

-កូន នាងពិតជាមានកូនមែន- អែលវិន អ៊ឹម៉ឹងៗក្តាប់ដៃណែន ទម្លាប់អារម្មណ៍កំហឹង។

-ជាកូនរបស់អាប្រុសណាឆាប់ទៅស៊ើបទៅ- ជេក ឱនទទួលបញ្ជា ហើយក៏ចេញទៅវិញ។

អែលវិន ឈរទម្លាប់កំហឹងក្នុងបន្ទប់ នាងហ៊ានណាស់ចាកចេញពី គេបែរជាទៅទាក់ទងប្រុសផ្សេងថែមទៀត ពិតជាស្រីមុខលុយមែនគេគិត ទាំងតំគួនមុននឹងដើរចេញពីបន្ទប់។





ស៊ូហ៊ី កំពុងរាក់ទាក់ភ្ញៀវនៅខាងមុខហាងស្របពេលរាងខ្ពស់របស់ បុរសម្នាក់ដើរមក ដោយនាងមិនបានចាប់អារម្មណ៍ទើបរាក់ទាក់ធម្មតា ហើយក៏ត្រូវឈរទ្រឹងពេលឃើញថាជាអ្នកណា។

-ខ្ញុំត្រូវការកាហ្វេ- អែលវិន ប្រាប់សំឡេងស្មើហើយក៏ដើរសំដៅតុ ជិតនោះធ្វើឲ្យអ្នកដែលឈរទ្រឹងមុននេះរាងភ្ញាក់មកវិញ នាងងាកមើលគេ បន្តិចមុននឹងដើរទៅប្រាប់បុគ្គលិករបស់ខ្លួន។

អែលវិន អង្គុយសម្លឹងនាងគ្រប់សកម្មភាពដោយទឹកមុខស្មើធ្វើឲ្យ នាងធ្វើខ្លួនមិនត្រូវនោះទេ ហើយក៏មិនដឹងថាគេមកក្នុងគោលបំណងអី នោះដែរកំពុងតែគិតភ្លឹក ធ្វើឲ្យកាហ្វេកំពប់លោកត្រូវដៃនាងស្រែកដោយ ភាពឈឺចាប់។

-បងស៊ូហ៊ី យ៉ាងម៉េចហើយ?- សំឡេង យូមី បុគ្គលិកក្នុងហាង របស់នាងបន្លឺឡើង។

-មិនអីទេ នៅមើលទីនេះទៅខ្ញុំទៅក្នុងបន្តិច- នាងប្រាប់ហើយក៏ ដើរទប់ដៃរបស់ខ្លួនទៅក្នុងក្រោមក្រសែភ្នែករបស់អ្នកម្នាងទៀត។

អែលវិន ព្រួយបារម្ភពីនាងដូចគ្នាតែបានត្រឹមសម្លឹងមើលកំពុងតែ អង្គុយស្លុងអារម្មណ៍ ស្របពេលឃើញក្មេងប្រុសស្រីពីរនាក់ដើរចូលមកជា ក្មេងដែលគេធ្លាប់ជួបកាលនៅមាត់សមុទ្រទើបញញឹមចុងមាត់។

-អេរិច អាយរីន- គេហៅតិចៗធ្វើឲ្យពួកគេនាំគ្នាងាកមកមើល ដោយភាពភ្ញាក់ផ្អើលមុននឹងរត់សំដៅមក។

-ពូស្អាតហេតុអីក៏មកដល់ទីនេះ?- សំឡេងក្មេងស្រីបន្លឺឡើងទាំង ដើរទៅជិតដោយភាពរីករាយ។

«ពូមកញ៉ាំកាហ្វេចុះក្មួយ ម៉េចក៏មកទីនេះដែរ?» គេសួរទាំងលើកនាងមកអង្គុយលើភ្លៅរួមទាំង អេរិចម្នាក់ទៀត។

«ម៉ាក់ធ្វើការនៅទីនេះ» អេរិច និយាយធ្វើឲ្យគេនឹកឃើញពួកគេធ្លាប់ប្រាប់ម្តងមកហើយកាលពីជួបដំបូង។

«មែនហ៎ ពិតជាចៃដន្យមែន» គេនិយាយទាំងញញឹមទាញពួកគេមកឱបជាប់ខ្លួនមានអារម្មណ៍កាន់តែស្និទ្ធស្នាលខ្លាំងឡើង។

ស៊ូហ៊ី ទើបចេញមកពីក្នុងបន្ទប់ពីលាងរបួសរួចរាល់ព្រោះគិតថាពេលនេះកូនរបស់នាងចេញពីសាលាមកហើយ តែពេលចេញមកបែរជាត្រូវឈប់ឆ្ងក់ពេលឃើញពួកគេកំពុងតែនៅលើភ្លៅរបស់ អែលវិន បេះដូងនាងស្ទើរឈប់ដើរចាប់ផ្តើមភ័យព្រួយមួយរំពេចន៍។

«ម៉ាក់» អាយរីន ស្រែកហៅទាំងស្ទុះចុះពីលើភ្លៅអ្នកម្នាងទៀតរត់សំដៅទៅរួមទាំង អេរិច ដូចគ្នា ស៊ូហ៊ី លេបទឹកមាត់ស្អិតករពេលប៉ះក្រសែភ្នែកដែល អែលវិន សម្លឹងមកធ្វើឲ្យនាងចាប់ផ្តើមបែកញើសតិចៗ។

«ម៉ាក់កូនឃ្លានហើយ» អាយរីន ប្រាប់ម្តាយទាំងអង្អែលពោះធ្វើឲ្យនាងញញឹមពេលឃើញភាពគួរឲ្យស្រលាញ់របស់កូន។

«ម៉ាក់ដឹងហើយ តោះទៅក្នុងទៅ» នាងប្រាប់ហើយក៏ដឹកដៃកូនទៅក្នុងឆ្លៀតងាកមកក្រោបន្តិចមុននឹងដើរចូលទៅ។

អែលវិន សម្លឹងមើលរហូតដល់ពួកគេទៅផុតទើបដើរចេញមកវិញគេមិនគិតថាក្មេងទាំងពីរនាក់នោះជាកូនរបស់នាងនោះទេ។



Blue
Romance





Scanned by CamScanner

...១២...

ស៊ូហ៊ី រៀបចំខ្លួនចេញពីហាងយ៉ាងប្រញាប់ប្រញាល់បន្ទាប់ពីខាងសាលាទូរស័ព្ទមកប្រាប់ថា អេរិច ត្រូវរបួសព្រោះមានឧបត្តហេតុត្រូវបញ្ជូនទៅមន្ទីរពេទ្យ បេះដូងអ្នកជាម្ដាយស្ទើរឈប់ដើរបន្ទាប់ពីឮ។

«លោកគ្រូពេទ្យកូនខ្ញុំយ៉ាងម៉េចហើយ?» ស៊ូហ៊ី សួរសំឡេងញ័រលាយយំព្រោះតែព្រួយបារម្ភ។

«របួសបន្តិចបន្តួចទេតែដោយសារត្រូវចំកន្លែងប្រជុំសសៃឈាម ធ្វើឲ្យបាត់បង់ឈាមអស់ច្រើន ហើយដោយសារនេះជាឈាមកម្រទើបមន្ទីរពេទ្យរបស់យើងគ្មាន ដូច្នេះតម្រូវឲ្យគ្រួសារសាច់ញាតិធ្វើការផ្តល់ឈាមបន្ថែមបើមិនដូច្នោះទេអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់អ្នកជំងឺ» គ្រូពេទ្យនិយាយក៏ដើរចេញទៅ ទុកឲ្យនាងនៅឈរសម្លឹងមើលបន្ទប់ទាំងព្រួយបារម្ភ គ្រួសារសាច់ញាតិមែនទេ នាងគ្មានគ្រួសារសាច់ញាតិណានោះទេតើធ្វើយ៉ាងម៉េចទៅ នាងគិតទាំងខ្វល់ខ្វាយ។

ស៊ូហ៊ី ចេញពីបន្ទប់ពិនិត្យទាំងអស់សង្ឃឹមបន្ទាប់ពីលទ្ធផលពិនិត្យគ្រុបឈាមរបស់ពួកនាងមិនដូច អេរិច នោះទេនាងអង្គុយយំនៅមុខបន្ទប់ស្ទើរខ្សោះទឹកភ្នែកទៅហើយ ព្រោះមិនដឹងត្រូវជួយកូនតាមវិធីណា។

«បងស្រីកុំបារម្ភពេក គ្រូពេទ្យប្រាប់ថានិងជួយស្វែងរកអ្នកមានប្រភេទឈាមដូច អេរិច ច្បាស់ជាមានអ្នកមានប្រភេទឈាមនេះ» ដូយ៉ុង និយាយលួងលោមទើបនាងញញឹមតិចៗតប។

«បងដឹងហើយ ឯងត្រឡប់ទៅមើលហាងវិញទៅទីនេះទុកឲ្យបង»

«បាទ បើចឹងខ្ញុំទៅសិនហើយ» គេប្រាប់ហើយក៏ដើរចេញទៅ។







ស៊ូហ៊ី នៅឈរមុខបន្ទប់សម្លឹងមើលកូនទាំងទឹកភ្នែកព្យាយាមជូតចេញយ៉ាងណាក៏នៅតែហូរមកមិនឈប់ អង្គុយទីនោះមួយសន្ទុះដូចជានឹកឃើញអ្វីមួយ ទើបស្ទុះក្រោករឹងដោយភាពត្រេកអរមុននឹងឈានជើងដើរចេញទៅ។

ស៊ូហ៊ី មកដល់មុខសណ្ឋាគារដែលនៅជាប់ហាងកាហ្វេរបស់នាង បន្ទាប់ពីគិតឃើញឪពុកកូនច្បាស់ជាមានប្រភេទឈាមដូចគ្នា នាងប្រញាប់ប្រញាល់ដើរចូលទៅក្នុងស្របពេលឃើញគេដើរចេញមកទើបដើរសំដៅទៅតែក៏ត្រូវឈប់ទ្រឹងទៅវិញ ព្រោះគេមិនមែនដើរមកតែម្នាក់ឯងនោះទេ គឺមានមនុស្សស្រីម្នាក់ចេញមកជាមួយគេដែរ។

«អរគុណ ដែលជូនខ្ញុំមកដល់ក្រោម អែលវិន» សំឡេងនារីម្នាក់នោះបន្លឺឡើងថែមទាំងកៀកដៃគេជាប់ថែមទៀត អែលវិន គ្រាន់តែញញឹមតបដោយមិនបានចាប់អារម្មណ៍ មានអ្នកណាម្នាក់កំពុងតែឈរមើលពួកគេនោះទេ។

ស៊ូហ៊ី ឈរសម្លឹងមើលរហូតពួកគេដើរទៅផុត ការឈឺចាប់ត្រង់ដើមទ្រូងខាងឆ្វេងវិលមករកនាងម្តងទៀត ព្យាយាមឃាត់ទឹកភ្នែកមិនឲ្យហូរតែធ្វើមិនបានចង់រត់ចេញក៏មិនអាចព្រោះមានរឿងត្រូវពឹងពាក់គេ។

អែលវិន មិនបានចាប់អារម្មណ៍ថានាងមកតាំងពីពេលណានោះទេ គេឃើញពេលដែលដើរហួសនាងទៅហើយ មើលទឹកមុខនាងដូចជាមានបញ្ហាថែមទៀត តែដោយសារគេជាប់រវល់ភ្ញៀវជាកូនស្រីដៃគូជំនួញទើបត្រូវទុកនាងមួយឡែកសិន។

«សូមធ្វើដំណើរដោយសុវត្ថិភាព» អែលវិន និយាយពេលជូនអ្នក

ម្នាក់ទៀតមកជល់រថយន្តមុននឹងពួកគេបើកចេញទៅបាត់ ទើបងាកមក មើលរាងស្ដើងនៅខាងក្រោយដែលកំពុងសម្លឹងមើលគេមិនព្រិច ដែលទាំង ដើរសំដៅមកគេថែមទៀត។

-ខ្ញុំសុំនិយាយជាមួយលោកបន្តិចបានទេ?- ស៊ូហ៊ី ប្រាប់សំឡេង ស្រាល អែលវិន ជ្រួញចិញ្ចើមមើលនារីចំពោះមុខមើលទៅនាងដូចជា មានបញ្ហាអីព្រោះផ្ទៃមុខនាងដូចជាសោកសៅ គេគិតក្នុងចិត្តមុននឹងតប។

-អញ្ជើញ- គេប្រាប់ហើយក៏ដើរសំដៅជណ្ដើរសម្រាប់អ្នកគ្រប់គ្រង ទើបនាងដើរទៅតាមក្រោយ ធ្វើឲ្យកូនចៅរបស់គេទាំងពីរនាំគ្នាមើលទាំង ងឿងឆ្ងល់ព្រោះមើលទៅពួកគេដូចជាស្ងាត់ស្ងៀម។

-និយាយកិច្ចការរបស់នាងមក- អែលវិន ប្រាប់ពេលឡើងមកដល់ បន្ទប់ធ្វើការរបស់គេមុននឹងដើរទៅអង្គុយសាឡុងក្នុងបន្ទប់ ស៊ូហ៊ី ឈរទ្រឹង មួយដង្ហើមមុននឹងចាប់ផ្ដើមនិយាយរឿងរបស់ខ្លួន។

-ជួយកូនផង- នាងនិយាយសំឡេងញ័រលើកដៃជូតទឹកភ្នែកលើ ថ្ពាល់ អែលវិន ជ្រួញចិញ្ចើមបន្ទាប់ពីឮ គេគិតថាគេប្រហែលជាស្ដាប់ច្រឡំហើយ ឃើញគេនៅស្ងៀមមិនតបតិតតែពីសម្លឹងមក ធ្វើឲ្យនាងធ្វើខ្លួន មិនត្រូវនោះទេ ដឹងថាគេច្បាស់ជាស្ដីបន្ទោសដែលនាងលាក់បាំងពីរឿង នាងមានកូន តែពេលនេះមិនថាត្រូវធ្វើអ្វីនោះទេឲ្យតែអាចជួយកូនបាន នាងព្រមធ្វើគ្រប់យ៉ាង។

-ជួយ អេរិច ផងគេមានគ្រោះថ្នាក់ត្រូវការអ្នកផ្ដល់ឈាម-

-ជាកូននាងមិនទាក់ទងនិងខ្ញុំទេ- គេប្រាប់សំឡេងស្មើរតែក្នុងចិត្ត ក៏បារម្ភពីគេដូចគ្នា តែពេលគិតថានាងមានកូនជាមួយអ្នកផ្សេងហើយបែរ





ជាមករត់រកឲ្យគេជួយ ហេតុអីមិនទៅរកប៉ាក្មេងនោះទៅ។

ស៊ូហ៊ី ងើបសម្លឹងមុខគេទាំងទឹកភ្នែកមិនបន្ទោសគេនោះទេដែលគេ និយាយបែបនេះព្រោះតែគេមិនដឹង តែក្នុងចិត្តនាងពិតជាអួលណែនក្នុង ទ្រូងព្រោះមិនដឹងថាត្រូវនិយាយប្រាប់គេយ៉ាងម៉េចនោះទេ នាងក្រមុំងក ដង្ហើមរម្ងាប់អារម្មណ៍មុននឹងចាប់ផ្ដើមនិយាយបន្ត។

-អេរិច ជាសាច់ឈាមរបស់លោកមេត្តាជួយគេផងទៅ- នាង និយាយទាំងអណ្ដែតអណ្ដូកលុតជង្គង់ចំពោះមុខគេ អែលវិន រាងទ្រឹង បន្តិចបន្ទាប់ពីឮ ក្មេងម្នាក់នោះជាកូនគេអ៊ីចឹងឬ? គេគិតក្នុងចិត្តស្ទុះក្រោក ពីសាឡុងសំដៅរាងស្ដើង ស្រវាចាប់ដើមដៃនាងឲ្យក្រោកមកប្រឈម ជាមួយគេ។

-ព្រោះតែរកប៉ាឲ្យក្មេងមិនបានមែនទេ ទើបលើកតួនាទីមកឲ្យខ្ញុំ- គេនិយាយសំឡេងតាមដើងធ្មេញ សម្លឹងរាងស្ដើងចំពោះដោយកំហឹង ស៊ូហ៊ី គ្រវីក្បាលទាំងទឹកភ្នែកមុននឹងតប។

-អេរិច ពិតជាកូនលោកមែន គេមានឈាមគ្រុបអូ ពេលនេះកំពុង ត្រូវការឈាមប្រភេទនេះសូមអង្វរជួយគេផងទៅ- អែលវិន នៅទ្រឹងសម្លឹង មុខនាងស្មើគេពិតជាមានឈាមប្រភេទនេះមែនមានតែអ្នកក្នុងគ្រួសារគេ តែប៉ុណ្ណោះដែលដឹង តែនាងបែរជាដឹងរឿងនេះ គ្មានពេលគិតច្រើនទៀត នោះទេគេប្រហែលត្រូវប្រញាប់ទៅមន្ទីរពេទ្យទើបដឹងច្បាស់។

អែលវិន កំពុងធ្វើដំណើរទៅមន្ទីរពេទ្យ ស៊ូហ៊ី ក៏មកដូចគ្នា គេ អង្គុយយ៉ាងស្ងៀមស្ងាត់កំពុងគិតរឿងជាច្រើន គេទទួលស្គាល់ថាមាន អារម្មណ៍ស្និទ្ធស្នាលប្លែកជាមួយក្មេងម្នាក់នោះ តែមិនធ្លាប់គិតថាគេជា



Scanned by CamScanner

សាច់ឈាមរបស់គេនោះទេ នេះប្រហែលជាទំនាក់ទំនងសាច់ឈាមហើយមែនទេ គិតហើយក៏ងាកទៅមើលរាងស្តើងដែលអង្គុយក្បែរ នាងហ៊ានខ្លាំងណាស់ដែលទុកកូនដោយមិនប្រាប់គេ ថែមទាំងចិញ្ចឹមគេរហូតមកដល់ធំថែមទៀត តើនាងមានបំណងអីឲ្យប្រាកដ គិតថាយកកូនធ្វើជាធ្នាក់មែនទេយល់សព្វទៅ បើលទ្ធផលចេញមកពិតជាសាច់របស់គេមែននោះ គេនិងជំរះបញ្ជីជាមួយនាងមិនខានទេ គេគិតទាំងតំគួន។

មួយម៉ោងក្រោយមក...

អែលវិន ចេញពីបន្ទប់ពិនិត្យដោយទឹកមុខស្មើរបន្ទាប់ពីលទ្ធផលចេញមកថា អេរិច ពិតជាសាច់ឈាមរបស់គេមែន មានអារម្មណ៍ថាសប្បាយចិត្ត តែពេលក្រឡេកឃើញរាងស្តើងដែលអង្គុយមុខបន្ទប់ធ្វើឲ្យកំហឹងកើតឡើងភ្លាមទើបដើរសំដៅនាងយ៉ាងលឿន។

ស៊ូហ៊ី ដែលមានអារម្មណ៍វិលមុខឃើញគេដើរសំដៅមកដឹងច្បាស់ថាដោយសាររឿងអី តែនាងត្រៀមខ្លួនទទួលគ្រប់យ៉ាងរួចរាល់ហើយមិនថាមានរឿងអីនោះទេ សំខាន់ឲ្យតែកូននាងផុតគ្រោះថ្នាក់គ្រប់គ្រាន់ហើយសម្រាប់នាងទោះត្រូវទទួលថ្នបាក់ពីគេយ៉ាងណាក៏ដោយ។

«នាងមានកូនហេតុអីមិនប្រាប់ខ្ញុំ ហ្អាស» គេសួរសំឡេងរឹងកន្ត្រាក់រាងស្តើងមកបុកដើមទ្រូងខ្លួនសម្លឹងមើលនាងដោយក្រសែភ្នែកមុត ស៊ូហ៊ីមិនតបបានត្រឹមបង្ហូរទឹកភ្នែកតែប៉ុណ្ណោះ ព្រោះពេលនេះរាងកាយនាងស្ទើរគ្មានកំលាំងឈរនឹងផង។

«នាងទុកកូនតើមានបំណងអីមែនទេ គិតថាយកកូនមកតោងត្បៀមខ្ញុំមែនទេ» សំឡេងគេនៅតែបន្លឺមកទៀត។





«ខ្ញុំគ្មានបំណងអីនោះទេ ខ្ញុំគ្រាន់តែចង់ចិញ្ចឹមគេតែប៉ុណ្ណោះ»

«គ្មានបំណង នាងគិតថាខ្ញុំជឿនាងមែនទេ»

«បើសិនជាលោកដឹង អាចឲ្យខ្ញុំទុកគេដែរទេ ក្នុងនាមជាម្តាយម្នាក់ លោកចង់ឲ្យខ្ញុំលើកដៃសម្លាប់កូនទាំងគេគ្មានកំហុសមែនទេ ខ្ញុំធ្វើមិនបានទេយ៉ាងណាគេជាកូនខ្ញុំ ខ្ញុំបង្កើតគេមើលថែគេហើយក៏មិនបានគិតថាយកគេធ្វើជាឧបករណ៍អីនោះដែរ»

«គិតថាខ្ញុំជឿនាងមែនទេ?» គេតបហើយក៏រុញរាងស្តើងចេញពីខ្លួន នាងក្រមុំស្ទើរតែដួលទៅហើយតែព្យាយាមទប់ជំហររបស់ខ្លួន។

«ជឿមិនជឿតាមចិត្តលោក» តបហើយក៏យោងរាងកាយដែលខ្សោះល្វើយរបស់ខ្លួនដើរចេញទៅទាំងទឹកភ្នែកជោគថ្ពាល់ ដើរបានបន្តិចក៏មានអារម្មណ៍ថាផែនដីកំពុងវិល ដោយសារបារម្ភពីកូននាងមិនបានញ៉ាំអីចូលពោះតាំងពីព្រឹកទើបធ្វើឲ្យសភាពរាងកាយដែលគ្មានកំលាំង នៅទ្រឹងមិនអាចបន្តទៅមុខបានក៏ស្រុញដួល ក្រោមក្រសែភ្នែកភ្ញាក់ផ្អើលរបស់អ្នកម្ខាងទៀត ទើបស្ទុះមកលើកគ្រានាងដោយការព្រួយបារម្ភ។

គេឈរសម្លឹងរាងស្តើង ដែលនៅលើគ្រែអ្នកជំងឺទឹកមុខស្លេកស្លាំងគួរឲ្យអាណិត គេមិនដឹងដូចគ្នាហេតុអីពេលខ្លះក៏បារម្ភពីនាងខ្លាំងយ៉ាងនេះគ្មានចម្លើយសម្រាប់ខ្លួនឯង កំពុងតែគិតស្របពេលអ្នកម្ខាងទៀតបើកភ្នែកមកមើល ទើបប្តូទឹកមុខស្មើរសម្លឹងនាង។

ស៊ូហ៊ី ដឹងថាគេកំពុងចងកំហឹងជាមួយនាងទើបបិទភ្នែកទៅវិញងាកមុខចេញព្រោះនាងគ្មានកំលាំងប្រកែកជាមួយគេនោះទេ។

«ខ្ញុំនឹងនាំគេទៅអង់គ្លេស»

សំឡេងស្មើបន្លឺឡើង ធ្វើឲ្យអ្នកដែលទើបបិទភ្នែកត្រូវបើកមកវិញយ៉ាងលឿនសម្លឹងមើលអ្នកម្ខាងទៀត។

-មិនបានទេ- នាងតបសំឡេងស្រាលទាំងប្រឹងក្រោកអង្គុយគ្រាន់តែឮគេថាចង់នាំកូនទៅបេះដូងនាងស្ទើរឈប់ដើរទៅហើយ ព្រោះតែពួកគេទើបនាងតស៊ូរស់តទៅទៀតចុះបើគ្មានពួកគេ តើនាងរស់យ៉ាងម៉េចទៅ នាងតិតទាំងខ្វល់ខ្វាយមុននឹងសំឡេងរបស់គេបន្លឺមកទៀត។

-ហេតុអីមិនបាន គេជាកូនខ្ញុំ នាងជាម្ដាយយ៉ាងម៉េចហេតុអីមិនចេះមើលកូនឲ្យបានល្អ ដឹងថាឈាមប្រភេទនេះជាឈាមកម្រហេតុអីក៏បណ្ដោយឲ្យមានរឿងបែបនេះកើតឡើង ចុះបើខ្ញុំមិននៅទីនេះតើគេទៅជាយ៉ាងម៉េចទៅ- គេតបសំឡេងរឹងសម្លឹងនាងដោយខ្សែភ្នែកដាក់កំហុស ស៊ូហ៊ី ដឹងថានាងជាម្ដាយមិនល្អតែនាងព្យាយាមមើលថែពួកគេយ៉ាងល្អបំផុតហើយតាមដែលអាចធ្វើបាន។

-សូមទោស- នាងតបហើយក៏ឱនមុខចុះបង្ហូរទឹកភ្នែកយ៉ាងស្ងៀមស្ងាត់ដោយមិនដឹងថាមានមនុស្សចូលមកនោះទេ។

-អ៊ី សូមទោស- សំឡេងអ្នកណាម្នាក់បន្លឺឡើងទើបពួកគេនាំគ្នាងាកទៅមើលហើយក៏ឃើញស្ត្រីម្នាក់ពរ អាយរីន ចូលមក។

-គឺ អាយរីន ចង់ជួបអ្នកម៉ាក់ទើបខ្ញុំនាំគេមក- នាងប្រាប់ទាំងពរនាងតូចទៅឲ្យម្ដាយដែលនៅលើគ្រែ។

-អរគុណអ្នកគ្រូ- ស៊ូហ៊ី តបរួចទើបគាត់ដើរចេញទៅវិញទើបនាងទាញកូនមកឱបជាប់ទ្រូង ព្រោះគិតថានាងតូចកំពុងភ័យព្រោះតែសំឡេងរបស់ពួកនាងមុននេះ។





-ម៉ាក់យំមែនទេ?- នាងតូចងើបមុខមកសួរម្ដាយទើបនាងត្រូវជូតទឹកភ្នែកចេញញញឹមតិចៗតបកូន។

-មិនមែនទេ ម៉ាក់មិនបានយំទេគ្រាន់តែមានអីហើរចូលភ្នែកទើបធ្វើឲ្យទឹកភ្នែកហូរចេញមក-

-មែនហ៎? ចាំកូនផ្លុំឲ្យល្អទេ- នាងតូចតបហើយក៏ក្រោករង្គុយទល់មុខម្ដាយលើកម្រៀមដៃតូចឆ្មារមកជូតទឹកភ្នែកចេញពីថ្ពាល់ រូបភាពស្និទ្ធស្នាលរបស់ពួកនាង ធ្វើឲ្យអ្នកដែលឈរមើលញញឹមតិចៗ និងភាពគួរឲ្យស្រលាញ់របស់នាងតូចម្នាក់នេះ។

-ម៉ាក់ហ្នាស បងប្រុសទៅណា អាយរីន អផ្សុកណាស់អត់ឃើញបងប្រុសមកលេងជាមួយកូនចឹង- អ្នកជាម្ដាយទ្រឹងបន្តិចមុននឹងតប។

-បងប្រុសកំពុងគេង បន្តិចទៀតនិងក្រោកមកលេងជាមួយកូនហើយ- នាងតបហើយក៏ទាញកូនមកឱបទឹកភ្នែកដែលទើបឈប់ក៏ចាប់ផ្ដើមហូរមកម្ដងទៀត។

អែលវិន ឈរសម្លឹងមើលនាងតូចនៅហ្នឹងមុខទាំងរិះគិតបើ អេរិចជាកូនគេចុះនាងច្រម៉ក់ម្នាក់នេះ... ឬពួកគេជាកូនភ្លោះ គិតហើយក៏ងាកទៅមើលនាងម្ដងទៀតឃើញនាងកំពុងសម្លឹងមកគេភ្លឹះៗ ហើយក៏ងាកចេញវិញធ្វើឲ្យគេជ្រួញចិញ្ចើម ប្រហែលនាងនៅខ្លាចដែលគេនិយាយឮៗថាឲ្យម្ដាយនាងមុននេះហើយ។

អែលវិន ត្រូវទៅមើលការងារនៅការដ្ឋានសាងសង់បន្ទាប់ពីមនុស្សរបស់គេរាយការណ៍ថាមានឧបតហេតុកើតឡើង ហើយក៏ជារឿងភ្ញាក់ផ្អើលពេលដឹងថា ការដ្ឋានរបស់គេធ្វើឲ្យកើតមានឧបតហេតុក្នុងសាលាម

គេយ្យ ហើយជាសាលារបស់ អេរិច នេះហើយទើបឲ្យប[illegible] បញ្ឈប់ការសាងសង់ជាបណ្តោះអាសន្ន ហើយក៏ត្រឡប់[illegible] ទៅជួបគ្រូពេទ្យសួរអាការៈរបស់កូនហើយ ក៏ដើរមកបន្ទប់ស[illegible] សូហ៊ី នាងគេងលក់ហើយនៅសល់តែនាងតូចដែលកំពុងអង្គុយជិតម្តាយ ទើបគេដើរតិចៗសំដៅទៅ ឃើញនាងងាកមកទើបយកដៃដាក់លើបបូរមាត់ឲ្យនាងស្ងាត់ដើរទៅលើកនាងមកពរដើរចេញទៅក្រៅ។

«អាយរីន ឃ្លានដែរទេ?» គេសួរនាងពេលនាំមកដល់ខាងមុខហាងបីហ្គឺរដែលនៅជិតមន្ទីរពេទ្យ នាងតូចមិនតបគ្រាន់តែងក់ក្បាលធ្វើឲ្យគេញញឹមហើយក៏ដើរចូលហាងកុម្មង់សាន់វិចមកឲ្យ គេអង្គុយមើលនាងញ៉ាំយ៉ាងភ្លឹកភ្លាំងមិនគិតថាខ្លួនមានកូនគួរឲ្យស្រលាញ់បែបនេះទេ។

«ឆ្អែតហើយមែនទេ?» គេសួរតិចៗទាំងហុចទឹកឲ្យនាងញ៉ាំ នាងតូចមិនតបតែនៅសម្លឹងទៅទូតាំងនៅក្នុងហាងធ្វើឲ្យគេមើលទៅតាម។

«ចង់ញ៉ាំទៀតមែនទេ?» នាងគ្រវីក្បាលមើលមុខគេភ្លឹះៗ។

«អាចខ្ចប់យកឲ្យបងប្រុសបានទេ?» នាងសួរទាំងសម្លឹងមើលមុខគេភ្លឹះៗ ធ្វើឲ្យគេញញឹមតិចៗ។

«បាន រឿងអីថាមិនបាន» គេនិយាយរួចក៏ងាកទៅប្រាប់អ្នករត់តុ។

អែលវិន នាំនាងមកដល់មន្ទីរពេទ្យមើលទៅនាងដូចជារីករាយជាងមុននេះបន្ទាប់ពីញ៉ាំហើយ។

«អាយរីន»

«ចាស»

«ចង់មានប៉ាដែរទេ?» គេមិនដឹងថាហេតុអីក៏សួរសំណួរនេះនោះទេ





ទាំងដែលគេមិនចូលចិត្តក្មេង តែពេលដឹងថាគេមានកូនធ្វើឲ្យគេមានអារម្មណ៍ចង់មើលថែពួកគេ។

«ម៉ាក់ប្រាប់ថាប៉ាទៅឆ្ងាយហើយ មិនអាចនៅជាមួយពួកខ្ញុំទេ» នាងតូចតបធ្វើឲ្យគេជ្រួញចិញ្ចើម ទៅឆ្ងាយ! នាងចង់ប្រាប់កូនថាគេស្លាប់ទាំងដែលគេនៅរស់ជ្រងោចឹងមែនទេ ទៅវិញច្បាស់ជាដឹងគ្នាមិនខានទេ គេគិតទាំងម៉ូម៉ៅងាកមកនាងតូចលើដៃម្តងទៀត។

«ចុះបើប៉ាត្រឡប់មកវិញ អាយរីន សប្បាយចិត្តដែលទេ?»

«សប្បាយចិត្តខ្លាំងណាស់ អាយរីន ចង់មានប៉ា» នាងតបហើយក៏ស្រវាឱបករគេជាប់ ប៉ាច្បាស់ជាត្រឡប់មកវិញមកយកកូនទៅនៅជាមួយនោះអី គេគិតក្នុងចិត្តមុននឹងត្រឡប់ទៅមន្ទីរពេទ្យវិញ។

ស៊ូហ៊ី ដើរចេញពីបន្ទប់អ្នកជំងឺព្រោះតែមិនឃើញកូនទើបនាងដើររកទាំងភ័យព្រួយតែបែរជាឃើញ អែលវិន កំពុងពនោងដើរមក។

«ម៉ាក់!» នាងតូចស្រែកហៅទាំងសប្បាយចិត្តទើបគេដាក់នាងចុះឲ្យរត់មករករាងស្តើងដែលកំពុងចាំ។

«កូនទើបមកពីណា?» នាងសួរកូនតិចៗដឹងថាគេប្រហែលនាំនាងទៅញ៉ាំអីហើយព្រោះមានយួររបស់ញ៉ាំមកជាមួយ។

«ទៅញ៉ាំអីជាមួយពូស្អាត» នាងតបហើយក៏ងាកទៅអ្នកកំពុងឈរមើល ស៊ូហ៊ី មិនមាត់គ្រាន់តែញញឹមដឹងដៃនាងទៅបន្ទប់សម្រាកវិញតែឆ្លៀតងាកទៅអ្នកម្ខាងទៀតដែលកំពុងឈរសម្លឹងនាងដោយខ្សែភ្នែកដាក់ទោស គេប្រហែលដឹងរឿងអីទៀតហើយនាងគិតក្នុងចិត្ត។

«ម៉ាក់ហ្មាស ពូស្អាតប្រាប់ថាប៉ានិងមកនៅជាមួយពួកយើងវិញតើ

មែនទេ?» នាងតូចសួរម្ដាយពេលនាំនាងមកដល់ក្នុង ធ្វើឲ្យអ្នកជាម្ដាយ
នៅស្ងៀមព្រោះរកពាក្យឆ្លើយជាមួយកូនមិនបាន មិនដឹងថាគេនិយាយអ្វី
ខ្លះជាមួយកូននោះទេ។

«អាយរីន ចង់ឲ្យប៉ាត្រឡប់មកវិញមែនទេ?» នាងសួរកូនតិចៗធ្វើ
ឲ្យនាងតូចងក់ក្បាលតបយ៉ាងលឿន។

«កូនចង់មានប៉ា មិត្តនៅសាលាគេមានប៉ាម៉ាក់មកទទួលគ្រប់គ្នា»
ពាក្យសម្ដីរបស់កូន ធ្វើឲ្យទឹកភ្នែកអ្នកជាម្ដាយស្រក់ចុះទាញនាងមកឱប
គិតថាមានត្រឹមនាង អាចធ្វើឲ្យកូនមានក្ដីសុខតែតាមពិតនាងគិតតែខ្លួន
ឯងតែប៉ុណ្ណោះ ពួកគេត្រូវការគ្រួសារមួយពេញលេញដូចអ្នកដទៃនាងជា
ម្ដាយអាត្មានិយមខ្លាំងណាស់មែនទេ គិតបណ្ដើរទឹកភ្នែកហូរមកបណ្ដើរ។

«ខ្ញុំមានរឿងចង់និយាយជាមួយនាង» សំឡេងគ្រលរបន្លឺឡើងទើប
ងាកទៅមើល អែលវិន កំពុងឈរសម្លឹងមក នាងងាកមកកូនដែលគេង
លក់លើគ្រែទាញភួយដណ្ដប់ឲ្យមុននឹងដើរទៅតាមគេ។

«ខ្ញុំនិងនាំពួកគេទៅអង់គ្លេស» គេប្រាប់ពេលនាំនាងមកខាងក្រៅ
ស៊ូហ៊ី នៅស្ងៀមតែក្នុងចិត្តពិតជាច្របូកច្របល់ ដឹងថាថ្ងៃនេះនឹងមកដល់
តែនាងមិនចង់បាត់បង់ពួកគេនោះទេ។

«ខ្ញុំគ្រាន់តែប្រាប់ឲ្យដឹង មិនបានសុំការយល់ព្រមពីនាងនោះទេ
ព្រោះខ្ញុំមានសិទ្ធក្នុងរឿងនេះ» សំឡេងគេនៅតែបន្លឺមកទៀតធ្វើឲ្យទឹកភ្នែក
នាងចាប់ផ្ដើមហូរដឹងថាគ្មានសិទ្ធរារាំងនោះទេ តែគេក៏ហួសហេតុដែរមិន
ខ្វល់ពីអារម្មណ៍នាងទាល់តែសោះ នាងជាអ្នកមើលថែពួកគេតាំងពីតូចតែ
គេបែរជាបំបែកនាងពីកូន មានអារម្មណ៍ណែនក្នុងទ្រូងមិនអាចនិយាយអ្វី





បានត្រឹមឈរសម្លឹងមុខគេតែប៉ុណ្ណោះ។

«ខ្ញុំយល់ហើយ» នាងតបហើយក៏បែខ្លួនចូលទៅក្នុងស្របពេល
សំឡេងរបស់គេបន្លឺមកទៀត។

«ខ្ញុំនិងឲ្យលុយនាងមួយចំនួន ចាត់ទុកថាជាថ្លៃឈ្នួលមើលថែពួក
គេកន្លងមក» នាងក្រមុំឈប់ឆ្ងក់ញញឹមចំអកមុននឹងបែបមក។

«ខ្ញុំមើលថែពួកគេក្នុងនាមជាម្ដាយ មិនមែនជាឈ្នួលបម្រើនោះទេ
ដូច្នេះទុកលុយរបស់លោកវិញទៅ សូមតែមើលថែពួកគេបន្តឲ្យល្អទៅ
បានហើយ» នាងនិយាយសំឡេងម៉ឺងម៉ាត់ហើយក៏ដើរចូលក្នុងវិញ ធ្វើឲ្យ
អ្នកម្ខាងទៀតចាប់ផ្ដើមម៉ូម៉ៅដែលនាងហ៊ានបដិសេធគេ។

ស៊ូហ៊ី អង្គុយធ្វើការក្នុងហាងទាំងគ្មានអារម្មណ៍ព្រោះប៉ុន្មានថ្ងៃមក
ហើយតាំងពីថ្ងៃដែលចេញពីពេទ្យ នាងស្ទើរមិនបានជួបមុខកូនព្រោះ
អែលវិន ជាអ្នកមើលថែនាំពួកគេទៅសាលាហើយក៏ទៅដើរលេង និងទុក
នៅក្នុងបន្ទប់ធ្វើការគេថែមទៀត រួមទាំងនាងរវល់ផងទើបមិនបានទៅ
ទទួលពួកគេមកវិញនោះទេ។

«ម៉ាក់ម៉ាក់» សំឡេងស្រែកហៅនៅខាងមុខហាង ធ្វើឲ្យអ្នកដែល
កំពុងអង្គុយរវើរវាយភ្ញាក់ព្រើតងាកទៅមើលយ៉ាងលឿន ហើយក៏ញញឹម
ស្ទុះទៅទទួលពួកគេយ៉ាងរីករាយ។

«បាស ម៉ាក់នៅទីនេះ» នាងនិយាយទាំងស្រវាឱបកូនទើបដោយ
ក្ដីនឹករឭកធ្វើឲ្យទឹកភ្នែកក៏ចាប់ផ្ដើមហូរ។

«ម៉ាក់យំទៀតហើយ» នាងតូចប្រាប់ម្ដាយទាំងលើកម្រាមដៃតូច
ទៅជូតឲ្យធ្វើឲ្យអ្នកជាម្ដាយញញឹម ធ្វើឲ្យអ្នកឈរមើលមានអារម្មណ៍ក្ដុក

ក្ដួលចម្លែកដូចគ្នា ពេលឃើញទឹកភ្នែករបស់នាង។

«កូនដើរលេងសប្បាយដែរទេ?» នាងប្ដូររឿងសួរកូនទាំងពីរដែលពួកគេទៅអង្គុយកៅអីក្នុងហាង។

«សប្បាយខ្លាំងណាស់ តែម៉ាក់ហ្មាស កូនឃ្លានហើយ» អេរិចប្រាប់ម្ដាយទាំងអង្អែលពោះធ្វើឲ្យនាងសើចព្រោះជាទម្លាប់ទៅហើយ។

«ម៉ាក់ដឹងហើយ» នាងតបកូនហើយក៏ក្រោកឈរងាកមើលមុខអ្នកម្ខាងទៀតដែលកំពុងសម្លឹងនាងដូចគ្នា។

-លោកត្រូវការអីដែរទេ?»

-អត់ទេ ផ្ញើពួកគេផងល្ងាចខ្ញុំនឹងមកទទួលពួកគេទៅវិញ- អែលវិន តបហើយក៏ដើរចេញទៅ មិនបាច់ប្រាប់ក៏នាងត្រូវមើលថែពួកគេដែរព្រោះជាកូនរបស់នាង នាងគិតក្នុងចិត្តហើយក៏ដើរទៅក្នុង។

ស៊ុហ៊ី ត្រូវនាំកូនត្រឡប់មកសណ្ឋាគារព្រោះពួកគេទទូចចង់ជួបអែនវិន ធ្វើឲ្យនាងមានអារម្មណ៍សោកសៅព្រោះនៅជាមួយគេតែប៉ុន្មានថ្ងៃមើលទៅពួកគេ ដូចជាសប្បាយចិត្តខ្លាំងជាងនៅជាមួយនាងថែមទៀត។

-ប៉ា/ប៉ា- សំឡេងស្រែកហៅទាំងរត់ទៅរកដោយភាពត្រេកអរធ្វើឲ្យអ្នកឈរមើលបង្ហាញស្នាមញញឹម ព្រោះឃើញក្ដីស្រលាញ់រវាងឪពុកកូនតែក៏មានអារម្មណ៍ឈឺក្នុងចិត្តពេលដឹងថាជិតបែកពីពួកគេ តែនាងគ្មានជម្រើសនោះទេ បើពួកគេនៅជាមួយនាងក៏មិនប្រាកដថាមានអនាគតល្អនោះដែរ នាងចង់ឃើញពួកគេមានអនាគតល្អមិនចង់ឲ្យមានវាសនាលំបាកដូចនាងនោះទេ។





-ហេតុអីក៏មកដល់ទីនេះ ប៉ាប្រាប់ហើយថាចាំទៅទទួល- អែលវិននិយាយទាំងញញឹមលើកពួកគេមកពង្លៀងសម្លឹងទៅរាងស្ដើង ដែលឈរធ្វើមុខស្រពោនសម្លឹងមក គេមិនដឹងថានាងកំពុងតែគិតអីនោះទេព្រោះប៉ុន្មានថ្ងៃមកនេះមើលទៅនាងដូចជាប្លែកៗ។

-នឹកប៉ាៗ- នាងតូចតបធ្វើឲ្យគេញញឹមមុននឹងដាក់ពួកគេចុះឲ្យមនុស្សជំនិតទាំងពីរមើលហើយក៏ដើរសំដៅរាងស្ដើង។

-ខ្ញុំត្រៀមឯកសាររួចរាល់ហើយស្អែកខ្ញុំនាំពួកគេទៅ នាងក៏ត្រូវទៅដូចគ្នា- គេនិយាយសំឡេងស្មើរធ្វើឲ្យអ្នកម្ខាងទៀតងាកមុខមកមើលទាំងងឿងឆ្ងល់ទើបគេត្រូវពន្យល់បន្ថែម។

-ត្រឹមមួយរយៈតែប៉ុណ្ណោះ ខ្ញុំខ្លាចពួកគេស្រែករកនាងប្រហែលយល់ពីរឿងនេះហើយ- គេប្រាប់ទាំងសម្លឹងមុខនាងតែកែវភ្នែករបស់គេបែរជាធ្វើឲ្យនាងមុខក្រហម។

-ចាសយល់ហើយ- នាងតបសំឡេងស្រាលហើយក៏ងាកទៅមើលកូនដែលកំពុងដើរលេង គេត្រូវការតែកូនប៉ុណ្ណោះនាងគ្មានសិទ្ធអីនោះទេចាំទុកតួនាទីនាងត្រឹមមើលថែកូនប៉ុណ្ណោះ នាងដាស់តឿនខ្លួនឯងក្នុងចិត្តអែលវិន ឈរសម្លឹងនាងដោយទឹកមុខស្មើតែក្នុងចិត្តកំពុងតែខ្វល់ខ្វាយពេលឃើញទឹកមុខស្រពោនសោកសៅរបស់នាង ធ្វើឲ្យគេមានអារម្មណ៍អាណិតមិនដឹងថាគេធ្វើនេះត្រូវឬខុសនោះទេ។





...១៣...

អែលវិន ធ្វើដំណើរតាមយន្តហោះផ្ទាល់ខ្លួនត្រឡប់មកអង់គ្លេសរួមទាំង ស៊ូហ៊ី និងកូនគេមានអារម្មណ៍រំភើបមិនធ្លាប់មានមិនគិតថាមានកូនដល់ទៅពីរនាក់ហើយគួរឲ្យស្រលាញ់យ៉ាងនេះនោះទេ គិតហើយក៏ងាកទៅមើលអ្នកក្បែរខ្លួនដែលកំពុងអង្គុយបង្ហូរទឹកភ្នែកយ៉ាងស្ងៀមស្ងាត់ គេមិនដឹងថានាងកំពុងតែគិតអីនោះទេ។

រថយន្តបានមកឈប់ខាងមុខភូមិគ្រឹះដ៏ធំស្កឹមស្កៃ អែលវិន ចុះពីរថយន្តដៃពរកូនម្ខាងម្នាក់រួមទាំង ស៊ូហ៊ី ចុះមកតាមក្រោយនាងឈរមើលទិដ្ឋភាពជុំវិញដោយភាពភ្លឹកភ្លាំង មុននឹងភ្ញាក់ខ្លួនពេលឃើញគេពរកូនដើរទៅដល់ក្នុងទើបដើរទៅតាមក្រោយ។

-ស្វាគមន៍អ្នកប្រុសត្រឡប់មកវិញ- សំឡេងមេផ្ទះចំណាស់បន្លឺឡើងថែមទាំងសម្លឹងក្មេងនៅលើដៃគេដោយភាពងឿងឆ្ងល់ រួមទាំងនារីដែលទើបចូលមកតាមក្រោយ។

-អ្នកប្រុសក្មេងទាំងពីរនេះ...-

-ជាកូនខ្ញុំ ចាប់ពីពេលនេះទៅពួកគេនឹងនៅទីនេះ- គេប្រាប់ហើយក៏ដើរឡើងទៅលើនៅសល់តែ ស៊ូហ៊ី មិនដឹងថាត្រូវទៅខាងណានោះទេទើបឈរស្ងៀម មេផ្ទះចំណាស់សម្លឹងនាងបន្តិចមុននឹងញញឹមមកធ្វើឲ្យនាងរាងធូចិត្តបន្តិចទើបញញឹមតប។

-អ្នកនាងជា...-

-ជាម៉ាក់របស់ អ្នកប្រុសតូច អ្នកនាងតូច- ជេក តបបន្ថែមទើបម្នាក់ៗនាំគ្នាងាកមកមើលនាងទាំងភ្ញាក់ផ្អើល។

-ចាសខ្ញុំយល់ហើយ- មេផ្ទះចំណាស់តបហើយក៏ងាកទៅមើលអ្នកបម្រើក្មេងដែលឈរជិតគាត់។

-ទៅរៀបចំបន្ទប់សម្រាប់អ្នកស្រីទៅ-

-កុំហៅខ្ញុំបែបនេះអី ហៅ ស៊ូហ៊ី ធម្មតាបានហើយ- នាងប្រាប់ទាំងញញឹមធ្វើឲ្យគាត់ងាកទៅមើល ជេក និង ជីម ក្នុងន័យសួរតែពួកគេគ្រាន់តែគ្រវីក្បាលហើយក៏យួរអីវ៉ាន់ឡើងទៅលើ។

អាហារពេលល្ងាចរៀបចំរួចរាល់នៅលើតុ ស៊ូហ៊ី ក៏ចូលធ្វើម្ហូបសម្រាប់កូនដូចគ្នាព្រោះគិតថាពួកគេមិនទាន់ស៊ាំម្ហូបនៅទីនេះ។

-ទីនេះជាផ្ទះប៉ាមែនទេ?- អេរិច បន្លឺឡើងធ្វើឲ្យគ្រប់គ្នានាំគ្នាងាកទៅមើល។

-បាទ ជាផ្ទះប៉ា ចូលចិត្តទីនេះទេ?- គេសួរទាំងទាញកូនមកអង្គុយលើភ្លៅ។

-ចូលចិត្តខ្លាំងណាស់ ទីនេះធំជាងផ្ទះកូនពីមុនទៀត- គេនិយាយទាំងធ្វើកាយវិការ ធ្វើឲ្យអ្នកជុំវិញនាំគ្នាញញឹមនិងភាពគួរឲ្យស្រលាញ់របស់គេ ស៊ូហ៊ី មិនមាត់គ្រាន់តែញញឹមតិចៗ។

-ម៉ាក់កូនអាចនៅទីនេះបានទេ?- អាយរីន ក្មេងស្រីតូចងាកទៅស្វាម្ដាយដែលអង្គុយជិតធ្វើឲ្យនាងរាងទ្រឹងបន្តិចមុននឹងតប។

-ច្បាស់ជាបានហើយ- នាងតបកូនទាំងញញឹមតែក្នុងចិត្តដូចកំពុងលេបដុំគ្រោះជាច្រើនដុំ តែនាងស្ម័គ្រ[illegible]ធ្វើឲ្យពួកគេសប្បាយចិត្ត សកម្មភាពរបស់នាងក៏មិនអា[illegible]ក្ខុករបស់អ្នកអង្គុយទល់មុខនេះដែរ ម៉ៃឈិន [illegible]



ពេលនេះយប់ទៅហើយ រាងស្ដើងកំពុងអង្គុយក្នុងសួនសម្លឹងមើលជុំវិញភូមិគ្រឹះដែលមានសួនផ្កាជាច្រើនប្រភេទ នាងមិនដឹងថាហេតុអីក៏នាងមកដល់ទីនេះនោះទេ ហើយមកដើម្បីអីជាពិភពមួយដែលនាងមិនធ្លាប់ស្គាល់ មកហើយក៏ត្រឡប់ទៅកន្លែងដើមវិញ ដោយនាំយកទាំងរឿងរ៉ាវជាច្រើនរួមទាំងភាពឈឺចាប់ថែមទៀត អង្គុយយូមានអារម្មណ៍ខ្យល់ត្រជាក់បក់មកទើបត្រឡប់ចូលទៅក្នុងវិញ ដើរមកដល់មុខបន្ទប់ស្របពេលរាងកាយក្រាស់ដើរមកឈរពីមុខធ្វើឲ្យនាងភ្ញាក់ព្រើត។

-ទើបមកពីណា?- គេសួរសំឡេងរឹង។

-មកពីខាងក្រៅ- នាងតបហើយក៏ឱនបន្តិចមុននឹងដើរសំដៅបន្ទប់របស់ខ្លួនតែក៏ត្រូវគេចាប់កវដៃជាប់ទើបងាកមកមើល។

-លោកមានការអីមែនទេ-

-គ្មានទេ គ្រាន់តែប្រាប់ដល់ម៉ោងទៅសម្រាកហើយ- គេប្រាប់ទាំងញញឹមមានល្បិចហើយក៏អូសនាងដើរទៅ។

-បន្ទប់ខ្ញុំនៅខាងនោះទេ- នាងនៅតែព្យាយាមប្រាប់ទាំងបេះដៃគេចេញព្រោះមិនដឹងគេចង់នាំនាងទៅណានោះទេ។

-អ្នកណាប្រាប់?- គេងាកមកតបសំឡេងស្មើរធ្វើឲ្យនាងឈប់ធីហើយចាប់ផ្ដើមដកដង្ហើមញាប់ពេលឃើញខ្សែភ្នែករបស់គេ កំលោះញញឹមចុងមាត់ពេលដឹងថានាងកំពុងគិតអី ហើយក៏លើកនាងបីសំដៅបន្ទប់របស់ខ្លួនដែលនៅខាងចុងគេ ស៊ូហ៊ី ដឹងថាគេចង់ធ្វើអីតែនាងគ្មានកំលាំងធីបម្រះជាមួយគេនោះទេទើបនៅស្ងៀម។

ម៉ៃឈិន បីនាងមកដាក់លើគ្រែថ្នមៗ សម្លឹងនាងដោយក្រសែភ្នែក

ស្រកបណ្ដានធ្វើឲ្យនាងងាកមុខចេញ មិនមែនព្រោះភាពអៀនខ្មាសទេ ព្រោះតែភាពតូចចិត្ត ចំពោះគេនាងនៅតែជាមនុស្សស្រីកំដរការសប្បាយ ពេលធុញក៏រុញចេញ ពេលត្រូវការក៏យកមកវិញ សប្បាយឆ្អែតក៏ទាត់ចោលតែប៉ុណ្ណោះ។

អែលវិន ចាត់ការអាវដំណេកស្ដើងរហូតអស់មុននឹងឱនទៅរកចុងកំពូលស្រួចគេថើបច្របាច់លិឍដោយភាពជក់ចិត្ត ហើយក៏ងើបមុខមកវិញសម្លឹងមើលអ្នកម្ខាងទៀត។

-នាងមិនបានឲ្យកូនបៅទឹកដោះទេមែនទេ?- គេសួរសំឡេងរឹងធ្វើឲ្យអ្នកដែលបិទភ្នែកព្រោះភាពស្រៀវស្រើបមុននេះត្រូវបើកមកវិញ។

-គឺ ខ្ញុំមិនសូវមានទឹកដោះ ហើយម្យ៉ាងទៀតពួកគេដល់ទៅពីរនាក់ទើបឲ្យពួកគេញុំាទឹកដោះគោ- នាងតបរដាក់រដុបទាំងអៀនខ្មាសព្រោះមិនដឹងហេតុអីគេចង់ដឹងរឿងនេះ ព្រោះតែរាងកាយនាងផ្លាស់ប្ដូរមែនទេគិតហើយក៏ទាញភួយមកគ្របខ្លួនតែក៏ត្រូវគេទាញចេញវិញ។

-បើកូនមិនបានបៅទុកឲ្យប៉ាវាក៏បានដែរ- គេរអ៊ូរទាំហើយក៏ឱនទៅរកដើមទ្រូងនាងម្ដងទៀត ស៊ុហ៊ុ សម្លឹងមើលទង្វើរគេទាំងមុខក្រហមព្រោះគេប្រៀបដូចជាកូនក្មេងកំពុងបៅដោះម្ដាយពិតមែន គេសួរព្រោះតែដើមទ្រូងនាងនៅតឹងណែន ដូចមនុស្សមិនធ្លាប់មានកូនទើបធ្វើឲ្យគេឆ្ងល់តែក៏ធ្វើឲ្យគេពេញចិត្តព្រោះវានៅតែពេញដៃដដែល។

អែលវិន សម្លឹងរាងស្ដើងនៅលើគ្រែដោយភាពពេញចិត្តបន្ទាប់ពីបានស្រូបកំលាំងពីនាងពេញមួយយប់ ធ្វើឲ្យគេមានអារម្មណ៍ស្រស់ស្រាយគិតហើយក៏ដើរទៅថើបថ្ងាស់នាងថ្នមៗមុននឹងដើរចេញពីបន្ទប់។





ស៊ុហ៊ុ ភ្ញាក់ដឹងខ្លួនជិតថ្ងៃត្រង់ទៅហើយ ទើបប្រញាប់ក្រោកទៅរៀបចំខ្លួនចុះទៅក្រោមព្រោះនាងមិនធ្លាប់ក្រោកយឺតបែបនេះទេ។

-សុំទោសដែលក្រោកយឺត- នាងប្រាប់មេផ្ទះដែលកំពុងធ្វើម្ហូបងាកមើលជុំវិញក៏មិនឃើញមានអ្នកណាទៀតសូម្បីតែកូន។

-ចាស មិនអីទេអ្នកនាងញុំាអាហារពេលព្រឹកទៅ- គាត់ងាកមកតបទាំងញញឹមធ្វើឲ្យនាងរាងធូចិត្តហើយក៏ដើរទៅតុអាហារ។

-អុំចុះអ្នកផ្សេងទៅណាអស់ហើយ ខ្ញុំចង់និយាយពី...- នាងសួរគាត់តិចៗទាំងញញឹមខ្មោះ។

-អ្នកប្រុសទៅធ្វើការហើយ គាត់នាំអ្នកប្រុសតូចអ្នកនាងតូចទៅជាមួយដែរ ពួកគេគួរឲ្យស្រលាញ់ដល់ហើយ- គាត់និយាយទាំងស្នាមញញឹមធ្វើឲ្យនាងញញឹមដូចគ្នា ដែលអ្នកនៅទីនេះស្រលាញ់កូនរបស់នាងតែស្នាមញញឹមក៏ត្រូវលប់ទៅវិញ ពេលគិតដល់ខ្លួនដែលមិនអាចរស់នៅទីនេះជាមួយពួកគេបាន។

-អ្នកនាងមានអីមែនទេ?-

-ចាសគ្មានអីទេ- នាងតបហើយក៏ចាត់ការអាហាររបស់ខ្លួនមុននឹងឮសំឡេងរបស់គាត់បន្លឺមកទៀត។

-មិនគួរឲ្យជឿសោះថាអ្នកប្រុសមានកូនធំប៉ុណ្ណឹងទៅហើយ ពីមុនគាត់មិនចូលចិត្តក្មេងនោះទេ តែពេលឃើញគាត់ស្រលាញ់កូនបែបនេះក៏ធ្វើឲ្យអុំសប្បាយចិត្តដូចគ្នា- នាងមិនតបគ្រាន់តែញញឹមទឹកឃើញអ៊ីមួយទើបងាកទៅមើលគាត់ម្ដងទៀត។

-តើអុំទំនេរដែរទេ?- នាងសួរគាត់តិចៗ។

«ចាស អ្នកនាងមានការអីមែនទេ?»

«ខ្ញុំចង់ធ្វើម្ហូបពីរបីមុខ សម្រាប់កូនហើយក៏ចង់ឲ្យអ៊ំជួយធ្វើឲ្យពួកគេញ៉ាំពេលដែលខ្ញុំមិននៅ» នាងប្រាប់ទាំងមុខស្រពោនធ្វើឲ្យស្ត្រីចំណាស់ងឿងឆ្ងល់។

«មានន័យយ៉ាងម៉េច អ្នកនាងមិនរស់នៅទីនេះទេមែនទេ?»

«ខ្ញុំរស់នៅត្រឹមមួយរយៈប៉ុណ្ណោះ» តបហើយក៏ដើរសំដៅផ្ទះបាយធ្វើឲ្យស្ត្រីចំណាស់តាមមើលដោយក្ដីអាណិត ព្រោះគាត់អាចស្មានដឹងខ្លះៗហើយថាព្រោះរឿងអី។

«ម៉ាក់កូនត្រឡប់មកវិញហើយ» សំឡេងស្រែកហៅនៅខាងមុខទ្វារធ្វើឲ្យអ្នកនៅផ្ទះបាយនាំគ្នាញញឹម។

«ចាស ម៉ាក់ដឹងហើយ» នាងតបពេលដើរចេញមកទើបពួកគេរត់សំដៅទៅយ៉ាងលឿន។

«ម៉ាក់កូនឃ្លានហើយ»

«កូនក៏ឃ្លានដែរ» សំឡេងពួកគេនិយាយបណ្ដាក់គ្នាធ្វើឲ្យអ្នកនៅទីនោះនាំគ្នាញញឹម។

«ទៅងូតទឹកសិនទើបអាចញ៉ាំបាន»

«យេ!!ទៅងូតទឹកសិន ទៅងូតទឹកសិន» ពួកគេនិយាយហើយក៏នាំគ្នារត់ឡើងទៅលើនៅសល់តែ រាងក្រាស់ដែលកំពុងឈរមើលទាំងស្នាមញញឹម ស៊ូហ៊ី ឃើញគេកំពុងសម្លឹងមកធ្វើឲ្យមុខនាងចាប់ផ្ដើមក្រហមពេលនឹកឃើញរឿងកាលពីយប់ ទើបងាកមុខចេញដើរសំដៅផ្ទះបាយយ៉ាងលឿន អែលវិន ញញឹមចុងមាត់បន្តិចមុននឹងដើរឡើងទៅលើ។



ផិតពីរខែទៅហើយដែល ស៊ូហ៊ី នឹងកូនពីមកនៅទីនេះមើលទៅពួកគេចាប់ផ្ដើមស៊ាំនិងអាកាសធាតុ រួមទាំងអាហារបានច្រើនហើយធ្វើឲ្យនាងមិនសូវបារម្ភដូចមុននោះទេ រាល់ព្រឹកនាងតែងតែក្រោកយឺតជាទម្លាប់ទៅហើយតាំងពីមកនៅទីនេះ ព្រោះត្រូវគេឆាឆៅរាល់យប់នាងស្ទើរមិនបានគេងទៅហើយ ក្រោកមកក៏ត្រូវមនុស្សក្នុងផ្ទះសម្លឹងមុខថែមទាំងនាំគ្នាញញឹមបែបចំអកថែមទៀតព្រោះឃើញស្នាមក្រហមលើករ បែបនេះតើឲ្យនាងយកមុខទៅទុកឯណាទៅ នាងគិតទាំងអៀនខ្មាស។

ស៊ូហ៊ី កំពុងធ្វើម្ហូបនៅខាងក្នុង ស្របពេលឮសំឡេងរថយន្តមកឈប់ខាងមុខ ទើបចេញមកទទួលដោយភាពរីករាយព្រោះគិតថាកូនៗត្រឡប់មក តែបែរជាត្រូវឈរទ្រឹងពេលឃើញ អែលវិន ដើរចូលមកថែមទាំងមាននារីម្នាក់ដើរមកជាមួយថែមទៀត នាងមានអារម្មណ៍ធ្លាប់ឃើញស្រីម្នាក់នោះនៅឯណា ហើយក៏នឹកឃើញធ្លាប់ឃើញនៅកូរ៉េតែមិនអាចធ្វើអ្វីបានត្រឹមឈរស្ងៀមសម្លឹងមើលពួកគេ តែមិនឃើញកូនរបស់នាង។

«អែលវិន ស្រីម្នាក់នេះជាអ្នកណា?» សំឡេងនារីដែលដើរចូលមកជាមួយគេបន្លឺឡើង ថែមទាំងសម្លឹងមកដោយក្រសែភ្នែកមិនចូលចិត្ត។

«ជាអ្នកបម្រើថ្មីរបស់លោកមែនទេ?» សំឡេងនាងនៅតែបន្លឺមកទៀត ស៊ូហ៊ី ងាកទៅមើលអ្នកម្ខាងទៀតចង់ដឹងថាគេឆ្លើយយ៉ាងម៉េចជាមួយស្រីម្នាក់នេះតែគេបែរជានៅស្ងៀមសម្លឹងមុខនាងស្មើរទៅវិញ។

«ពួកយើងទៅក្នុងទៅ» គេប្រាប់ហើយក៏នាំគ្នាដើរទៅ ស៊ូហ៊ី ក្រឡេករកមើលកូនមិនឃើញចុះមកតាម ធ្វើឲ្យនាងងឿងឆ្ងល់តែក៏មិនបានសួរគេនោះដែរ គិតថាប្រហែលជានៅក្នុងឡាន។

-នែ! នាងជួយយកទឹកក្រូចឲ្យខ្ញុំមួយកែវផង- ស្រីម្នាក់នោះប្រាប់ទាំងដឹកដៃគេទៅអង្គុយនៅសាឡុង ធ្វើដូចទីនេះជាផ្ទះរបស់ខ្លួន ស៊ូហ៊ី ដកដង្ហើមរម្ងាប់អារម្មណ៍ម្យ៉ាងមុននឹងដើរទៅរថយន្តរកមើលកូន។

នាងមកដល់រថយន្តឃើញកូនកំពុងគេង ទើបងាកទៅសម្លក់អ្នកនៅខាងក្នុងទាំងម៉ូម៉ៅ ព្រោះតែស្រីម្នាក់ធ្វើឲ្យគេទុកកូនចោលបែបនេះឲ្យនាងទុកចិត្តគេយ៉ាងម៉េចទៅ នាងគិតក្នុងចិត្តទាំងតំគួនមុននឹងលើកកូនមកពរថែមទាំងប្រាប់ឲ្យ ជេក ជួយពរ អេរិច ម្នាក់ទៀតតែក៏ត្រូវរាងក្រាស់ចូលមកពរជំនួសថែមទាំងសម្លឹងកូនចៅដោយក្រសែភ្នែកមុត ឃើញទឹកមុខរបស់នាងមុននេះ ធ្វើឲ្យគេមានអារម្មណ៍ខុសដែលទុកកូនចោលក្នុងឡានទើបដើរចេញមកវិញយ៉ាងលឿនបែបនេះ។

ស៊ូហ៊ី មិនមាត់ធ្វើមុខស្មើរពរកូនឡើងទៅលើដោយមិនមើលអ្នកណាទាំងអស់រហូតដល់បន្ទប់ដាក់កូនគេងលើគ្រែ។

-គេលេងច្រើនទើបគេងលក់ក្នុងឡាន- អែលវិន ប្រាប់តែពេលពរ អេរិច ទៅដាក់លើគ្រែមួយទៀត ស៊ូហ៊ី នៅស្ងៀមទាញភួយមកដណ្ដប់ឲ្យកូនយ៉ាងស្ងាត់ស្ងៀម ធ្វើឲ្យគេមានអារម្មណ៍មិនស្រួល។

-ខ្ញុំអាចមើលពួកគេបាន លោកអញ្ជើញចុះទៅទទួលភ្ញៀវរបស់លោកបន្តចុះ- ស៊ូហ៊ី ងាកមកប្រាប់គេបន្តិចហើយក៏ងាកមុខចេញ ធ្វើឲ្យគេមានអារម្មណ៍ម៉ូម៉ៅព្រោះគិតថានាងកំពុងតែសិកសៀតឲ្យគេ។

-ពួកគេជាកូនខ្ញុំហើយទីនេះក៏ជាផ្ទះខ្ញុំ ទោះចង់នៅទីណាក៏ជារឿងរបស់ខ្ញុំដូចគ្នា- គេប្រាប់សំឡេងស្មើរមុននឹងដើរចេញទៅទុកឲ្យរាងស្ដើងនេះអង្គុយបង្ហូរទឹកភ្នែកយ៉ាងស្ងៀមស្ងាត់ នាងចង់ចាកចេញពីទីនេះមិនចង់រស់នៅជាមួយមនុស្សគ្មានបេះដូងដូចគេម្នាក់នេះទេ តែដើម្បីកូននាងត្រូវតែទ្រាំ។ គិតហើយក៏ងាកទៅលើគ្រែ។

-សូមទោស ដែលម៉ាក់មិនអាចមើលថែពួកកូនឲ្យបានយូរជាងនេះ ម៉ាក់ជាម៉ាក់មិនល្អ សង្ឃឹមថាកូនរស់នៅមានក្ដីសុខពេលដែលម៉ាក់មិននៅ- នាងនិយាយតិចៗអង្អែលក្បាលកូនពេញដោយក្ដីស្រលាញ់។

-អែលវិន ស្រីម្នាក់មិញជាអ្នកណា មិនមែនអ្នកបម្រើថ្មីរបស់លោកទេមែនទេ?- ឡេណា កូនស្រីរបស់លោក ឌីអូ ជាដៃគូជំនួញរបស់គេសួរទាំងសម្លឹងមើលទៅលើបែបមិនពេញចិត្តតែព្យាយាមធ្វើមុខស្រពោន។

-នាងជាម្ដាយកូនខ្ញុំ- គេប្រាប់សំឡេងស្មើអង្គុយផ្អែកសាឡុងដោយឫកពារហាត់នឿយ។

-ជាម្ដាយកូនលោក តែមិនមែនជា...-

-ខ្ញុំថាគួរនិយាយរឿងការងាររបស់យើងល្អជាង- គេប្រាប់ទាំងទាញឯកសារនៅលើតុមកមើល ធ្វើឲ្យអ្នកម្ខាងទៀតមានអារម្មណ៍ម៉ូម៉ៅតែព្យាយាមធ្វើមុខញញឹមញញែម នាងលួចស្រលាញ់គេជាយូរមកហើយថែមទាំងព្យាយាមទាក់ទាញគេថែមទៀត តែគេមិនធ្លាប់យកភ្នែកមើលនោះទេ គិតថានាងត្រឹមកូនស្រីដៃគូជំនួញរបស់គេតែប៉ុណ្ណោះ ដោយសារឃើញគេមិនសូវចាប់អារម្មណ៍ទើប ប្រើឡេះនិយាយការងាររបស់ឪពុកដើម្បីបានស្និទ្ធស្នាលជាមួយគេបន្ថែមទៀត។

អែលវិន ឡើងទៅបន្ទប់របស់កូនបន្ទាប់ពីនិយាយការងារចប់ ឃើញ ស៊ូហ៊ី កំពុងគេងឱបកូនទឹកមុខនៅមានស្នាមទឹកភ្នែកនៅឡើយទេ គេមិនយល់ហេតុអីក៏នាងយំមិនឈប់បែបនេះ នៅជាមួយគេធ្វើឲ្យនាង

លំបាកខ្លាំងណាស់មែនទេ គេគិតទាំងម៉ូម៉ៅហើយក៏ដើរ[illegible] សម្រាកបស់ខ្លួនវិញ។

-ប៉ា ខ្ញុំមិនសុខចិត្តទេ?- ឡេណា ឲ្យឡាដាក់បុរសចំណាស់ដែលកំពុងអង្គុយលើសាឡុងបន្ទប់ទទួលភ្ញៀវ ធ្វើឲ្យគាត់ងាកមុខមកមើលកូនស្រីទាំងងឿងឆ្ងល់។

-មានរឿងអីមែនទេ?- លោក ឌីអុ ម្ចាស់សណ្ឋាគារនិងកាស៊ីណូ ងាកមកសួរកូនស្រីសំណព្វ គាត់រាងចំណាស់ទៅហើយតែរូបរាងនៅតែសង្ហារក្មេងកំលោះដូច្នេះបានជាមានស្រីគោងមិនឈប់ រួមទាំងគាត់ជាអ្នកមានស្រាប់រឿងស្រីក្មេងមានមិនខ្វះ។

-អែលវិន គេមានកូនហើយថែមទាំងស្រីម្នាក់នោះមកនៅក្នុងផ្ទះគេថែមទៀត- ឡេណា រៀបរាប់ទាំងម៉ូម៉ៅដើរទៅអង្គុយលើសាឡុងជិតឪពុក ធ្វើឲ្យបុរសចំណាស់រិះគិតបន្តិចមុននឹងសើចចេញមក។

-គេមានកូនតែមិនទាន់មានប្រពន្ធឯណា?-

-ប៉ាចង់មានន័យថា...- ឡេណា និយាយហើយក៏ឈប់ទ្រឹងមុននឹងញញឹមចេញមកបែបជ័យជំនះ តែក៏មុខស្រពោនវិញ។

-តែស្រីម្នាក់នោះមើលទៅក៏ស្អាតមិនអន់ដែរ បានជាគេទុកក្បែរខ្លួនបែបនេះនោះ-

-មនុស្សស្រីត្រូវការតែលុយតែប៉ុណ្ណោះ បានលុយហើយក៏ចេញទៅ កូនកុំគិតច្រើនពេក- សំឡេងបុរសចំណាស់បន្លឺមកទាំងញញឹមលាក់គំនូចធ្វើឲ្យនាងញញឹមពេញចិត្តព្រោះដឹងថាឪពុកចង់ធ្វើអី។

អែលវិន ត្រូវទៅមើលការងារនៅបរទេសច្រើនថ្ងៃ គេចង់នាំកូននិង





ស៊ូហ៊ី ទៅជាមួយដែរតែខ្លាចមានបញ្ហាទើបទៅតែម្នាក់ឯងរួមទាំងមនុស្សរបស់គេម្នាក់ទៀតគឺ ជីម ហើយទុកឲ្យ ជេក កូនចៅម្នាក់ទៀតនៅមើលការខុសត្រូវនៅភូមិគ្រឹះ។

សំឡេងរថយន្តមកឈប់ខាងមុខភូមិគ្រឹះធ្វើឲ្យ ស៊ូហ៊ី ដែលកំពុងអង្គុយមើលកូនរត់លេងក្នុងសួន ងាកទៅមើលទាំងងឿងឆ្ងល់ព្រោះជារថយន្តមិនធ្លាប់ស្គាល់ បុរសចំណាស់រួមទាំងនារីក្មេងចុះមកថែមទាំងមានអង្គរក្សហែហមមកទៀត តែនាងស្គាល់ច្បាស់ស្រីម្នាក់នោះជាមនុស្សស្រីដែលមកកាលពីថ្ងៃមុនតែបុរសចំណាស់ម្នាក់នោះ នាងមិនស្គាល់គិតហើយក៏ងាកមកមើលកូនវិញ ព្រោះមិនមែនជាតួនាទីរបស់នាងដែលត្រូវទៅរាក់ទាក់ពួកគេនោះទេ។

-សួស្តី- សំឡេងគ្រលាក់ទាក់នៅខាងក្រោយទើបធ្វើឲ្យនាងត្រូវងាកទៅមើលម្តងទៀតជាបុរសចំណាស់មុននេះឯង មើលទៅខ្សែភ្នែកគាត់ដែលសម្លឹងមកមិនធម្មតានោះទេ ឃើញហើយធ្វើឲ្យនាងចង់ដើរគេចប្រហែលមិនអាចទេទើបដាច់ចិត្តក្រោកឈររាក់ទាក់តប។

-ចាសសួស្តីលោក អែលវិន គាត់មិននៅនោះទេ- នាងរាក់ទាក់តបហើយក៏ប្រាប់បន្ថែមតែបែរជាធ្វើឲ្យពួកគេទាំងពីរ ងាកមើលមុខគ្នាញញឹមទៅវិញ។

-ខ្ញុំដឹងហើយតែពួកខ្ញុំមិនបានមករកគេនោះទេ គឺមករកនាង- ឡេណា ប្រាប់សំឡេងស្មើរញញឹមចុងមាត់ដើរមកជិតទាំងសម្លឹងនាងពីលើដល់ក្រោមបែបចំអក ស៊ូហ៊ី នៅស្ងៀមសម្លឹងពីនាក់ឪពុកកូនបែបរិះគិតមិនដឹងពួកគេមកមានបំណងអីព្រោះនាងមិនធ្លាប់ស្គាល់ពួកគេនោះទេ។

-សូមទោស ខ្ញុំគ្មានកិច្ចការអីជាមួយអ្នកនាងនោះទេ- ស៊ូហ៊ី តប សំឡេងស្មើរដើរទៅកន្លែងផ្សេងតែក៏ត្រូវអ្នកម្នាងទៀតចាប់ដៃជាប់។

-តែពួកខ្ញុំមាន- សំឡេងបុរសចំណាស់បន្លឺឡើងថែមទាំងដើរមកជិត ឡេណា សម្លឹងមើលឪពុករបស់នាងទាំងញញឹមព្រោះមើលទៅគាត់ប្រហែលជាពេញចិត្តស្រីម្នាក់នេះខ្លាំងណាស់ ជាឪពុកកូននឹងគ្នាហេតុអីក៏នាងមិនដឹងរឿងទាំងនេះ។

ស៊ូហ៊ី បង្ហាញទឹកមុខធុញទ្រាន់សម្លឹងមើលពួកគេទាំងពីរនាងមិនធ្លាប់ស្គាល់ពួកគេនោះទេហេតុអីក៏ត្រូវមានរឿងនិយាយគ្នានោះ។

-អញ្ជើញនិយាយការងាររបស់អ្នកទាំងពីរមក ខ្ញុំមានការត្រូវធ្វើ- នាងប្រាប់ហើយក៏បេះដៃអ្នកម្នាងទៀតចេញដើរមកអង្គុយបង់ក្នុងសួន។

-នាងគ្រាន់តែជាម្ដាយរបស់កូនគេ គិតថាគេនិងរៀបការជាមួយនាងឬយ៉ាងម៉េច- ឡេណា និយាយបង្អើរថែមទាំងពេបមាត់ចំអក ស៊ូហ៊ី នៅស្ងៀមព្យាយាមរម្ងាប់អារម្មណ៍ នាងដឹងខ្លួនឯងច្បាស់ថានៅទីនេះក្នុងឋានៈអី គិតហើយក៏ងាកទៅមើលអ្នកម្នាងទៀតដោយទឹកមុខស្មើ។

លោក ឌីអូ សម្លឹងនារីចំពោះមុខដោយក្ដីពេញចិត្តហើយក៏ស្រមៃទៅឆ្ងាយព្រោះតែនាងស្រស់ស្អាតបែបនេះទើប អែលវិន ទុកនាងក្បែរខ្លួន គាត់គិតហើយក៏អង្អែលបបូរមាត់ដោយក្ដីស្រេកឃ្លាន ស៊ូហ៊ី មើលបុរសចំណាស់ចំពោះមុខដោយមិនទុកចិត្ត ជាពិសេសខ្សែភ្នែករបស់គេដែលមើលមកនាងបើមានរឿងអីមែននោះ តើគិតយ៉ាងម៉េចព្រោះគ្មានអ្នកណានៅទីនេះនោះទេ ចង់ស្រែកហៅក៏មិនដឹងស្រែករកអ្នកណាថែមទៀត នាងគិតក្នុងចិត្តទាំងខ្វល់ខ្វាយតែព្យាយាមនៅស្ងៀម។





-អែលវិន ឲ្យនាងប៉ុន្មាន?- សំឡេងបុរសចំណាស់បន្លឺឡើងធ្វើឲ្យនាងងាកមុខទៅមើលទាំងងឿងឆ្ងល់។

-ខ្ញុំមិនយល់ពីសម្ដីរបស់លោកនោះទេ-

-គេឲ្យប្រាក់នាងប៉ុន្មាន ខ្ញុំនិងឲ្យលើសគេបីដងបើនាងព្រមទៅនៅជាមួយខ្ញុំ- បុរសចំណាស់ប្រាប់ទាំងញញឹមចុងមាត់ ស៊ូហ៊ី ញញឹមចំអកបន្ទាប់ពីឮ ព្រោះតែប្រាក់ទៀតហើយពួកអ្នកមានគិតថាប្រាក់អាចទិញគ្រប់យ៉ាងបានឬយ៉ាងម៉េច នាងគិតក្នុងចិត្ត។

-អរគុណសំណើររបស់លោក តែខ្ញុំមិនត្រូវការនោះទេ- ស៊ូហ៊ី តបសំឡេងស្មើរហើយក៏ក្រោកដើរចេញ តែក៏ត្រូវបុរសចំណាស់តាមចាប់ដៃជាប់ នាងក្រមុំរលាស់ចេញយ៉ាងលឿនសម្លឹងមុខដោយក្រសែភ្នែកមុត។

-នែនាង គាត់ជាប៉ារបស់ខ្ញុំណា- សំឡេង ឡេណា បន្លឺឡើងទាំងដើរទៅឈរជិតឪពុក ស៊ូហ៊ី ងាកទៅមើលមុខនាងទាំងហួសចិត្ត ពួកគេជាឪពុកកូនហើយមកធ្វើរឿងឆ្កួតស្អីហ្នឹងនាងគិតទាំងម៉ូម៉ៅ។

-នាងគិតថាអាម្សៀរ អែលវិន នោះអាចឲ្យនាងច្រើនជាងខ្ញុំឬយ៉ាងម៉េច ឬក៏ក្បាច់លើគ្រែគេអស្ចារ្យជាងខ្ញុំបានជានាងនៅជក់ចិត្តហ្នឹងគេបែបនេះ ខ្ញុំក៏ជំនាញមិនចាញ់គេនោះដែរមិនជឿនាងសាកមើលទៅ ឲ្យតែនាងព្រមមកនៅជាមួយខ្ញុំ ខ្ញុំនិងឲ្យនាងគ្រប់យ៉ាង- សំឡេងបុរសចំណាស់នៅតែបន្លឺឡើងទាំងញញឹមចំអក ស៊ូហ៊ី ក្ដាប់ដៃណែនដោយក៏ហឹងព្យាយាមរម្ងាប់អារម្មណ៍បើនៅជិតនាងមានដំបង នាងនិងយកសំពងក្បាលបុរសម្នាក់នេះហើយដែលហ៊ាននិយាយមើលងាយនាងបែបនេះ។

-ខ្ញុំមិនត្រូវការប្រាក់របស់លោក អញ្ជើញយកឡប់ទៅវិញទៅកាន់ខ្ញុំ

ទ្រាំលែងបានជាងនេះ» នាងប្រាប់ហើយក៏ដើរចេញ។

«ប៉ាខ្ញុំជាដៃគូរជំនួញរបស់គេ ពួកយើងកំពុងគិតពីរឿងរបៀបមុខជំនួញថ្មី ហើយក៏អាចនឹងមានដំណឹងល្អរវាងខ្ញុំនិងគេឆាប់ៗនេះដែរ» សំឡេងរបស់ ឡេណា បន្លឺឡើងតែនាងមិនខ្វល់ដើរសំដៅទៅក្នុងផ្ទះព្រងើយ ធ្វើឲ្យពីរនាក់ឪពុកកូនសម្លឹងមើលទាំងម៉ូម៉ៅដែលនាងមិនព្រមសហការ។

«ប៉ាធ្វើយ៉ាងម៉េចទៅ?» ឡេណា ងាកមកសួរឪពុក។

«ត្រឡប់ទៅវិញសិនទៅ» គាត់ប្រាប់ហើយក៏ដើរចេញតែឆៀតងាកទៅមើលរាងស្ដើងដែលដើរទៅក្នុងមុននេះទាំងសោកស្ដាយ។

ស៊ូហ៊ី មកសំងំអង្គុយយំក្នុងបន្ទប់ទាំងឈឺចិត្ត គេមើលងាយមិនគ្រប់នៅប្រើអ្នកដំទែមកបន្ថែមទៀត ចង់កម្ចាត់នាងចេញក៏មិនបាច់ប្រើផែនេះដែរ នាងមិនបាននៅតាមគោងគេព្រោះតែប្រាក់នោះទេ នាងគ្រាន់តែចង់មើលថែកូន បើគេគិតថានាងគួរឲ្យខាននាងនឹងចេញដើម្បីឲ្យគេស្ងប់ចិត្តទៅចុះ នាងគិតក្នុងចិត្តព្យាយាមជូតទឹកភ្នែកមុននឹងចុះទៅក្រោម។

ស៊ូហ៊ី ធ្លាប់រៀនគូគំនូរពី ហេជីន ទើបយកឧបករណ៍មកគូររូបរបស់កូនកំពុងរត់លេងក្នុងសួន គិតថាពេលដែលនឹកពួកគេនាងអាចមើលគំនូរទាំងនេះគិតរឿងនេះ ធ្វើឲ្យនាងសោកសៅតែប្រឹងញញឹមលើកទឹកចិត្តខ្លួនឯងមុននឹងគូរបន្ត រូបមួយផ្ទះទៀតជារូបរបស់ អែលវិន និងកូនតែគ្មានរូបនាងនោះទេ ព្រោះនាងគ្មានចំណែកក្នុងគ្រួសារនេះគិតហើយទឹកភ្នែកក៏ចាប់ផ្ដើមហូរជូតយ៉ាងណាក៏មិនស្ងួត។

«អ្នកនាងកំពុងធ្វើអី?» សំឡេងមេផ្ទះចំណាស់បន្លឺឡើងធ្វើឲ្យអ្នក





ដែលកំពុងយំប្រញាប់ជូតទឹកភ្នែកងាកមកមើល។

«កំពុងគូររូបអីចង់បានដែរទេ ចាំខ្ញុំគូរឲ្យទុកជាកាដូតែមិនដឹងថាស្អាតឬអត់ទេ» នាងតបទាំងញញឹមក្រៀម គាត់សម្លឹងគំនូររបស់នាងធ្វើឲ្យគាត់មានអារម្មណ៍អាណិត គាត់នៅជាមួយនាងមួយរយៈមកនេះយល់ថាមានអារម្មណ៍ពេញចិត្ត ព្រោះនាងមិនដូចមនុស្សស្រីមុនៗរបស់អ្នកប្រុសគាត់នោះទេ ហើយក៏ចង់ឲ្យនាងក្លាយជាចៅហ្វាយស្រីទីនេះដែរ តែមិនដឹងថាបំណងប្រាថ្នាគាត់បានសម្រេចឬអត់ទេ។

«ស្អាតណាស់អ្នកនាង» គាត់តបទាំងញញឹមហើយដើរ ស៊ូហ៊ី ដាក់ជក់ចុះលូកដៃស្រវាឱបគាត់យំកាន់តែខ្លាំង ទើបគាត់លើកដៃអង្អែលខ្នងនាងតិចៗក្នុងន័យលួងលោម។

ស៊ូហ៊ី រៀបចំអីវ៉ាន់រួចរាល់គិតថាដល់ពេលដែលនាងត្រូវចាកចេញហើយតែឆៀតដើរទៅមើលកូននៅបន្ទប់មុននឹងទៅ ចុះមកដល់ជាន់ក្រោមមានសភាពស្ងាត់ព្រោះពួកគេនាំគ្នាសម្រាកអស់ហើយ មកដល់ខាងមុខនាងសម្លឹងមើលជុំវិញភូមិគ្រឹះទាំងក្ដីអាល័យមុននឹងដើរចេញទៅ។

អែលវិន ត្រឡប់មកវិញមុនពេលកំណត់ព្រោះមានអារម្មណ៍នឹកអ្នកផ្ទះជាពិសេសរាងស្ដើង គេមិនធ្លាប់មានអារម្មណ៍បែបនេះនោះទេ តែពេលមកដល់បែរជាមិនឃើញនាងទៅវិញ ធ្វើឲ្យគេចាប់ផ្ដើមម៉ូម៉ៅ។

«នាំគ្នានៅផ្ទះយ៉ាងម៉េច បានជាមិនដឹងថាបាត់មនុស្ស» អែលវិន និយាយសំឡេងរឹងសម្លឹងមុខកូនចៅរួមទាំងអ្នកបម្រើក្នុងផ្ទះ។

«អ្នកនាងចាកចេញទៅពេលយប់ជាពេលពួកគេសម្រាកទើប...»

«ឆាប់ទៅតាមរកភ្លាមទៅ ថានាងទៅណា» ជីម ឱនទទួលហើយក៏

ដើរចេញទៅស្របពេលមនុស្សរបស់គេម្នាក់ទៀតដើរចូលមក។

«អ្នកនាងធ្វើដំណើរទៅកូរ៉េហើយចៅហ្វាយ» ដេក រាយការណ៍ធ្វើឲ្យគេក្ដាប់ដៃណែនដោយកំហឹង ដែលនាងហ៊ានទៅចោលគេជិតកូន។

«នៅមានរឿងមួយទៀតចៅហ្វាយ» ដេក រាយការណ៍បន្តធ្វើឲ្យគេផ្ដេញចិញ្ចើមងាកមកមើល។

«រឿងអី?»

«កាលពីថ្ងៃមុនលោក ឌីអូ និងអ្នកនាង ឡេណា មកទីនេះហើយមិនដឹងនិយាយស្អីខ្លះជាមួយអ្នកនាងនោះទេទើប...»

«ហេតុអីក៏ទើបតែប្រាប់ពេលនេះ» គេនិយាយសំឡេងរឹងស្មុះក្រោកពីសាឡុងវីង ដឹងថាគានោះជាកញ្ចាស់ល្មោភកាមហើយមកជួបជាមួយនាងបែបនេះទៀតធ្វើឲ្យគេមានអារម្មណ៍នៅមុនសុខនោះទេ គិតហើយក៏ឡើងទៅបន្ទប់គេមិនទាន់បានជួបមុខកូននោះទេ ព្រោះបារម្ភតែរឿងបាត់ភាងស្តើង។

ស៊ូហ៊ី កំពុងអង្គុយស្រូបខ្យល់អាកាសមាត់ឆ្នេរមួយអាទិត្យជាងហើយដែលនាងដល់ទីនេះវិញ មានអារម្មណ៍នឹកកូនបានត្រឹមអង្គុយបង្ហូរទឹកភ្នែក ចង់ទូរស័ព្ទទៅតែខ្លាចធ្វើឲ្យពួកគេកាន់តែនឹក ទើបសុខចិត្តមើលរូបគំនូររបស់ខ្លួន។

«បងស្រីហេតុអីមកអង្គុយទីនេះ ខ្យល់ត្រជាក់ខ្លាំងណាស់ឆាប់ចូលក្នុងវិញទៅ» សំឡេង ជូយ៉ុង បន្លឺឡើងទើបនាងងាកទៅមើល។

«បងមិនអីទេ ឯងទៅមើលហាងទៅ» នាងតបហើយក៏ប្រឹងក្រោកឈរទាំងធីងធោងធ្វើឲ្យគេត្រូវចូលទៅជួយគ្រា ប៉ុន្មានថ្ងៃមកនេះនាងមាន





អារម្មណ៍វិលមុខជានិច្ចទើបមិនបានទៅធ្វើការសម្រាកនៅផ្ទះ។

«ទឹកមុខបងស្លេកស្លាំងខ្លាំងណាស់ទៅពេទ្យទៅល្អទេចាំខ្ញុំជូនទៅ»

«បងមិនអីទេ ឯងកុំបារម្ភអី» នាងតបទាំងញញឹមក្រៀមនដឹងរោគារបស់ខ្លួនច្បាស់ណាស់ទើបមិនចង់ទៅពេទ្យ ជូយ៉ុង សម្លឹងមើលបងស្រីដោយក្ដីអាណិតតាំងពីត្រឡប់មកពីអង់គ្លេសវិញតែងតែបែបនេះ គេឆ្ងល់ក្នុងចិត្តតែក៏មិនហ៊ានសួរ។

«បងបែបនេះទៀតហើយ» គេតបទាំងសំឡេងស្រាលគ្រានាងចូលទៅក្នុងផ្ទះ ដោយមិនដឹងថាមានអ្នកណាកំពុងតែសម្លឹងមកដោយក្រសែភ្នែកខឹងក្រោធនោះទេ។

«នាងរត់ចោលខ្ញុំនិងកូន ព្រោះតែមកនៅជាមួយអាប្រុសក្មេងនេះមែនទេ?» អែលវិន និយាយសំឡេងតាមជើងធ្មេញទាញកន្ត្រាក់រាងស្តើងមកអឹបទ្រូង ហើយងាកទៅសម្លឹង ជូយ៉ុង ដោយក្រសែភ្នែកហាមពេលគេចង់រត់មកជួយរាងស្តើង។

«មិនទាក់ទងនិងលោកទេ» នាងប្រាប់សំឡេងស្រាលព្រោះគ្មានកំលាំងថែមទាំងប្រឹងរើឲ្យផុតពីដៃគេថែមទៀត។

«មិនទាក់ទងអ៊ីចឹងមែនទេ» គេសួរបញ្ជាក់ រត់ចោលកូនមកនៅជាមួយប្រុសហើយនៅថាមិនទាក់ទងនឹងគេទៀតមែនទេ គិតក្នុងចិត្តទាំងគំគួនងាកទៅមើលអ្នកម្ខាងទៀតដោយក្រសែភ្នែកមុត មុននឹងលែងដៃពីនាងស្ទុះទៅដាល់មុខរបស់ ជូយ៉ុង មួយកំលាំងដៃធ្វើឲ្យនាងបើកភ្នែកធំៗសម្លឹងមើលដោយភាពភ្ញាក់ផ្អើល។

«លោកធ្វើឆ្កួតស្អីហ្នឹង» នាងស្រែកឲ្យគេមុននឹងរត់ទៅមើល ជូយ៉ុង

ដែលកំពុង[illegible]ហូរឈាម
ពេលឃើញនាងយកចិត្តទុកដាក់ប្រុសម្នាក់ ធ្វើឲ្យគេកាន់តែក្ដៅ[illegible]

-ស្រលាញ់វាខ្លាំងណាស់មែនទេ ហើយតាំងពីពេលណាមក[illegible] វាមែននេះ ចាំមើលខ្ញុំនឹងសម្លាប់វាចោល- និយាយហើយក៏ដើរសំដៅទៅ[illegible] ទាញនាងចេញ ចាប់ប្រមូលកម្លាំងរបស់ ដូយ៉ុង ហើយឡើងមកលើដៃ រៀបនឹងវាយមុខគេបន្ថែមក៏ត្រូវនាងស្ទុះទៅចាប់ដៃជាប់។

-ឆាប់លែងគេឲ្យទៅ ខ្ញុំមិនបានរត់ចោលកូនក្រមុំតែរស់តូចនាថ របស់ខ្ញុំដែលត្រូវមើលថែគេតែប៉ុណ្ណោះ- នាងតបទាំងទឹកភ្នែកថែមទាំង ព្យាយាមបេះដៃគេចេញ តែគេមិនខ្វល់យកចិត្តទុកដាក់ពាក្យសម្ដីរបស់ នាងព្រោះពេលនេះកំហឹងរបស់គេកំពុងតែកើនឡើងព្រោះតែនាង។

-ខ្ញុំមិនលែងខ្ញុំនឹងសម្លាប់វា- គេប្រាប់សំឡេងតាមដើងធ្មេញយាដៃ បំរុងដាល់អ្នកម្ខាងទៀតតែក៏ត្រូវនាងចាប់ជាប់ អំណាចនៃកំហឹងធ្វើ ឲ្យគេវាសដៃរបស់ខ្លួន គិតថាឲ្យនាងចេញឆ្ងាយពីគេតែបែរជាធ្វើឲ្យរាងស្ដើ ងដែលគ្មានកំលាំងត្រូវបោកទៅបុកជញ្ជាំងមួយទំហឹង មុននឹងទ្រោមដួល នៅជិតនោះក្រោមក្រសែភ្នែកផ្អើលរបស់អ្នកនៅទីនេះ។

-បងស្រី- ដូយ៉ុង ស្រែកហៅយ៉ាងតក់ស្លុតមុននឹងគាសដៃរុញអ្នក ម្ខាងទៀតចេញរត់ទៅលើកគ្រានាងយ៉ាងលឿន សព្ទនាមដែលគេហៅមុន នេះធ្វើឲ្យអ្នកដែលកំពុងមានកំហឹងដោជនភ្ញាក់ខ្លួនដូចគេដាស់ គេដឹងថា នាងមានប្អូនប្រុសតែមិនធ្លាប់ឃើញមុខនោះទេទើបគេមិនស្គាល់។

-បងស្រី បងស្រីយ៉ាងម៉េចហើយ?- ដូយ៉ុង ស្រែកតិចៗលាយយំ ទាំងអង្រួននាងឲ្យដឹងខ្លួន ធ្វើឲ្យអ្នកដែលកំពុងស្លុងអារម្មណ៍ត្រូវងាកទៅ





មើលយ៉ាងលឿនកាន់តែធ្វើឲ្យគេភ្ញាក់ផ្អើលថែមទៀតនោះ គឺឈាមហូរជា ច្រើនហូរមកតាមជើងរបស់នាងធ្វើឲ្យគេកាន់តែតក់ស្លុតលើសដើម។

-ដូយ៉ុង នាំ នាំបងទៅពេទ្យ លឿន....- នាងនិយាយសំឡេងស្អក លើកដៃខ្ទប់ពោះបង្ហាញទឹកមុខឈឺចាប់។

-ស៊ូហ៊ី- អ៊ែលវិន ស្រែកហៅសំឡេងញ័រទាំងរត់ទៅក្បែរទាញនាង មកក្រាទាំងព្រួយបារម្ភថែមទាំងរុញអ្នកម្ខាងទៀតចេញ។

-កុំ កុំកើតអីឲ្យសោះណា- និយាយបណ្ដើរលើកនាងមកឱបជាប់ ខ្លួងបណ្ដើរទឹកភ្នែកកូនប្រុសស្ទើរស្រក់ គេគ្មានបំណងរុញនាងនោះទេ។

-ជេក ឆាប់ ឆាប់យកឡានមក- គេស្រែកប្រាប់កូនចៅមុននឹង លើកនាងបីដើរចេញទៅ។

ពីរម៉ោងក្រោយមក...

អ៊ែលវិន កំពុងអង្គុយមុខបន្ទប់សង្គ្រោះទឹកមុខសោកសៅសម្លឹង ទៅទ្វារបន្ទប់ញឹកញាប់ ព្រោះតែគេទើបធ្វើឲ្យមានរឿងបែបនេះ គេគិត បន្ទោសខ្លួនឯងក្នុងចិត្តមុននឹងឮសំឡេងអ្នកក្បែរខ្លួនបន្លឺឡើង។

-គ្រួសារខ្ញុំមានតែបីនាក់ម៉ាក់និងគាត់ បងស្រីលំបាកតាំងពីតូចអ៊ីក៏ គាត់ធ្វើដែរឲ្យតែបានលុយមកផ្គត់ផ្គង់គ្រួសារ គាត់មិនធ្លាប់ត្អូញត្អែឲ្យតែ អ្នកផ្ទះបានហូបឆ្អាញ់ខ្លួនឯងសុខចិត្តអត់ មកដល់ធំរៀនបណ្ដើរធ្វៀកធ្វើ ការបណ្ដើរដើម្បីបានលុយបង់ថ្លៃសាលាឲ្យខ្ញុំ រហូតដល់ម៉ាក់ឈឺក៏សុខ ចិត្តលះបង់កិត្តិយសជាមនុស្សស្រីយកប្រាក់មកព្យាបាលម៉ាក់ តែចុង ក្រោយម៉ាក់ក៏នៅចាកចេញទៅ គាត់រស់នៅកំសត់ពេកហើយរហូតដល់ មានកូនត្រូវអ្នកស្រុកអ្នកភូមិរិះគន់ជាស្រីមានកូនអត់ប្ដី តែគាត់មិនខ្វល់

សុខចិត្តចិញ្ចឹមកូនទាំងលំបាកចុងក្រោយក៏ត្រូវលះបង់កូនឲ្យគេ ព្រោះខ្លាចពួកគេត្រូវលំបាកវេទនាដោយសារខ្លួន គេងយំព្រោះតែនឹកកូនក៏មិនហ៊ានទូរស័ព្ទទៅព្រោះខ្លាចធ្វើឲ្យពួកគេនឹកកាន់តែខ្លាំង បានត្រឹមអង្គុយបង្ហូរទឹកភ្នែក ខ្ញុំមិនយល់ហេតុអីក៏គាត់ត្រូវជួបរឿងទាំងនេះ គាត់វេទនាគ្រប់គ្រាន់ហើយសូមឈប់ធ្វើបាបគាត់ទៀតទៅ បើលោកមិនស្រលាញ់គាត់ដោះលែងគាត់ឲ្យមានសេរីភាពទៅ ត្បិតតែគ្រួសារពួកខ្ញុំក្រតែមិនធ្លាប់ចង់បានប្រាក់របស់អ្នកណានោះទេ ដូច្នេះសូមឈប់មើលងាយគាត់ទៀតទៅ៉ ដូយ៉ុង និយាយបណ្ដើរជូតទឹកភ្នែកបណ្ដើរមុននឹងដើរចេញទៅ។

អែលវិន អង្គុយស្ងៀមទ្រឹងបន្ទាប់ពីស្ដាប់រឿងទាំងអស់នេះទឹកភ្នែកកូនប្រុសស្រក់ចុះជាច្រើនដំណក់ គេមិនគិតថានារីរាងតូចម្នាក់នេះឆ្លងកាត់ជីវិតជូចត់បែបនេះនោះទេ គេធ្លាប់គិតថានាងជាមនុស្សស្រីលក់ខ្លួនព្រោះតែប្រាក់តែនាងធ្វើក៏ព្រោះ... គិតត្រឹមហ្នឹងធ្វើឲ្យគេមានអារម្មណ៍ខុសកាន់តែខ្លាំងយកដៃច្បូតមុខដោយភាពស្ដាយក្រោយ។

«សូមទោស ស៊ូហ៊ី» គេនិយាយតិចៗស្របពេលទ្វារបន្ទប់ត្រូវបើកដោយក្រុមគ្រូពេទ្យទើបគេដើរទៅជិតយ៉ាលឿន។

«លោកគ្រូពេទ្យ នាងយ៉ាងម៉េចហើយ» គេសួរសំឡេងព្រួយបារម្ភស្របពេល ដូយ៉ុង ទើបដើរមកដល់ដូចគ្នា គ្រូពេទ្យធ្វើទឹកមុខតានតឹងបន្តិចមុននឹងតប។

«ខួរក្បាលផ្នែកគ្រប់គ្រងការមើលឃើញរបស់នាង ប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរពេលនេះអាចនៅមិនទាន់ច្បាស់លាស់ តែវាអាចបណ្ដាលឲ្យមើលមិនឃើញទៅជាងងឹតពិការភ្នែកទាំងសងខាង ពួកយើងត្រូវរង់ចាំលទ្ធផលបញ្ជាក់ពីការពិនិត្យ ឬអាចចាំរហូតដល់អ្នកជំងឺដឹងខ្លួនដើម្បីតាមដានអាការៈបន្ត» ម្នាក់ៗនាំគ្នាឈរស្ងៀមបន្ទាប់ពីឮមិនគិតថាប៉ះពាល់ធ្ងន់ធ្ងរដល់ថ្នាក់នេះនោះទេ អែលវិន គិតក្នុងចិត្តមុននឹងឮគ្រូពេទ្យបន្ថែមមកទៀតទើបងាកទៅមើល។

«នៅមានរឿងមួយទៀត សំណាងហើយដែលនាំនាងមកទាន់អាចសង្គ្រោះកូនក្នុងផ្ទៃបានតែត្រូវចាំមើលលទ្ធផលជាក់ស្ដែងសិន» គ្រូពេទ្យប្រាប់ហើយក៏ដើរចេញទៅធ្វើឲ្យ អែលវិន មានទឹកមុខភ្ញាក់ផ្អើលបន្ទាប់ពីឮទើបងាកទៅមើលអ្នកឈរក្បែរ ដូយ៉ុង ធ្វើទឹកមុខធម្មតាព្រោះគេសង្ស័យរឿងនេះយូរហើយពេលឃើញអាការៈរបស់បងស្រីគេ។

«លោកប្រហែលជាសប្បាយចិត្តហើយ ដែលគាត់ក្លាយជាបែបនេះ ហើយមិនបាច់ឲ្យខ្ញុំប្រាប់ទេ ថាកូនក្នុងផ្ទៃគាត់ជាកូនរបស់អ្នកណានោះ លោកប្រហែលជាដឹងច្បាស់ហើយ» ដូយ៉ុង និយាយសំឡេងស្មើហើយក៏ដើរចេញទៅទុកឲ្យគេនៅឈរទ្រឹងតែម្នាក់ឯង។

រាងស្ដើងដែលគេងនៅលើគ្រែអ្នកជំងឺ ទឹកមុខស្លេកស្លាំង មានបង់រុំពេញក្បាលដៃបណ្ដាងសេរ៉ូម ធ្វើឲ្យអ្នកឈរមើលមានអារម្មណ៍ខ្លោចចិត្ត អែលវិន សម្លឹងមើលពោះរាបស្មើរបស់នាងមុននឹងដើរទៅជិត គេរៀះនឹងសម្លាប់កូនរបស់ខ្លួនឯងទៅហើយ គេគិតក្នុងចិត្តលូកដៃទៅប៉ះពោះរបស់នាងតែមិនទាន់ដល់ ស្របពេលឮសំឡេងបើកទ្វារបន្ទប់បន្លឺឡើងទើបដកដៃចេញមកវិញងាកទៅមើលអ្នកម្ខាងទៀតជា ដូយ៉ុង ដើរចូលមកថែមទាំងមានផ្កាមួយបាច់មកទៀត។

«បងស្រីចូលចិត្តផ្កាលីលី ទើបខ្ញុំទិញមកលោកប្រហែលជាមិនដឹង

នោះទេ ព្រោះលោកមិនធ្លាប់ចាប់អារម្មណ៍ពីចំណូលចិត្តរបស់គាត់.. ជុំយ៉ុង និយាយហើយក៏យកទៅដាក់ថូនៅលើតុ អែលវិន ងាកសម្លឹងមើលប្អូនជំនិត គេមិនធ្លាប់ដឹងអ្វីទាក់ទងនិងនាងពិតមែន គ្រាន់តែចាំបានរបស់ជួរនេះ ក្រអូបក្លិនផ្កាមួយនេះ គិតហើយក៏ងាកទៅអ្នកម្ខាងទៀត។

-ឯងទៅមើលហាងទៅ ទុកខ្ញុំនៅមើលនាង-

-ខ្ញុំជាប្អូនគាត់ ខ្ញុំអាចនៅមើលគាត់បាន លោកមិនបាច់បារម្ភទេ- ជុំយ៉ុង តបសំឡេងស្មើរហើយក៏ទាញកៅអីមកអង្គុយជិតគ្រែ ធ្វើឲ្យអ្នកម្ខាងទៀតចាប់ផ្ដើមម៉ូម៉ៅតែព្យាយាមនៅស្ងៀមម្ងាប់អារម្មណ៍ខឹង ព្រោះគេមិនដឹងថានៅទីនេះក្នុងតួនាទីអីដូចគ្នា។

-បងស្រីខ្លាចងងឹតណាស់ ខ្ញុំខ្លាចគាត់ភ្ញាក់ហើយ...- ជុំយ៉ុង និយាយហើយក៏ឱនមុខចុះយ៉ាងស្ងៀមស្ងាត់ ធ្វើឲ្យគេចាប់ផ្ដើមយល់ ងាកទៅមើលរាងស្ដើងនៅលើគ្រែ អារម្មណ៍អាណិតមានណែនពេញទ្រូង គិតពីទង្វើរបស់ខ្លួនកាន់តែស្អប់ខ្លួនឯងកាន់តែខ្លាំង។

ជុំយ៉ុង ត្រូវត្រឡប់ទៅមើលហាងព្រោះ អ៊ីនប៊ី ទូរស័ព្ទមកថាមានភ្ញៀវកុម្មង់ច្រើនទើបគេត្រូវទៅមើល តែនៅចិត្តមិនដាច់ពីអ្នកជំងឺរហូត អែលវិន អះអាងបញ្ជាក់ទើបគេយល់ព្រមទៅ។







...១៤...

ពីរថ្ងៃមកហើយ ដែលនាងមិនទាន់ដឹងខ្លួនធ្វើឲ្យគេកាន់តែបារម្ភ ទើបទៅជួបគ្រូពេទ្យតែគេប្រាប់ថាមិនអីទើបត្រឡប់មកវិញ គេអង្គុយមើលនាងតាំងពីព្រឹករហូតដល់ល្ងាច ជួយជូតខ្លួនប្តូរខោអាវឲ្យនាងថែមទាំងប្តូរផ្កាមួយថ្ងៃម្តងថែមទៀត គេមិនដឹងថាហេតុអីក៏គេអាចធ្វើបានបែបនេះនោះទេ ទាំងដែលគេមិនធ្លាប់ធ្វើវាជាមួយអ្នកណាម្នាក់ពីមុនមកសោះ។

-ទឹក ឃ្លានទឹក- សំឡេងស្អកឮតិចៗធ្វើឲ្យអ្នកដែលកំពុងអង្គុយធ្វើការជិតនោះក្រវៅកមកមើលដោយស្វ័យប្រវត្តិ ហើយក៏ដើរមកជិតដោយក្តីបារម្ភ ព្រោះខ្លាចនាងមានរឿងអីតែបន្ទាប់ពីឮនាងប្រាប់ទើបប្រញាប់រត់ទៅចាក់ទឹកលើកយ៉ាងលឿន គ្រានាងឲ្យក្រោកមុននឹងបញ្ចុកហើយក៏ដាក់នាងឲ្យគេងវិញ។

-ដូយ៉ុង ពេលនេះយប់ហើយមែនទេ ហេតុអីមិនបើកភ្លើង- នាងនិយាយសំឡេងស្រាលលើកដៃរាវរកអ្នកម្ខាងទៀត អែលវិន ក្តុកក្តួលក្នុងចិត្តបន្ទាប់ពីឮនាងសួរបែបនេះ ពេលនេះជាពេលរសៀលនោះទេភ្លើងក្នុងបន្ទប់ក៏បើកដែរតែនាងបែរជាថា... គេលើកដៃខ្ទប់មាត់សម្លឹងមើលនាងដោយក្តីអាណិត ស្របពេលអ្នកណាម្នាក់ដើរចូលមកទើបងាកទៅមើលហើយក៏យកដៃដាក់លើបបូរមាត់ឲ្យស្ងាត់ពេលឃើញ ដូយ៉ុង ដើរចូលមកគេងឿងឆ្ងល់បន្តិចតែក៏នៅស្ងៀមរហូតឮសំឡេងរបស់ ស៊ូហ៊ី បន្លឺឡើង។

-ដូយ៉ុង ឮបងសួរទេហេតុអីមិនបើកភ្លើង បងខ្លាចងងឹតណាស់ឆាប់បើកភ្លើងទៅ- នាងនិយាយបណ្តើរដៃរាវរកបណ្តើរទើបគេដើរមកក្បែរចាប់ដៃនាងជាប់ទាំងក្តុកក្តួល។

-ភ្លើងដាច់ហើយ បងកុំខ្លាចអីខ្ញុំនៅទីនេះហើយ- គេនិយាយហើយក៏យកដៃម្ខាងខ្ទប់មាត់បិទសំឡេងយំរបស់ខ្លួន ស៊ូហ៊ី នៅស្ងៀមនឹកឃើញអ្វីមួយទើបងាកទៅអ្នកក្បែរខ្លួនតែភ្នែកត្រង់សម្លឹងទៅមិនចំគោលដៅ ទើបគេលើកដៃគ្រវីខាងមុខ ក៏ភ្នែកនាងមិនព្រិចធ្វើឲ្យគេកាន់តែច្បាស់ថានាងមើលមិនឃើញពិតមែន។

-ដូយ៉ុង ចុះ...កូន- នាងសួរតិចៗលើកដៃស្ទាបពោះរបស់ខ្លួនធ្វើឲ្យគេយល់ទើបព្យាយាមសម្រួលអារម្មណ៍មុននឹងតប។

-គេមិនអីទេ គេមានសុវត្ថិភាពល្អទេ-

-បងសូមទោស ដែលមានរឿងបែបនេះកើតឡើងម្តងទៀត- នាងនិយាយហើយក៏ឱនមុខចុះបង្ហូរទឹកភ្នែក។

-បងមិនបាច់សុំទោសខ្ញុំនោះទេ ខ្ញុំដឹងថាមិនមែនជាកំហុសបង-

-ចុះគេ...ទៅណាហើយ- សំឡេងនាងនៅតែបន្លឺមកថែមទាំងងាកមើលជុំវិញបន្ទប់ដែលមានតែភាពងងឹតសម្រាប់នាង។

-គេត្រឡប់ទៅវិញហើយ- ដូយ៉ុង តបហើយក៏ងាកទៅមើលអ្នកម្ខាងទៀតដែលឈរសម្លឹងមក។

-កុំ កុំប្រាប់គេថាបងមានកូនណា បងចង់មើលថែគេ- នាងប្រាប់ទាំងទឹកភ្នែកលើកដៃស្ទាបពោះរបស់ខ្លួនទាំងញញឹម។

អែលវិន មានអារម្មណ៍អួលណែនក្នុងទ្រូងពេលឮហើយឃើញរូបភាពទាំងនេះទ្រាំមិនបានទើបដើរចេញមកក្រៅ គេអង្គុយនៅមុខបន្ទប់យកដៃបោចសក់របស់ខ្លួន ព្រោះតែគេទើបនាងក្លាយជាបែបនេះ ព្រោះតែគេម្នាក់គត់មិនដឹងយូរប៉ុណ្ណានោះទេទើបឃើញ ដូយ៉ុង ដើរចេញមក។

«គាត់គេងលក់ហើយ» គេប្រាប់សំឡេងស្រាលដើរមកអង្គុយកៅអីក្បែរអ្នកម្នាងទៀត។

«គ្រូពេទ្យប្រាប់ថាអការៈរបស់នាងត្រូវធ្វើការវះកាត់ជាបន្ទាន់ ខ្ញុំនិងនាំនាងទៅអង់គ្លេស» អែលវិន ប្រាប់សំឡេងស្រាលទើបគេងាកមកមើល

«បើលោកចង់នាំគាត់ទៅដើម្បីធ្វើបាបទៀតនោះ មិនចាំបាច់ទេខ្ញុំអាចមើលថែគាត់បាន» ដូយ៉ុង តបសំឡេងស្ទើរហើយក៏ក្រោកចេញពីកៅអីមុននឹងឮសំឡេងរបស់គេបន្លឺមកទៀត។

«ខ្ញុំមិនបាននាំនាងទៅធ្វើបាប ខ្ញុំចង់នាំនាងទៅព្យាបាលនៅទីនោះខ្ញុំគ្រាន់តែប្រាប់មិនបានសុំអនុញ្ញាតិពីឯងនោះទេ»

«តើខ្ញុំអាចជឿលោកយ៉ាងម៉េចទៅ?»

«ឯងគិតថាខ្ញុំជាមនុស្សឬមិនមែន ដែលធ្វើបាបប្រពន្ធកូនខ្លួនឯងនោះ?» ដូយ៉ុង ញញឹមចំអកមុននឹងតប។

«ប្រពន្ធ? លោកធ្លាប់ទុកគាត់ជាប្រពន្ធដែរមែនទេ?» អែលវិន នៅស្ងៀមគេមិនដឹងថានិយាយពាក្យនេះចេញទៅយ៉ាងម៉េចនោះទេ តែអ្វីដែលប្រាកដនោះគឺគេចង់មើលថែនាងមិនថាមានរឿងអីកើតឡើង។

«ពីមុនមិនមែន តែពីពេលនេះទៅនាងជាប្រពន្ធរបស់ខ្ញុំ» អែលវិន តបសំឡេងម៉ឺងម៉ាត់ធ្វើឲ្យគេមានអារម្មណ៍ជឿជាក់បន្តិច។

រាងស្តើងនៅលើគ្រែអ្នកជំងឺចាប់ផ្តើមដឹងខ្លួន បើកភ្នែកម្តងណាក៏ជួបតែភាពងងឹតទោះបីជាខ្លាចតែនាងនៅតែសន្សឹមៗចុះពីគ្រែ ដើរតិចៗដៃរាវរកបង្អួចហើយក៏ប៉ះទើបសសៀរៗបើក ព្រោះចង់ដឹងកាពិតមានតែខ្យល់ដែលបក់មកប៉ះផ្ទៃមុខ សភាពក៏ងងឹតស្លុបដូចគ្នាមិនឃើញសូម្បីតែ





ពន្លឺអ្វីមួយធ្វើឲ្យនាងកាន់តែ ច្បាស់ថាជាបញ្ហាភ្នែករបស់នាង គិតហើយក៏លើកដៃមកប៉ះភ្នែករបស់ខ្លួន។

«ភ្នែកខ្ញុំ ភ្នែកខ្ញុំមើលមិនឃើញទេ ហ៊ីហ៊ី!» នាងនិយាយបណ្តើរយំបណ្តើរដាក់ខ្លួនអង្គុយចុះជិតជញ្ជាំង ស្របពេលទ្វារបន្ទប់ត្រូវបើកដោយរាងសក្រាស់របស់ អែលវិន។

«ស៊ូហ៊ី» គេស្រែកហៅដោយក្តីបារម្ភមុននឹងដើរទៅជិត។

«កុំចូលមកជិតខ្ញុំ ឆាប់ចេញទៅ ឆាប់ចេញទៅ ហ៊ីហ៊ី» នាងស្រែកប្រាប់អ្នកម្នាងទៀតយ៉ាងខ្លាំងឱបខ្លួនឯងយំយ៉ាងឈឺចិត្ត ដែលពួកគេនាំគ្នាកុហកនាង អែលវិន សម្លឹងមើលនាងទាំងខ្លោចចិត្ត។

«បងខ្លាចណាស់ ដូយ៉ុង នាំបងចេញពីទីនេះទៅ ហ៊ីហ៊ី» នាងប្រាប់ទាំងអណ្តឺតអណ្តកប្រឹងខ្លួនឲ្យក្រោកឈរ ទើបគេដើរទៅគ្រាទាញនាងមកឱបលួងលោម។

«សុំទោស មកពីខ្ញុំ គឺមកពីខ្ញុំ» គេប្រាប់ទាំងឈឺចិត្តរឹងរឹងដៃឱបនាងកាន់តែណែន រាងកាយកក់ក្តៅធ្វើឲ្យនាងសំងំស្ងៀមរហូតគេងលក់ទើបគេលើកបីទៅដាក់លើគ្រែ ទាញភួយមកដណ្តប់ដោយភាពទន់ភ្លន់។

«បងសុំទោសចំពោះរឿងកន្លងមក ចាប់ពីពេលនេះទៅបងនឹងប៉ះប៉ូវជូនអូនវិញទាំងអស់» គេនិយាយតិចៗជិតត្រចៀកឱនទៅថើបថ្ងាស់នាងថ្នមៗមុននឹងដើរចេញពីបន្ទប់។

«ជេក ត្រៀមយន្តហោះខ្ញុំនឹងនាំ ស៊ូហ៊ី ទៅអង់គ្លេស»

«បាទចៅហ្វាយ» ជេក តបហើយក៏ដើរចេញទៅទើបគេដើរចូលបន្ទប់អ្នកជំងឺវិញ។

ស៊ូហ៊ី ភ្ញាក់ដឹងខ្លួននាពេលព្រឹកធ្លាប់តែបើកភ្នែកឡើងដោយភាពស្រស់ស្រាយសម្លឹងមើលជុំវិញបន្ទប់ ដោយភាពរីករាយតែពេលនេះបែរជាជួបតែភាពងងឹតស្លុងទើបបិទភ្នែកទៅវិញ បង្ហូរទឹកភ្នែកយ៉ាងស្ងៀមស្ងាត់ហើយក៏ក្រោកសន្សឹមៗចុះពីគ្រែគិតថាទៅបន្ទប់ទឹក មានអារម្មណ៍ទីនេះដូចជាមានក្លិនប្លែកៗដូចជាធ្លាប់ស្គាល់ មិនមែនបន្ទប់មន្ទីរពេទ្យនោះទេ គិតបណ្តើរដើរបណ្តើរសសៀតិចៗដៃក៏រាវរក តែមិនប៉ះអ្វីទាល់តែសោះធ្វើឲ្យនាងចាប់ផ្តើមឆ្ងល់ ស្របពេលឮសំឡេងបើកទ្វារបន្ទប់បន្តិចឡើង ទើបងាកទៅរកប្រភពសំឡេង។

«ដូយ៉ុង មែនទេ?» នាងសួរតិចៗទាំងដើរសំដៅទៅលូកដៃទៅរកអ្នកម្ខាងទៀត អែលវិន មិនតបគេដើរតិចៗមករកនាងដូចខ្លាចគ្រានាងខ្លាចមានរឿងអីកើតឡើង។

«ដូយ៉ុង ពេលនេះម៉ោងប៉ុន្មានហើយ ទីនេះជាកន្លែងណា» នាងសួរបណ្តើរចេះតែដើរទៅមុខបណ្តើរ រហូតជំពប់ជើងរកដួលទើបគេស្រវ៉ាឱបនាងជាប់ ស៊ូហ៊ី នៅស្ងៀមក្នុងរង្វង់ដៃអ្នកម្ខាងទៀតនាងចាំក្លិនទឹកអប់នេះច្បាស់ណាស់ថាជាអ្នកណា គិតហើយក៏ប្រឹងរើបម្រះតិចៗ។

«ចង់ទៅបន្ទប់ទឹកមែនទេ ចាំបងនាំទៅ» អែលវិន ប្រាប់ហើយក៏លើករាងស្តើងបីទើបនាងត្រូវស្រវ៉ាតោងករគេជាប់ព្រោះខ្លាចធ្លាក់។

«ទីនេះជា...» នាងសួរគេតិចៗទាំងស្រពិចស្រពិល។

«ជាផ្ទះបង» គេតបហើយក៏ដាក់នាងឲ្យឈរ ស៊ូហ៊ី ងាកខ្លួនបម្រុងគេចដោយភាពភ័យព្រួយតែក៏ត្រូវគេចាប់ជាប់។

«ចង់ទៅណា ចាត់ការធុរៈរបស់អូនឲ្យរួចរាល់ហើយហៅបង បង





នៅចាំមុខបន្ទប់» គេប្រាប់ហើយក៏បែខ្លួនដើរចេញទៅ។

«កូន ខ្ញុំមិនចង់ឲ្យពួកគេឃើញខ្ញុំក្នុងសភាពបែបនេះទេ» នាងនិយាយផងយំផងដាក់ខ្លួនអង្គុយចុះលើឥដ្ឋទាំងល្វើយ ធ្វើឲ្យគេមានអារម្មណ៍អាណិតទើបដើរមកវិញ។

«កុំបារម្ភអី ពួកគេមិននៅទីនេះទេ» គេប្រាប់ហើយក៏លើកគ្រានាងឲ្យក្រោកឈរ ធ្វើឲ្យនាងចាប់ដៃគេជាប់ទាំងងឿងឆ្ងល់រៀបនឹងហាមាត់សួរតែក៏ត្រូវគេនិយាយកាត់។

«ចាំបងប្រាប់ ចាត់ការធុរៈរបស់អូនសិនទៅ» គេប្រាប់ហើយក៏ដើរចេញទើបនាងភ្លូងធ្វើតាម។

អែលវិន បីនាងមកដាក់លើគ្រែថែមទាំងទាញភួយមកគ្របឲ្យដោយភាពទន់ភ្លន់ ធ្វើឲ្យនាងចាប់ផ្តើមឆ្ងល់ពីទង្វើនិងភាពផ្លាស់ប្តូររបស់គេឬមកពីនាងមានកូនទើបគេធ្វើបែបនេះ គេចង់ដណ្តើមកូនពីនាងទៀតហើយមែនទេ នាងគិតទាំងតូចចិត្ត។

«ហេតុអីក៏យំ មានរឿងអីមែនទេ? អូនឈឺត្រង់ណាមែនទេ» គេសួរទាំងព្រួយបារម្ភទាញភួយចេញពីខ្លួននាង ដើម្បីបានមើលរាងកាយខ្លាចមានបញ្ហាត្រង់ណាតែគ្មានអីនោះទេ។

«ខ្ញុំមិនអីទេ» នាងតបហើយក៏ប្រះខ្លួនគេងបែខ្នងរាវរកទាញភួយមកគ្របខ្លួនជិតត្រឹមករធ្វើឲ្យគេញញឹមតិចៗ មុននឹងសសៀរៗទៅគេងក្បែរលូកដៃឱបពីក្រោយធ្វើឲ្យរើបម្រះតិចៗ។

«នៅឲ្យស្ងៀមទៅ» គេប្រាប់សំឡេងស្រាលទើបនាងនៅស្ងៀមនឹកឃើញអ្វីទើបងាកមកប្រឈមជាមួយអ្នកម្ខាងទៀត។

«លោកនាំកូនទៅណា?»

«ពួកគេនៅជាមួយ ហេជីន អូនកុំបារម្ភអី»

«ហេតុអីក៏ស្គាល់នាង?»

«បងស្គាល់នាងពេលនៅអង់គ្លេស ហើយក៏ទើបតែដឹងថានាងជាមិត្តរបស់អូនដូចគ្នា» គេរៀបរាប់ប្រាប់ហើយក៏រឹតរង្វង់ដៃណែនជាងមុន ព្រោះមានអារម្មណ៍កក់ក្តៅទើបនាងនៅស្ងៀម ថែមទាំងសសៀរទៅកេកាងកាយកក់ក្តៅបន្ថែមទៀតធ្វើឲ្យគេញញឹមចុងមាត់។

ចាប់ផ្តើមជាទម្លាប់ ដែលបើកភ្នែកឡើងជួបតែភាពងងឹតទោះបីពេលនេះជាពេលថ្ងៃឬយប់នៅតែដូចគ្នា គិតហើយក៏រាវរកអ្នកក្បែរខ្លួនតែមិនឃើញគេនោះទេ ទើបក្រោកចុះពីគ្រែដើរតិចៗតាមទិសដៅដែលចាំបានថាមានអ្វីខ្លះ។

«ចង់ទៅបន្ទប់ទឹកមែនទេ ហេតុមិនប្រាប់បង» សំឡេង អែលវិនបន្លឺឡើងទើបងាកទៅរកប្រភពនោះ តែរាងកាយនាងបែរជាត្រូវលើកឡើងទាំងមិនទាន់ត្រៀមខ្លួនទើបស្រវ៉ាតោងអ្នកម្ខាងទៀតជាប់។

«ខ្ញុំអាចដើរទៅខ្លួនឯងបាន» នាងប្រាប់តិចៗ។

«ចុះបើដើរទៅបុកអីដួលនោះគិតយ៉ាងម៉េច?» គេប្រាប់សំឡេងរឹងទើបនាងនៅស្ងៀម គេបារម្ភពីនាងឬបារម្ភពីកូនឲ្យប្រាកដ នាងសួរខ្លួនឯងក្នុងចិត្តធ្វើឲ្យគេដឹងថានាងកំពុងគិតអីម្យ៉ាង។

«បារម្ភទាំងពីរនាក់ហ្នឹង» គេប្រាប់ហើយក៏ដាក់នាងចុះ ហេតុអីក៏គេដឹងថានាងកំពុងគិតអី ទឹកមុខនាងបង្ហាញប្រាប់គេឬយ៉ាងម៉េច។

«ចាត់ការធុរៈអូនទៅ ហើយប្រាប់បង» គេប្រាប់ហើយក៏លួចធ្អក់



ថើបបបូរមាត់នាងបន្តិចមុននឹងដើរចេញ ស៊ូហ៊ី ចាប់ផ្តើមមុខក្រហមតិចៗ មិនដឹងហេតុអីក៏គេយកចិត្តទុកដាក់ជាមួយនាងដល់ថ្នាក់នេះ ព្រោះនាងជាមនុស្សពិការគួរឲ្យអាណិតមែនទេ គិតហើយទឹកភ្នែកចាប់ផ្តើមហូរបើនាងមើលមិនឃើញហេតុនោះគិតយ៉ាងម៉េច នាងកិតទាំងខ្វល់ខ្វាយលើកដៃស្ទាបភ្នែករបស់ខ្លួន ធ្វើឲ្យអ្នកឈរមើលមានអារម្មណ៍តូចចិត្តដូចគ្នាគេមិនបានចេញទៅក្រៅនោះទេព្រោះខ្លាចនាងមានគ្រោះថ្នាក់ ដឹងថានាងកំពុងគិតអីចង់ចូលទៅលួងលោម ព្រោះតែគេទើបនាងក្លាយជាបែបនេះសន្យាគេគ្មានថ្ងៃបោះបង់នាងនោះទេ មិនថានាងក្លាយជាអ្វីក៏ដោយ។

«ពេលនេះម៉ោងប៉ុន្មានហើយ លោកមិនទៅធ្វើការទេហ៎?» នាងសួរតិចៗពេលគេបីមកដាក់លើគ្រែ។

«ម៉ោង៩ព្រឹកហើយ បងដាក់ច្បាប់សម្រាកដើម្បីមើលថែអូន» គេតបហើយទាញភួយមកគ្របលើខ្លួននាងថ្នមៗ អ្នកស្តាប់ជ្រួញចិញ្ចើម។

«លោកជាអគ្គនាយកត្រូវដាក់ច្បាប់សម្រាកដែរមែនទេ?»

«ត្រូវហើយ បើមិនធ្វើបែបនេះកូនចៅបងច្បាស់ជាកឿងមិនខាន» គេតបទាំងសើចប្រះខ្លួនគេងក្បែរ លូកដៃទៅឱបនាងស្រាលៗ។

«ស្អែកពួកយើងទៅពេទ្យ បងណាត់គ្រូពេទ្យពិនិត្យអការៈរបស់អូនអាចធ្វើការវះកាត់ក្នុងពេលឆាប់ៗនេះ»

«ចុះបើវះកាត់ហើយ នៅតែមើលមិនឃើញវិញនោះ» នាងនិយាយហើយក៏យំទើបគេទាញមកឱបលួងលោម។

«ច្បាស់ជាអាចមើលឃើញវិញ គ្រូពេទ្យទីនេះជាអ្នកជំនាញ»

«ខ្ញុំខ្លាចបើមិនអាចមើលឃើញ... តើ...» និយាយហើយក៏កម្រើក

ខ្លួនចេញតិចៗចង់មើលអ្នកម្ខាងទៀត តែបានត្រឹមសម្លឹងដើមទ្រូងរបស់គេ ចំពោះនាងជាភាពងងឹត អែលវិន ដឹងថានាងមានន័យពីអ្វីទើបទាញនាងមកឱបវិញហើយរឹតរង្វង់ដៃណែនជាងមុន។

«មិនថាអូនក្លាយជាអ្វី បងមិនបោះបង់អូននិងកូននោះទេ ឈប់បារម្ភរឿងនេះទៀតបងសន្យា» គេនិយាយសំឡេងម៉ឺងម៉ាត់ ធ្វើឲ្យនាងនៅស្ងៀមមួយដង្ហើមមុននឹងលើកដៃឱបតបគេ ទឹកមុខញញឹមពេញដោយក្ដីស្រលាញ់ទោះមិនដឹងថាពាក្យទាំងនេះអាចជឿបានប៉ុន្មានក៏ដោយ។

អែលវិន នាំនាងមកដល់មន្ទីរពេទ្យបន្ទាប់ពីចូលបន្ទប់ពិនិត្យខាងមន្ទីរពេទ្យតម្រូវឲ្យនាងសម្រាកទីនេះទើបគេត្រូវយល់ព្រម ព្រោះបារម្ភពីអាការៈរបស់នាង ទាំងដែលចង់ឲ្យនាងសម្រាកនៅផ្ទះជាង ស្របពេលមនុស្សរបស់គេទូរស័ព្ទមកថាមានបញ្ហានៅសណ្ឋាគារ ទើបគេទាក់ទើបន្តិចមុននឹងទៅ តែចិត្តនៅតែបារម្ភរាងស្ដើងជានិច្ចទើបដាក់បញ្ជាឲ្យកូនចៅនៅមើលបន្ត រហូតគេត្រឡប់មកវិញ។

«ឈប់សិន ស្រីម្នាក់នោះជា...» សំឡេងនារីម្នាក់បន្លឺឡើងទាំងសម្លឹងទៅរាងស្ដើងមួយរូប ដែលកំពុងដើរតិចៗសសៀរៗតាមជញ្ជាំងមន្ទីរពេទ្យមុននឹងមានអ្នកគ្រូពេទ្យម្នាក់មកជួយគ្រា ធ្វើឲ្យនាងចាប់ផ្ដើមឆ្ងល់ពីសកម្មភាពរបស់ពួកគេ។

«មានអីមែនទេ ឡេណា» សំឡេងនារីម្នាក់ទៀតបន្លឺឡើងសួរមិត្ត។

«គឺជួបអ្នកស្គាល់ ឯងទៅមុនទៅគ្នាទៅរាក់ទាក់គេបន្តិច» ឡេណាប្រាប់មិត្តហើយក៏ដើរសំដៅទៅពួកគេ ដែលឃើញមុននេះទាំងញញឹមលាក់គំនួចព្រោះអាចស្មានដឹងខ្លះៗ តែចង់ទៅមើលឲ្យច្បាស់ជាង។





«សូមទោសអ្នកគ្រូពេទ្យ អ្នកជំងឺមុននេះនាងឈឺអីមែនទេ?» ឡេណា សួរគ្រូពេទ្យដែលទើបគ្រា ស៊ូហ៊ី ទៅបន្ទប់មុននេះ។

«អ្នកនាងត្រូវជាអ្វីនឹងអ្នកជំងឺដែរ» គ្រូពេទ្យសួរតបទាំងសម្លឹងមើលអ្នកម្ខាងទៀតបែបរិះគិត ធ្វើឲ្យនាងទាក់ទើរមុននឹងរកនឹកតប។

«ជាមិត្តភក្តិ»

«នាងមានការប៉ះទង្គិចត្រង់ក្បាល ប៉ះពាល់ដល់ការមើលឃើញ» គ្រូពេទ្យតបហើយក៏ដើរចេញទៅ ឡេណា ភ្ញាក់ផ្អើលបន្ទាប់ពីឮក្រោយមកក៏ញញឹមមានល្បិចមុននឹងដើរសំដៅបន្ទប់នោះ។

«អ្នកគ្រូពេទ្យ ខ្ញុំចង់ទៅបន្ទប់ទឹក» ស៊ូហ៊ី ឮសំឡេងបើកទ្វារបន្ទប់គិតថាជាគ្រូពេទ្យទើបប្រាប់ហើយក៏សសៀរៗចុះពីគ្រែ ទើបអ្នកម្ខាងទៀតត្រូវទៅជួយទប់ខ្លួន ដោយសារមើលមិនឃើញទើបចេះតែដើរតាមអ្នកនាំធ្វើឲ្យនាងងឿងឆ្ងល់ បន្ទប់ទឹកនៅជិតនោះទេហេតុអីក៏ដើរយូរហើយមិនទាន់ដល់ គិតហើយក៏ងាកទៅអ្នកម្ខាងទៀត។

«អ្នកគ្រូពេទ្យ ចង់នាំខ្ញុំទៅណា?»

«ទៅកន្លែងដែលសមនឹងនាងហ្នឹងហើយ» ឡេណា ប្រាប់សំឡេងរឹងហើយក៏រុញនាងចូលឡានមុននឹងបើកចេញទៅ ស៊ូហ៊ី ចាប់ផ្ដើមភ័យព្រោះមិនដឹងអ្នកម្ខាងទៀតចង់ធ្វើអី ស្ដាប់សំឡេងមុននេះមានអារម្មណ៍ធ្លាប់ស្គាល់តែរកនឹកមិនឃើញ ព្រោះខួរក្បាលរបស់នាងកំពុងតែវិលវល់។

«នាងជាអ្នកណា ចង់នាំខ្ញុំទៅណា ឆាប់លែងខ្ញុំទៅ» ស៊ូហ៊ី និយាយអង្វរទាំងរាវដៃរកកន្លែងបើកទ្វារ។

«បើកទៅបើនាងចង់ស្លាប់ បើកទ្វារហើយលោតចុះទៅ» សំឡេងអ្នកខាងមុខបន្លឺឡើង ថែមទាំងជាន់ហ្វ្រាំងបន្ថែមល្បឿនធ្វើឲ្យអ្នកខាងក្រោយទប់ខ្លួនមិនទាន់បោកក្បាលទៅកៅអីខាងមុខ ស៊ូហ៊ី មានអារម្មណ៍ឈឺក្បាលខ្លាំងណាស់ហើយក៏ខ្លាចខ្លាំងណាស់ដែរ តែព្យាយាមទប់ខ្លួនព្រោះខ្លាចប៉ះទង្គិចអីផ្សេងធ្វើឲ្យប៉ះពាល់ដល់កូនក្នុងផ្ទៃ។

អែលវិន ត្រឡប់មកដល់មន្ទីរពេទ្យយ៉ាងប្រញាប់ប្រញាល់ បន្ទាប់ពីមនុស្សរបស់គេរាយការណ៍បាត់ ស៊ូហ៊ី ធ្វើឲ្យគេស្ទើរឆ្កួតទៅហើយ។

«នាំគ្នាមើលមនុស្សយ៉ាងម៉េច បានជាបាត់មិនដឹង ហ្អាស» គេស្រែកគំហកឲ្យកូនចៅ ថែមទាំងសម្លឹងទៅគ្រូពេទ្យដែលមានតួនាទីមើលថែមនាងដោយក្រសែភ្នែកមុត។

«នៅមាននាងទៀតមើលអ្នកជំងឺយ៉ាងម៉េចបានឲ្យបាត់ បើជាមនុស្សធម្មតាមិនអីទេ តែនេះនាងពិការភ្នែកណា»

«ខ្ញុំសុំទោស គឺខ្ញុំនាំនាងទៅសម្រាកហើយចេញមកយកថ្នាំពេលទៅវិញក៏មិនឃើញ» គ្រូពេទ្យនិយាយរាងខ្សោយទាំងឱនមុខចុះ។

«ឆាប់នាំគ្នាទៅតាមរកមើល ហើយឆែកមើលកាមេរ៉ាសុវត្ថិភាពឲ្យលឿនទៅ បើរកមិនឃើញខ្ញុំនឹងដេញពួកឯងចេញទាំងអស់» គេនិយាយសំឡេងរឹងទើបម្នាក់នាំគ្នាបំបែកផ្លូវយ៉ាងប្រញាប់ប្រញាល់។

អែលវិន ត្រូវចេញទៅតាមរកដោយផ្ទាល់បន្ទាប់ពីកូនចៅរបស់គេរាយការណ៍ថាមានមនុស្សនាំនាងចេញពីមន្ទីរពេទ្យ បេះដូងគេស្ទើរតែរាំងទៅហើយមិនអាចនៅស្ងៀមនោះទេ គេមិនអាចឲ្យនាងមានរឿងអីទៀតទេគិតហើយក៏ទាញទូរស័ព្ទចុចទៅរកមិត្ត។

(អាឡូ អែលវិន មានការអីមែនទេទើបខលមក) សំឡេងក្នុងទូរស័ព្ទបន្លឺឡើងបែបសប្បាយ តែអ្នកម្ខាងទៀតគ្មានអារម្មណ៍លេងនោះទេ។

«ចាស្ទីន ជួយគ្នារឿងមួយជួយតាមរក ស៊ូហ៊ី នាងបាត់ខ្លួនហើយមានមនុស្សនាំនាងទៅ ឆាប់ឲ្យមនុស្សរបស់ឯងជួយរកផង» អ្នកស្ដាប់ជ្រួញចិញ្ចើមបន្ទាប់ពីឮ។

(មានរឿងអីគ្នាមិនយល់ទេ ឯងនិយាយឲ្យច្បាស់បន្តិចមក) អ្នកម្ខាងទៀតធ្វើភ្នែកឡេងឡាមចង់តែគប់ទូរស័ព្ទចោលនោះទេ តែព្យាយាមទប់អារម្មណ៍ព្រោះកំពុងតែពឹងគេឲ្យជួយ។

«ចាំគ្នាប្រាប់ឯងពេលក្រោយ ពេលនេះជួយតាមរកនាងសិនទៅ បន្តិចទៀតគ្នាផ្ញើរូបថតនាងឲ្យ» អែលវិន និយាយហើយក៏បិទទូរស័ព្ទ ធ្វើឲ្យ ចាស្ទីន នៅរិះគិតពីសម្ដីមិត្តនៅឡើយទេ រហូតឮសំឡេងផ្ញើសារចូលទើបលើកមកមើលម្ដងទៀតជារូបថតរបស់ ស៊ូហ៊ី ធ្វើឲ្យគេភ្លឹកមើលបន្តិចមុននឹងចាត់ការទាក់ទងទៅកូនចៅរបស់គេឲ្យតាមរក។

ផ្ទះថ្មមួយនៅម្ដុំជាយក្រុង មានបុរសមាឌធំបួនប្រាំនាក់នៅឈរខាងមុខដូចជារង់ចាំអ្វីមួយ ស្របពេលមានរថយន្តបើកចូលមកនារីស្ដើងចុះពីរថយន្តដើរទៅបើកទ្វារបាំងខាងក្រោយ អុសនារីម្នាក់ទៀតចេញមកទាំងក្រដាបក្រដួស។

«អ្នកនាងមានអីឲ្យខ្ញុំបម្រើមែនទេ?» សំឡេងបុរសម្នាក់បន្លឺឡើងទាំងឱនលំទោនជាការគោរពអ្នកម្ខាងទៀត។

«គ្មានអីធំដុំទេ គ្រាន់តែចង់ឲ្យប្រដៅស្រីម្នាក់នេះបែបសប្បាយៗ»

ឡេណា ប្រាប់ទាំងញញឹមងាកទៅមើល ស៊ុហ៊ី ដែលមានទឹកមុខស្លេកស្លាំងមិនដឹងពូកគេចង់ធ្វើអីនោះទេ ថែមទាំងភ្នែកមើលមិនឃើញ ថែមទៀតចង់រត់ក៏មិនដឹងរត់តាមណា បានត្រឹមឈរបង្ហូរទឹកភ្នែកសង្វេគខ្លួន។

-ស្រីម្នាក់នេះជាអ្នកណាអ្នកនាង- សំឡេងបុរសម្នាក់សួរទាំងសម្លឹងមើលទៅ ស៊ុហ៊ី ទាំងញញឹមចុងមាត់។

-មិនបាច់ចង់ដឹង គ្រាន់តែធ្វើតាមអ្វីដែលខ្ញុំប្រាប់បានហើយ- ឡេណា ប្រាប់សំឡេងរឹងទើបម្នាក់ៗនាំគ្នាស្ងាត់ស្ងៀម។

ស៊ុហ៊ី ត្រូវនាំមកកាន់បន្ទប់ជាន់ក្រោមសសៀរៗអង្គុយកៀនជញ្ជាំងឱបខ្លួនដោយភាពភ័យខ្លាច ក្នុងចិត្តបុណ្យឲ្យមានមនុស្សមកនាំនាងចេញពីទីនេះតែប៉ុណ្ណោះ។

-អ៊ែលវិន មកជួយខ្ញុំផង- នាងននិយាយតិចៗតែក៏អាចធ្វើឲ្យគេឮ ឡេណា ងាកមកសម្លក់នាងដោយភាពឈ្នានីសបន្ទាប់ពីឮ។

-នាងគិតថាគេអាចមកជួយនាងទាន់មែនទេ យល់សប្តទៅ- ឡេណា និយាយទាំងញញឹមចំអកងាកទៅញាក់មុខដាក់កូនចៅរបស់ខ្លួន។

-ឆាប់ចាត់ការនាងទៅ-

-ចង់ ចង់ធ្វើអី កុំធ្វើបាបខ្ញុំអី- នាងនិយាយបណ្តើរកិលខិតថយក្រោយបណ្តើរទាំងភ័យខ្លាចព្រោះដឹងថាមានមនុស្សកំពុងដើរសំដៅមក។

-ពួកយើងមិនធ្វើបាបនាងទេ គ្រាន់តែផ្តល់មេរៀនសប្បាយៗ- បុរសម្នាក់និយាយហើយក៏នាំគ្នាសើចគិលាពេញបន្ទប់។

-សូមអង្វរកុំធ្វើបាបខ្ញុំអី ខ្ញុំមានផ្ទៃពោះហើយ-





ស៊ុហ៊ី និយាយបណ្តើរលើកដៃសំពះបណ្តើរគួរឲ្យអាណិត ធ្វើឲ្យពួកគេឈប់ទ្រឹងងាកមកមើលមុខគ្នា ឡេណា ស្ទុះចុះមកយ៉ាងលឿនបន្ទាប់ពីឮ។

-នាងថាម៉េច មានផ្ទៃពោះអ៊ីចឹងឬ?- ឡេណា ខទានទាំងភ្ញាក់ផ្អើលសម្លឹងមើលពោះរាបស្មើរបស់នាងមុននឹងញញឹមចុងមាត់។

-ល្អចាត់ការរហូតនាងរលូតកូននោះ- នាងនិយាយហើយក៏សើចបង្ហាញភាពពិសពុល តែកូនចៅរបស់នាងនាំគ្នាទាក់ទើ ព្រោះបើឲ្យពួកគេសម្លាប់សត្រូវគ្មានបញ្ហានោះទេ តែពេលធ្វើបាបមនុស្សស្រីទន់ខ្សោយធ្វើឲ្យពួកគេរាងអាណិត។

-ហេតុអីមិននាំគ្នាចាត់ការទៅ- ឡេណា ស្រែកប្រាប់ទើបពួកគេនាំគ្នាដើរសំដៅរាងស្តើងស្របពេលមានមនុស្សបើកទ្វារចូលមក។

-អ្នកនាងមានមនុស្សមករក- បុរសម្នាក់ចូលមកប្រាប់ធ្វើឲ្យពួកគេនាំគ្នាងាកមកមើល។

-អ្នកណាគេ?- ឡេណា សួរសំឡេងរឹង។

-គឺខ្ញុំ- សំឡេងអ្នកណាម្នាក់ទៀតបន្លឺឡើងនៅមាត់ទ្វារថែមទាំងដើរចូលមកដោយញញឹមញញែម ធ្វើឲ្យនាងចាប់ផ្អើលធ្វើខ្លួនមិនត្រូវ។

-កំពុងធ្វើអីមែនទេ ដូចជាអ៊ូអរម្លេះ- ចាស៊ីន សួរសំឡេងធម្មតា មុននឹងងាកទៅមើលរាងស្តើងដែលអង្គុយកៀនជញ្ជាំងដោយក្តីអាណិត ងាកមកមើលអ្នកចំពោះមុខ។

-មិនទាក់ទងនិងលោកទេ- ឡេណា តបសំឡេងស្អៀងាកទៅមើលកូនចៅឲ្យនាំ ស៊ុហ៊ី ទៅកន្លែងផ្សេងតែក៏ត្រូវ ចាស៊ីន ចូលមកវាំង។



Scanned by CamScanner

-លោកចង់យ៉ាងម៉េច?- ចាស៊ីន ញញឹមចុងមាត់មុននឹងតប។

-មានមនុស្សឲ្យខ្ញុំតាមរកស្រីម្នាក់នោះ ចៃដន្យដល់ហើយដែលបានជួបនៅទីនេះ- គេនិយាយហើយក៏ងាកទៅមើល ស៊ុហ៊ុ។

ឡេណា ចាប់ផ្ដើមដកដង្ហើមញាប់ព្រោះដឹងថាជាអ្នកណា នាងដឹងថា ចាស៊ីន ជាមិត្តជិតស្និទ្ធរបស់ អែលវីន ច្បាស់ណាស់ជាគេអ្នកបញ្ជា។

-ខ្ញុំបានប្រាប់គេពីកន្លែងនេះ ប្រហែលជាជិតមកដល់ហើយនាងចង់នៅជួបគេដែរទេ ឬក៏ចង់ទៅមុនតាមចិត្ត- ឡេណា ចាប់ផ្ដើមភ័យងាកទៅមើលកូនចៅរបស់ខ្លួនទាំងម៉ូម៉ៅ មិនគួរបរាជ័យបែបនេះសោះ។

-ខ្ញុំទៅមុនក៏បាន- នាងប្រាប់ហើយក៏នាំគ្នាដើរចេញទៅ។

ចាស៊ីន ដើរមកជិតរាងស្ដើងធ្វើឲ្យនាងថយក្រោយដោយភាពភ័យខ្លាចតែក៏ប៉ះទៅនឹងជញ្ជាំងទើបលើកដៃអង្វរទាំងទឹកភ្នែក។

-កុំធ្វើបាបខ្ញុំអី-

-ខ្ញុំមិនធ្វើបាបនាងទេ ចាំខ្ញុំមិនបានឬយ៉ាងម៉េច?- ស៊ុហ៊ុ អង្គុយស្ងៀមផ្ទៀងស្ដាប់សំឡេង។

-លោកគឺ ចាស៊ីន មែនទេ?- នាងសួរតិចៗទាំងលើកដៃរាវរកធ្វើឲ្យគេចាប់ផ្ដើមងឿងឆ្ងល់សម្លឹងមើលនាងមិនដាក់ សន្សឹមៗលើកដៃគ្រវីខាងមុខតែនាងបែបជានៅស្ងៀម មិនព្រិចភ្នែកធ្វើឲ្យគេកាន់តែច្បាស់។

-ត្រូវហើយ គឺខ្ញុំ- គេតបហើយក៏ហុចដៃទៅឲ្យនាងកាន់ មើលទៅនាងប្រហែលជាភ័យហើយទើបខិតទៅឱបតិចៗលួងលោម។

-អែលវីន ឲ្យលោកមកមែនទេចុះគេទៅណា ហេតុអីមិនមក- នាងសួរតិចៗពេលគេនាំចេញមកដល់ក្រៅ។





-គេកំពុងតាមរកនាងដូចគ្នា តែខ្ញុំមកជួបមុន- គេតបហើយក៏គ្រានាងចូលឡាន នាងមិនជំទាស់គិតថាគេនាំទៅផ្ទះរបស់ អែលវីន។

ចាស៊ីន ងាកមកសម្លឹងនារីក្បែរខ្លួន តែភ្នែកថ្លាឆ្វង់សម្លឹងទៅមុខត្រង់ហាក់ដូចគ្មានអ្វីទាំងអស់ គេមិនដឹងថានាងមានរឿងអីនោះទេទើបក្លាយជាបែបនេះ ហើយចុះមៀរមិត្តរបស់គេនោះគិតយ៉ាងម៉េចចំពោះនាងទៅវិញ គេរិះគិតរហូតរថយន្តឈប់ចតនៅខាងមុខភូមិគ្រឹះមួយ ដែលមានផ្ទៃដីធំទូលាយជុំវិញសុទ្ធតែផ្កាចំរុះពណ៌គ្រប់ប្រភេទ។

-ដល់ហើយឆាប់ចុះមក- គេប្រាប់ទាំងគ្រានាងចុះពីឡាន នាងក្រមុំស្ងៀមទ្រើងព្រោះកំពង់ជក់ចិត្តស្រូបក្លិនផ្កា ដែលស៊ាំទម្លាប់ហើយជាក្លិនដែលនាងចូលចិត្តថែមទៀត គឺផ្កាលីលី ហើយក៏នឹកភ្ញាក់ខ្លួនពេលគិត

ថាទីនេះមិនមែនជាផ្ទះរបស់ អែលវីន នោះទេ។

-ទីនេះជាកន្លែងណា?- នាងងាកមកសួរអ្នកក្បែរខ្លួន។

-ជាផ្ទះរបស់ខ្ញុំ- ចាស៊ីន តបហើយក៏គ្រានាងដើរទៅក្នុងតែនាងមិនព្រមនៅឈរស្ងៀមព្រោះមិនដឹងអ្នកម្ខាងទៀតចង់ធ្វើអី។

-ខ្ញុំចង់ទៅផ្ទះរបស់ អែលវីន លោកអាចនាំខ្ញុំទៅបានទេ?-

-ខ្ញុំនឹងនាំនាងទៅ រង់ចាំឲ្យខ្ញុំពិសោធរឿងមួយសិន- គេប្រាប់ទាំង

ញញឹមណាក់តែនាងមិនអាចឃើញនោះទេ។

-ឆាប់ចូលក្នុងទៅ ខ្ញុំមិនធ្វើអីនាងនោះទេកុំបារម្ភអី- គេប្រាប់

សំឡេងម៉ឺងម៉ាត់ទើបនាងព្រមដើរតាមទាំងមិនសូវទុកចិត្ត។

-ផ្ទះលោកដាំផ្កាលីលីច្រើនមែនទេ?- នាងសួរពេលគេនាំមកដល់ក្នុងធ្វើឲ្យអ្នកម្ខាងទៀតជ្រួញចិញ្ចើមព្រោះនាងមើលមិនឃើញ ម៉េចក៏ដឹង

ថាគេដាំផ្កាប្រភេទនេះ។

«ហេតុអីក៏នាងដឹង បើ...»

«នេះជាផ្កាដែលខ្ញុំចូលចិត្ត ដូច្នេះខ្ញុំចាំក្លិនបានគ្រប់ពណ៌» នាងតប ទាំងញញឹមស្រស់ធ្វើឲ្យគេញញឹមដូចគ្នា។

«ពិតមែនហំ បែបនេះល្អហើយ» តបហើយក៏ងាកទៅមើលមេផ្ទះ ដែលទើបដើរចេញមក។

«អ៊ំជួយនាំនាងទៅបន្ទប់សម្រាកផង» គេប្រាប់ហើយក៏ធ្វើកាយវិការប្រាប់ថាភ្នែកនាងមើលមិនឃើញទេ ឲ្យគាត់ចាត់ការចុះផ្សេងៗនាងផង មេផ្ទះចំណាស់ងក់ក្បាលមុននឹងនាំនាងឡើងទៅលើ។

អែលវិន ស្ទើរឆ្កួតទៅហើយព្រោះតែតាមរកនាងមិនឃើញគេឲ្យមនុស្សតាមរកគ្រប់ច្រកល្ហកនៅតែមិនឃើញ ទើបត្រឡប់មកផ្ទះតែពេលបកដល់ធ្វើឲ្យគេនឹកនាងកាន់តែខ្លាំង ទើបចេញទៅតាមរកបន្តពេលនេះយប់ទៅហើយ នៅតែរកនាងមិនទាន់ឃើញថែមទៀត។

«ស៊ីហ៊ី ត្រឡប់មកវិញមក ត្រឡប់មកវិញមក» គេស្រែកហៅនាងក្នុងចិត្តគេយល់ហើយថាមិនអាចរស់គ្មាននាងនោះទេ។

«អ៊ំគិតធ្វើយ៉ាងម៉េចទៅ?» ជេក ងាកទៅសួរមេផ្ទះចំណាស់ដែលឈរព្រួយ ព្រោះប៉ុន្មានថ្ងៃមកហើយដែលចៅហ្វាយគេមិនព្រមញ៉ាំមិនព្រមផឹកតិចតែតែអង្គុយសញ្ជឹងក្នុងបន្ទប់ទទួលភ្ញៀវ ហើយពេលខ្លះក៏សំងំក្នុងបន្ទប់ធ្វើការធ្វើឲ្យពួកគេនាំគ្នាព្រួយបារម្ភ។

«ខ្ញុំក៏មិនដឹងដូចគ្នា អាណិតអ្នកប្រុសដល់ហើយ គាត់មិនធ្លាប់បែបនេះទេ» មេផ្ទះចំណាស់តបទាំងសម្លឹងទៅបន្ទប់ទទួលភ្ញៀវ។



«មែនហើយអ៊ំ» ជេក តបទាំងមុខស្រពោនស្របពេលមានមនុស្សដើរចូលមកទើបងាកទៅមើលជាដៃគូរបស់គេនោះហើយ មើលទៅដូចជាប្រញាប់ប្រញាល់ប្លែកទើបគេត្រូវទៅស្ទាក់សួរ។

«ជីម មានរឿងអីមែនទេ?»

«បានដំណឹងពីអ្នកនាងហើយ ខ្ញុំទៅរាយការណ៍ប្រាប់ចៅហ្វាយ» គេតបហើយក៏ដើរទៅក្នុងយ៉ាងលឿន ម្នាក់ៗនាំគ្នាត្រេកអរបន្ទាប់ពីឮ។

«ចៅហ្វាយ មនុស្សរបស់យើងរាយការណ៍មកថា...» ជីម និយាយហើយក៏ទាក់បន្តិចធ្វើឲ្យ អែលវិន ងាកមកសម្លឹងមុខយ៉ាងលឿន។

«មានរឿងអី»

«មានគេឃើញអ្នកនាងនៅជាមួយ អ្នកប្រុស ចាស្ទីន» អែលវិន អង្គុយទ្រឹងបន្ទាប់ពីឮ គេក្តាប់ដៃណែនតែភ្នែកពេញដោយកំហឹងមិនគិតថាមិត្តដែលគេទុកចិត្តហ៊ានយកមនុស្សស្រីរបស់គេទៅលាក់ទុកនោះទេ។

«ត្រៀមឡានខ្ញុំនឹងទៅផ្ទះរបស់គេ» គេប្រាប់សំឡេងរឹងហើយក៏ដើរចេញទៅមនុស្សជំនិតម្នាក់ៗនាំគ្នាលេបទឹកមាត់ ព្រោះមើលទៅចៅហ្វាយគេខឹងម្តងនេះមិនធម្មតានោះទេ។

ចាស្ទីន កំពុងអង្គុយក្នុងបន្ទប់ទទួលភ្ញៀវស្របពេលឮសម្រែកជើងដើរចូលមកទើបងាកទៅមើល គេធ្វើមុខញញឹមៗពេលឃើញថាជាអ្នកណា អែលវិន ដើរចូលមកដោយឫកពារហ្មឹងធឹងតែភ្នែកមុតសម្លឹងមក គេដឹងថាអាចនិងមានគ្រាប់បែកផ្ទុះនាពេលបន្តិចទៀតនេះ តែធ្វើជានៅស្ងៀមចាំមើលប្រតិកម្មរបស់អ្នកម្ខាងទៀត។

«អែលវិន ខ្យល់អីបក់ឯងមកដល់ទីនេះពិតជាចម្លែកមែន» ចាស្ទីន



Scanned by CamScanner

និយាយទាំងញញឹមថែមទាំងក្រោកឈរភក់ទាក់ កណ្ដាប់ដៃរបស់អ្នកម្ខាងទៀតទៅវិញ ធ្វើឲ្យគេដួលទៅលើសាឡុងទាំងមិនទាន់បានត្រៀមខ្លួន។

«ឯងនាំនាងទៅទុកឯណា ឆាប់នាំនាងមក» អែលវិន ស្ទុះទៅទាញករអាវអ្នកម្ខាងទៀតនិយាយសំឡេងតាមធ្មេញ។

«ឯងនិយាយស្អីយើងមិនយល់» ចាស៊ីន សួរហើយលើកដៃផូតឈាមដែលហូរបែបហាក៏ធ្វើឲ្យអ្នកម្ខាងទៀតកាន់តែក្ដៅ។

«ឯងជាអ្នកនាំ ស៊ូហ៊ី មកមែនទេ ឆាប់និយាយទៅ»

«យើងមិនបាននាំនាងមក»

«មានមនុស្សរបស់យើងឃើញឯងនៅជាមួយនាង»

«មនុស្សរបស់ឯងពិតជាប៉ិនដឹងមែនហ្ន៎» គេនិយាយលាយសើច។

«ឆាប់និយាយមកថានាងនៅឯណា»

«ហេតុអីក៏នៅតាមរកនាង ក្រែងឯងបោះបង់នាងមែនទេ ឬក៏ឯងស្រលាញ់នាង» អែលវិន ទឹកមុខពោរពេញដោយកំហឹងសម្លឹងមើលមុខអ្នកម្ខាងទៀតទ្រឹងមុននឹងតប។

«ជារឿងរបស់យើង» គេតបហើយក៏លែងដៃរបស់ខ្លួន ថយមកឈរសម្លឹងអ្នកម្ខាងទៀតដោយក្រៃភ្នែកមុត។

«បើឯងមិនស្រលាញ់នាង ដោះលែងនាងទៅ» ចាស៊ីន ប្រាប់សំឡេងស្រាលតែកាន់តែបន្ថែមកំហឹងឲ្យអ្នកម្ខាងទៀត។

«យើងប្រាប់ហើយថាជារឿងរបស់យើង ឯងកុំលូកដៃ» អែលវិន ប្រាប់សំឡេងតាមធ្មេញ។





«តែយើងអាណិតនាង ដែលត្រូវរស់នៅជាមួយមនុស្សដូចជាឯងដែលមិនដែលខ្វល់ មិនដែលផ្ដល់ក្ដីស្រលាញ់ឲ្យនាង»

«ម៉េចក៏ឯងដឹងថាយើងមិនដែលខ្វល់ពីនាង បើយើងមិនខ្វល់យើងមិនមែនដើររកនាងស្ទើរឆ្កួតបែបនេះទេ» គេនិយាយហើយក៏ដាក់ខ្លួនអង្គុយសាឡុងយកដៃបោចសក់ខ្លួនឯងធ្វើឲ្យ ចាស៊ីន មានអារម្មណ៍អាណិតមិត្តព្រោះមិនធ្លាប់ឃើញគេក្នុងសភាពបែបនេះនោះទេ។

«ឯងកំពុងតែស្រលាញ់នាងហើយ នៅមិនដឹងខ្លួនទៀត» ចាស៊ីន និយាយលាយសើចហើយក៏ស្រែកថ្ងូរព្រោះឈឺមាត់។

«មែន! យើងស្រលាញ់នាង ទាំងស្រលាញ់ទាំងអាណិតខ្លាំងទៀតផង ព្រោះតែយើងទើបនាងក្លាយជាបែបនេះ យើងចង់មើលថែចង់ប៉ះប៉ូវរាល់កំហុសទាំងអស់ ឲ្យតែនាងត្រឡប់មកវិញឲ្យយើងធ្វើអ្វីក៏បានដែរ» ម្នាក់ៗនាំគ្នាសម្លឹងមើលគេដោយក្ដីអាណិត ចាស៊ីន ងាកទៅងក់ក្បាលដាក់មេផ្ទះទើបគាត់ឱនទទួលហើយក៏ដើរចេញទៅ។

ស៊ូហ៊ី នៅឈរខាងក្រៅបន្ទប់នេះនាងកំពុងឈរយំមានអារម្មណ៍រំភើបរហូតស្រក់ទឹកភ្នែក មិនគិតថាបានឮពាក្យទាំងនេះនោះទេ។

«អែលវិន...» សំឡេងស្រួយស្រែសបន្លឺឡើងទើបធ្វើឲ្យអ្នកដែលអង្គុយសញ្ជប់សញ្ជឹងស្ទុះក្រោករកមើលប្រភពសំឡេងដោយស្វ័យប្រវត្តិ។

«ស៊ូហ៊ី» អែលវិន ឧទានដោយភាពត្រេកអរពេលឃើញថាជាអ្នកណាស្ទុះរត់ទៅឱបនាងដោយក្ដីនឹករឭក។

«គឺអូនពិតមែន» គេឧទានតិចៗហើយក៏រុញនាងចេញដើម្បីបានមើលមុខឲ្យច្បាស់ គេលើកដៃស្ទាបថ្ពាល់ទាំងសងខាងទាញនាងមកថើប

នៅមុខអ្នកជុំវិញនោះដោយមិនខ្មាស មុននឹងទាញនាងមកឱបម្ដងទៀត ហើយក៏ផ្អៀតងាកទៅសម្លក់អ្នកម្ខាងទៀតដោយក្រសែភ្នែកគំគួន។

«កុំមកសម្លឹងយើងដោយក្រសែភ្នែកបែបនេះ យើងមិនបាននាំនាងមកគ្រាន់តែជួបមនុស្សអាក្រក់ចង់ធ្វើបាបនាង ទើបនាំមកទីនេះ» ចាស្ទីន និយាយហើយក៏ដើរទៅអង្គុយសាឡុងធ្វើហី។

«ពួកយើងត្រឡប់ទៅវិញទៅ» អែលវិន ប្រាប់រាងស្ដើងក្នុងល្បែងទ្រូងមុននឹងរសាយរង្វង់ដៃ លើកនាងបីដើរចេញទៅដោយមិនងាកមើលអ្នកណាទាំងអស់ធ្វើឲ្យ ចាស្ទីន ចាប់ផ្ដើមម៉ូម៉ៅតែញញឹមតិចៗព្រោះបានធ្វើរឿងដែលច្បាស់លាស់សម្រាប់មិត្តគេ។

«ស៊ីហ៊ឺ ទំនេរមកលេងផ្ទះផងខ្ញុំនឹងកំដរនាងដើរលេងសួនផ្កាលីលីរបស់ខ្ញុំទៀតណា» គេស្រែកប្រាប់ពេលនាងចូលឡានផុតនៅសល់តែ អែលវិន ដែលសម្លឹងមកដោយក្រសែភ្នែកមុតមុននឹងក្រឡេកឃើញជុំវិញផ្ទះរបស់មិត្តគេសុទ្ធតែជាផ្កាដែលនាងចូលចិត្តមែន គិតហើយក៏ចាប់ផ្ដើមម៉ូម៉ៅទៅវិញនឹងទិញផ្កាទាំងនេះដាំជុំវិញផ្ទះដូចគ្នា មិនឲ្យនាងមកទីនេះទៀតនោះទេ។







...១៥...

អែលវិន បីរាងស្ដើងមកដល់បន្ទប់ដាក់នាងឲ្យឈរមុននឹងចាត់ការដោះខោអាវនៅលើខ្លួននាងរហូតអស់

«ចង់ ចង់ធ្វើអី» នាងសួរដាច់ៗ។

«មើលលើខ្លួនអូនមានស្នាមអីខ្លះ»

«គ្មាន គ្មានទេ»

«បើគ្មានល្អហើយ តោះទៅងូតទឹក» គេប្រាប់ហើយក៏ចាត់ការខោអាវរបស់ខ្លួនរហូតអស់ដូចគ្នានៅសល់តែរាងកាយទទេស្អាតទាំងពីរ មុននឹងលើកបីនាងសំដៅបន្ទប់ទឹក។

«តែខ្ញុំទើបងូតពេលមុនមកនេះទេ» នាងប្រាប់គេតិចៗទាំងដៃនៅតោងករគេជាប់ព្រោះខ្លាចធ្លាក់។

«ចង់ងូតឲ្យអស់ក្លិនផ្ទះនោះ» គេប្រាប់សំឡេងស្មើស៊ូហ៊ី ដឹងថាគេនៅខឹងទើបមិនមាត់សុខចិត្តស្របតាម គេដាក់នាងចុះក្នុងអាងថ្មមៗមុននឹងចុះទៅតាម។

«អង្គុយឲ្យស្ងៀមចាំបងដុះខ្លួនឲ្យ» ប្រាប់ទាំងញញឹមមានល្បិចទាញរាងស្ដើងមកអង្គុយលើភ្លៅ យកស្បៀមកដូសខ្នងឲ្យនាងថ្នមៗដុះផងស្ទាបអង្អែលផងជាពិសេសដុំសាច់ទាំងពីរខាងមុខ ត្រូវស្ទាបច្របាច់មិនឈប់ធ្វើឲ្យខ្លួននាងចាប់ផ្ដើមក្ដៅទៅហើយហាមយ៉ាងណាក៏មិនស្ដាប់។

«អែលវិន» គេហៅគេតិចៗទាំងចាប់ដៃរវាមទាំងពីរនោះ។

«យ៉ាងម៉េច ហ៊ឹម!» តបហើយក៏ឱបចង្កេះនាងជាប់ដាក់មុខលើស្មារសខ្ចីដាក់បបូរមាត់លើសៀតថ្ពាល់នាងថ្នមៗ។



«ដឹងថាពេលរកអូនមិនឃើញ បងវេទនាប៉ុណ្ណាដែរទេបងខ្លាចខ្លាំងណាស់ខ្លាចមិនបានជួបអូនទៀត» គេប្រាប់សំឡេងស្រាលជិតត្រចៀកធ្វើឲ្យនាងនៅស្ងៀមមុននឹងឮគេបន្ថែមទៀត។

«មៀវនោះមានធ្វើអីអូនខ្លះពេលនៅទីនោះ?» គេសួរសំឡេងរឹងធ្វើឲ្យនាងញញឹមតិចៗ ទោះមិនបានឃើញទឹកមុខគេក៏នាងអាចស្មានដឹងដែរថាយ៉ាងម៉េច។

«គេមិនបានធ្វើអីទេ គ្រាន់តែ...»

«គ្រាន់តែយ៉ាងម៉េច ឆាប់និយាយមក!» គេប្រាប់ទាំងទាញនាងមកប្រឈមនាងក្រមុំញញឹមតិចៗមុននឹងតប។

«គេនាំអូនដើរលេងក្នុងសួនផ្កាតែប៉ុណ្ណឹងទេ!»

«ចុះពេលងូតទឹក អ្នកណាជាអ្នកផ្លាស់ខោអាវឲ្យអូន»

«មេផ្ទះជាអ្នករៀបចំឲ្យទេ»

«បែបនេះធូរទ្រូងបន្តិច» និយាយហើយក៏ឱបនាងណែនម្ដងទៀត។

«នៅជាមួយគេសប្បាយខ្លាំងណាស់មែនទេ បានជាមិននឹកនារកបងទាល់តែសោះ» គេសួរសំឡេងតូចចិត្តពេលនឹកឃើញពាក្យដែលមិត្តគេនិយាយមុននឹងត្រឡប់មកវិញ។

«មិនមែនបែបនោះទេ» នាងតបសំឡេងស្រាលងាកមកប្រឈមជាមួយអ្នកម្ខាងទៀតលើកដៃអង្អែលទ្រូងគេតិចៗ បែបនេះក៏ធ្វើឲ្យខ្លួនគេចាប់ផ្ដើមឡើងកម្ដៅទៅហើយ តែព្យាយាមស្ងប់អារម្មណ៍។

«មិនមែនបែបនោះ តើបែបណា?»

«ពេលនោះខ្ញុំខ្លាច ហើយភ័យខ្លាំងណាស់មិនដឹងថាខ្លួនឯងនៅ

ឯណា អាចត្រឡប់មកវិញបានឬអត់ទេ សំណាងដែលគេបកជួររោល... នាងគេបបណ្ដើរផ្អែកក្បាលលើទ្រូងគេបណ្ដើរ។

«គេមិនបានធ្វើអីទេ ថែមទាំងនាំខ្ញុំទៅមន្ទីរពេទ្យពិនិត្យអាការៈថែមទៀត ប៉ុន្មានថ្ងៃមកនេះខ្ញុំសម្រាកនៅមន្ទីរពេទ្យរហូតទើបតែទៅផ្ទះនោះទេ»

អែលវិន នៅស្ងៀមចាំស្ដាប់បន្ត។

«កុំខឹងគេអី គេជាមនុស្សល្អទេ»

«ខឹងរួចហើយ ក៏បានបញ្ចេញកំហឹងរួចហើយដែរ» ពាក្យសម្ដីរបស់គេធ្វើឲ្យនាងងើបមុខមកចំពោះមុខសួរដោយភាពភ្ញាក់ផ្អើល។

«លោកវ៉ៃគេមែនទេ?»

«ត្រូវហើយ អ្នកណាប្រើគេឲ្យមកកុហកធ្វើអី!»

«គេមិនបានកុហកគ្រាន់តែ...»

«សប្បាយចិត្តណាស់មែនទេ រួមដៃជាមួយគេមកធ្វើបាបប្ដីខ្លួនឯងឲ្យតាមរកស្ទើរឆ្កួតបែបនេះ ចាំមើលបងនឹងដាក់ទោសអូន»

«សូមទោស ខ្ញុំ...» បបូរមាត់ស្ដើងត្រូវអឹបជាប់មុននឹងដកមកវិញ។

«ហាមនិយាយពាក្យខ្ញុំទៀត ត្រូវប្រើពាក្យអូនជំនួស យល់ដែរទេ?»

«អូនដឹងហើយ» តបហើយក៏ឱនមុខចុះព្រោះអៀន។

«តោះឆាប់ក្រោកទៅ» គេប្រាប់ហើយក៏ក្រោកចេញពីអាងទើបគ្រានាងឲ្យក្រោកតាមក្រោយដើរទៅងូតទឹកផ្កាឈូកបន្ត មុននឹងជូតខ្លួនបីនាងទៅដាក់លើគ្រែ។

«ចាំបងជូតសក់ឲ្យ» ប្រាប់ហើយក៏យកកន្សែងមកជូតថ្នមៗ ស៊ូហ៊ី





ហួសចិត្តមិនគិតថាគេយកចិត្តទុកដាក់តាំងពីរឿងនេះទេ ជូតសក់រួចរាល់ហើយក៏រុញនាងឲ្យគេងរាបលើគ្រែតាមទៅថើបបបូរមាត់តូច ដៃក៏ចាត់ការបោសអង្អែលសព្វពេញរាងកាយស្ដើង គេអូសបបូរមាត់មកសាច់ស្មារថើបឈ្ងុសអស់ចិត្តរហូតមកដល់ដើមទ្រូង ដែលយល់ថាវាកាន់តែរីកធំជាងមុនព្រោះតែនាងមានទម្ងន់ គេថើបច្របាច់ថ្នមៗលិឍត្រលាស់ពីម្ខាងទៅម្ខាងដោយភាពថ្នាក់ថ្នម។

«អែលវិន បានហើយ» សំឡេងស្រួយបន្លឺឡើងតែគេមិនខ្វល់។

«បងកំពុងធ្វើឲ្យអូនមានក្ដីសុខ» គេងើបមកតបហើយក៏ឱនទៅវិញ

«បងកំពុងធ្វើឲ្យអូនរងារច្រើនជាង» គេញញឹមតិចៗបន្ទាប់ពីឮនាងនិយាយបែបនេះ ទើបអូសបបូរមាត់កាន់តែទាបទៅរហូតមកដល់ពោះដែលពេលនេះ មានសភាពទុងធំជាងមុខព្រោះតែជីវិតតូចក្នុងនោះកំពុងតែរីកលូតលាស់ជាលំដាប់។

«បន្តិចទៀតបានហើយ» តបហើយក៏ប្រើច្រមុះថើបសព្វផ្ទៃពោះរបស់នាងគេថើបផ្ចិតថ្នមៗតែក៏ធ្វើឲ្យនាងមានអារម្មណ៍ស្រៀវដូចគ្នា។

«បានហើយ ឆាប់គេងទៅ» គេប្រាប់ហើយក៏ប្រះខ្លួនក្បែរទាញនាងមកគេងកើយទ្រូងដោយក្ដីស្រលាញ់ ចង់ឲ្យរាត្រីបែបនេះមានជារៀងរហូត នាងគិតក្នុងចិត្តលូកដៃទៅឱបគេកាន់តែណែន។

«នៅមានរឿងមួយទៀតដែលបងមិនទាន់បានសួរអូន»

«រឿងអីមែនទេ?»

«ថ្ងៃមុនតាចាស់នោះមកនិយាយស៊ីជាមួយអូនខ្លះ?» គេនិយាយសំឡេងខឹងធ្វើឲ្យនាងនៅស្ងៀមរកនឹកមិនដឹងថាគេចង់និយាយពីអ្នកណា

ហើយក៏គិតឃើញពេលដល់ពីរនាក់ឪកូនកាលពីថ្ងៃមុន។

«គ្មានអីទេ» នាងតបតិចៗហើយក៏ឱបគេជាប់។

«ឆាប់ប្រាប់បងមក» គេកម្រើកខ្លួនតិចៗដើម្បីបានមើលមុខនាង។

«គេថានឹងឲ្យលុយអូនឲ្យច្រើន បើអូនព្រមទៅនៅជាមួយគេ» នាងតបហើយក៏ឱបគេយំ។

«អូនមិនចង់បានលុយទេ អូន...»

«បងដឹងហើយ កុំយំអី» គេឱបលួងលោមថើបថ្ពាស់នាងថ្នមៗ គាកញ្ចាស់នេះពិតជាហ៊ានមែនដែលមករកមនុស្សរបស់គេដល់ផ្ទះ ថែមទាំងនិយាយពាក្យទាំងនេះថែមទៀត ច្បាស់ជាដឹងគ្នាមិនខាន។

អែលវិន នាំនាងមកពិនិត្យសុខភាពនិងរាងកាយម្តងទៀតម្តងនេះគេលែងធ្វេសប្រហែស ទុកនាងឲ្យនៅម្នាក់ឯងដូចលើកមុនទៀតហើយ បន្ទាប់ពីពិនិត្យហើយពេទ្យក៏ប្រាប់ថាសុខភាពនាងប្រក្រតី ហើយក៏រឹងមាំអាចទទួលការះកាត់បានទើបគេមិនសូវបារម្ភ ព្រោះខ្លាចខ្លាំងជាងគេគឺមានការប៉ះពាល់ដល់កូនក្នុងផ្ទៃរបស់នាង។

«ឯងមកធ្វើអីទៀតហើយ?» ចាស៊ីន សួរអ្នកដែលទើបដើរចូលមកសំឡេងរឹងថែមទាំងសម្លឹងចុងភ្នែក។

«យើងចង់មកយ៉ាងម៉េច?» អែលវិន តបសំឡេងស្មើរដើរទៅអង្គុយលើតុធ្វើការអ្នកម្ខាងទៀតធ្វើមិនដឹង ឃើញមុខអ្នកម្ខាងទៀតនៅមានស្នាមកណ្តាប់ដៃនៅឡើយធ្វើឲ្យគេមានអារម្មណ៍ខុស ដែលលេងដៃធ្ងន់បន្តិចតែមកពីគេជាអ្នកលេងមុនធ្វើអី គិតហើយក៏លួចញញឹម។

«បើមកសើចចំអកយើងដដែល ឆាប់ទៅវិញទៅប្រយ័ត្នយើងសងសឹក» ចាស៊ីន ប្រាប់សំឡេងស្មើតែអ្នកម្ខាងទៀតញាក់ស្មារតីមិនខ្វល់មុននឹងតបទៅវិញ។

«សូមទោស ហើយក៏អរគុណឯងដែរ»

«យើងមិនទទួល ឆាប់ទៅវិញទៅ» ចាស៊ីន តបហើយក៏ឈ្ងោកធ្វើការងាររបស់ខ្លួនមិនចាប់អារម្មណ៍អ្នកម្ខាងទៀត។

«ចង់ត្រូវបន្ថែមមែនទេ ទើបមិនទទួល» អែលវិន និយាយហើយក៏ដើរសំដៅកៅអីរបស់មិត្ត។

«បើឯងហ៊ានវ៉ៃយើងទៀត យើងនិងនាំប្រពន្ធឯងទៅលាក់ទុក មិនឲ្យឯងបានជួបនាងរហូត» គេនិយាយសំឡេងម៉ឺងម៉ាត់ធ្វើឲ្យអ្នកម្ខាងទៀតត្រូវឈប់ស្ងៀមដូចគ្នា។

«សមមុខ ទីបំផុតយើងរកចំនុចខ្សោយរបស់ឯងបានហើយ ហាសហាស» ចាស៊ីន និយាយទាំងសើចចំអក អែលវិន ចង់តែស្ទុះទៅដាល់បន្ថែមទៀតទេ តែនឹកឃើញក៏ធ្វើឲ្យគេអស់សំណើចដូចគ្នា។

«ឈប់សើចទៅ អាចង្រៃមិនអ៊ីចឹងយើងនឹងវ៉ៃហើយ» អែលវិន ប្រាប់សំឡេងរឹងតែគេមិនខ្វល់គិតតែសើចមិនឈប់។

«អ្នកណាជាអ្នកនាំនាងទៅ ប្រាប់យើងមក» អែលវិន សួរសំឡេងស្មើរទើបធ្វើឲ្យគេឈប់សើច។

«មនុស្សស្រីម្នាក់ ឯងគួរប្រយ័ត្នផង»

«អ្នកណាគេ?»

«គិតមើលខ្លួនឯងទៅ ស្រីរបស់ឯងមានប៉ុន្មានអ្នក»

«អាចង្រៃ...» អែលវិន និយាយហើយក៏ដើរចេញមកវិញក្នុងចិត្ត

កំពុងតែគិតពីមនុស្សដែលមិត្តគេនិយាយមុននេះ។

ថ្ងៃនេះជាថ្ងៃវះកាត់របស់ ស៊ូហ៊ី មានអារម្មណ៍ភ័យខ្លាចតែក៏ព្យាយាមរម្ងាប់អារម្មណ៍របស់ខ្លួន ពេលគិតថាមានមនុស្សម្នាក់នៅក្បែរគេតែលួងលោមលើកទឹកចិត្តនាងរហូតធ្វើឲ្យនាងមានអារម្មណ៍កក់ក្តៅ។

«អែលវិន» ស៊ូហ៊ី ហៅតិចៗទាំងលើកដៃរាវរក ទើបគេលូកមកចាប់ដៃនាងជាប់ព្រោះដឹងថានាងខ្លាច។

«បងនៅទីនេះហើយកុំបារម្ភអី» គេព្យាយាមនិយាយលួងលោមទាញនាងមកឱបតែគេក៏ភ័យដូចគ្នា។

«ខ្ញុំខ្លាច បើវះកាត់ហើយនៅតែមិនឃើញវិញនោះ...»

«មិនអាចទេ ច្បាស់ជាមើលឃើញ ហើយទោះបីជាមើលមិនឃើញក៏បងនៅក្បែរអូនជានិច្ច ពួកយើងរស់នៅជាមួយគ្នាជាមួយកូន» គេឱបលួងលោម ទើបនាងស្រាំឱបតបជាប់បន្ថយអារម្មណ៍ភ័យខ្លាចមុននឹងចូលបន្ទប់វះកាត់។

ពីរម៉ោងកន្លងផុតការវះកាត់ក៏ត្រូវបញ្ចប់ នាងត្រូវសម្រាកមន្ទីរពេទ្យដើម្បីមើលអាការៈបន្តមួយរយៈ រហូតដល់ពេលវេលាសមល្មមដែលអាចដោះបង់រុំភ្នែករបស់នាងចេញបាន។

ពេលវេលាវះកាត់កន្លងផុតទៅ រហូតមកដល់ពេលដែលត្រូវបើកបង់ធ្វើឲ្យនាងចាប់ផ្តើមភ័យខ្លាចម្តងទៀត ខ្លាចមិនអាចមើលឃើញគិតហើយក៏លើកដៃរាវរកអ្នកម្នាងទៀត។

«កុំបារម្ភអី បងនៅទីនេះ» អែលវិន ប្រាប់តិចៗចាប់ដៃផ្តល់កំលាំងចិត្ត ទោះបីនាងមើលមិនឃើញក៏គេនៅមើលថែនាងជានិច្ច គេគ្មានថ្ងៃ







បោះបង់ចោលនាងនោះទេ។

ស៊ូហ៊ី សាកល្បងបើកភ្នែករបស់ខ្លួនបន្ទាប់ពីគ្រូពេទ្យបើកបង់រុំរួសចេញអ្វីគ្រប់យ៉ាងនៅតែស្ថិតក្នុងភាពងងឹត ក្តីសង្ឃឹមរបស់នាងទាំងអស់ត្រូវបាត់បង់ទាំងស្រុង គិតហើយក៏ធ្វើឲ្យទឹកភ្នែកនាងចាប់ផ្តើមហូរដូចដាក់ទំនប់ទើប អែលវិន ត្រូវទាញនាងមកឱប។

«អែលវិន ខ្ញុំមើលមិនឃើញទេ ហ៊ឺហ៊ឺ» នាងតបទាំងទឹកភ្នែកស្រាំឱបគេយ៉ាងខ្លាំង ឃើញនាងស្ថិតក្នុងសភាពបែបនេះធ្វើឲ្យបេះដូងរបស់គេចាប់ផ្តើមឈឺកាន់តែខ្លាំង ព្រោះរឿងទាំងនេះបណ្តាលមកពីគេ។

ស៊ូហ៊ី អង្គុយក្នុងសួនច្បារក្នុងភូមិគ្រឹះយ៉ាងស្ងៀមស្ងាត់ជាច្រើនថ្ងៃមកហើយដែលនាងតែងអង្គុយទីនេះ ងាកទៅណាក៏ឃើញតែភាពងងឹតធ្វើឲ្យនាងចាប់ផ្តើមមានអារម្មណ៍ធុញទ្រាន់ ម៉ូម៉ៅចង់រត់ចេញឲ្យឆ្ងាយតែពេលគិតដល់ជីវិតតូចក្នុងផ្ទៃ ធ្វើឲ្យនាងចាប់ផ្តើមរសាយកំហឹងមិនដឹងមូលហេតុទាំងនេះ។

«ជុប ជុប» សំឡេងថើបថ្ពាល់បន្លឺឡើងធ្វើឲ្យអ្នកដែលកំពុងអង្គុយស្លុងអារម្មណ៍ភ្ញាក់ព្រើតវាសដៃទៅរកអ្នកម្នាងទៀត។

«មកសំងំអង្គុយទីនេះទៀតហើយមែនទេ» អែលវិន និយាយហើយក៏ដាក់ខ្លួនអង្គុយក្បែរទាញនាងមកឱប។

«បងមកវិញហើយមែនទេ?» នាងសួរតិចៗ ទាំងញញឹមក្រៀមឃើញសភាពសោកសៅរបស់នាងធ្វើឲ្យគេចាប់ផ្តើមបារម្ភ។

«ហ៊ឹម! ទើបមកដល់ ពេញចិត្តក្លិនផ្កានេះទេ?» គេសួរទាំងកាន់បាច់ផ្កាមួយបាច់មកដាក់ពីមុខនាង ស៊ូហ៊ី ឱនទៅមុខ ដើម្បីស្រូបក្លិនជា



Scanned by CamScanner

ក្លិនផ្កាដែលនាងចូលចិត្តទើបលូកដៃទៅរាវរកហើយក៏ប៉ះបាច់ផ្កានោះ។

-ពេញចិត្តខ្លាំងណាស់ នេះជាផ្កាលីលីពណ៌ស៊ីជំពូរដែលអូនចូលចិត្ត អរគុណ- នាងប្រាប់ហើយក៏ងាកទៅអ្នកក្បែរខ្លួនចង់ថើបគេដើម្បីអរគុណតែមិនដឹងថាត្រូវធ្វើយ៉ាងម៉េច។

-ចង់អរគុណបងមែនទេ?- គេធ្វើសួរទើបនាងញញឹមបែបអៀន។

-ចាំបងធ្វើវិញ- ប្រាប់ហើយក៏ឱនទៅបិទបបូរមាត់ថើបជញ្ជក់លុកអណ្ដាតទៅមកដោយភាពពេញចិត្ត រហូតសំឡេងទូរស័ព្ទរោទ៍ក៏មិនចង់ឈប់ព្រោះតែបបូរមាត់នេះនៅតែផ្អែមសម្រាប់គេ។

-អ៊ែលវិន ទទួលទូរស័ព្ទសិនទៅ- ស៊ូហ៊ី ព្យាយាមប្រាប់ទាំងរុញរាងក្រាស់ចេញធ្វើឲ្យគេចាប់ផ្ដើមមុំមៅ ព្រោះមានអ្នកមកកាត់ចង្វាក់ទើបដាច់ចិត្តបញ្ឈប់ទាញទូរស័ព្ទមកមើលហើយក៏ត្រូវសម្រួលទឹកមុខ។

-អាឡូម៉ាក់-

(អ៊ែលវិន កូននៅឯណា?)

-នៅអង់គ្លេស ម៉ាក់មានអីមែនទេ?-

(ច្បាស់ជាមានហើយ ម៉ាក់ចង់ដឹងពត៌មានទាំងនោះតើពិតដែរទេ?)

អ៊ែលវិន ជួញចិញ្ចើមងាកមកមើលនារីក្បែរខ្លួន។

-ពត៌មានអីគេម៉ាក់?-

(ហើយកូនមិនដឹងទេឬ គេចុះផ្សាយថាកូនមានកូនដល់ទៅពីរនាក់ ម៉ាក់ចង់ឲ្យយល់ទៅហើយដឹងទេ បន្ទាប់ពីឮ សរុបទៅមិនមែនជារឿងពិតទេមែនទេ?)

-ពិតជាទទួលពត៌មានបានលឿនមែន- គេនិយាយលាយសើច។





(មានន័យថាម៉េចកូន នេះមានន័យថាជារឿងពិតមែនទេ?)

-បើម៉ាក់ចង់ដឹងមកមើលដោយផ្ទាល់ទៅ-

(ពិតជាយ៉ាប់មែនកូននេះ) សំឡេងក្នុងទូរស័ព្ទបន្លឺមកមុននឹងសំឡេងចុចផ្ដាច់បន្លឺឡើង ទើបគេងាកអ្នកក្បែរខ្លួនកំពុងមានទឹកមុខទូល់ខ្វាយគេស្មានដឹងថានាងកំពុងគិតអី តែសម្រាប់គេរឿងនេះជារឿងងាយស្រួលនោះទេ។

-ពួកយើងទៅបន្តក្នុងបន្ទប់ទៀតទៅល្អទេ- ប្រាប់ហើយក៏លើករាងស្ដើងបីសំដៅក្នុង។

-អ៊ែលវិន បានហើយ អ្ហា...- សំឡេងស្រែកប្រាប់លាយស្រៀវស្រើបថែមទាំងដៃប្រឹងរុញអ្នកម្ខាងទៀតចេញតែមិនបានសម្រេច ទាល់តែសោះគេរឹតតែវាយលុកធ្វើឲ្យនាងស្រែកថ្ងូរកាន់តែខ្លាំង។

-បន្តិចទៀតណា មិនទាន់បានទេ- គេងើបមកតបហើយក៏ឱនទៅវិញដៃទាំងសងខាងចាប់ភ្លៅទាំងពីរជាប់ បបូរមាត់ធ្វើការយ៉ាងសកម្មធ្វើឲ្យរាងស្ដើងរមួលខ្លួនទៅមកមិនឈប់ រហូតអស់ចិត្តទើបដកបបូរមាត់។

-បងកំពុងធ្វើឲ្យអូនស្រួលខ្លួនទេនោះអី- គេប្រាប់ហើយក៏ប្រះខ្លួនទៅក្បែរទាញអ្នកដែលកំពុងដង្ហើមដង្ហក់មកឱប នាងក្រមុំសាស្ងៀតទៅកាន់កាយកក់ក្ដៅមេះដូងគេលោតញាប់ ដឹងថាគេព្យាយាមទប់អារម្មណ៍របស់ខ្លួន គិតហើយក៏លួចញញឹមតែត្រូវគេដឹង។

-ឈប់ញញឹមទៅ បងដឹងថាអូនកំពុងសើចចំអកឲ្យយ៉ាងហ្នឹងហើយ ញ៉ាំម្ដងទៀត- គេប្រាប់ទាំងសើចហើយលើកដៃបុកច្រមុះនាងដោយក្ដីស្រឡាញ់ ព្រោះតែមិនអាចមើលឃើញធ្វើឲ្យនាងចង់ប៉ះ ទើបលើកដៃរបស់ខ្លួនប៉ះ

ដើមទ្រូងសសៀតិចទៅដល់ផ្ទៃមុខទើបគេចាប់ជាប់។

«អូនកំពុងធ្វើឲ្យបងក្ដៅខ្លួនទៀតហើយដឹងទេ» គេប្រាប់ហើយក៏ចាប់ដៃនាងមកថើប។

«អូនអាចស្ទាបមុខបងបានទេ?» គេសួរគេតិចៗទើបលើកដៃនាងមកប៉ះថ្ពាល់ពុកមាត់ត្រើមៗប៉ះដៃនាងទើបដកចេញយ៉ាងលឿន។

«ហេតុអីមិនកោរពុកមាត់ចេញ» នាសួរតិចទាំងលូកដៃទាំងពីរទៅស្ទាបម្ដងទៀត។

«មកពីបងរវល់ហ្នឹងណា ចាំអូនជាអ្នកកោឲ្យ» នាងក្រមុំស្ងៀមមួយរំពេចន៍នាងក៏ចង់បំពេញតួនាទីភរិយាដូចគ្នា តែនាងគ្មានលទ្ធភាពនោះទេ គិតត្រឹមនេះទឹកមុខចាប់ផ្ដើមស្រពោនធ្វើឲ្យ គេរាងស្រងាកចិត្តបន្តិចព្រោះមិនគួរនិយាយពាក្យនេះតែគេពិតជាចង់ឲ្យនាងធ្វើវាពិតមែន។

«កុំគិតច្រើនពេកឆាប់គេងទៅ» គេលួងនាងតិចៗមុននឹងទាញ មកឱបទើបនាងនៅស្ងៀម។

«អូននឹកកូន ចង់ជួបពួកគេខ្លាំងណាស់»

«បងដឹងហើយ ចាំស្អែកយើងខលទៅលេងពួកគេល្អទេ» នាងមិនតបគ្រាន់តែងក់ក្បាលដោយភាពរីករាយមុននឹងបិទភ្នែកគេង។

ស៊ូហ៊ី ភ្ញាក់ដឹងខ្លួននាពេលព្រឹកបើកភ្នែកជួបតែភាពងងឹតហើយក៏បិទទៅវិញរហូតឮសម្រឹបជើងដើរមកទើបបើកម្ដងទៀត។

«ភ្ញាក់ហើយមែនទេ តោះទៅងូតទឹក» សំឡេងដែលស៊ាំទម្លាប់បន្លឺឡើងធ្វើឲ្យអ្នកនៅលើគ្រែញញឹមតប យល់ថាមានអារម្មណ៍កក់ក្ដៅទោះភ្នែកមើលមិនឃើញតែអាចស្ដាប់ឮ តែមិនដឹងពេលវេលាបែបនេះមានរាង





រហូតដែរទេ នាងគិតក្នុងចិត្តទាំងសោកសៅរហូតរាងកាយត្រូវលើកឡើងទើបភ្ញាក់ព្រើតស្ទុះតោងអ្នកម្ខាងទៀតជាប់។

«កំពុងតែគិតអីទៀតហើយ ហឹម!» គេសួរតិចៗពេលដើរមកជិតដល់បន្ទប់ទឹក នាងគ្រាន់តែគ្រវីក្បាលតបមិននិយាយអ្វីទើបគេនៅស្ងៀមរិះគិត គេធ្លាប់ទៅជួបគ្រូពេទ្យចិត្តសាស្ត្រទាក់ទងផ្លូវចិត្តអ្នកពិការភ្នែកត្រូវការការមើលថែយកចិត្តទុកដាក់ជាពិសេស។

«អូនកំពុងគិតអីប្រាប់បងមកមើល»

«គ្មានអីពិតមែន» នាងតបសំឡេងស្រាលទាំងគ្រវីក្បាលតិចៗ។

«គ្រូពេទ្យប្រាប់ថាមិនអាចគិតច្រើនបានទេ ព្រោះអាចប៉ះពាល់ដល់កូនក្នុងផ្ទៃអាចនឹងទទួលសំពាធទាំងនេះដូចគ្នា ដូច្នេះទើបបងចង់ឲ្យអូននិយាយចេញមកកុំលាក់ទុកបានទេ?» គេនិយាយសំឡេងសោកសៅធ្វើឲ្យនាងធ្វើខ្លួនមិនត្រូវ។

«បើអូនសម្រាលកូនហើយ បងនឹងយកគេទៅហើយ បោះបង់អូនដែរទេ?» នាងសួរគេតិចៗទឹកភ្នែកក៏ចាប់ផ្ដើមហូរ អែលវិន នៅស្ងៀមសម្លឹងមុខនាងដោយក្ដីអាណិត នាងគិតខ្លាចរឿងនេះរហូតមកមែនទេ ពាក្យសម្ដីរបស់នាងធ្វើឲ្យគេនឹកឃើញទង្វើរបស់ខ្លួនកន្លងមកដែលបំបែកនាងពីកូនគិតរឿងនេះធ្វើឲ្យគេក្ដុកក្ដួលចិត្ត ទើបទាញនាងមកឱប។

«បងគ្មានថ្ងៃធ្វើបែបនោះដាច់ខាត លែងមានទៀតហើយបងសន្យា បងគ្មានថ្ងៃបោះបង់អូនជាដាច់ខាតមិនថាអូនក្លាយជាអ្វីនោះទេ ស្ដាប់បានទេឈប់គិតរឿងនេះតទៅទៀតគិតពីសុខភាពកូនផងណា» នាងមិនតបគ្រាន់តែងក់ក្បាលស្រាំឱបគេជាប់។



Scanned by CamScanner

អែលវិន នាំនាងមកញ៉ាំអាហារពេលព្រឹករួចរាល់មុននឹងទៅធ្វើការ ដោយដោះបញ្ហារុកផ្ទះមើលថែនាងឲ្យបានល្អ រហូតគេទៅពុកមើបរោង សុំបេផ្ទះឲ្យជូនទៅសួនផ្កាចំហៀងភូមិគ្រឹះ នាងក្រមុំអង្គុយលើស្មៅស្រូប ក្លិនផ្កាដែលខ្លួនចូលចិត្តធ្វើឲ្យមានអារម្មណ៍ស្រស់ស្រាយ មុននឹងប្រះខ្លួនគេងលើស្មៅពណ៌ខៀវស្រងាត់ តែសម្រាប់នាងមានតែភាពងងឹតនៅខាងមុខតែប៉ុណ្ណោះ គិតហើយដៃក៏សន្សឹមស្ទាបក្រោលស្មៅដែលទៅជិតខ្លួន រហូតបិទភ្នែកគេងលក់ មិនដឹងយូរប៉ុណ្ណានោះទេ រហូតមានអារម្មណ៍ពន្លឺថ្ងៃកំពុងតែជះចំផ្ទៃមុខ ទើបបើកភ្នែកមកមើលហើយក៏បិទទៅវិញព្រោះមានអារម្មណ៍ថាចាំងភ្នែក គិតត្រឹមនេះធ្វើឲ្យនាងទ្រឹងបន្តិចមុននឹងសាកបើកម្តងទៀត... ភ្លាមនោះមានអារម្មណ៍ថាអ្វីជុំវិញខ្លួនដែលធ្លាប់តែជាភាពងងឹតប្រែជាមានរូបរាងកាន់តែច្បាស់ជាលំដាប់ នាងព្រិចភ្នែកញាប់ស្អេកដោយភាពមឹងមាំង គិតថាខ្លួនកំពុងតែយល់សព្វច្រើនជាងទើបបិទភ្នែកទៅវិញ ស្របពេលឮសម្រឹបជើងដូចជារត់មកធ្វើឲ្យនាងត្រូវបើកភ្នែកមកមើលម្តងទៀត។

«ស៊ូហ៊ី អូនយ៉ាងម៉េចហើយ?» អែលវិន ស្រែកដោយភាពតក់ស្លុតស្ទុះចូលមកលើកគ្រានាងដោយភាពភ័យព្រួយ គេទើបមកពីធ្វើការមិនឃើញនាងនៅបន្ទប់ហើយក៏នាំគ្នាដើររកពេញផ្ទះទៅហើយ នៅតែមិនឃើញធ្វើឲ្យគេស្ទើរឆ្កួតទៅហើយ ហើយមកឃើញនាងនៅគេងលើស្មៅបែបនេះទៀតធ្វើឲ្យគេកាន់តែបារម្ភខ្លាចនាងមានរឿងអីកើតឡើង។

«ហេតុអីមកនៅត្រង់នេះដឹងថាបងតាមរកស្ទើរឆ្កួតទៅហើយ» គេឧទានតិចៗក្នុងន័យបន្ទោស ពិនិត្យមើលរាងកាយស្តើងដោយយកចិត្ត





ទុកដាក់ព្រោះខ្លាចប៉ះទង្គិចត្រង់ណាក។

នាងក្រមុំងាកមកសម្លឹងមើលអ្នកចំពោះមុខទឹកមុខភ័យព្រួយរបស់គេ ធ្វើឲ្យនាងមើលឃើញច្បាស់ខ្លាំងណាស់ នាងអាចមើលឃើញវិញហើយមើលឃើញពិតមែន នាងឧទានក្នុងចិត្តទឹកភ្នែកនៃភាពត្រេកអរស្រក់ចុះធ្វើឲ្យអ្នកម្ខាងទៀតព្រួយកាន់តែខ្លាំងទើបទាញនាងមកឱប។

«សូមទោស ដែលនិយាយឮមុននេះមកពីបងបារម្ភខ្លាំងពេក» គេប្រាប់តិចៗជិតត្រចៀកតូច នាងមិនតបគ្រាន់តែគ្រវីក្បាលទើបគេបន្ថែមកំលាំងឱបកាន់តែខ្លាំងជាងមុន។

«ពួកយើងទៅបន្ទប់វិញទៅ ទីនេះក្តៅណាស់» ប្រាប់ហើយក៏លើករាងស្តើងបីទើបនាងត្រូវស្រវាឱបករគេជាប់ ចង់ប្រាប់គេពីរឿងនេះតែគិតថាចាំមួយរយៈទៀតព្រោះចង់ដឹងពីគេឲ្យកាន់តែច្បាស់សិន។

នាងក្រមុំអង្គុយលើគ្រែ សម្លឹងមើលជុំវិញបន្ទប់ដើម្បីឲ្យប្រាកដចិត្តថាភ្នែកនាងពិតជាអាចមើលឃើញដូចដើម ហើយក៏ច្បាស់ពិតមែនរូបភាពទាំងនោះពិតជានៅចំពោះមុខនាងពិតមែន គិតហើយក៏សន្សឹមៗចុះពីគ្រែដើរទៅបើកបង្អួច ក្លិនក្រអូបពីសួនផ្ការហើរមកប៉ះច្រមុះទើបបិទភ្នែកស្រូបក្លិនទាំងនោះដោយភាពរីករាយ។

«ស៊ូហ៊ី ហេតុអីក៏ឈរទីនេះ?» អែលវិន ដែលទើបចេញពីបន្ទប់ទឹកសួរដោយការចម្លែកចិត្តព្រោះគិតថានាងគេងទៅហើយ សំឡេងរបស់គេធ្វើឲ្យនាងភ្ញាក់ព្រើតងាកទៅមើល។

«អឺ មកស្រូបក្លិនផ្កា» នាងតបហើយក៏ងាកមកវិញលួចសើចតិចៗទើបគេត្រូវដើរមកជិត មានអារម្មណ៍ប្លែកនិងខ្សែភ្នែករបស់នាងមុននេះតែ



Scanned by CamScanner

គំនៅស្ងៀមប្រហែលមកពីគេគិតច្រើន។

«ឆាប់ទៅគេងទៅយប់ហើយ ស្រួបកាលពីព្រឹកមិនទាន់ភ្លេចទៀតឬយ៉ាងម៉េច?» ប្រាប់ហើយក៏លូកដៃមកឱបចង្កេះនាងពីក្រោយដាក់មុខលើស្មារស្ទើងលួចថ្នក់ថ្ពាល់មួយខ្សឹតថែមទៀត។

«ចាំមើលកូនបងកើតមកញៀនផ្កា បងនឹងរករឿងអូនហើយ» គេនិយាយតិចៗលាយសើចហើយក៏លើករាងស្ទើងសំដៅគ្រែ។

អែលវិន ត្រូវធ្វើដំណើរទៅបរទេសគេមិនចង់ទៅនោះទេ ព្រោះតែបារម្ភពីរាងស្ទើងតែព្រោះការងារបន្ទាប់ទើបត្រូវទៅខានមិនបាន។

រថយន្តទំនើបមកឈប់ខាងមុខភូមិគ្រឹះ រាងស្ទើងស៊ិចស៊ីចុះពីរថយន្តដោយឫកពាឡូយឆាយសំដៅខាងក្នុង ប្រៀបដូចជាអ្នកស្គាល់ទីនេះច្បាស់ធ្វើឲ្យអ្នកទីនេះគ្រវីក្បាលហួសចិត្ត។

«អ្នកប្រុសមិននៅទេ» សំឡេងមេផ្ទះបន្លឺឡើងសម្លឹងអ្នកម្ខាងទៀតដោយខ្សែភ្នែកមិនពេញចិត្ត។

«ខ្ញុំមិនមែនមករកគេទេ ខ្ញុំចង់ជួបស្រីម្នាក់នោះ» ឡេណា ប្រាប់សំឡេងស្ទើរដើរទៅអង្គុយសាឡុងបែបហ៊ើ មេផ្ទះសម្លឹងមកដោយភាពហួសចិត្តហើយក៏ងឿងឆ្ងល់ព្រោះមិនដឹងនាងចង់ជួបអ្នកណា ស្របពេលក្រឡេកទៅឃើញរាងស្ទើងដើរចុះពីជណ្តើរ ធ្វើឲ្យគាត់បើកភ្នែកធំៗដោយភាពភ្ញាក់ផ្អើល។

«ពុទ្ធោអ្នកនាង ហេតុអីក៏ចុះមកតែឯងបែបនេះ» គាត់ឧទានទាំងឡើងទៅជួយគ្រានាងចុះមក ស៊ូហ៊ី រាងភ្ញាក់បន្តិចគិតថានាងមើលឃើញទើបចុះមកដោយខ្លួនឯងបាន ភ្លេចគិតពីរឿងនេះថាគ្មានអ្នកណាដឹង។





«សូមទោសអ៊ំគឺខ្ញុំចង់រៀនធ្វើអ្វីដោយខ្លួនឯង» នាងតបតិចៗទាំងញញឹមខ្មាស់ដាក់អ្នកម្ខាងទៀត។

«មិនបានទេ ចុះបើមានរឿងអីកើតឡើងវិញនោះ នេះបើអ្នកប្រុសដឹងអ្នកក្នុងផ្ទះនេះច្បាស់ជាស្លាប់មិនខានទេ» គាត់និយាយទាំងដង្ហើមធំ។

ឡេណា អង្គុយនៅសាឡុងសម្លឹងមើលដោយភាពជិនឆ្អន់ ខ្សែភ្នែកពេញដោយភាពស្អប់ខ្ពើម គួរឲ្យស្តាយដែលផែនការលោកមុនបរាជ័យកុំអីស្មានថានាងមានមុខមកឈរត្រង់នេះមែនទេ។

«អ៊ំមុននេះខ្ញុំឮដូចជាមានមនុស្សមកមែនទេ?» ស៊ូហ៊ី សួរតិចៗទាំងដឹងថាជាអ្នកណាហើយក៏ឃើញច្បាស់ផងដែរ។

«គឺខ្ញុំមានរឿងចង់និយាយជាមួយនាង សង្ឃឹមថានៅចាំខ្ញុំបាន» សំឡេង ឡេណា បន្លឺឡើងទាំងសម្លឹងមកអ្នកម្ខាងទៀតដោយភាពឈ្នានីស ស៊ូហ៊ី ឈរទ្រឹងធ្វើខ្សែភ្នែកត្រង់ដូចមនុស្សពិការព្រោះមិនចង់ឲ្យគេដឹង មានអារម្មណ៍សំឡេងនេះដូចជាប្រហែលៗ។

«ខ្ញុំចង់និយាយជាមួយនាងតែពីរនាក់» ឡេណា ប្រាប់សំឡេងរឹងទាំងសម្លឹងទៅមេផ្ទះចំណាស់ ពេលឃើញគាត់ឈរជិតអ្នកម្ខាងទៀតបន្ទាប់ពីគ្រានាងមកអង្គុយលើសាឡុង គាត់ងាកទៅសម្លក់អ្នកម្ខាងទៀតបន្តិចមុននឹងដើរចេញ។

«គ្រាន់តែជាមនុស្សស្រីពិការភ្នែកម្នាក់ គិតថាអស្ចារ្យណាស់មែន
ទេ?» សំឡេងអ្នកម្ខាងទៀតអ៊ូតិចៗតែក៏អាចស្តាប់ឮ។
«អ្នកនាងមានការអី និយាយមក» ស៊ូហ៊ី ប្រាប់សំឡេងស្មើ។
«នាងដឹងហើយថាប៉ាខ្ញុំនឹងគេកំពុងតែបង្កើតមុខរបរជាមួយគ្នា ហើយក៏

កំពុងគិតគូរពីរឿងភ្ជាប់ទំនាក់ទំនងរវាងពួកយើងដូចគ្នា ហើយអាចនិងរៀបការក្នុងពេលឆាប់ៗថែមទៀត នាងគ្រាន់តែជាម្ដាយកូនរបស់គេជាមនុស្សស្រីធម្មតាគ្មានអីទាំងអស់ថែមទាំងពិការបែបនេះទៀត គិតថាគេនិងទុកនាងយូរប៉ុណ្ណា!.. ឡេណា និយាយទាំងពេបមាត់បែបចំអក។

ស៊ូហ៊ី នៅស្ងៀមព្យាយាមរម្ងាប់អារម្មណ៍ដឹងថានាងនិងគេខុសគ្នាឆ្ងាយណាស់ដូចមេឃនិងដី តែនាងស្រលាញ់គេចង់នៅក្បែរគេចង់ឲ្យគេមើលថែនាងដូចគ្នា ហើយក៏ដឹងថាខ្លួនឯងជាបន្ទុករបស់គេថែមទៀត។

ស៊ូហ៊ី ឈរមាត់បង្អួចសម្លឹងមើលទេសភាពជុំវិញភូមិគ្រឹះ ដោយភាពសោកសៅលើកដៃអង្អែលពោះថ្នមៗ។

-អ៊ុនហ៊ី ពួកយើងចាកចេញពីទីនេះល្អទេ ម៉ាក់ដឹងថាម៉ាក់មិនល្អបោះបង់កូន តែទីនេះមានចាំមើលថែបងប្រុសបងស្រីហើយពួកយើងកុំនៅទៀតអីណា.. និយាយហើយក៏យំ អែលវិន តែងនាំនាងទៅពិនិត្យសុខភាពជានិច្ចដឹងថាជាកូនស្រីទើបជ្រើសដាក់ឈ្មោះនេះ។









Scanned by CamScanner

...ភាគបញ្ចប់...

មាត់ផ្ទេរនាពេលព្រឹក ទេសភាពស្រស់ស្រាយជាទីពេញចិត្តរាង ស្តើងមួយរុបដើរទប់ពោះបណ្តើរ ផ្លៀតឱនរើសសំបកខ្យងបណ្តើរមើលទៅ នាងមានភាពរីករាយនិងអ្វីដែលខ្លួនធ្វើ ដោយមិនដឹងថាមានអ្នកណាម្នាក់កំពុងឈរមើលនាងនោះទេ។

«ដើរលេងផ្តេកនៅ?» សំឡេងគ្រលរបន្លឺឡើងខាងក្រោយធ្វើឲ្យអ្នកដើរឈប់ឆ្ងក់ឈរទ្រើងមិនហ៊ានងាកមកនោះទេ នាងចាំសំឡេងនេះច្បាស់ណាស់ដឹងថាជាអ្នកណា គឺគេ គេមកតាមនាងមែនទេ នាងសួរក្នុងចិត្តគិតហើយក៏ដើរទៅមុខយ៉ាងលឿន។

«ជាក ស៊ូហ៊ី ឆាប់ឈប់ភ្លាមអូនចង់រត់ទៅណា ហ្អាស» អែលវិនស្រែកបណ្តើរដើរបណ្តើរព្រោះនាងពោះធំដើរមិនលឿននោះទេ។

«បងប្រាប់ឲ្យឈប់ស្តាប់ឮដែរទេ» គេស្រែកម្តងទៀតស្ទុះទៅចាប់ដៃនាងឲ្យបែរមកប្រឈម នាងក្រមុំងាកមុខចេញបង្ហូរទឹកភ្នែកមិនហ៊ានមើលមុខគេនោះទេ។

«រត់ចោលប្តីនិងកូន សប្បាយខ្លាំងណាស់មែនទេ?» គេសួរសំឡេងស្ទើរតែក្នុងចិត្តមានអារម្មណ៍ឈឺខ្លាំងណាស់ ដែលនាងមិនព្រមជឿគេសូម្បីតែបន្តិចនៅតែចាកចេញពីគេថែមទៀត គេក្រឡប់ពីបរទេសមកដល់ក៏បាត់នាង បេះដូងគេស្ទើរប្រេះទៅហើយគិតថានាងអាចមានគ្រោះថ្នាក់តែក្រោយមកក៏ដឹងថានាងមកកូរ៉េ កាន់តែធ្វើឲ្យគេងឿងឆ្ងល់ថែមទៀត ព្រោះភ្នែករបស់នាងងងឹត ពេលនេះគេដឹងច្បាស់ហើយដឹងថានាងរៀបគំរោងចង់ចាកចេញពីគេ ថែមទាំងលាក់បាំងរឿងភ្នែកភ្លឺថែម





ទៀតគេគិតទាំងតូចចិត្ត។

«បងដឹងថាបងជាមនុស្សអាក្រក់ធ្លាប់ធ្វើបាបអូន តែសូមអង្វរកុំទៅចោលបងទៀតបានទេ ត្រឹមតែពីរដងមកនេះបងស្ទើរស្លាប់ស្ទើររស់ទៅហើយ ទុកឱកាសឲ្យបងកែខ្លួនបានមើលថែអូននិងកូនផងបានទេ» គេនិយាយមុខស្ងួតសម្លឹងមើលនាងដោយខ្សែភ្នែកគួរឲ្យអាណិត។

នាងក្រមុំនៅស្ងៀម សម្លឹងមើលគេដោយខ្សែភ្នែកមិនអាចមើលដឹង គេផ្លាស់ប្តូរខ្លាំងណាស់ផ្លាស់ប្តូរហេតុនាងមិនចង់ជឿ។

«សូមអង្វរលើកលែងទោសឲ្យបង ផ្តល់ឱកាសឲ្យបងបានទេ?» គេនិយាយទាំងមុខស្រពោនសម្លឹងមើលនាងចាំស្តាប់ចម្លើយ។

«ខ្ញុំមិនធ្លាប់ខឹងបងទេ អ្វីដែលធ្លាប់ជួបកន្លងមកខ្ញុំគ្រាន់តែគិតថាវាជាវាសនារបស់ខ្ញុំតែប៉ុណ្ណោះ» ពាក្យសម្តីរបស់នាងធ្វើឲ្យគេញញឹមតិចៗទាញនាងមកឱប ស្រីម្នាក់នេះល្ងង់ខ្លាំងណាស់គេធ្វើបាបនាងដល់ថ្នាក់នេះហើយ នៅមិនស្អប់ខឹងថែមទៀតបែរជាគិតទៅរឿងវាសនាទៅវិញ។

«បងស្រលាញ់អូន ស្តាប់បានទេ បងស្រលាញ់អូន ហាមចាកចេញពីបងទៀត ទោះបីជាអូនរត់ទៅដល់ជើងមេឃក៏បងតាមយកមកវិញដែរឮដែរទេ» គេនិយាយលាយស៊ើចរឹតរង្វង់ដៃឲ្យណែនជាងមុន នាងក្រមុំមិនតបបានត្រឹមញញឹមទាំងទឹកភ្នែក។

«ក្រែងបងជិតរៀបការនោះអី» អែលវិន ជ្រួញចិញ្ចើមស្នាមញញឹមមុននេះរលប់បាត់បន្ទាប់ពីឮ ទើបរុញរាងស្តើងចេញតិចៗ។

«អូននិយាយអី អ្នកណាប្រាប់?» គេសួរសំឡេងរឹង។

«គឺអ្នកនាង ឡេណា នាងប្រាប់ថា...»



Scanned by CamScanner

-កុំជឿសម្ដីស្រីម្នាក់នោះ បងនិងនាងគ្មានទំនាក់ទំនងអីនោះទេ បើនិយាយពីមុខជំនួញបងដកហ៊ុនចេញពីពួកគេអស់ហើយ អូនមិនដឹងឬយ៉ាងម៉េចកាលអូនត្រូវចាប់ទៅលើកមុនជាស្នាដៃរបស់នាង ស្រីម្នាក់នោះពិសពុលខ្លាំងណាស់រួមទាំងឪពុកនាងដែរ បងចាត់ការពួកគេរួចហើយ អូនកុំបារម្ភអី- ស៊ូហ៊ី នៅស្ងៀមសម្លឹងមើលមុខគេភ្លឹះៗ មុននឹងលើកដៃទៅប៉ះថ្ពាល់របស់គេថ្នមៗ នាងពិតជានឹកគេខ្លាំងណាស់ប៉ុន្មានថ្ងៃមកនេះ ថែមទាំងឃើញមុខគេច្បាស់បែបនេះទៀត។

-បងមិនទាន់ដាក់ទោសអូននៅឡើយទេ ដែលមនប្រាប់បងពីរឿងអូនមើលឃើញវិញនោះ- គេប្រាប់តិចៗធ្វើឲ្យនាងសើចដាក់ដៃចុះមកវិញតែត្រូវគេចាប់ទៅថើបជាប់។

-ពួកយើងត្រឡប់ទៅវិញទៅ ដឹងថាពួកកូននឹកអូនប៉ុណ្ណាដែរទេ បងក៏នឹកអូនស្ទើរស្លាប់ដូចគ្នា- គេនិយាយតិចៗសម្លឹងមកនាងដោយខ្សែភ្នែកអង្វរទើបងាកងក់ក្បាលតប បែបនេះធ្វើឲ្យស្នាមញញឹមនៃសេចក្ដីសុខបង្ហាញឡើងមក ហើយក៏លោទៅថើបមាត់នាងជាប់ជាការថើបដ៏ផ្អែមល្ហែមថ្នាក់ថ្នមយ៉ាងជក់ចិត្តមិនខ្វល់ពីអ្វីជុំវិញខ្លួននោះទេ។

-អាហេម ដូចជាផ្អែមល្ហែមដល់ហើយបងស្រីខ្ញុំ មិនខ្មាសអ្នកណាគេសោះ- សំឡេងបន្លឺឡើងខាងក្រោយធ្វើឲ្យអ្នកដែលកំពុងថើបគ្នាជក់ចិត្តឈប់ឆ្ងក់ ស៊ូហ៊ី មានអារម្មណ៍ខ្មាសប្អូនប្រុសទើបជ្រប់មុខដើមទ្រូងរឹងមាំជាប់ព្រោះនាងមិនធ្លាប់បង្ហាញភាពស្និទ្ធស្នាលបែបនេះនោះទេ។

-ជារឿងប្ដីប្រពន្ធគេ កុំមករចេះ- អែលវីន ងាកមកស្ដីតបពេលឃើញថាជាអ្នកណាហើយក៏ឱបរាងស្ដើងជាប់ ដូយ៉ុង បានត្រឹមញញឹម







មានអារម្មណ៍សប្បាយចិត្តដែលបងស្រីរបស់គេមានសុភមង្គល។

«មកតាមគាត់ទៅវិញមែនទេ ឆាប់ទៅលឿនៗទៅ» ដូយ៉ុង ប្រាប់ទាំងញាក់ភ្នែកដាក់អ្នកម្ខាងទៀត ធ្វើឲ្យអ្នកដែលជ្រប់មុខត្រូវងើបមកយ៉ាងលឿនបន្ទាប់ពីឮ។

«ឯងចង់ដេញបងមែនទេ?» ស៊ូហ៊ី សួរតបទាំងសម្លក់ប្អូនប្រុសមិនដាក់ធ្វើឲ្យគេអស់សំណើច។

«មិនបានដេញគ្រាន់តែប្រាប់ ពិបាកមែនមនុស្សស្រីមានផ្ទៃពោះរំអក់រំអួនច្រើនមែនទែន» គេនិយាយហើយក៏ដើរចេញទុកឲ្យនាងនៅធ្វើមុខក្រញ៉ូវហើយក៏ងាកមកសម្លក់អ្នកក្បែរខ្លួនដែលកំពុងសើចដូចគ្នា។

«បានហើយគោះពួកយើងទៅវិញទៅ ដឹងថាមិនបានគេងឱបអូននឹងកូនបងវេទនាប៉ុណ្ណាទេ?» ប្រាប់ហើយក៏លើករាងស្ដើងមកប៉ីមុននឹងដើរសំដៅឡានដែលឈប់ចាំ។

........................

«ម៉ាក់/ម៉ាក់» សំឡេងស្រែកហៅដោយភាពត្រេកអរ ថែមទាំងរត់សំដៅទៅយ៉ាងលឿនធ្វើឲ្យអ្នកជាប៉ាត្រូវរត់មកទទួលជាមុន ព្រោះខ្លាចធ្វើរាងស្ដើងដួលព្រោះតែកំលាំងរត់បុករបស់ពួកគេ។

«ម៉ាក់ទើបមកពីណា អាយរីន នឹកម៉ាក់ណាស់» សំឡេងក្មេងស្រីតូចបន្លឺឡើងទាំងលោទៅថើបថ្ពាល់ម្ដាយដោយក្ដីនឹករឭក។

«ខ្ញុំក៏នឹកម៉ាក់ដូចគ្នា» អេរិច និយាយទាំងឡើងមកអង្គុយលើភ្លៅប៉ារបស់គេដើម្បីបាននៅជិតម្ដាយដូចគ្នា។

-សូមទោសមកពីម៉ាក់រវល់ទើបមិនបានមកជួបកូន ពេលនេះម៉ាក់មកហើយម៉ាក់លែងទៅណាទៀតហើយ សប្បាយចិត្តដែរទេ?»

«សប្បាយចិត្តខ្លាំងណាស់» ពួកគេតបព្រមគ្នាទាំងលោទៅថើបថ្ពាល់នាងម្ខាងម្នាក់ ហើយក៏លោទៅថើបប៉ាគេម្ខាងម្នាក់។

-នៅមានប្អូនម្នាក់ទៀត» អែលវិន ប្រាប់ទាំងលើកដៃទៅស្ទាបពោះរបស់នាងធ្វើឲ្យពួកគេនាំគ្នាសម្លឹងមើលដោយភាពរីករាយ។

-ប្អូននៅទីនេះមែនទេ?» នាងតូចសួរទាំងលូកដៃទៅស្ទាប។

-ត្រូវហើយប្អូននៅទីនេះ» ស៊ូហ៊ុ តបកូនទាំងងាកទៅមើលគេដែលកំពុងមើលមកនាងដូចគ្នា ស្នាមញញឹមពោរពេញដោយសុភមង្គលបង្ហាញលើផ្ទៃមុខ ទើបទាញពួកគេមកឱបរួមគ្នា ថែមទាំងលោទៅថើបថ្ពាសម្តងម្នាក់ៗ ទាំងអ្នកម៉ាក់កូនទាំងពីរ ពិតជាមានក្តីសុខខ្លាំងណាស់គេគិតក្នុងចិត្តស្របពេលរថយន្តមកឈប់ចតខាងមុខភូមិគ្រឹះ។

អែលវិន ចុះមកក្រឡេកមើលរថន្តផ្សេងទៀតដែលឈប់ខាងមុខគេផ្ញើញចិញ្ចើមបន្តិមុននឹងចូលទៅក្នុងវិញ។

-អូននៅទីនេះសិនហើយ ចាំតិចទៀតចាំចុះទៅណា» គេប្រាប់ហើយកចុះទៅនាំកូនទាំងពីនាក់ចុះទៅដែរ នាងក្រមុំងឿងឆ្ងល់តែក៏ធ្វើតាមដោយអង្គុយស្ងៀមសម្លឹងមើលទៅពួកគេដើរចេញទៅ។

-សួស្តី ម៉ាក់អញ្ជើញមកដល់យូរហើយមែនទេ?» អែលវិន សួរទាំងញញឹមដើរទៅថើបថ្ពាល់គាត់យកចិត្ត។

-ម៉ាក់មកដល់យូរហើយ ដឹងថាម៉ាក់មកព្រោះរឿងអីហើយមែនទេ ល្មមប្រាប់បាននៅ ដឹងថាម៉ាក់ខ្វល់ចិត្តប៉ុណ្ណាដែរទេព្រោះតែរឿងកូន» អ្នក





ស្រី សុងហ៊ី និយាយទាំងសម្លក់កូនប្រុសដោយភាពក្តាញ់ តែគេបែរជាធ្វើដូចគ្មានរឿងអ្វីទៅវិញ អែលវិន ឈប់ញញឹមងាកទៅញាក់ភ្នែកដាក់អ្នកនៅមាត់ទ្វារឲ្យចូលមកបន្ទាប់ពីដាក់ម៉ូគ្នារួចរាល់។

«ប៉ាៗ» សំឡេងក្មេងទាំងពីររត់មកឱបកូនប្រុសធ្វើឲ្យស្ត្រីចំណាស់ត្រូវស្ងៀមទ្រឹងសម្លឹងមើលពួកគេមិនដាក់ភ្នែក មុននឹងងាកទៅមើលកូនប្រុសដែលកំពុងសើចសប្បាយ។

«អេរិច អាយវីន រាក់ទាក់លោកយាយទៅ»

«សួស្តី លោកយាយ»

«សួស្តី លោកយាយ» ពួកគេរាក់ទាក់ទាំងខិនតោរពគួរឲ្យស្រលាញ់ មើលមុខពួកគេគឺដូចកូនប្រុសគាត់មិនខុសទេ គិតហើយក៏គ្រវីក្បាលហួសចិត្ត ព្រោះនៅសុខៗមានចៅធំប៉ុណ្ណឹងទៅហើយ តែគួរតែសប្បាយចិត្តទើបត្រូវ ព្រោះគាត់តែងតែតឿនកូនប្រុសរៀបការព្រោះចង់បានចៅដូចគ្នា។

«ចាសសួស្តី» គាត់តបទាំងទាញពួកគេមកអង្គុយលើភ្លៅមើលមុខពួកគេយូរៗទៅមានអារម្មណ៍ដូចនណាម្នាក់ទៀត គិតរឿងនេះក៏ងាកមើលជុំវិញខ្លួនព្រោះមិនឃើញម៉ាករបស់ពួកគេ។

«ចុះម៉ាក់ចៅទៅណាហើយ» គាត់សួរតិចៗ ទើបពួកគេងាកទៅមើលអ្នកជាប៉ាដែលកំពុងញញឹមមិនឈប់នោះ ទើបគាត់ងាកទៅតាម។

«ចាំបន្តិចម៉ាក់» គេប្រាប់ហើយក៏ក្រោកចេញទៅធ្វើឲ្យអ្នកជាម៉ាក់តាមសម្លឹងមើលមិនឈប់ ព្រោះមិនដឹងកូនប្រុសគាត់ទៅធ្វើបាបកូនស្រីអ្នកណានោះទេរហូតមានកូនប៉ុណ្ណឹងទៅហើយ នេះត្រូវសាពគមិនតាមរក

រឿងទៅហើយទេ កាត់គិតទាំងខ្វល់ខ្វាយស្របពេលឃើញគេដើរកាន់ទាំងដឹកដៃនារីម្នាក់មកថែមទៀត។

«មកដល់ហើយម៉ាក់» គេប្រាប់ទាំងទាញរាងស្តើងដែលដើរក្រោយឡើងមកខាងមុខ ស៊ូហ៊ី ទាក់ទើមិនចង់ចុះពីឡាននោះទេពេលដឹងថាគេនាំនាងមកជួបម៉ាក់គេ ព្រោះនាងនឹកឃើញពាក្យសម្តីគាត់ពីលើកមុនគិតថាគាត់អាចមិនពេញចិត្តដែលនាងក្លាយជាកូនប្រសារ។

អ្នកស្រី សុងហ៊ី បើកភ្នែកធំៗដោយភាពភ្ញាក់ផ្អើលពេលឃើញនាងតិចហើយក៏ងាកទៅមើលមុខកូនប្រុសក្នុងន័យសួរបញ្ជាក់ ព្រោះមិនគួរឲ្យជឿនិងអ្វីដែលបានឃើញ។

«សួស្តី អ៊ំស្រី» ស៊ូហ៊ី រាក់ទាក់តបហើយក៏ឱនមុខចុះពេលឃើញទឹកមុខផ្លាស់ប្តូររបស់គាត់។

«មានន័យយ៉ាងម៉េច អែលវិន» គាត់សួរកូនប្រុសសំឡេងស្មើថែមទាំងសម្លឹងមុខគេទ្រឹង ធ្វើឲ្យគេដឹងថាម៉ាក់គេកំពុងតែចង់ធ្វើសង្គ្រាមជាមួយគេហើយ។

«ស៊ូហ៊ី ជាម៉ាក់របស់ អេរិច និងអាយរីន»

«ម៉ាក់ដឹងហើយ តែឯងមិនមែនចង់...»

«ហើយនាងក៏ជាប្រពន្ធខ្ញុំដែរ» គេតបបន្ថែមកាន់ដៃនាងយ៉ាងណែនព្រោះដឹងថានាងកំពុងខ្លាច។

«ជាប្រពន្ធ តែម៉ាក់បានជ្រើសមនុស្សស្រីដែលសក្តិសមសម្រាប់ឯងរួចហើយ»

«ខ្ញុំមិនត្រូវការស្រីណាទាំងអស់ ក្រៅពីស្រីម្នាក់នេះ» គេប្រាប់ទាំង





ទាញនាងក្រមុំបកទៅពីក្រោយធ្វើឲ្យអ្នកជាម្តាយគេនិយាយអ្វីមិនរួច។

«ឯងមានវីបញ្ជាក់ថានាងជាប្រពន្ធពេញសិទ្ធរបស់ឯងនោះ» អ្នកស្រី សុងហ៊ី សួរបង្អាប់ស្នាមញញឹម ធ្វើឲ្យគេនៅស្ងៀមទ្រឹងបន្ទាប់ពីឮហើយក៏ងាកទៅសម្លឹងមើលនារីក្បែរខ្លួនមុននឹងងាកទៅតបម្តាយ។

«ស្អែកពួកខ្ញុំនឹងទៅចុះអាពាហ៍ពិពាហ៍ ស៊ូហ៊ី ជាប្រពន្ធខ្ញុំម្នាក់គត់ ខ្ញុំមិនរៀបការជាមួយស្រីណាទាំងអស់ក្រៅពីនាង» សម្តីម៉ឺងម៉ាត់របស់កូនប្រុសធ្វើឲ្យអ្នកជាម្តាយញញឹមចេញមកដោយភាពរីករាយ មុននឹងងាកទៅមើលអ្នកចំពោះមុខ ដែលកំពុងតែមានទឹកមុខសោកសៅ។

«ស៊ូហ៊ី មកនេះមក» គាត់ហៅតិចៗធ្វើឲ្យនាងងើបមុខមកមើលហើយក៏ងាកទៅមើលអ្នកក្បែរខ្លួនសុំយោបល់។

«ម៉ាក់ចង់ធ្វើអី?» គេសួរហើយក៏ទាញនាងមកឱបជាប់ហ្មត់អ្នកជាម្តាយគ្រវីក្បាលហួសចិត្តមិនគិតថាកូនប្រុសរបស់គាត់ ហួងហែងនាងដល់ថ្នាក់នេះនោះទេ។

«ម៉ាក់មានរឿងចង់និយាយជាមួយកូនប្រសារម៉ាក់ យ៉ាងម៉េច?» គាត់សួរតបទាំងសើចដើរមកដឹកដៃនាងចេញទៅ ធ្វើឲ្យគេចាប់ផ្តើមប្រហុកប្រហល់ពីការផ្លាស់ប្តូររបស់គាត់។

«អ៊ំស្រីខ្ញុំ...»

«នៅហៅអ៊ំស្រីទៀតមែនទេ គួរតែម៉ែមែន» គាត់ប្រាប់តិចៗទាំងសើចពេលដឹកដៃនាងមកដល់សួនផ្កា ហើយក៏ធ្វើឲ្យនាងស្មានមិនត្រូវពីទង្វើរបស់គាត់ទើបសម្លឹងមុខភ្លឺះៗ។

«ខ្ញុំសូមទោស» នាងតបតិចៗទាំងឱនមុខចុះទើបគាត់លូកដៃទៅ



Scanned by CamScanner

[illegible]។

-[illegible]។

-[illegible]។

-[illegible]។

-[illegible]។

-[illegible]?-

-[illegible]-

-ពិតជាយ៉ាប់មែនកូនអ្នកនេះ [illegible]?- នាង[illegible] ព្រោះគេកំណាចហើយក៏[illegible]។

-បើពិបាកឆ្លើយមិនបាច់ឆ្លើយទេ- គាត់ប្រាប់ហើយក៏នាំនាងដើរទៅក្នុងវិញ ធ្វើឲ្យអ្នកដែលអង្គុយក្នុងបន្ទប់ទទួលភ្ញៀវលេងជាមួយកូនទាំងពីរត្រូវងើបមកទទួលយ៉ាងលឿន។



-នាំគ្នានិយាយរឿងអីខ្លះទេ?- [illegible] ម៉ាំងត្រាមក អង្គុយសាឡុងម្ដងទៀត ព្រោះគាត់កំពុងតែជក់លេងជាមួយចៅទាំងពីរ។

-គ្មានអីទេ- នាងតបតិចៗហើយក៏ងាកទៅញញឹមស្រស់ដាក់ស្រីចំណាស់ធ្វើឲ្យគាត់ងាកមកសម្លក់កូនប្រុសកំពូលខិល ដឹងថាម៉ាក់គេនិងនាងច្បាស់ជាមានអីលាក់បាំងជាមិនខានទេ។

-ម៉ាក់ខ្ញុំនាំ ស៊ូហ៊ី ទៅសម្រាកហើយព្រោះធ្វើដំណើរឆ្ងាយប្រហែលហត់ កូនខ្ញុំក៏ត្រូវការសម្រាកដែរ- គេប្រាប់ទាំងគ្រាងខ្សឹក[illegible] ធ្វើឲ្យអ្នកម្ដាយភ្លៀតមកសម្លក់ម្ដងទៀត ដឹងថាកូនប្រុសច្បាស់[illegible] ព្រោះគាត់ជាអ្នកចិញ្ចឹមផ្ទាល់ដៃ។

-ច្បាស់ហើយថានាំនាងទៅសម្រាក?- គាត់[illegible] ញញឹមសងធ្វើឲ្យគេញញឹមតបម៉ាក់គេពិតជាប៉ិនល្បើសម្រើ[illegible]

-បាទម៉ាក់- តបហើយក៏នាំគ្នាដើរទៅ ទើប[illegible] ឲ្យស្រលាញ់ទាំងពីរដែលអង្គុយក្បែរ។

ក្នុងបន្ទប់សម្រាកជាន់លើ គេបីនាងមកដាក់[illegible] ការខោអាវស្ដើងលើខ្លួនរហូតអស់ទាំងពីរនាក់។

-បង បងធ្វើអីហ្នឹង- នាងសួរតិចៗទាំងយក[illegible] របស់ខ្លួនមុខក៏ចាប់ផ្ដើមក្រហមតិចៗដែរធ្វើឲ្យគេញញឹម[illegible]។

-ដាក់ទោសដែលរត់ចោលបង- គេតបហើយក៏[illegible] លើថ្ពាល់ម្ដងៗព្រោះខ្លាចប៉ះពាល់ពោះនាង បាត់ដៃក្ដៅ[illegible] ទាំងពីរច្របាច់ថ្មមៗធ្វើឲ្យនាងចាប់ផ្ដើមថ្ងូរ។

-មិនបានទេ- នាងតបទាំងចាប់ដៃគេចេញ [illegible]

គេចាប់ឲ្យបែរមកវិញឱនទៅទល់ថ្ពាស់ភ្នែកទល់ភ្នែកច្រមុះទល់ច្រមុះ។

«មិនអាណិតបងទេឬយ៉ាងម៉េច ច្រើនខែហើយណា» សំឡេងស៊ុច ស៊ុបខ្សឹបឡើងរួមទាំងទឹកមុខគួរឲ្យអាណិតរបស់គេ ធ្វើឲ្យនាងចាប់ផ្តើមធ្វើខ្លួនមិនត្រូវដឹងថាគេព្យាយាមទប់អារម្មណ៍កន្លងមកព្រោះតែនាង ឃើញអ្នកម្ខាងទៀតកំពុងតែលង់និងភាពអង្សរបស់គេទើបផ្អៀក ឱនបបូរមាត់ទៅគ្រប់គ្រងចុងស្រួចទើបលើកដៃគោងករគេជាប់។

-អែលវិន កូន...»

-បងដឹងហើយ បងនឹងធ្វើថ្នមៗល្អទេ» គេងើបមកតបហើយក៏ឱនទៅវិញដឹងថាគេកំពុងត្រូវការនាងខ្លាំង ទើបមិនជំទាស់ព្រោះនាងក៏ត្រូវការគេដូចគ្នា គេអូសបបូរមាត់មកដល់ពោះមុននឹងចុះទាបទៅ ទើបញែកជើងត្រៀមទទួលភាពសុខស្រួលដែលគេផ្តល់ឲ្យ។

-អ៊ុំា អែលវិន កូន...» សំឡេងស្អកនិយាយដាច់ៗព្រោះកំពុងតែស្រៀវស្រើបប្រាប់អ្នកម្ខាងទៀតដែលកំពុងវាយលុកខ្លាំងៗ ទើបគេត្រូវបន្ថយល្បឿនព្រោះតែភ្លេចខ្លួន។

«បងដឹងហើយ» តបហើយក៏វាយលុកបន្ត រហូតសំឡេងស្រែកតំកាមដោះលែងអារម្មណ៍បន្លឺឡើង ទើបប្រះខ្លួនគេងផិតរាងស្តើងទាញនាងមកឱបដោយស្នាមញញឹមពេញដោយក្តីស្រលាញ់។

«បងស្រលាញ់អូន» សំឡេងស្រាលបន្លឺជិតត្រចៀក មុននឹងបិទភ្នែកគេងខណៈដែលស្នាមញញឹមផុសលើផ្ទៃមុខសរលោង។

«អូនក៏ស្រលាញ់បងដូចគ្នាស្រលាញ់ខ្លាំងណាស់» តបហើយលូកដៃឱបតបរាងក្រាស់ ធ្វើឲ្យអ្នកដែលបិទភ្នែកញោចស្នាមញញឹមដូចគ្នា។





## អវសានបទ

«អុនហ៊ី ថៅយាយថ្ងៃនេះពិតជាស្រស់ស្អាតមែនហ្ន៎» សំឡេងស្ត្រីចំណាស់បន្លឺឡើង ពេលឃើញនាងតូចអាយុពីរខួបដើរចុះមកក្នុងឈុតរ៉ូបរាត្រីព្រះនាងតូចដ៏ស្រស់ស្អាត។

«ម៉ាក់ប្រាប់ថាថ្ងៃនេះ អ៊ុនហ៊ី ជាម្ចាស់កម្មវិធី ដូច្នេះត្រូវតែស្រស់ស្អាតជាងគេ» សំឡេងនាងតូចបន្លឺឡើងទាំងរត់ទៅរកអ្នកម្ខាងទៀតធ្វើឲ្យមនុស្សចាស់ទាំងពីរនាំគ្នាញញឹមនិងភាពគួរឲ្យស្រលាញ់របស់នាង។

«អ៊ុនហ៊ី...!» សំឡេងគ្រលដែលស៊ាំទម្លាប់បន្លឺឡើងធ្វើឲ្យនាងងាកទៅមើលដោយភាពត្រេកអរ។

«ប៉ាៗ» នាងស្រែកដោយភាពរីករាយថែមរត់ទៅរក ធ្វើឲ្យអ្នកជាប៉ាលាដៃត្រៀមរួចជាស្រេច។

«នឹក ប៉ាៗខ្លាំងណាស់ ជុប ជុប» នាងឧទានទាំងហោទៅថើបថ្ពាល់ទាំងសងខាង។

«ប៉ាក៏នឹកកូនដូចគ្នាព្រះនាងតូចរបស់ប៉ា ជុប ជុប» ភាពស្និទ្ធស្នាលរវាងពីរនាក់ប៉ាកូន ធ្វើឲ្យនារីខុសវ័យទាំងពីរនាំគ្នាសម្លឹងមើលដោយស្នាមញញឹម។

អែលវិន សម្លឹងមើលកូនស្រីពៅដ៏គួរឲ្យថ្នាក់ដោយស្នាមញញឹមសុភមង្គល ហើយក៏ធ្វើឲ្យគេនឹកឃើញរឿងរ៉ាវកាលពីមុន តើនឹងធ្វើឲ្យបាត់បង់នាងប្រម៉ក់ម្នាក់នេះទៅហើយ ស៊ូហ៊ី ដឹងថាស្វាមីកំពុងគិតអ្វីទើបដើរទៅជិតលូកដៃទៅឱបពួកគេទាំងពីរ ចង់ប្រាប់ថាពួកនាងនៅជាមួយគ្នាជានិច្ចទើបគេឈប់គិតពីរឿងទាំងនោះងាកមកញញឹមតប។

«អោះនាំគ្នាទៅកន្លែងពិធីតែម្តងទៅ» សំឡេងស្ត្រីចំណាស់បន្លឺឡើងមុននឹងនាំគ្នាសំដៅសួនច្បារចំហៀងផ្ទះ ដែលជាកន្លែងរៀបចំពិធីខួបកំណើតរបស់នាងប្រប៉ក់តូចនេះ មានតែសមាជិកក្នុងគ្រួសាររួមទាំងអ្នកបម្រើតែប៉ុណ្ណោះ។

«រីករាយថ្ងៃកំណើត អ៊ុនហ៊ី ជាកាដូរបស់ប៉ា» អែលវិន ប្រាប់កូនស្រីពេលនាំគ្នាដើរមកដល់តុពិធីដែលមាននំកំពស់ប្រាំជាន់។

«នេះជាកាដូយាយ»

«ហើយនេះជាកាដូម៉ាក់»

«នេះជាកាដូបងប្រុស អេរិច»

«ហើយនេះជាកាដូបងស្រី អាយរីន»

«អរគុណ ប៉ាៗ លោកយាយ ម៉ាក់ បងប្រុស បងស្រី អ៊ុនហ៊ីស្រលាញ់អ្នកទាំងអស់គ្នាខ្លាំងណាស់» នាងតូចទទួលកាដូមកទុកដោយស្នាមញញឹមមុននឹងលោទៅថើបថ្ពាល់ម្នាក់ៗដោយក្តីស្រលាញ់។

«នៅមានកាដូរបស់អ្នកមីងទៀតណ៎ា» សំឡេងអ្នកណាម្នាក់បន្លឺឡើងខាងក្រោយទើបនាំគ្នាងាកទៅមើល។

«ម៉ាក់មីង ហេជីន» នាងតូចស្រែកដោយភាពត្រេកអរពេលឃើញអ្នកម្នាងទៀតដើរចូលមក ជាគ្រួសាររបស់ ហេជីន និង វីឆាត រួមទាំងកូនទាំងបីនាក់របស់នាងដូចគ្នា។

«យើងមិនបានអញ្ជើញឯងទេ?» សំឡេង អែលវិន បន្លឺឡើងពេលឃើញអ្នកមិនត្រូវគ្នាដូចជា វីឆាត ដើរចូលមក។

«យើងជូនប្រពន្ធយើងមកលេងមិត្តភក្តិ» វីឆាត តបបែបហី។





«មិត្តភក្តិប្រពន្ធឯងជាប្រពន្ធយើង» អែលវិន ប្រាប់សំឡេងរឹងធ្វើឲ្យនារីទាំងបីនាំគ្នាញញឹមគ្រវីក្បាលហួសចិត្ត គឺ អ្នកស្រី សុងហ៊ី ស៊ូហ៊ី រួមទាំង ហេជីន ព្រោះពួកគេឲ្យតែជួបពេលណាគឺមិនដែលត្រូវគ្នានោះទេ។

«ធំៗអស់ទៅហើយ នៅឈ្លោះគ្នាមើលតែកូនក្មេងកើតកូននេះ» សំឡេងអ្នកស្រី សុងហ៊ី បន្លឺឡើងទាំងសម្លឹងមើលកូនប្រុស។

«មៀវនេះគេរករឿងខ្ញុំមុនអ៎ីស្រី» វីឆាត តបទាំងដើរទៅជិតប្រពន្ធ។

«យើងមិនបានរករឿងឯងទេ គ្រាន់តែប្រាប់» អែលវិន តបហើយក៏ដើរទៅឈរជិតប្រពន្ធដូចគ្នាធ្វើឲ្យពួកនាងនាំគ្នាញញឹម។

«បងថ្ងៃនេះជាថ្ងៃខួបកូនយើងណ៎ា» ស៊ូហ៊ី និយាយលួងតិចទើបគេនៅស្ងៀមធ្វើមុខក្រញ៉ូវ។

«ក៏បាន» គេតបហើយក៏ឆ្លៀតសម្លក់ទៅ វីឆាត ធ្វើឲ្យគេអស់សំណើចព្រោះមៀវនេះនៅមិនប្តូរចរិកសោះ។

«រីករាយថ្ងៃកំណើត អ៊ុនហ៊ី នេះជាកាដូរបស់មីង» ហេជីន ប្រាប់ទាំងហុចប្រអប់យ៉ាងធំទៅឲ្យនាង។

«ចាសអរគុណ ម៉ាក់មីង»

«នេះជាកាដូរបស់បង យូជីន ណ៎ា»

«ហើយនេះជាកាដូរបស់ បងឆាល និងបងខាល» កូនភ្លោះទាំងពីររបស់ វីឆាត ប្រាប់ទាំងស្នាមញញឹមហុចទៅឲ្យ នាងតូចនៅស្ងៀមសម្លឹងប្រអប់កាដូភ្លឺៗមុននឹងងាកទៅមើលម៉ាក់របស់នាង។

«ហេតុអីមិនទទួលកូន បងប្រុសឲ្យហើយ» ស៊ូហ៊ី សួរកូនស្រីដែលនៅស្ងៀម។



Scanned by CamScanner

«បងខាល និងបងឆាល តែងតែយកសត្វមកបន្លាចកូន កូនមិនទទួលរបស់គាត់ទេ» នាងតបហើយក៏លោតទៅឱបកប៉ានាងជាប់។

«ចរិកដូចប៉ាគេមិនខុស នៃល្អមើលកូនឯងផងមើញទេចេះមកធ្វើបាបកូនស្រីយើង» អែលវិន ងាកទៅថាឲ្យ វីឆាត ដែលកំពុងឈរជិតកូនភ្លោះរបស់គេទាំងពីរ។

«កូនមានធ្វើបាបប្អូនមែនដែរទេ ប្រាប់ប៉ាមកមើល» វីឆាត សួរកូន ពួកគេក្រវីក្បាលឡើងញាប់។

«មិនបានបន្លាចទេ» ឆាល ភ្លោះបងតបយ៉ាងលឿន។

«ប៉ិន កុហកដូចគ្នា» អែលវិន រអ៊ូរទាំៗ។

«ឯងថាឲ្យអ្នកណា?» វីឆាត បន្លឺសួរទាំងសម្លឹងមុខអ្នកម្ខាងទៀតធ្វើឲ្យអ្នកនៅជុំវិញនេះនាំគ្នាក្រវីក្បាលហួសចិត្ត។

«ពិតជាយ៉ាប់មែនគូនេះ ឈ្លោះគ្នាតាំងពីតូចរហូតដល់ធំ ហើយពេលនេះមានកូនប៉ុន្មានអ្នកទៅហើយនៅមិនទាន់ឈប់ទៀត» សំឡេងអ្នកស្រី សុងហ៊ី បន្លឺឡើងធ្វើឲ្យពួកគេម្នាក់ៗនៅស្ងៀមកំពុងសម្លឹងគ្នាបែបស៊ីសាច់ហុតឈាម។

«កូនឆាល ខាល ប្រាប់ម៉ាក់មកមើលកូនដាក់របស់អីឲ្យប្អូន ហ៎ឹម!» ហេជីន សួរកូនប្រុសពួកគេនៅស្ងៀមមើលមុខគ្នាបន្តិចមុននឹងតប។

«ជារបស់ដែល អ៊ុនហ៊ី ចូលចិត្តនោះអី?» ឆាល ភ្លោះបងតបហើយក៏បើកឲ្យមើលធ្វើឲ្យម្នាក់ៗនាំគ្នាញញឹម ព្រោះជាតុក្កតាខ្លាឃ្មុំនឹងមានផ្កាលីលីជាច្រើនពណ៌។

«ជារបស់ដែល អ៊ុនហ៊ី ចូលចិត្តមែនទេ?» ហេជីន សួរស្ទាបស្ទង់





កាន់ប្រអប់កាដូឲ្យនាងមើល ធ្វើឲ្យនាងនៅស្ងៀមធ្វើមុខជូរ សម្លឹងមើលរបស់ទាំងនោះមួយសន្ទុះមុននឹងទទួលព្រោះជារបស់ដែលនាងស្រលាញ់។

«អ៊ុនហ៊ី ទទួលក៏បាន តែបើលើកក្រោយនៅបន្លាចអូនទៀត គេឈប់និយាយរកហើយ» នាងតូចតបទាំងធ្វើងើយដាក់ពួកគេធ្វើឲ្យមនុស្សចាស់នាំគ្នាញញឹមក្នាញ់នឹកឫកពាររបស់នាង។

ពិធីកាត់នំបញ្ចប់ ក្មេងៗនាំគ្នារត់លេងយ៉ាងសប្បាយក្រោមស្នាមញញឹមរបស់មនុស្សចាស់ដែលអង្គុយនៅតុជុំគ្នា អ្នកស្រី សុងហ៊ី សម្លឹងមើលនារីទាំងពីរដែលអង្គុយក្បែរ ពួកនាងក៏មានវាសនាមិនខុសពីគាត់ប៉ុន្មានដែរបន្ទាប់ពីឆ្លងកាត់រឿងរ៉ាវលំបាក ក៏ត្រូវមកជួបសុភមង្គលដូចពេលនេះ។

«ហត់ដែរទេ?» សំឡេងស្រាលបន្លឺឡើងទាំងដើរទៅឱបអ្នកម្ខាងទៀតដែលទើបបើកទ្វារចូលមក។

«តិចតួច»

«ចាំបងម៉ាស្សាឲ្យល្អទេនិងបានស្រួលខ្លួន» គេសួរតិចៗទាំងលើកនាងសំដៅគ្រែមុននឹងតាមទៅទ្រោមពីលើ។

«ក្រែងប្រាប់ថាម៉ាស្សានោះអី?» នាងសួរតបទាំងសម្លឹងមុខគេបែបដឹងមុនកំលោះញញឹមចុងមាត់មុននឹងតប។

«ហ្នឹងមិនកំពុងតែធ្វើ» ប្រាប់ហើយក៏ចាត់ការអាវដំណេកស្តើងរហូតអស់បង្ហាញរាងកាយទទេស្អាតទាក់ភ្នែក នាងក្រមុំសម្លក់ព្រោះដឹងពីគោលបំណងតែនាងពិតជាគ្មានកំលាំងនោះទេ។

«កុំអី អូនគ្មានកំលាំងទេ?» នាងប្រាប់តិចៗទាំងបិទភ្នែកដោយ



Scanned by CamScanner

ភាពល្ងើយ ហើយក៏ត្រូវបើកភ្នែកមកវិញពេលបាតដៃក្តៅកំពុងច្របាច់ដើមទ្រូងមុននឹងមានអ្វីសើមៗកំពុងវារមបន្ត។

-ទុកបងជាអ្នកចាត់ការ អូននៅឲ្យស្ងៀមទៅ- គេប្រាប់ហើយក៏កម្រើកខ្លួនបន្តិចមុននឹងឱនទៅគ្រប់គ្រងចំនុចស្រៀវស្រើបបំផុតរបស់នាងបង្កើតសំឡេងថ្ងូរមិនដាច់។

-ម៉េរលីន បានហើយ- នាងប្រាប់សំឡេងស្អកទាំងញញួស្មារគេចេញតិចៗទើបព្រមដកបបូរមាត់ឡើងមកទ្រោមពីលើរាងស្តើង សម្លឹងមុខនាងដែលពេលនេះចាប់ផ្តើមក្រហមដោយភាពរោលរាល តែនៅប្រឹងហាមឃាត់គេ។

-បងស្រលាញ់អូន- គេប្រាប់សំឡេងស្រាលទាំងយកច្រមុះទៅត្រដុះជាមួយច្រមុះរបស់នាងទៅមក។

-អូនដឹងហើយ ព្រោះបងប្រាប់អូនរាល់ថ្ងៃទៅហើយ- តបហើយក៏លើកដៃកោងករគេជាប់។

-បងដឹង យ៉ាងណានៅតែចង់និយាយព្រោះខ្លាចអូនភ្លេច ហើយចាកចេញពីបងម្តងទៀត-

-បងនៅមិនទាន់ឈប់គិតរឿងនេះទៀតមែនទេ?- នាងជ្រួញចិញ្ចើមស្មារទាំងសម្លឹងចំកែវភ្នែកទាំងគូរបស់គេ។

-បងខ្លាចពេលត្រឡប់មកវិញមិនឃើញអូន ហើយតែងតែមានអារម្មណ៍បែបនេះរាល់ថ្ងៃ- គេប្រាប់ទាំងធ្វើមុខស្ងួតធ្វើឲ្យនាងចាប់ផ្តើមអាណិតទើបទាញគេមកអឹបដើមទ្រូងខ្លួន។

-អូនគ្មានថ្ងៃទៅណាទៀតនោះទេ លុះត្រាតែបងដេញអូនចេញ-





-បងគ្មានថ្ងៃដេញអូនចេញទៅណាជាដាច់ខាត ស្លាប់បានទេ- គេប្រាប់សំឡេងម៉ឺងម៉ាត់សម្លឹងចំកែវភ្នែករបស់នាង នាងក្រពុំញញឹមផ្អែមរស់នៅជាមួយគេរយៈពេលកន្លងមក ធ្វើឲ្យនាងដឹងពីទំហំក្តីស្រលាញ់របស់គេដែលមានចំពោះនាងជ្រាលជ្រៅប៉ុណ្ណា ដូច្នេះមិនថាមានរឿងអ្វីកើតឡើងនោះទេនាងគ្មានថ្ងៃចាកចេញពីគេជាដាច់ខាត នាងគិតក្នុងចិត្តមុននឹងទាញគេឱនមករកបបូរមាត់របស់ខ្លួន សំឡេងស្រែកថ្ងូរនៃសេចក្តីសុខក៏បន្លឺឡើងដែលពោពេញដោយសុភមង្គល ពេញមួយរាត្រីហើយក៏ជារឿងរហូតទៅសម្រាប់ពួកគេ។

ចប់ដោយបរិបូរណ៍



Scanned by CamScanner